សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITÉ ROYALE DE DROIT ET D'ÉCONOMIE

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ដំណើរការថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **លឹម សេងលាង**
**អ៊ូច សូនីតា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ទូរ សុខុម៉ា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៣

ឆ្នាំចូលរៀន ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **លឹម សេងលាង** និង**អ៊ុច សុនីតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈក្រុម P4C1ជំនាន់ទី១៣នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០១៩-២០២០។

សូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌ការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក អ្នកម្តាយ ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេង ចំពោះកូនដែលមានតម្លៃពុំអាចកាត់ថ្លៃបានព្រោះលោកទាំងពីរបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សាកូនៗតាំងពីកូននៅក្នុងផ្ទៃឧទរនូវហើយពេលដែលកូនធំដឹងក្តីបន្តិចលោកទាំងពីរបានទូន្មានអប់រំប្រៀនប្រដៅដាស់តឿនកូនឲ្យប្រព្រឹត្តល្អរាប់អានមិត្តភក្តិល្អជាដើមម្យ៉ាងវិញទៀតលោកបានខិតខំធ្វើការទាំងថ្ងៃក្តៅថ្ងៃរងាត្រជាក់ដើម្បីតែបានថវិកាយកមកទំនុបបម្រុងការសិក្សារបស់កូនព្រមទាំងផ្តល់ការស្រឡាញ់ការថ្នាក់ថ្នមភាពកក់ក្តៅនិងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរដល់កូនៗ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យគ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ដោយទំនួលខុសត្រូវយ៉ាងខ្ពង់ខ្ពស់ ចំពោះការសិក្សារបស់និស្សិតទាំងអស់ ដោយលោកពុំគិតពីបញ្ហាការលំបាកនឿយហត់អ្វីឡើយ ផ្ទុយទៅវិញលោកខិតខំដាស់តឿន ទូន្មាន អប់រំសិស្ស-និស្សិតអោយខិតខំប្រឹងប្រែងសិក្សា ស្វែងរកចំណេះវិជ្ជាមកដាក់ខ្លួននិងពង្រឹងខ្លួនឯងធ្វើយ៉ាងណាអោយជាមនុស្សម្នាក់ដែលមានសមត្ថភាពពេញលេងដែលសង្គមគេត្រូវការជាដើម។ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យគ្រប់រូប ក៏តែងតែខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវ រិះរកបេកគំហើញថ្មីៗ បន្ថែមដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធន៍ដ៏ល្អៗដល់សិស្ស-និស្សិតគ្រប់គ្នាផង។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌិត **ទូរ សុខុម៉ា** ដែលជាសាស្ត្រាចារ្យណែនាំរបស់យើងខ្ញុំទាំងពីរនាក់ ដែលតែងតែផ្តល់នូវគន្លឹះ ទ្រឹស្តី និងការអនុវត្តក្នុងការសិក្សាស្វែងយល់លើប្រធានបទរបស់យើងខ្ញុំ សាស្ត្រាចារ្យមិនដែលរអ៊ូរទាំ ឬមានភាពធុញទ្រាន់ចំពោះការផ្តល់នូវគំនិតយោបល់អ្វីឡើយ បើទោះបីជាមានការនឿយហត់ក្នុងការបំពេញការងារយ៉ាងណាក្តីក៏សាស្ត្រាចារ្យនៅតែផ្តល់ស្នាមញញឹម ហើយសប្បាយចិត្តពេលដែលឃើញសិស្សនិស្សិតខិតខំសិក្សាស្រាវជ្រាវឯកសារនានា ដែលពាក់ព័ន្ធទៅនឹងប្រធានបទ។ សាស្ត្រាចារ្យថែមទាំងព្យាយាមពន្យល់ណែនាំ និងប្រាប់នូវបទពិសោធន៍ល្អៗ ព្រមទាំងវិធីសាស្ត្រផ្សេងៗ ដែលទាក់ទងនឹងការសិក្សស្រាវជ្រាវផងដែរ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមជូនពរអោយលោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត និងបុគ្គលិកដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ មានតែសុខភាពល្អសម្រេចបានជោគជ័យគ្រប់

ភារកិច្ច  និងសូមឲ្យសមប្រកបជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីក្លាយជាបការៈដទៃឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ខែ..................ឆ្នាំ...........ត្រូវនឹងថ្ងៃ.....................។

# អារម្ភកថា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាសកលវិទ្យាល័យមួយដែលបានផ្តល់នូវជម្រកក់ក្តៅដល់ ខ្ញុំករុណាអាត្មាភាព **លឹម សេងលាង** និង **អ៊ូច សូនីតា** រយៈពេលបួនឆ្នាំក្នុងការសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រៅពីការណែនាំ ទូន្មាន អប់រំ ប្រៀនប្រដៅ ពីសំណាក់លោកឪពុក អ្នកម្តាយ ដែលជាគ្រូដំបូងរបស់យើងខ្ញុំ ឬ/និងថាជាគ្រូទីមួយដែលបានផ្តល់នូវការដាស់តឿនបង្ហាត់បង្រៀន បង្ហាញផ្លូវល្អ ហើយយើងខ្ញុំពិតជាមានសំណាងដែលបានមកសិក្សាបន្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលជាសាកលវិទ្យាល័យមួយដែលយើងខ្ញុំប៉ងប្រាថ្នាថាពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិ យើងខ្ញុំនឹងមកបន្តការសិក្សានៅទីនេះ ឥឡូវបំណងរបស់យើងខ្ញុំបានសម្រេច ហើយពិតជាមានភ័ព្វសំណាងណាស់ដែលបានមកជួបសាស្រ្តាចារ្យដែលមានចំពោះដឹង បទពិសោធន៍ ក្រមសីលធម៌ខ្ពស់ ក្នុងការបង្ហាត់បង្រៀន ការផ្ទេរនូវពុទ្ធិចែករំលែកនូវចំណេះដឹង និងការដាស់តឿនប្រកបដោយវិជ្ជាជីវៈហើយពុំដែលគិតពីការលំបាក ភាពនឿយហត់អ្វីឡើយ។

នៅក្នុងផ្នែកមួយនៃការសិក្សាបរិញ្ញបត្ររដ្ឋបាលសាធារណៈរយៈពេលបួនឆ្នាំ យើងខ្ញុំបានចាប់អារម្មណ៍លើប្រធានបទមួយដែលទាក់ទងនឹងដំណើរការថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ដែលយើងខ្ញុំយល់ថាដំណើរការថវិកាជាតិ និងប្រព័ន្ធដំណើរការដែលមាននៅក្នុងបណ្តុំថវិកាជាតិមានសារៈសំខាន់ខ្លាំងណាស់ ហើយក៏មានភាពស្មុកស្មាញក្នុងការយល់ផងដែរមិនថាតែនៅក្នុងប្រទេសកម្ពុជានេះទេដែលពិបាកយល់សូម្បីតែប្រទេសផ្សេងទៀតនៅលើពិភពលោកក៏ដូចគ្នាដែរ។ ម្យ៉ាងវិញទៀតប្រទេសកម្ពុជាជាប្រទេសដែលប្រកាន់យករបបទីផ្សារសេរី ហើយជាប្រទេសកំពុងតែអភិវឌ្ឍន៍ ដូចនេះហើយធ្វើអោយប្រទេសកម្ពុជាមានការនាំចេញនាំចូលច្រើនហើយការប្រកួតប្រជែងនៃវិស័យជាច្រើនក៏កំពុងតែកើតមានឡើង។

ហេតុដូចនេះហើយទើបក្រុមរបស់យើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី **ដំណើរការថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា** មកធ្វើការសិក្សាស្រាវជ្រាវដើម្បីបានជាគន្លឹះឯកសារនិងចំណេះដឹងបន្ថែមដល់និស្សិតជំនាន់ក្រោយៗបន្តទៀត។

បើទោះបីជាខ្លឹមសារទាំងស្រុងនៅក្នុងសៀវភៅសារណា នេះមានការពិនិត្យយ៉ាងយកចិត្តទុកដាក់យ៉ាងណាក្តី យើងខ្ញុំយល់ថាវានៅក្នុងអត្ថបទនេះនៅតែមានន័យខុសឆ្គងឬអាចខុសនូវអក្ខរាវិរុទ្ធខ្លះ ដោយអចេតនា ឬការភ្លាំងភ្លេចខ្លះជាក់ជាមិនខានឡើយ តែទោះបីជាយ៉ាងណា យើងខ្ញុំទាំងពីរនាក់សូមទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្រ្តចារ្យ មិត្តអ្នកអាន ទាំងអស់គ្នាដើម្បីអោយការសិក្សាស្រាវជ្រាវក្រោយទៀតកាន់តែមានភាពសុក្រិត និងល្អប្រសើរហើយទទួលផលប្រយោជន៍ច្រើនដល់មិត្តអ្នកអាន និងមិត្តនិស្សិតជំនាន់ក្រោយៗទៀត។ សូមអរគុណ!!!

# មាតិកា


ទំព័រ

ពន្យល់ពាក្យ................................................................................................ iii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ....................................................................**១**

២. ចំណោទបញ្ហានៃការស្រាវជ្រាវ...................................................................**២**

៣. គោលបំណងនៃការស្រាវជ្រាវ.................................................................. **៣**

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .......................................................**៤**

៥. សារៈសំខាន់នៃការស្រាវជ្រាវ ...................................................................**៥**

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ.........................................................................**៦**

៧. រចនាសម្ព័ន្ធនៃការសិក្សស្រាវជ្រាវ ............................................................ **៧**

## ជំពូក១

## បញ្ញត្តិនៃដំណើរការថវិកាជាតិ

១.១. បញ្ញត្តិទូទៅ ............................................................................................ ១០

១.១.១.រដ្ឋធម្មនុញ្ញ................................................................................................ ១០

១.១.២.ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ...................................១២

១.២.ប្រភពចំណូលថវិកាជាតិ ...........................................................................១៣

១.២.១ ថវិការបានពីចំណូលសារពើពន្ធ ......................................................................១៣

១.២.២.ប្រភពថវិកាពីចំណូលបន្ទាប់បន្សំ ......................................................................២១

១.៣. ការគណនាពន្ធគយ........................................................................................ ២២

១.៤ ទោសបញ្ញត្តិលើការអនុវត្តថវិកា.................................................................... ២៣

## ជំពូក២

## នីតិវិធីដំណើរការថវិកា

២.១ រចនាសម្ព័ន្ធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ..........................................................២៥

២.២ ដំណើរការថវិកា ....................................................................................................................៣៤
២.២.១ ដំណើរការថវិកាថ្នាក់ជាតិ ......................................................................................................៣៤
២.២.២ ដំណើរការថវិកាថ្នាក់ក្រោមជាតិ ..............................................................................................៤២
២.៣ សមត្ថកិច្ចរៀបចំថវិកាជាតិ ក្នុងប្រតិបត្តិការចំណាយ.....................................................................៤៩
២.៣.១. ភ្នាក់ងាររដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ..........................................................................៤៩
២.៣.២. ភ្នាក់ងារជាមន្ត្រីដទៃទៀត .......................................................................................................៥០
២.៣.៣.បុគ្គលិកលក្ខណៈអ្នកអនុវត្តថវិកា..............................................................................................៥១
២.៤. ប្រតិបត្តិការចំណាយ ..................................................................................................................៥៤
២.៥. សិទ្ធិអំណាច និងការទទួលខុសត្រូវ ...........................................................................................៥៥
២.៥.១. ភារកិច្ចរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.......................................................................៥៥
២.៥.២. ភារកិច្ចរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ....................................................................៥៦
២.៥.៣. ភ្នាក់ងារអនុវត្តថវិកា ...............................................................................................................៥៦
២.៥.៤. នីតិវិធីត្រួតពិនិត្យថវិកា ...........................................................................................................៦០
២.៦.គំហើញទាក់ទងការប្រមូលពន្ធ ....................................................................................................៦១

## ជំពូក៣

## ពិភាក្សាលើដំណើរការថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជា

៣.១.ពិភាក្សាលើប្រសិទ្ធភាពប្រភពចំណូលថវិកា .........................................................................៦៤
៣.២.ពិភាក្សាលើប្រសិទ្ធភាពបែងចែកថវិកា.........................................................................................៦៥
៣.៣.ពីភាក្សាលើចំណុចខ្លាំង និងចំនុចខ្សោយនៃដំណើរការថវិកាជាតិ ...............................................៦៧
សេចក្តីសន្និដ្ឋាន ......................................................................................................................... **៧០**
អនុសាសន៍................................................................................................................................**៧៣**
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# ពន្យល់ពាក្យ

**រដ្ឋបាលថ្នាក់ជាតិ** ជាសំដៅដល់រដ្ឋបាលដែលមានឋានៈចាប់ពីថ្នាក់នាយកដ្ឋានអគ្គនាយកដ្ឋាន ក្រសួង ទីស្តីការគណៈរដ្ឋមន្ត្រីនិងស្ថាប័នកំពូលផ្សេងទៀតឡើងទៅ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ**សំដៅដល់រដ្ឋបាលដែលមានឋានៈចាប់ពីថ្នាក់រាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក ឃុំសង្កាត់ចុះក្រោម។

**អាណាប័ក**គឺជាភ្នាក់ងារសាធារណៈក្នុងការបញ្ជាប្រតិបត្តិការចំណូលនិងបញ្ជាថវិកាចំណាយរបស់រដ្ឋ។ អាណាប័ក ពិនិត្យសិទ្ធិទាំងឡាយរបស់រដ្ឋ ជំរះបញ្ជីចំណូលនិងកិច្ចសន្យា។ អាណាប័ក មានពីរប្រភេទផ្សេងគ្នាគឺ អាណាប័កដើមខ្សែ និង អាណាប័កតាមការប្រទានសិទ្ធិ ឬ អាណាប័កផ្ទេរសិទ្ធិ។

**អាណាប័កដើមខ្សែ** គឺជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលមានសិទ្ធិពេញលេញក្នុងការបញ្ជាប្រតិបត្តិចំណូល  និងបញ្ជាចំណាយដោយខ្លួនឯងផ្ទាល់និងត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាចនិងមុខងាររបស់ខ្លួន។

**អាណាប័កផ្ទេរសិទ្ធិ** គឺជាអភិបាលរាធានីខេត្តដែលទទួលបានសិទ្ធិប្រទានពីអាណាប័កដើមខ្សែសម្រាប់កិច្ចប្រតិបត្តិហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន  ឬជាប្រធានមន្ទីរជំនាញរាជធានីខេត្តដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័កដើមខ្សែសម្រាប់កិច្ចប្រតិបត្តិហិរញ្ញវត្ថុនៃថវិកាបន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គណនេយ្យករសាធារណៈ**  ទទួលខុសត្រូវក្នុងតំណាក់កាលចុងក្រោយនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈដោយគណនេយ្យករសាធារណៈ ទទួលខុសត្រូវក្នុងការប្រមូលចំណូល ដែលអាណាប័កបានប្រគល់ឱ្យប្រមូលឥណទេយ្យដែលមាននៅក្នុងកិច្ចសន្យា ប្រមូលមូលបត្រកម្មសិទ្ធិ ឬមូលបត្រផ្សេងៗទៀតដែលដែលគណនេយ្យករ ត្រូវធានារក្សាទុក ព្រមទាំងបញ្ចូលក្នុងបេឡា នូវប្រាក់ពន្ធដារដែលបង់ដល់ដៃនិងចំណូល គ្រប់ប្រភេទទាំងអស់ដែលរដ្ឋមានតីតិសម្បទាទទួល ទូទាត់ចំណាយ តាមបញ្ជាអាណាបក័ដែលនៅអមជាមួយ ការពារនិងរក្សាទុកនូវមូលនិធិ តម្លៃនានារបស់រដ្ឋនិងគ្រឹះស្ថានសាធារណៈផ្សេងៗទៀត កាន់កាប់មូលនិធិ និងចលនាមូលនិធិប្រាក់ទំនេរ រក្សាទុកនូវលិខិតយុត្តការនៃកិច្ចប្រតិបត្តិការ និងឯកសារគណនេយ្យ កាន់កាប់គណនេយ្យតាមតំណែងដែលខ្លួនដឹកនាំ។

**ថវិកាកម្មវិធី** គឺជាផ្នែកមួយនៃកម្មវិថីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវតុថសាធារណៈ

**ថវិកាជាតិ** គឺជាសេចក្តីថ្លែងការណ៍មួយរបស់រដ្ឋាភិបាលស្តីពីគម្រោងប្រមូលចំណូល និងការចំណាយ

**អង្គភាពថវិកា** គឺជាអង្គភាពរដ្ឋដែលទទួលថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ

**អ្នកជាប់ពន្ធនិវេសជន** គឺជារូបវន្តបុគ្គលដែលមាននិវាសដ្ឋាន ឬជនដែលមានវត្តមាន នៅក្នុងប្រទេសកម្ពុជាលើសពី១៨២ថ្ងៃក្នុងរយៈពេល១២ខែ និងនីតិបុគ្គល ឬក្រុមអាជីវកម្មដែលត្រូវបានបង្កើតឬគ្រប់គ្រងក្នុងព្រះរាជាណាចក្រកម្ពុជាជាគោល។

**អ្នកជាប់ពន្ធអនិវេសជន** មានរូបវន្តបុគ្គលដែលទទួលប្រាក់ចំណូលប្រភពកម្ពុជា

**ទំនិញ** គឺជាទ្រព្យរូបី ក្រៅពីដីធ្លី និងប្រាក់កាស

**សេវា** គឺជាការផ្តល់អ្វីមួយដែលមានតម្លៃ ក្រៅពីទំនិញដីធ្លី និងប្រាក់កាស

**ពន្ធគយ** គឺជាពន្ធឬអាករទៅលើទំនិញទាំងឡាយណាដែលនាំចេញ ឬនាំចូលដែលឆ្លងកាត់ដែនគយ

**សារពើពន្ធ** ពន្ធក្នុងស្រុកលើទំនិញ និងលើសេវា

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ដំណើរការថវិកានៅព្រះរាជាណាចក្រកម្ពុជា ជាកត្តាមួយសំខាន់ដែលជំរុញរាល់គម្រោង និងបេសកម្ម ទាំងអស់របស់អង្គភាពទាំងឡាយអាចប្រព្រឹត្តទៅបានល្អនិងដោយរលូតគ្រប់រចនាសម្ព័ន្ធរបស់អង្គភាពទាំងនោះ រាប់ទាំងអង្គភាពឯកជន និងអង្គភាពសាធារណៈ។ មានអំណះអំណាងច្រើនណាស់ដែលបង្ហាញថាដំណើរការ ថវិកាក្នុងអង្គភាពជាផ្នែកមួយដែលមិនអាចខ្វះបាន និងមានសំខាន់ក្នុងការនាំដំណើរការការងារ ក្នុងអង្គភាព មួយអោយដើរទៅមុនជារលូន ប្រកដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ អង្គភាពមួយទាមទារចាំបាច់ណាស់ នូវការរៀបចំដំណើរការថវិការបស់ខ្លួនអោយបានត្រឹមត្រូវ ប្រាកដប្រជា និងតម្លាភាព ដោយហេតុថាដំណើរការ ថវិកាមានសារៈសំខាន់ ប្រសិនបើដំណើរការថវិកាបានរៀបចំទៅដោយភាពមិនត្រឹមត្រូវ មិនប្រាកដប្រជា និង មិនតម្លាភាពអាចធ្វើអោយដំណើរការការងារ គម្រោង បេសកម្មទាំងមូលដំណើរការទៅមិនបានគ្រប់ជ្រុង ជ្រោយ មិនច្បាស់លាស់មិនរលូន ក៏អាចដល់ដំណាក់កាលមិនចប់សព្វគ្រប់ទៀតផង ព្រោះការរៀបចំថវិកាមិន បានត្រឹមត្រូវអាចធ្វើអោយថវិកាដែលគ្រោងនឹងចំណាយមិនគ្រប់គ្រាន់ ឬធ្វើអោយថវិកានេះមិនច្បាស់ថាត្រូវ យកទៅចំណាយលើមុខងារអ្វើអោយច្បាស់លាស់ឬថវិកានេះត្រូវយកទៅអោយក្រុមការងារមួយណាជាអ្នក ចំណាយជាហេតុធ្វើអោយដំណើរការការងារ គម្រោង បេសកម្ម របស់អង្គភាពបាត់បង់នូវប្រសិទ្ធភាពនិង ប្រសិទ្ធផល។ ដំណើរការថវិកាក្នុងអង្គភាពមួយមិនមានលក្ខណៈដូចគ្នារហូតនោះទេ ព្រោះថវិកាមានលក្ខណៈ បទបែនទៅតាមស្ថានភាពជាក់ស្តែងព្រោះចំណូល និងចំណាយក្នុងអង្គភាពមួយមានការចូលនិងចេញមិន ច្បាស់លាស់ពីមួយខែទៅមួយខែ ឬមួយឆ្នាំទៅមួយឆ្នាំដូចចំណូល ឬចំណាយទេអាចមានការប្រែប្រួលគ្រប់ ពេលវេលា។ ដោយភាពបទបែន និងសារៈសំខាន់នៃថវិកានេះហើយទើបធ្វើអោយអង្គភាពមួយត្រូវការជា ចាំបាច់ អ្នកដែលទទួលខុសត្រូវក្នុងដំណើរការថវិកាដោយមានភារៈកិច្ចធ្វើអោយដំណើរការថវិកាមានភាពត្រឹម ត្រូវច្បាស់លាស់ព្រោះភាពត្រឹមត្រូវនៃដំណើរការថវិកានេះហើយទើបអាចធ្វើអោយដំណើរការ ការងារ គម្រោង បេសកម្មទាំងអស់របស់អង្គភាពមានការប្រព្រឹត្តទៅដោយរលូន និងទទួលបានប្រសិទ្ធិភាព និងប្រសិទ្ធផល។

ជាក់ស្តែងបើយើងងាកទៅមើលវិស័យសាធារណៈវិញ យើងអាចមើលឃើញយ៉ាងច្បាស់ថាដំណើរការ ថវិកាជាតិជាវិធីដ៏សំខាន់មួយសំរាប់ស្ថាប័នរដ្ឋទាំងអស់ដើរទៅសម្រេចនូវគម្រោង ផែនការរបស់ខ្លួន មិនត្រឹមតែ ផែនការរបស់ស្ថាប័នរដ្ឋនេះទេដែលត្រូវសម្រេចបានដោយពឹងទៅលើងដំណើរការថវិកាជាតិ រចនាសម្ព័ន្ធខាង ក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋទាំងអស់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក៏ត្រូវការដំណើរការថវិកាមួយដ៏ ត្រឹមត្រូវផងដែរ។ ដំណើរការថវិកាជាតិវាគឺជាជំនួយមួយដ៏ធំសំរាប់ រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំង អស់បើកថវិកាប្រចាំខែដល់បុគ្គលិតដែលកំពុងបំពេញភារៈកិច្ចក្នុងអង្គភាពរបស់ខ្លួនក្រៅពីនេះនៅមានការស្នើសុំ

ថវិកាសំរាប់ចំណាយលើគម្រោង បេសកម្មផ្សេងទៀតដែលអង្គភាពទាំងអស់គិតថាចាំបាច់ក្នុងការបំពេញឬអភិវឌ្ឍន៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬក្នុងវិស័យរបស់ខ្លួន...។ល។

ទោះបីជាយើងមានដំណើរការថវិកាជាតិដែលប្រព្រឹត្តដោយមានការផ្ចិតផ្ចង់ និងមានការតម្រង់ទិសដោយច្បាប់ អនុក្រឹត្យ សារាចរ និងបទដ្ឋានច្បាប់ផ្សេង រួមជាមួយនឹងអង្គភាពដែលមានសមត្ថកិច្ចពាក់ព័ន្ធចូលរួមក្នុងដំណើរការរៀបចំថវិកាជាតិ មានទាំងការរៀបចំតាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ ការតាមដានត្រួតពិនិត្យមុនពេលអនុម័តអោយប្រើប្រាស់ និងបានតាមដានត្រួតពិនិត្យក្រោមពេលអនុម័តរួចហើយក៏ដោយ ក៏ដំណើរការថវិកានូវតែជួបឧបសគ្គមួយចំនួនផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទស្តីពីដំណើរការថវិការដ្ឋនៃព្រះរាជណាចក្រកម្ពុជានេះដោយក្រុមរបស់យើងខ្ញុំមានគោលបំណងស្វែងរកអ្វីជាឧបសគ្គដល់ដំណើរការថវិកាជាតិជុំវិញការប្រមូលថវិកាចូលក្នុងឃ្លាំងជាតិ។ ការប្រមូលថវិកាចូលក្នុងឃ្លាំងជាតិនេះ រដ្ឋជួបបញ្ហាដូចជា ភាពខ្វះការយល់ដឹងរបស់ប្រជាជន ការគេចពន្ធដែលកើតមានឡើងពីសំណាក់អាជីវករមួយចំនួនដែលមានចិត្តចង់បានប្រាក់ចំណេញច្រើនហួសហេតុចេញពីអាជីវកម្មរបស់ខ្លះដោយយើងបានដឹងរួចហើយថាពន្ធដែលរដ្ឋប្រមូលបានពីប្រជាពលរដ្ឋ និងអាជីវករជាចំណូលយ៉ាងធំរបស់រដ្ឋក្នុងដំណើរការការងារ ផែនការងអភិវឌ្ឍន៍ផ្សេងៗរបស់ក្រសួង និងស្ថាប័ន។ ភាពខ្វះការយល់ដឹងរបស់ប្រជាជន គឺសំដៅដល់ប្រជាពលរដ្ឋមួយចំនួនមិនបានធ្វើការសិក្សាអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងបទដ្ឋានច្បាប់ដែលជាហេតុធ្វើអោយពួកគេមិនបានដឹង និងមិនយល់ពីកាតព្វកិច្ចក្នុងការបង់ពន្ធជូនចំពោះរដ្ឋហើយ ប្រាក់ដែលពួកគេទទួលបានពីការងារមិនបានបង់ពន្ធចូលរដ្ឋនេះទេ ហើយមានប្រជាជនខ្លះបានដឹងអំពីកាតព្វកិច្ចរបស់ខ្លួនហើយតែមិនដឹងថាប្រាក់ពន្ធរបស់ពួកគេជាជំនួយដល់ការងាររដ្ឋ។ ការគេចពន្ធដែលកើតមានឡើងពីសំណាក់អាជីវករមួយចំនួនដែលមានតួនាទីបង់ពន្ធចូលរដ្ឋតែបែបជាមានចិត្តចង់ចំណេញខ្ពស់ពីសំណាក់អាជីវកម្មរបស់ខ្លួនរួចហើយធ្វើគ្រប់វិធីដើម្បីធ្វើការគេចពន្ធ ការធ្វើការគេចពន្ធនេះធ្វើអោយរដ្ឋពិបាកក្នុងការគ្រប់គ្រងនិងបាត់បងថវិកាជាតិច្រើន។

ដូចដែលបានលើកឡើងត្រួតៗខាងលើនូវបញ្ហាដែលបានប៉ះពាល់ចំពោះដំណើរការថវិកាជាតិក្រុមយើងខ្ញុំបានដាក់ចេញនូវសំណួរស្រាវជ្រាវ ដើម្បីស្វែងរកមូលដ្ឋានចម្បងដែលជាបញ្ហាដល់ដំណើរការថវិកា ដើម្បីដាក់ចេញជាអនុសាសន៍ជូនរាជរដ្ឋាភិបាល ក្នុងការបង្កើនឲ្យប្រសើរឡើងនៃដំណើរការថវិកាជាតិ។ យើងខ្ញុំដាក់ចេញនូវសំណួរស្រាវជ្រាវដូចខាងក្រោម៖

១. តើមានកត្តាអ្វីខ្លះជាឧបសគ្គដល់ដំណើរការថវិកាជាតិ?

២. តើធ្វើដូចម្តេចដើម្បីឲ្យដំណើរការថវិកាជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំទៅលើប្រធានបទស្ដីពី ដំណើរថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជានេះដោយក្រុមយើងខ្ញុំមានគោលបំណងចំនួនបីគឺៈ

គោលបំណងទី១ ស្វែងយល់ពីបទដ្ឋានគតិយុត្តដែលមាននៅក្នុងដំណើរថវិការដ្ឋទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជាដូចជាច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈជាច្បាប់ដែលនិយាយយ៉ាងលម្អិតអំពីដំណើរការថវិកាទាំងមូលដែលត្រូវធ្វើក្នុងរយៈពេលមួយឆ្នាំដែលគ្រប់ក្រសួងស្ថាប័នទាំងអស់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវប្រតិបត្តិតាម ច្បាប់ស្ដីពីសារពើពន្ធជាច្បាប់និយាយពីប្រភេទនៃពន្ធដែលប្រទេសកម្ពុជាមានហើយត្រូវប្រមូលនិងកាតព្វកិច្ចផ្នែកពន្ធទាំងអស់ដែលមានចំពោះពលរដ្ឋ។

គោលបំណងទី២ ស្វែងយល់ពីអង្គភាពឬស្ថាប័នដែលមានភារកិច្ច និងកាតព្វកិច្ចក្នុងដំណើរការថវិកាជាតិដោយក្រុមយើងខ្ញុំនឹងទៅសិក្សាស្វែងយល់អំពីអង្គភាពណាខ្លះដែលពាក់ព័ន្ធនឹងការប្រមូលថវិការដ្ឋ ក្រោយពេលប្រមូលរដ្ឋតើថវិការដ្ឋនឹងត្រូវយកទៅទុកនៅកន្លែងណាថវិកាដែលប្រមូលបានរួចហើយនឹងក្លាយទៅជាថវិកាសំរាប់ក្រសួងស្ថាប័នរដ្ឋទាំងអស់យកទៅចំណាយក្នុងសកម្មភាពការងាររបស់ខ្លួនតាមរយៈការស្នើសុំទៅលើរដ្ឋដោយយើងនឹងទៅសិក្សាពីអង្គភាពណាដែលមានតួនាទីត្រួតពិនិត្យនិងយកសេចក្ដីស្នើសុំរបស់ស្ថាប័ននិងអង្គភាពរដ្ឋទាំងនេះទៅអោយអង្គភាពដែលមានសមត្ថកិច្ចក្នុងការអនុម័តថវិកាជាតិ។

គោលបំណងទី៣ ស្វែងយល់ពីវិធីសាស្ត្រដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីធ្វើអោយដំណើរការថវិកាជាតិមានភាពរលូតទៅមុខព្រោះនៅក្នុងដំណើរការថវិកាទាំងមូលមានភាពសំខាន់ខ្លាំងណាចំពោះសកម្មភាពការងាររបស់ស្ថាប័នរដ្ឋទាំងអស់ទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិដូចនេះបើថវិកាជាតិមានសារៈសំខាន់ខ្លះយ៉ាងនេះរាជរដ្ឋាភិបាលកម្ពុជាប្រាកដជាមានយុទ្ធសាស្ត្រ និងវិធីសាស្ត្រជាច្រើនក្នុងការធ្វើអោយដំណើរការថវិកាជាតិមានភាពរលូតទៅមុខដោយក្រុមយើងខ្ញុំមានសម្គាល់យកចំនុចក្នុងវិធីសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងបញ្ហាដែលដំណើរការថវិកាជាតិមានបញ្ហាដូចជាពេលថវិកាដែលប្រមូលបានមានចំនួនតិចជាងថវិកាដែលត្រូវចំណាយតើរាជរដ្ឋាភិបាលនឹងធ្វើដូចម្ដេច? ពេលដែលថវិកាជាតិមិនបានចំណាយចំគោលដៅឬក៏ខុសទិន្នន័យតើរាជរដ្ឋាភិបាលនឹងត្រូវធ្វើដូចម្ដេច?

គោលបំណងនៃការស្រាវជ្រាវនេះ នឹងបើកបង្ហាញពីដំណើរថវិការដ្ឋទាំងមូលទាំងក្រសួងស្ថាប័នរដ្ឋដែលពាក់ព័ន្ធនឹងថវិការដ្ឋថាក្នុងរយៈពេលមួយឆ្នាំក្រសួងស្ថាប័នដែលពាក់ព័ន្ធមានតួនាទីនិងភារកិច្ចអ្វីខ្លះដែលត្រូវធ្វើ។ ការស្រាវជ្រាវនេះនឹងសិក្សាទៅលើគន្លឹះសំខាន់ក្នុងដំណើរការថវិកាទាំងមូលចាប់តាំងពីការប្រមូលថវិកាដល់ចំណាយថវិកាទៅវិញ ដោយបូករួមទាំងបទដ្ឋានគតិយុទ្ធដែលមានចែងនៅក្នុង ច្បាប់ អនុក្រឹត្យ សារាចរជាដើម។ ការសិក្សាស្រាវជ្រាវនេះក៏បានលើកយកស្ថានភាពជាក់ស្ដែងដែលមាននៅក្នុងដំណើរការថវិការដ្ឋយក

បង្ហាញជាឧទាហរណ៍ទៅលើច្បាប់និងបទបញ្ញត្តិដែលបានចែង។ មិនតែប៉ុណ្ណោះការសិក្សាស្រាវជ្រាវនេះ ក៏បានលើកយកសិទ្ធិ អំណាច និងដែលសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធយកមកនិយាយផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានដែនកំណត់ទៅលើច្បាប់ ឬបទដ្ឋានគតិយុត្តដែលកំពុងមានសុពលភាព និងឯកសារពាក់ព័ន្ធផ្សេងៗទៀតដូចជា៖

ទី១៖ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ៥៦ និងមាត្រា៥៧

ទី២៖ ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាត្រា១ ដល់មាត្រា ៤ និងជំពូកទី២ស្តីពីរចនាសម្ព័ន្ធថវិកា និងសិទ្ធិអំណាច ផ្នែកទី១ស្តីពីរចនាសម្ព័ន្ធថវិកា មាត្រា១២ ដល់មាត្រា ២៣

ទី៣៖ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ មាត្រា១ ដល់មាត្រា៦

ទី៤៖ ច្បាប់ទូទាត់ ឆ្នាំ២០១៦ មាត្រា២ ដល់មាត្រា៥

ទី៥៖ ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង់ឆ្នាំ ១៩៩៥ មាត្រា៣ ដល់មាត្រា៥

ទី៦៖ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩ ជំពូកទី១ ស្តីពីអន្តរការិយកម្មធនាគារនិងហិរញ្ញវត្ថុ មាត្រា១ ដល់មាត្រា ៤ និងជំពូកទី២ ស្តីពីដែនអនុវត្តន៍ មាត្រា៩ និងមាត្រា១០

ទី៧៖ ច្បាប់សារពើពន្ធឆ្នាំ១៩៩៧ មាត្រា១ដល់មាត្រា១០

ទី៨៖ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រោមជាតិឆ្នាំ២០១១ មាត្រា ១១ ដល់មាត្រា២៧

ទី៩៖ ច្បាប់ស្តីពីគយឆ្នាំ២០០៧ មាត្រា៣ ដល់ មាត្រា២៤

ងាកមកនិយាយអំពីដែនកំណត់នៃប្រធានបទនេះវិញក្រុមយើងខ្ញុំបានកំណត់ថានឹងសិក្សាទៅលើថាតើរដ្ឋមានប្រភពថវិកាអ្វីខ្លះក្នុងដែលខ្លួនអាចប្រមូលបាន? តើអង្គភាពណាជាអ្នកទទួលបន្ទុកប្រមូលថវិកាជាតិ? ក្រោយពេលដែលរដ្ឋប្រមូលថវិការួច តើអង្គភាពណាជាអ្នកគ្រប់គ្រងលើការថវិកាដែលបានប្រមូលរួចហើយ? ហើយអង្គភាពទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលចង់បានថវិកានេះយកទៅប្រើប្រាស់ក្នុងការងារ មុខចំណាយរបស់ខ្លួនប្រចាំឆ្នាំ តើក្រសួងនិងស្ថាប័នរដ្ឋទាំងអស់ត្រូវធ្វើដូចម្តងដើម្បីទទួលបានថវិការបស់រដ្ឋដើម្បីចំណាយក្នុងឆ្នាំថវិការបស់ខ្លួនដើម្បីបំពេញសកម្មភាពការងារ និងបេសកម្មរួមទាំងគម្រោងដែលខ្លួនចង់សម្រេចបាន? ក្រោយពេលដែលរដ្ឋយល់ព្រមលើចំនួនថវិកាដែលអង្គភាពរដ្ឋទាំងអស់ស្នើរួចហើយ តើអង្គភាពរដ្ឋទាំងអស់នោះទទួលបានថវិកាពីរដ្ឋត្រូវឆ្លងការដំណាក់កាលអ្វីខ្លះ អង្គភាពណាជាអ្នកទទួលបន្ទុកក្នុងដំណើរការទាំងអស់នេះ?និងបញ្ហាអ្វីខ្លះដែលរដ្ឋជួបប្រទះក្នុងដំណើរការថវិការបស់ខ្លួន?

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ជាកត្តាសច្ចានុម័តិ ប្រធានបទមួយនេះមិនត្រឹមតែបើកបង្ហាញពីគោលបំណងរបស់ក្រុមយើងខ្ញុំទេ ប្រធានបទមួយនេះក៏មានសារៈសំខាន់ជាច្រើនដូចជាៈ

+មានសារៈសំខាន់ចំពោះសង្គម ដោយប្រធានបទមួយនេះនឹងបង្ហាញដល់ជនទាំងឡាយណាដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជាអាចយល់ដឹងពីពន្ធរបស់ប្រទេសកម្ពុជា និងការព្វកិច្ចដែលខ្លួនត្រូវមានចំពោះការបង់ពន្ធ យល់ដឹងអំពីដំណើរការថវិកាជាតិរបស់ខ្លួនដែលកំពុងធ្វើប្រតិបត្តិការជារៀងរាល់ឆ្នាំ

+មានសារៈ សំខាន់ចំពោះអាជីវករ អ្នករកស៊ីដែលជាជនបរទេសដែលមកតាំងទីកន្លែងការងារនៅប្រទេសកម្ពុជា ដោយពួកគេអាចយល់ដឹងអំពីពន្ធដែលខ្លួនកំពុងតែជាប់ យល់ដឹងអំពីប្រព័ន្ធការងាររបស់ប្រទេសកម្ពុជាដែលមានចំពោះផ្នែកថវិកា

+មានសារៈសំខាន់ចំពោះសេដ្ឋកិច្ច ព្រោះការបើកបង្ហាញពីបញ្ហាដែលប្រទេសជួបប្រទះក្នុងដំណើរការប្រមូលថវិកានេះ អាចធ្វើអោយអាជីវករ ឬអ្នករកស៊ីនៅប្រទេសកម្ពុជាប្តូរគំនិត និងឥរិយាបទរបស់ខ្លួនឲ្យស្របច្បាប់វិញ។

+មានសារៈសំខាន់ចំពោះនិស្សិតគ្រប់វិស័យ ដោយនិស្សិតអាចយកទៅធ្វើជាអត្ថបទក្នុងការជំនួយស្មារតីរបស់ខ្លួនក្នុងការសិក្សា អាចយកដឹងពីដំណើរថវិកាជាតិរបស់ខ្លួនដែលខុសនាមខ្លួនជាទំពែងស្នង់ឫស្សីជំនាន់ក្រោយ ឬក៏អាចក្លាចជាអត្ថបទយោងទៅដល់ក្រុមអ្នកសិក្សាដែលកំពុងតែធ្វើការស្រាវជ្រាវទៅលើដំណើរការថវិការដ្ឋ ឬក្រុមនិស្សិតដែលកំពុងសិក្សាផ្នែកច្បាប់ រដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលកំពុងតែស្វែងរកការយល់បន្ថែមទៀតចំពោះដំណើរការថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

+មានសារៈសំខាន់ចំពោះក្រុមយើងខ្ញុំ ព្រោះការធ្វើការសិក្សាស្រាវជ្រាវមួយនេះនឹងធ្វើអោយក្រុមយើងខ្ញុំមានការយល់ដឹងបន្ថែមអំពីដំណើរការថវិកាជាតិទាំងការប្រមូលពន្ធមានទាំងពន្ធដា និងពន្ធគយ យល់ដឹងអំពីប្រភពចំនួលរដ្ឋទាំងអស់មិនត្រឹមតែពន្ធនេះទេក្រៅពីពន្ធនៅមានចំណូលមិនមែនសារពើពន្ធមួយទៀតដែលជាចំណូលរបស់រដ្ឋ យល់ដឹងថាក្រោយពីការប្រមូលថវិការួចហើយរដ្ឋបានយកថវិកាដែលប្រមូលបាននេះទៅចំណាយតាមរបៀបណា យល់ដឹងអំពីអង្គភាពដែលចូលពាក់ព័ន្ធនឹងដំណើរការថវិកាជាតិថានៅពីក្រោយដំណើរការថវិកាជាតិមានអង្គភាពនាខ្លះជាអ្នកគ្រប់គ្រងនិងត្រួតពិនិត្យ ក្រៅពីអាចក្លាចជាអាវុធដ៏សំខាន់សំរាប់ក្រុមយើងខ្ញុំទទួលបានសញ្ញាប័ត្របញ្ចប់ឆ្នាំទី៤

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្រុមរបស់យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រមួយចំនួនទៅលើការសិក្សាស្រាវជ្រាវចំពោះប្រធានបទមួយនេះដើម្បីឲ្យប្រធានបទមួយនេះទទួលបានលទ្ធផលនៃការសិក្សាស្រាវជ្រាវមានលក្ខណៈវិទ្យាសាស្ត្រ និងមានកម្រិតជឿជាក់ដែលអាចទទួលយកបាន។កម្រិតនៃការជឿជាក់របស់ប្រធានបទនេះផ្អែកទៅលើទិន្នន័យនិងការវិភាគទិន្នន័យ។

*ការកំណត់អថេរ*

ជាបឋមយើងត្រូវកំណត់អថេរជាមុនសិន ដើម្បីកំណត់ទិសដៅស្វែងរកទិន្នន័យ។ អថេរមានពីរគឺ អថេរឯករាជ្យ និងអថេរមិនឯករាជ្យ។

+ អថេរឯករាជ្យមានដូចជា ច្បាប់ និងបទដ្ឋានគតិយុត្តនានា(ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីគយ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង អនុក្រឹត្យស្តីពីការគ្រប់គ្រង់ចំណូលមិនមែនសារពើពន្ធ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រពឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុ)។

+ អថេរមិនឯករាជ្យ គឺដំណើរការថវិកាជាតិ ដែលប្រែប្រួលទៅតាមច្បាប់ និងបទដ្ឋានគតិយុត្តដែលជាធាតុចូលដើម្បីធ្វើការសិក្សាពីប្រសិទ្ធភាពនៃដំណើរការថវិកាជាតិ

*ការប្រមូលទិន្នន័យ*

ការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានទៅស្វែងរកទិន្នន័យដែលមានស្រាប់ដូចជាសៀវភៅច្បាប់ និងលិខិតបទដ្ឋានគតិយុត្តយកមកវិភាគ។ ទិន្នន័យដែលក្រុមយើងខ្ញុំលើកយកមកសរសេរក្នុងកិច្ចការស្រាវជ្រាវនេះ គឺយកមកពី បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបណ្ណាល័យផ្សេងៗទៀត ឯកសារមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកសារបានមកពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ឯកសារបានមពីគេហទំព័ររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា គេហទំព័ររបស់រដ្ឋសភា រួមទាំងទិន្នន័យនិងពត៌មានបានមកពី Google E-Book និង Youtubeជាដើម។

ការវិភាគទិន្នន័យ

ទិន្នន័យដែលក្រុមយើងខ្ញុំប្រមូលបានមកត្រូវយកមកវិភាគតាមបែបពិពណ៌នា ពីលក្ខខណ្ឌច្បាប់ ពីប្រភពថវិកាដែលរដ្ឋប្រមូលបាន ការរៀបចំថវិកាជាកញ្ចប់របស់រាជរដ្ឋាភិបាលសំរាប់ការចំណាយតាមប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នអង្គភាពរដ្ឋទាំងអស់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដំណើរថវិការដ្ឋតាមដំណាក់កាល ការត្រួតពិនិត្យទៅលើថវិកាដែលបានចំណាយរបស់រដ្ឋ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ចំពោះរចនានៃការស្រាវជ្រាវនេះត្រូវបានចែកចេញជា១កថាខណ្ឌ និង២ជំពូកគឺៈ

កថាខណ្ឌទី១ និយយាអំពីៈ សេចក្តីផ្តើមដែលបរិយាយអំពី លំនាំបញ្ហានៃកាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី១ៈ មូលដ្ឋានច្បាប់ដែលមានពាក់ព័ន្ធនឹងដំណើរការថវិការដ្ឋ លើយកប្រភពថវិកាដែលរដ្ឋមាន ហើយត្រូវបានបែងចែកចេញជាជំពូក គណនី អនុគណនី ដំណាក់នៃការរៀបចំថវិការបស់រដ្ឋគ្រប់ក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ជំពូកទី២ៈ លើកយកអង្គភាព ដែលទាក់ព័ន្ធក្នុងការទទួលខុសត្រូវក្នុងដំណើរការថវិកាជាតិ និងការត្រួតពិនិត្យដែលធ្វើដោយសវកម្មផ្ទៃក្នុង និងផ្ទៃក្រៅ។

ជំពូកទី៣ៈ លើយកទិន្នន័យដែលក្រសួងបានបូកសរុបប្រចាំឆ្នាំមកធ្វើអាចការពិភាក្សាសំរាប់ចំនុចខ្លាំង និងចំនុចខ្សោយ រួចហើយក៏ធ្វើជាសេចក្តីសន្និដ្ឋាន និងអនុសាសន៍ជាចុងក្រោយ

# ជំពូក១

# បញ្ញត្តិនៃដំណើរការថវិកាជាតិ

ថវិការជាតិគឺជាសេចក្តីថ្លែងការណ៍មួយរបស់រដ្ឋាភិបាលស្តីពីគម្រោងប្រមូលចំណូលនិងការចំណាយ។ ថវិកាជាតិអនុញ្ញអោយរដ្ឋាភិបាលកំណត់ថាតើខ្លួនមានប្រាក់ចំណូលគ្រប់គ្រាន់ឬទេដើម្បីបំពេញចំណាយរបស់ខ្លួន។ថវិកាជាតិផ្តល់អាជ្ញាអោយអង្គការនីតិប្រតិបត្តិប្រមូលចំណូលនិងចំណាយទៅវិញដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួនដូចជាកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍនសេដ្ឋកិច្ច។ថវិកាជាឧបករណ៍ដ៏សំខាន់បំផុតរបស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយទាំងនេះ។[១]

ថវិកាជាតិគឺជាឧបករណ៍នៃគោលនយោបាយប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងរដ្ឋាភិបាលនៃប្រទេសភាគច្រើនមកដល់បច្ចុប្បន្ននៅតែមានការលំបាលក្នុងការធានានិងធ្វើអោយសាធារណជនមានជំនឿថាថវិការបស់រដ្ឋាភិបាលគឺពិតជាឧបករណ៍របស់គោលនយោបាយហើយការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលគឺពិតជាដើម្បីបម្រើអោយប្រជាពលរដ្ឋប្រកបដោយភាពស័ក្តិសិទ្ធនិងប្រសិទ្ធភាពប្រាកដមែន។ម៉្យាងទៀតសូម្បីតែការគោរពគោលការណ៍ថវិកាក៏សំខាន់៣គឺវិន័យ(រក្សាតុល្យភាព និងចីរភាព)ប្រសិទ្ធភាពវិភាជថវិកា(ធានាការវិភាជចំគោលដៅអាទិភាព)និងប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា(ធានាការប្រើប្រាស់ថវិកាប្រកបដោយភាពស័ក្តិសិទ្ធនិងប្រសិទ្ធភាព)ក៏រដ្ឋាភិបាលនៃបណ្តាលប្រទេសមួយចំនួនមកដល់បច្ចុប្បន្ននៅតែពុំទាន់អាចគោរពបានពេញលេញនៅឡើយ។[២]ថវិកាជាតិគឺជាគម្រោងតុល្យភាពនៃធនធានអចិន្ត្រៃយ៍និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ។ថវិកាជាតិចែកចេញជាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ធនធនាអចិន្ត្រៃយ៍គឺជាចំណូលរបស់ជាតិដែលចែកជាចំណូលចរន្តនិងចំណូលមូលធន។បន្ទុកអចិន្ត្រៃយ៍ គឺជាចំណាយរបស់ជាតិដែលចែកជាចំណាយចរន្តនិងចំណាយមូលធន។[៣]ថវិកាជាតិ(តាមន័យនយោបាយ)ជាឧបករណ៍នយោបាយរបស់រដ្ឋាភិបាលមានន័យថាផែនការនិងគម្រោងរបស់រដ្ឋាភិបាលមិនអាចលាក់បាំងបានឡើយតាមរយៈការវិភាគលើចំណាយនិងចំណូលរបស់រដ្ឋ។ការចំណាយនិងចំណូលរបស់រដ្ឋធ្វើឲ្យគេមើលយល់ថាតើរដ្ឋចង់បន្ថយពន្ធលើផលទុនដើម្បីបំពេញចិត្តរាស្រ្តឬចង់យកចិត្តសហគ្រាសដោយបន្ថយពន្ធខ្លះៗ ជាដើម។[៤]ថវិកា(ន័យសេដ្ឋកិច្ច)គឺជាចំណាយនិងចំណូលដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។មានន័យថាបើសេដ្ឋកិច្ចមានដំណើរការល្អនោះចំណូលតាមរយៈពន្ធដារបានច្រើនតែបើសេដ្ឋកិច្ចមានដំណើរការមិនល្អទេ(សេដ្ឋ

[១] សៀវភៅណែនាំអំពីថវិកាជាតិដែលផលិតឡើងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល នៅខែកញ្ញា ឆ្នាំ២០០៧

[២] សៀវភៅទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០

[៣] ឯកសារបទវិចារណកថារបស់សមាគមសាលាត្រាជូ

[៤] ទូរ សុខុម៉ា នីតិហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០១៨ ទំព័រ ២

កិច្ចធ្លាក់ចុះ) នោះចំណូលក៏ធ្លាក់ចុះដែរព្រោះការធ្លាក់ចុះតម្លៃពន្ធ។យោងតាមបាតុភូតនេះហើយបានជាអ្នកសេដ្ឋកិច្ចវិទូខ្លះ បានបង្កើតមុខវិជ្ជាមួយថ្មីទៀតគឺ "សេដ្ឋកិច្ចហិរញ្ញវត្ថុ" ដើម្បីសិក្សាពីបញ្ហានេះ ។ថវិកាសំដៅដល់សំណុំនៃគណនីដែលពិពណ៌នាសម្រាប់ឆ្នាំនីមួយៗ អំពីធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ឬរបស់ស្ថាប័នឬរបស់អង្គភាពណាមួយ។[៥]

ដំណើរការថវិការដ្ឋត្រូវធ្វើឡើងស្របតាមបទដ្ឋានគតិយុត្តជាបង្អែកនិងរៀបចំបង្កើតឡើងនូវអង្គភាពមួយចំនួនជាអ្នកត្រួតពិនិត្យដំណើរការថវិកា។ទោះបីរដ្ឋាភិបាលរៀបចំដំណើរការថវិកាដោយមានប្បញ្ញត្តិ និងអង្គភាពអនុវត្តបញ្ញត្តិក៏ដោយរដ្ឋាភិបាលនូវតែជួបបញ្ហាមួយចំនួនតូចផងដែរបញ្ហាទាំងនេះមានដូចជាការគេចពន្ធការស៊ីសំណូក។ពន្ធគឺជាប្រភពចំណូលជាតិដ៏ចំបងចំពោះរាជរដ្ឋាភិបាលដែលអាចអោយរាជរដ្ឋាភិបាលមានលទ្ធភាពក្នុងការធ្វើដំណើរការថវិកាជាតិអោយទៅមុខបានព្រមទាំងមានលទ្ធភាពផ្គត់ផ្គង់ថវិកាទៅដល់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសំរាប់ធ្វើសកម្មភាពគ្រប់វិស័យប៉ុន្តែប្រភពចំណូលដ៏ធំមួយនេះត្រូវជួបនឹងបញ្ហាព្រោះតែការគេចពន្ធដែលធ្វើអោយដំណើរការថវិកាជាតិមានការថយចុះនូវចំនួនដោយអាចធ្វើអោយដំណើរការការងារគម្រោងនិងបេសកម្មរដ្ឋមួយចំនួនបាត់បងប្រសិទ្ធភាពនិងប្រសិទ្ធផលឬអាចផ្អាក់គម្រោងការដោយលើកយកទៅធ្វើនៅឆ្នាំថវិកាបន្ទាប់ក៏មាន។សំរាប់រាជរដ្ឋាភិបាលកម្ពុជាដោយមានអគ្គនាយកដ្ឋានគយបានបង្ហាញថាទំនិញគេចពន្ធភាគច្រើនគឺជាប្រភេទទំនិញដែលជាប់ពន្ធ ឬអាករខ្ពស់ដូចជាឡាន ម៉ូតូ[៦] បារី ស្រាជាដើម។ប្រភេទទំនិញទាំងនេះជាប្រភេទទំនិញដែលអាចផ្តល់នូវថវិកាច្រើនដល់ដំណើរការថវិកាជាតិ។ចំណែកបញ្ហាមួយទៀតគឺការស៊ីសំណូកដែលធ្វើអោយប៉ះពាល់ដល់ដំណើរការថវិកាជាតិគឺការស៊ីសំនូករបស់មន្ត្រីផ្នែកពន្ធដែលទទួលបន្ទុកក្នុងការិយាល័យបង់ពន្ធ។ការស៊ីសំនូកនេះគឺភាពច្រើនមន្ត្រីផ្នែកពន្ធតែងតែចង់បានថវិកាកម្រៃបន្ថែមផ្សេងទៀតដោយអោយអ្នកបង់ពន្ធបំពេញនូវឯកសារយ៉ាងច្រើនដែលធ្វើអោយដំណើរការបង់ពន្ធមានរយៈពេលយូរដែលជាហេតុធ្វើអោយថវិកាចូលជាតិមានភាពលំបាកនិងយឺតយ៉ាវនាំអោយមន្ត្រីគយមានឪកាសក្នុងការរកលុយបន្ថែម[៧]ដែលធ្វើអោយដំណើរការថវិកាក៏ជួបបញ្ហាតាមនឹងដែរ។ព្រោះតែដំណើរការថវិកាជាតិជាកត្តាដ៏សំខាន់សំរាប់រាជរដ្ឋាភិបាលក្នុងការធ្វើសកម្មភាពការងារទោះជាដំណើរការថវិកាជាតិជួបបញ្ហាច្រើនយ៉ាងណាក៏ដោយក៏រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងរកនូវគ្រប់យុទ្ធសាស្ត្រចេញនូវគ្រប់គោលនយោបាយដើម្បីដោះស្រាយផងដែលមានដូចជាអភិក្រមទាំង៥បទបញ្ញាត្តិទាំង១០របស់សម្តេចតេជោ ហ៊ុន សែន ដោយនៅក្នុងនេះមានអភិ

[៥] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា៤

[៦] បទសម្ភាស របស់ឯកឧត្តម បណ្ឌិត គុណ ញឹម ប្រធានអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាមួយទូរទស្សន៍BTV ស្តីពីលទ្ធផលប្រមូលពន្ធ អាករ និងបញ្ហាប្រឈម ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧

[៧] អត្ថបទចេញផ្សាយរបស់អង្គការ IFC MPDF ស្តីអំពី ព្រឹត្តិបត្រ័ស្តីពីបញ្ហាអាជីវកម្ម មាតិកា ឧបសគ្គច្បាប់និងសំណូក ទំព័រ២និង៣

ក្រុមទី៤ការព្យាបាល អភិក្រមទី៥ វះកាត់ មានគោលបំណងក្នុងការកាត់បន្ថយមន្ត្រីពុករលួយនិងបទបញ្ញត្តិទី៦ ដែលសំដៅដល់ការគាំទ្រការប្រមូលថវិកាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទប់ស្កាត់ការរកស៊ីគេចពន្ធដាក់ទោសអ្នកដែលរកស៊ីខុសច្បាប់និងការពារអ្នករកស៊ីស្រប់ច្បាប់មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលកម្ពុជាក៏មានខិតខំប្រឹងប្រែងស្វែងរកយុទ្ធសាស្ត្រជាច្រើនជាពិសេសផ្អែកលើបញ្ញត្តិច្បាប់ក្នុងការបញ្ឈប់មិនអោយមានបញ្ហាដល់ដំណើរការថវិកាជាតិផងដែរក្នុងយុទ្ធសាស្ត្រទាំងនេះក៏មានជាលិខិតបញ្ញាស្តីពីវិធានការបង្កើតប្រសិទ្ធភាពក្នុងការទប់ស្កាត់និងបង្ក្រាបអំពីគេចពន្ធដែរ ដើម្បីប្រមូលថវិកាចូលរដ្ឋធានាដំណើរការថវិកាជាតិប្រកបដោយប្រសិទ្ធភាព។ខាងក្រោមនេះបង្ហាញពីបញ្ញត្តិមួយចំនួនៈ

## ១.១. បញ្ញត្តិទូទៅ

ដំណើរការថវិកាត្រូវតែស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រដែលជាច្បាប់កំពូលនិងត្រូវបានបង្ហាញពីដំណើរការថវិកានេះកាន់តែច្បាស់តាមរយៈបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ដូចជាៈ

### ១.១.១.រដ្ឋធម្មនុញ្ញ

រាល់ដំណើរការឬសកម្មភាពរបស់រដ្ឋទាំងអស់ត្រូវប្រតិបត្តិទៅដោយមានមូលដ្ឋានច្បាប់ជាគោល រួមទាំងដំណើរការថវិការដ្ឋផងដែល ដំណើរការថវិកាជាតិទាំងមូលអាចដើរទៅមុនបានដោយមានបទដ្ឋានច្បាប់ដែលត្រូវបានអនុម័តដោយសភាជាវិថី ហើយការអនុម័តរបស់សភាត្រូវយករដ្ឋធម្មនុញ្ញ ១៩៩៣ជាចង្កៀងបំភ្លឺ។ ថ្ងៃទី២៤ ខែកញ្ញាឆ្នាំ១៩៩៣ ព្រះមហាក្សត្រទ្រង់ឡាយព្រះហត្ថលេខាលើអត្ថបទរដ្ឋធម្មនុញ្ញ ហើយបង្កើតបានរដ្ឋសភានិងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ មូលហេតុដែលរដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាព្រោះនៅក្នុងរដ្ឋធម្មនុញ្ញបាននិយាយពីមូលដ្ឋានច្បាប់ទាំងអស់នៅក្នុងប្រទេសកម្ពុជាដោយនៅក្នុងរដ្ឋធម្មនុញ្ញដែលបានអនុម័តនៅឆ្នាំនេះក៏មានជំពូកមួយដែលនិយាយទាក់ទងនឹងប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាដែលសព្វថ្ងៃនេះជាជំពូក៥ ស្តីអំពីសេដ្ឋក្ិចនៃរដ្ឋធម្មនុញ្ញ[៨]។នៅក្នុងជំពូកនេះមានចែងពាក់ព័ន្ធនឹងប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាការប្រមូលនិងចំណាយថវិកាជាតិ។របបគ្រប់គ្រងរូបិយវត្ថុនិងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់[៩] ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលកម្ពុជានឹងចេញនូវសេចក្តីព្រាងច្បាប់ចំនួនបីសំរាប់រដ្ឋសភានិងព្រឹទ្ធសភាអនុម័តនិងពិនិត្យ។ ច្បាប់ទាំងបីនេះមានដូចជា ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ច្បាប់ហិរញ្ញវត្ថុកែតម្រូវ ច្បាប់ទូទាត់ថវិកា ច្បាប់ទាំងបីនេះមានគោលបំណង់និយាយពី របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុសំរាប់ប្រចាំឆ្នាំតែម្តង ឧទាហរណ៍ សំរាប់ឆ្នាំ២០២០កម្ពុជានឹងចេញនូវឆ្នាំដែលនិយាយបន្ថែមអំពីរបបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុដោយច្បាប់បីគឺច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រង់គ្រង់ឆ្នាំ២០២០ ច្បាប់ហិរញ្ញវត្ថុកែតម្រូវឆ្នាំ២០២០ និង

[៨] រដ្ឋធម្មនុញ្ញត ជំពូក៥ អំពីសេដ្ឋកិច្ច

[៩] រដ្ឋធម្មនុញ្ញត មាត្រា៥៧

ច្បាប់ទូទាត់ថវិកាឆ្នាំ២០២០។ នៅក្នុងរដ្ឋធម្មនុញ្ញមាត្រា ៥៨ បានចែងថា ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។ ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ក្នុងច្បាប់[១០]។ ដោយការចែងនៅក្នុងមាត្រា ៥៨នៃរដ្ឋធម្មនុញ្ញនេះបានបង្កើតជាច្បាប់ជាច្រើនសំរាប់អនុវត្តដល់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង នឹងចាត់ចែងក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋ ដើម្បីទទួលបានចំណូល និងចាត់ចែងលើចំណាយរបស់ប្រចាំឆ្នាំខ្លួនក្នុងដំណើរការងារ ការអនុវត្តផែនការ សកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ដូចជា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលជាច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគោរពការណ៍បូរណភាព អាជ្ញាភាពឯកត្តភាព សមាគតភាព សកលភាព សង្គតិភាព គណនេយ្យភាព តម្លាភាព ស្ថិរភាព ភាពគ្រប់ជ្រុងជ្រោយ និងសមតិទ្ធកម្ម[១១] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ[១២] ដែលជាច្បាប់សំរាប់កំណត់អំពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅព្រះរាជាណាចក្រកម្ពុជាតាមរយៈការបង្កើតនូវប្រភពធនធានហិរញ្ញវត្ថុដើម្បីអោយរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពសមស្របក្នុងការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាពនិងលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋភិបាល អនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដែលជាអនុក្រឹត្យមួយនិយាយអំពីយន្តការ វិធាន និងនីតិវិធីនៃការប្រមូល ការបង់ ការកៀរគរ ការកត់ត្រា ការតាមដាន និងការត្រួតពិនិត្យវាយតម្លៃលើចំណូលមិនមែនសារពើពន្ធព្រមទាំអការចាត់វិធានអនុវត្តកិច្ចសន្យា និងការតឹងទារបំណុលមិនមែនសារពើពន្ធ[១៣] អនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត[១៤]។ ក្រៅពីច្បាប់ អនុក្រឹត្យទាំងអស់នេះហើយនៅមាន បទដ្ឋានគតិយុត្តិដ៏ទៃទៀតដែលបានដើតួក្នុងការងារដំណើរការថវិការដ្ឋ រួមទាំងសៀវភៅជាច្រើនដែលរដ្ឋបានចេញផ្សាយក្នុងគោលបំណងអោយសាធារណៈជនយល់ដឹងអំពីដំណើរការថវិការដ្ឋ ប៉ុន្តែសៀវភៅទាំងអស់នេះត្រូវបានបែងចែកជាផ្នែកទៅតាមមុខងារ និងតាមប្រធានបទដែលក្រសួង អង្គភាព ស្ថាប័នរដ្ឋជាអ្នកចេញផ្សាយដូចជាសៀវភៅស្តីអំពីពន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាដើម។

[១០] រដ្ឋធម្មនុញ្ញត មាត្រា៥៨

[១១] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា២

[១២] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១១

[១៣] អនុក្រឹត្យលេខ៧២ អនក្រ.បកចុះថ្ងៃទី៨ ខែមិថុនាឆ្នាំ២០១៨ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ មាត្រា២

[១៤] អនុក្រឹត្យលេខ២៥ អនក្រ.បកចុះថ្ងៃទី៩ ខែមីនាឆ្នាំ២០២០ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

### ១.១.២.ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុលោមតាមអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[១៥] ដែលជាអនុក្រឹត្យស្តីពីការការកំណត់បេសកម្មរបស់ក្រសួង និងមុខការនៃអគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន និងនាយកដ្ឋាននានា[១៦]។ សំរាប់ភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុមានដូចជារួចចំណែករៀបចំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល[១៧] គ្រប់គ្រងនិងសម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុពង្រឹងអភិបាលកិច្ចល្អទៅលើអ្វីដែលជាប់ពាក់ព័ន្ធនិងការគ្រប់គ្រងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុសាធារណៈធ្វើការបែងចែកនិងបែងចែកឡើងវិញនូវផលទុនជាតិតាមរយៈការប្រមូលចំណូលនិងកម្មវិធីនីយកម្មនិងថវិកានីយកម្មនៃចំណាយសាធារណៈកសាងប្រព័ន្ធហិរញ្ញវត្ថុអោយឯកភាពទូទាំងប្រទេសហើយធានាអោយអនុវត្តប្រព័ន្ធនេះអោយបានត្រឹមត្រូវតាមច្បាប់ស្តីពីហិរញ្ញវត្ថុនិងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំនីមួយៗព្រមទាំងច្បាប់ពាក់ព័ន្ធនិងបទបញ្ញាដទៃទៀត រៀបចំកសាងសេចក្តីព្រាងច្បាប់និងបទបញ្ញាផ្សេងៗសំរាប់ការគ្រប់គ្រងម៉ាគ្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗឬជាលក្ខណៈអចិន្ត្រៃយ៍ រៀបចំ និងគ្រប់គ្រងថវិការដ្ឋ រៀបចំ និងអនុវត្តគោលនយោបាយចំណូលថវិកាជាតិ ប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធបង់ចូលបេឡាថវិកាជាតិ ធ្វើតារាងតុល្យភាពនិងវិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ពិនិត្យ និងចុះទដ្ឋាការលើចំណាយរបស់ក្រសួង និងស្ថាប័ននានាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ វិភាគតាមដាន និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី មធ្យមនិងរយៈពេលវែងនិងដាក់ចេញនូវ វិធានការដើម្បីតម្រង់ទិស និងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ចចូលរួមចំណែក អភិវឌ្ឍ គ្រប់គ្រងនិងត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុ រួមមានកិច្ចការធានារ៉ាប់រងទីផ្សារមូលប័ត្រ ឡូតូ កាស៊ីណូ បេឡាសោធននិវត្តន៍និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ និងចូលរួមការរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល លើកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា នៅក្នុងសេដ្ឋកិច្ចពិភពលោក ពិសេសកិច្ចការសមាហរណកម្មសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌអាស៊ាន ចូលរួមក្នុងការងារកៀងគរជំនួយ ព្រមទាំងរៀបចំផែនការខ្ចី និងសងបំណុលបរទេស ហើយតាមដាន និងត្រួតពិនិត្យលើការអនុវត្តផែនការទាំងនោះ គ្រប់គ្រង និងត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈនៃបណ្តាលក្រសួង-ស្ថាប័ន- និងខេត្ត-

---

[១៥] អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[១៦] អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មាត្រា១

[១៧] អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មាត្រា៣

ក្រុង ព្រមតាំងស្ថាប័នរដ្ឋកាន់កាប់ ឬស្វ័យគ្រប់គ្រង ចូលរួមរៀបចំគោលនយោបាយ និងគ្រងគ្រងកិច្ចការវិនិយោគ បំពេញមុខងារអធិការកិច្ច លើផ្នែកហិរញ្ញវត្ថុសាធារណៈ បណ្តុះបណ្តាល និងធ្វើវិក្រឹតការជាប្រចាំនូវមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ[១៨]។

## ១.២.ប្រភពចំណូលថវិកាជាតិ

បច្ចុប្បន្នដំណើរការថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជា មានប្រភពថវិកាពីរដើម្បីផ្គត់ផ្គង់ដល់ក្រសួងស្ថាប័ន។ ប្រភពទាំងពីរនេះត្រូវបានបែងចែកជាពីរគឺ ប្រភពចម្បង និងបន្ទាប់បន្សំ។ ប្រភពចម្បងរបស់ថវិកាជាតិគឺ ពន្ធដារ និងពន្ធគយ។ ពន្ធដារជា ថវិកាដែលប្រមូលបានពីពន្ធ និងអាករទៅលើទំនិញនិងសេវាដែលមាននៅក្នុងប្រទេសដូចជាពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស ពន្ធប៉ាតង ពន្ធប្រថាប់ត្រាជាដើម។ ចំណែកពន្ធគយវិញ គឺជាថវិកាដែលប្រមូលបានពីពន្ធ និងអាករទៅលើទំនិញដែលក្នុងស្រុកនាំចេញទៅក្រៅប្រទេសនិងទំនិញក្រៅស្រុកនាំចូលមកក្នុងប្រទេសកម្ពុជាហើយទំនិញទាំងអស់នេះត្រូវតែឆ្លងកាត់ដែនគយមិនថាផ្លូវទឹកផ្លូវគោគឬផ្លូវអាកាស។ ប្រភពបន្ទាប់បន្សំ របស់រដ្ឋគឺជាថវិកាដែលរដ្ឋប្រមូលបានក្រៅពីពន្ធដារ និងពន្ធគយមានដូចជា ថវិកាដែលបានមកពីការវិនិយោគ ការខ្ចី អាជីវកម្មរបស់រដ្ឋ ទីផ្សារមូលបត្រកម្ពុជាជាដើមប្រភេទចំណូលនេះហៅថាចំនូលបន្ទាប់បន្សំព្រោះប្រភេទចំណូលដែលមាននៅក្នុងនេះមានចំនួនតិចហើយមានប្រភេទចំនូលខ្លះសិងតែមិនមានចំនូលផលក្នុងឆ្នាំខ្លះទោះចាប់ទុកថាជាចំនូលបន្ទាប់បន្សំ។ ប្រភពចំណូលដែលរដ្ឋទទួលបានត្រូវបែងចែកជាជំពូក គណនី អនុគណនីឬអាចលម្អិតជាងនេះទៅទៀតបើចាំបាច់។

### ១.២.១ ថវិកាបានពីចំណូលសារពើពន្ធ

#### ១.២.១.១. ប្រភពចំណូលបានមកពីពន្ធដារ

ក.ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលត្រូវបានបែងចែកចេញជាពីរប្រភេទគឺ ប្រាក់ចំណូលប្រភពកម្ពុជានិងប្រាក់ចំណូលប្រភពបរទេស[១៩]។ ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទរួម បញ្ចូលទាំងចំណូលមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្មព្រមទាំងប្រាក់ ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគការប្រាក់ថ្លៃឈ្នួល និងសួយសារផង។ ប្រាក់ចំណូលជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណូលមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគដែលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម។ អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ ២០ភាគ

[១៨] សៀវភៅស្តីពីហិរញ្ញវត្ថុសាធារណៈ របស់បណ្ឌិត ហង់ ជួនណារ៉ុន

[១៩] អត្ថបទចុះផ្សាយរបស់គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ៖https://www.tax.gov.kh/btop.php

រយចំពោះប្រាក់ចំណូលដែលសម្រេចបានដោយនីតិបុគ្គល ៣០ភាគរយ ចំពោះប្រាក់ចំណូលដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័ន ធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំង ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ០ភាគរយ ចំពោះប្រាក់ចំណូលរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈ ពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោមចំពោះប្រាក់ចំណូលដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គលនិងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គលៈចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ក្នុងការធានារ៉ាប់រងឬ ធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ពីររបៀប គឺទី១ ៥% នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬនូវហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា និងទី២ ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពដទៃទៀតក្រៅពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗពន្ធលើប្រាក់ចំណូលត្រូវបានកំណត់តាមមាត្រា២០នៃច្បាប់ស្តីពីសារពើពន្ធ។[២០]

| ល.រ | ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ១ | ពី | ០៛ | ដល់ | ១៦ ០០០ ០០០៛ | ០% |
| ២ | ពី | ១៦ ០០០ ០០១៛ | ដល់ | ២៤ ០០០ ០០០៛ | ៥% |
| ៣ | ពី | ២៤ ០០០ ០០១៛ | ដល់ | ១០២ ០០០ ០០០៛ | ១០% |
| ៤ | ពី | ១០២ ០០០ ០០១៛ | ដល់ | ១៥០ ០០០ ០០០៛ | ១៥% |
| ៥ | | | លើសពី | ១៥០ ០០០ ០០០៛ | ២០% |

ខ.ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញគឺ ជាពន្ធគិតលើប្រាក់ចំណេញជាប់ពន្ធរបស់ អ្នកជាប់ពន្ធនិវាសនជនចំពោះចំណូលប្រភពកម្ពុជា និងបរទេស អ្ន កជាប់ពន្ធអនិវាសនជនចំពោះចំណូលប្រភពកម្ពុជា។ ចំពោះអ្នកជាប់ពន្ធលើប្រាក់ចំណេញ ត្រូវចុះបញ្ជីនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សាខាក្រុមហ៊ុនបរទេសឬក្រុមហ៊ុនពហុជាតិនិងសហគ្រាសដទៃទៀតដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១០០០លានរៀលឡើងទៅឬសាខាពន្ធដាខេត្ត/សាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ ដែលសហគ្រាសនោះ

[២០] ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ មាត្រា២០

តាំងនៅក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីការចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។ ត្រូវចាប់ទុកជាអ្នកជាប់ពន្ធនិវាសជនលុះត្រា រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២ថ្ងៃនៅក្នុងរយៈពេល១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្តនីតិបុគ្គលឬក្រុមអាជីវកម្មដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។រីឯអ្នកជាប់ពន្ធអនិវាសនជនវិញគឺជា រូបវន្តបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសជន ប៉ុន្តែទទួលបានចំណូលប្រភពកម្ពុជានីតិបុគ្គលឬក្រុមអាជីវកម្មដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងមានគ្រឹះស្ថានជាអចិន្ត្រៃយ៍ក្នុងព្រះរាជណាចក្រកម្ពុជា។ប្រាក់ចំណូលដែលត្រូវបានកំណត់ថាជាប្រាក់ចំណូលប្រភពកម្ពុជាមានដូចជា ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជនឬក្រុមអាជីវកម្មនិវាសនជនឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន ប្រាក់ចំណូលពីការធ្វើអាជីវកម្ម ឬសេវាកម្មដែលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រាក់ចំណូលពីការគ្រប់គ្រងនិងសេវាបច្ចេកទេសដែលបានទូទាត់ដោយបុគ្គលនិវាសនជនប្រាក់ចំណូលដែលបានមកពីចលនទ្រព្យឬអចលនទ្រព្យដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ឬសិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបីដែលទូទាត់ដោយបុគ្គលនិវាសនជនឬបុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជាផលចំណេញពីការលក់អចលនទ្រព្យ ឬពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាផលចំណេញពីការលក់អចលនទ្រព្យដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជន នៅក្នុងព្រះរាជាណាចក្រកម្ពុជាបុព្វលាភបានពីធានារ៉ាបរង ឬធានារ៉ាប់រងបន្តលើហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនុវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ចំណូលទាំងឡាយណាដែលមិនត្រូវបានចាត់ទុក ថាជាចំណូលប្រភពកម្ពុជាគឺចាត់ទុកថាជាចំណូលប្រភពបរទេស។

គ.ពន្ធលើប្រាក់បៀវត្សរ៍

ពន្ធលើប្រាក់បៀវត្ស គឺជាប្រាក់ដែលរដ្ឋប្រមូលបានពីពលរដ្ឋទាំងអស់ដែលបានប្រតិបត្តិការងារហើយទទួលបានចំណូលពីប្រភពក្នុងប្រទេសកម្ពុជាឬបានចំណូលពីប្រភពក្រៅប្រទេសកម្ពុជាប៉ុន្តែមានក្រុមហ៊ុនមួយចំនួនក៏បានចេញថ្លៃបង់ពន្ធលើប្រាក់បៀវត្សរ៍របស់បុគ្គលរបស់ខ្លួនទៅដល់រដ្ឋដែល។ពាក្យថាប្រាក់ចំណូលប្រភពកម្ពុជាចង់សំដៅដល់ក្រុមហ៊ុនដែលបានតាំងទីកន្លែងប្រតិបត្តិការងារនៅកម្ពុជាហើយរកចំណូលពីប្រភេទកម្ពុជាឧទាហរណ៍ក្រុមហ៊ុនអចលទ្រព្យមួយបានធ្វើការសាងសងផ្ទះនៅលើទឹកដីប្រទេសកម្ពុជាហើយបានលក់ឬបង់រំលស់ដោយទទួលបានប្រាក់ចំណូលពីប្រជាពលរដ្ឋដែលមានសញ្ជាតខ្មែរចំណែកពាក្យថាប្រាក់ចំណូលប្រភព

បរទេសវិញចង់សំដៅដល់ក្រុមហ៊ុនឬសហគ្រាសឬអង្គភាពឯកជនទាំងឡាយដែលមានទីតាំងនៅប្រទេសកម្ពុជាតែរកចំណូលពីបរទេសដូចជាក្រុមហ៊ុនផលិតគំនូជីវចលឬចនាម៉ូតបានតាំងទីកន្លែងនៅប្រទេសកម្ពុជាតែរកអតិថិជនពីបរទេសតាមរយៈការសហការផ្សេងដើម្បីយកការងារមកធ្វើនៅប្រទេសកម្ពុជាក្រោយពីធ្វើរួចក៏បញ្ជូនការងារទៅបរទេសវិញហើយទទួលប្រាក់ចំណូលពីក្រៅប្រទេស។ពន្ធលើប្រាក់បៀវត្សនេះត្រូវបានបែងចែកជាពីរប្រភេទគឺ អ្នកជាប់ពន្ធនិវាសនជន និងអ្នកជាប់ពន្ធអនិវាសនជន។អ្នកជាប់ពន្ធនិវាសនជន ជាពន្ធត្រូវកាត់ទុកដោយនិយោជិកពីនិយោជកពីប្រាក់បៀវត្សប្រភពកម្ពុជានិងពីប្រាក់បៀវត្សប្រភពបរទេសត្រូវចាប់ទុកថាជាអ្នកជាប់ពន្ធលើនិវាសនជនបានលុះត្រាតែបុគ្គលនេះមានលំនៅដ្ឋានឬកន្លែងស្នាក់នៅអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជានិងមានវត្តមានក្នុងប្រទេសកម្ពុជាច្រើនជាង១៨២ថ្ងៃក្នុងរយៈពេល១២ខែ នៃការបញ្ចប់ឆ្នាំសារពើពន្ធចរន្ត/ឆ្នាំជាប់ពន្ធចរន្ត[២១]។ចំណែកឯអ្នកជាប់ពន្ធអនិវាសនជនវិញគឺជាពន្ធត្រូវកាត់ទុកពីប្រាក់បៀវត្សប្រភពកម្ពុជាត្រូវចាប់ទុកថាជាអ្នកចាប់ពន្ធអនិវាសនជនបានលុះត្រាតែបុគ្គលនេះមិនមែនលក្ខណៈដូចទៅនឹងអ្នកជាប់ពន្ធនិវាសនជនប៉ុន្តែទទួលបានប្រាក់បៀវត្សប្រភពកម្ពុជា[២២]។ ពន្ធលើប្រាក់បៀវត្សត្រូវគិតដូចខាងក្រោម៖

| ល.រ | ភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ១ | ពី | ០៛ | ដល់ | ១ ៣០០ ០០០៛ | ០% |
| ២ | ពី | ១ ៣០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% |
| ៣ | ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ៤ | ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| ៥ | | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

ពន្ធលើប្រាក់បៀវត្សនេះ ជាចំណែកមួយនៃចំណូលរបស់ថវិកាជាតិដើម្បីបំពេញដំណើរការថវិកា។

ឃ.ពន្ធលើអចនទ្រព្យ

ពន្ធលើអចលទ្រព្យគឺជាពន្ធលើដែលរដ្ឋប្រមូលបានពីម្ចាស់កម្មសិទ្ធិនៃអចលទ្រព្យ។ចំពោះអចលនទ្រព្យដែលជាប់ពន្ធនេះមានដូចជា ដី(ដែលមាន ឬគ្មានអគារ)លំនៅដ្ឋាន អគារឬសំណង់ផ្សេងៗដែលនៅលើដីរួមមាន សណ្ឋាគារ ផ្ទះ ល្វែង ការិយាល័យ ខុនដូ រោងចក្រ ឃ្លាំងទំនិញ អគារឧស្សាហកម្មនិងចំណតរថយន្ត។

[២១] សៀវភៅណែនាំស្តីពីពន្ធលើប្រាក់បៀវត្ស ទំព័រទី១

[២២] សៀវភៅណែនាំស្តីពីពន្ធលើប្រាក់បៀវត្ស ទំព័រទី១

ចំណែកឯម្ចាស់កម្មសិទ្ធិឬកម្មសិទ្ធិករវិញគឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបណ្ណសម្គាល់សិទ្ធិឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី។[២៣] ពន្ធនេះត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០,១% (សូន្យក្បៀសមួយភាគរយ) លើតម្លៃអចលនទ្រព្យ[២៤]។មូលដ្ឋានគិតពន្ធ គឺជាតម្លៃ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះដោយកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០,០០០,០០០ (មួយរយលាន) រៀល។ តម្លៃដីផ្ទះអគារនិងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះត្រូវកំណត់តាមតម្លៃទីផ្សារដោយគណកម្មការវាយតម្លៃអចលនទ្រព្យដែរបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។អ្នកកាន់កាប់គឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់អចលទ្រព្យប៉ុន្តែមិនមានបណ្ណសម្គាល់សិទ្ធិឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី។ចំពោះអ្នកទទួលផលប្រយោជន៍ចុងក្រោយគឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសិទ្ធិប្រើប្រាស់ឬសិទ្ធិអាស្រ័យផល សិទ្ធិចាត់ចែង និងសិទ្ធិអាស្រ័យនៅចុងក្រោយលើអចលទ្រព្យ។[២៥]

ង.អាករលើតម្លៃបន្ថែម

អាករលើតម្លៃបន្ថែមគឺជាចំណុលបានមកពីការបង់អាករលើតម្លៃបន្ថែមដោយសហគ្រាសផ្គត់ផ្គង់ទំនិញឬចែកចាយឬសេវាក្នុងព្រះរាជានាចក្រកម្ពុជា។អាករលើតម្លៃបន្ថែមមានដូចជាអាករលើតម្លៃបន្ថែមលើទំនិញជាបន្ទុករបស់រដ្ឋ អាករលើតម្លៃបន្ថែមលើសេវាជាបន្ទុករបស់រដ្ឋអាករលើតម្លៃបន្ថែមរបបនាំចូល(សហគ្រាសប្រេងឥន្ធនៈ)អាករលើតម្លៃបន្ថែម របបនាំចូល(សហគ្រាសផ្សេងៗ)អាករលើតម្លៃបន្ថែមរបបនាំចូល(ជាបន្ទុករបស់រដ្ឋ)។អាករលើតម្លៃបន្ថែមលើទំនិញជាបន្ទុករបស់រដ្ឋគឺជាចំណូលបានមកពីអាករលើតម្លៃបន្ថែមលើទំនិញជាបន្ទុករបស់រដ្ឋដែលមានការសម្រេចពីរាជរដ្ឋាភិបាល។អាករលើតម្លៃបន្ថែមលើសេវាជាបន្ទុករបស់រដ្ឋគឺជាចំណូលដែលរដ្ឋទទួលបានមកពីអាករលើតម្លៃបន្ថែមលើសេវាជាបន្ទុករបស់រដ្ឋដែលមានការសម្រេចពីរាជរដ្ឋាភិបាល។អាករលើតម្លៃបន្ថែម របបនាំចូល(សហគ្រាសប្រេងឥន្ធនៈ)គឺជាចំណូលដែលទទួលបានពីការបង់អាករបន្ថែមលើតម្លៃប្រេងឥន្ធនៈដែលបាននាំចូល។ អាករលើតម្លៃបន្ថែមរបបនាំចូល(សហគ្រាសផ្សេងៗ)គឺជាប្រាក់ដែលរដ្ឋទទួលបានពីការបង់អាករបន្ថែមលើតម្លៃទំនិញឬសេវកម្មផ្សេងៗក្រៅពីប្រេងឥន្ធនៈដែលបាននាំចូល។និងចុងក្រោយគឺអាករលើតម្លៃបន្ថែមរបបនាំចូល(ជាបន្ទុករបស់រដ្ឋ)គឺជាចំណូលដែលរដ្ឋទទួលបានពីអាករលើតម្លៃបន្ថែមលើការនាំចូលទំនិញជាសម្ភារកសិកម្មនិងទំនិញផ្សេងទៀត(ការកត់ត្រាជាចំណូលថវិកាក្នុងអនុគណនីដើម្បីតុល្យភាព

[២៣] សៀវភៅណែនាំស្តីពីពន្ធលើអចលទ្រព្យ ទំព័រទី១

[២៤] អត្ថបទចុះផ្សាយរបស់គេហទំព័រអគ្គនាយដ្ឋានពន្ធដារ https://www.tax.gov.kh/bpro.php

[២៥] សៀវភៅណែនាំស្តីពីពន្ធលើអចលទ្រព្យ ទំព័រទី២

រវាងចំណាយថវិកាដែលជាបន្ទុករបស់រដ្ឋ)។[២៦]ការផ្គត់ផ្គង់ជាប់អាករសំដៅដល់ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ១.២.១.២.ប្រភពថវិកាពីពន្ធគយ

ពន្ធគយគឺជាថវិកាដែលរដ្ឋប្រមូលបានពីពន្ធនិងអាករលើទំនិញដែលនាំចេញឬនាំចូលដោយឆ្លងកាត់ដែនគយ។ដែនគយមានដែនដី ដែនទឹក ដែនអាកាសនិងកោះនានានៃព្រះរាជនាចក្រកម្ពុជារាជរដ្ឋាភិបាលមានសិទ្ធិបង្កើតតំបន់រួចពន្ធនានា ដែលមិនស្ថិតនៅក្រោមការអនុវត្តទាំងស្រុងឬភាគខ្លះនូវនីតិវិធីគយ[២៧]។ប្រតិបត្តិការគយប្រព្រឹត្តនៅក្នុងដែនគយទាំងមូលរាប់បញ្ចូលទាំងវង់អំណាចគយតាមបណ្តោយព្រំដែនគោកនិងតំបន់ឆ្នេរក្រោមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ។មណ្ឌលសមុទ្រមានព្រំដែនពីឆ្នេរទៅក្រៅចម្ងាយ២០គីឡូម៉ែត្រពីឆ្នេរសមុទ្រចូលមកក្នុងចម្ងាយ២០គីឡូម៉ែត្រ ព្រមទាំងដីចម្ងាយ២០គីឡូម៉ែត្រពីមាត់ទន្លេ មាត់ស្ទឹង មាត់ព្រែកដែលហូរចាក់ទៅសមុទ្រមកទល់នឹងការិយាល័យគយនៅដើមគេបង្អស់គិតពីសមុទ្រមកនិងរង្វង់២០គីឡូម៉ែត្រជុំវិញការិយាល័យនេះ។តាមព្រំដែនគោកចូមកខាងក្នុងចម្ងាយ២០គីឡូម៉ែត្រ។[២៨]តម្លៃគិតពន្ធគយលើទំនិញនាំចូល គឺជាថ្លៃដែលបានទូទាត់ឬនឹងត្រូវទូទាត់ពិតប្រាកដលើទំនិញ។ការប្រកាសតម្លៃគិតពន្ធគយនៃទំនិញនាំចូល ត្រូវអនុលោមតាមបញ្ញត្តិមាត្រា១៨ចំនុច "ខ" នៃច្បាប់ស្តីពីគយ[២៩]និងបញ្ញត្តិប្រកាសលេខ៣៨៧ សហវ.គរ ចុះថ្ងៃទី២២ ខែឧសភាឆ្នាំ២០០៨របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល[៣០]។ តម្លៃគិតពន្ធគយនៃទំនិញនាំចូលត្រូវប្រកាសជាប្រាក់រៀល[៣១] ។ចំពោះទំនិញនាំចេញឬនាំចូលត្រូវគណនាតាមវិធីសាស្ត្រចំនួនពីរគឺវិធីសាស្ត្រសំរាប់ទំនិញទូទៅនិងវិធីសាស្ត្រសំរាប់ទំនិញប្រេងសាំង ឬម៉ាស៊ូត។

ចំពោះនីតិវិធីនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយត្រូវមានទីកន្លែងការដាក់ឯកសរស្នើសុំផ្ទៀងផ្ទាល់តម្លៃគិតពន្ធគយ តម្លៃគិតពន្ធគយឯកសារត្រឹមត្រូវបុគ្គលដែលមាននីតិសម្បទាស្នើសុំរយៈពេលនៃការផ្ទៀងផ្ទាល់តម្លៃគិតពន្ធគយយន្តការឧទ្ធរដែលតម្លៃគិតពន្ធគយមធ្យោបាយទំនាក់ទំនង។ទីតាំងសំរាប់នីតិវិធីនៃការផ្ទៀងផ្ទាល់តម្លៃគិតពន្ធគយមានពីរគឺអង្គភាពតម្លៃគិតពន្ធគយនៅតាមសាខានិងការិយាល័យគយនិងរដ្ឋាករមូលដ្ឋាន(ក្នុង

[២៦] ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភាឆ្នាំ២០១៧ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជំពូក៧០ គណនី៧០០២ ចាប់ពីអនុគណនី៧០០២២ដល់ អនុគណនី៧០០២៧

[២៧] ច្បាប់ស្តីពីគយឆ្នាំ២០០៧ មាត្រា២

[២៨] ច្បាប់ស្តីពីគយឆ្នាំ២០០៧ មាត្រា៤

[២៩] ច្បាប់ស្តីពីគយឆ្នាំ២០០៧ មាត្រា១៨

[៣០] ប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិត ពន្ធគយលើទំនិញនាំចេញ

[៣១] ច្បាប់ស្តីពីគយឆ្នាំ២០០៧ មាត្រា២៣

ក្របខ័ណ្ឌវិមជ្ឈការ)និងនាយកដ្ឋានផែនការបច្ចេកទេសនិងកិច្ចការអន្តរជាតិនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ការដាក់ឯកសារស្នើសុំផ្ទៀងផ្ទាល់តម្លៃគិតពន្ធគយត្រូវភ្ជាប់មកជាមួយនូវបណ្តាលឯកសារគាំទ្រដូចជា វិក្កយបត្រពាណិជ្ជកម្មបញ្ជីវេចខ្ចប់និងអញ្ញត្តិប័ណ្ណចំនួន៣ច្បាប់វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមប័ណ្ណប៉ាតង់លិខិតផ្ទេរសិទ្ធិ អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនម្ចាស់ទំនិញនិងអ្នកតំណាងលិខិតអនុញ្ញាត(ប្រសិនបើតម្រូវ)តែក្នុងករណីខ្លះមន្ត្រីគយមានសមត្ថកិច្ចអាចតម្រូវអោយមានឯកសារពាក់ព័ន្ធបន្ថែមទៀតគឺ កិច្ចសន្យាលក់ ប័ណ្ណបញ្ជាទិញលិខិតបញ្ជាក់ប្រតិបត្តិការតាមធនាគារតារាងតម្លៃសាធារណៈ និងឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងកិច្ចចម្លងការឬការទូទាត់ឯកសារដែលបញ្ជាក់ពីអត្តសញ្ញាណឬយថាប្រភេទលម្អិតច្បាស់លាស់នៃទំនិញ។ហើយដើម្បីអោយឯកសារមានភាពត្រឹមត្រូវត្រូវមានលក្ខណដូចជាបានបំពេញដោយត្រឹមត្រូវគ្រប់ប្រឡង់ព័ត៌មានពុំមានភាពមិនប្រក្រតីឬការកោសលុបមានបោះត្រាបញ្ជាក់របស់ក្រុមហ៊ុនម្ចាស់ទំនិញចំពោះឯកសារច្បាប់ចម្លង។ល។បុគ្គលដែលមាននីតិសម្បទាស្នើសុំលុះត្រាតែម្ចាស់ក្រុមហ៊ុនស្នើសុំនាំចូល ឬ បុគ្គលិករបស់ក្រុមហ៊ុនស្នើសុំនាំចូលដែលមានទទួលសិទ្ធិតំណាងពីម្ចាស់ក្រុមហ៊ុន(ត្រូវភ្ជាប់មកជាមួយនូវបណ្ណសំគាល់បុគ្គលិកក្រុមហ៊ុន) នីតិបុគ្គលឬបុគ្គលដែលមាននីតិសម្បទានជាជើងសាគយ។រយៈពេលនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយបើក្នុងករណីឯកសារមានភាពត្រឹមត្រូវនិងគ្រប់គ្រាន់ការផ្ទៀងផ្ទាត់និងការសម្រេចលើតម្លៃគិតពន្ធគយនឹងធ្វើឡើងក្នុងរង្វង់ពី១ទៅ២ថ្ងៃធ្វើការប៉ុន្តែក្នុងករណីមិនអាចធ្វើបានដោយប្រការណាមួយ មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចនឹងចុះអាទិសង្កេតនៅលើឯកសារពាក់ព័ន្ធបញ្ជាក់ពីមូលហេតុនៃការយឺតយ៉ាវក្នុងការចេញសេចក្តីសម្រេចនេះ។យន្តការឧទ្ធរណ៍នៃតម្លៃគិតពន្ធគយត្រូវធ្វើឡើងតាមការកំណត់ក្នុងច្បាប់ប្រសិនបើបុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចរបស់មន្ត្រីគយមានសមត្ថកិច្ចលើតម្លៃគិតពន្ធគយអាចធ្វើការតវ៉ាជាលាយលក្ខណ៍ទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអក្សរស្របតាមបញ្ញត្តិមាត្រា២៨នៃច្បាប់ស្តីពីគយ។ចំពោះមធ្យោបាយទំនាក់ទំនងវិញបើក្នុងករណីមានចម្ងល់ពីវិធីសាស្ត្រគណនាឬនីតិវិធីនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយបុគ្គលពាក់ព័ន្ធអាចសាកសួរព័ត៌មាននៅនាយកដ្ឋានផែនការបច្ចេកទេសនិងកិច្ចការអន្តរជាតិ នៃ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយឬទីកន្លែងផ្សេងទៀតទៅតាមការកំណត់ របស់នាយកទីចាត់ការគយនិងរដ្ឋាករ។រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញប្រកាសកំណត់ ពេលវេលារបៀបរបបតម្រូវការឯកសារ កាលៈទេសៈ និងការលើកលែងនានាពាក់ព័ន្ធនឹងការរាយការណ៍ពីទំនិញនាំចូល[៣២]។ទំនិញដែលយកចេញពីប្រទេសកម្ពុជាទៅកាន់ទីផ្សារប្រទេសក្រៅ

---

[៣២] អត្ថបទចេញផ្សាយរបស់គេហទំព័រអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
http://www.customs.gov.kh/%E1%9E%93%E1%9E%B8%E1%9E%8F%E1%9E%B7%E1%9E%9C%E1%9E%B7%E1%9E%92%E1%9E%B8%E1%9E%98%E1%9E%BB%E1%9E%93%E1%9E%96%E1%9F%81%E1%9E%9B

ដែលឆ្លង់កាត់ដែនគយត្រូវហៅថាទំនិញនាំចេញរីឯពន្ធនាំចេញត្រូវគិតទៅលើប្រភេទទំនេញនាំចេញពីប្រភេទកម្ពុជាទៅប្រភេទក្រៅ។ទំនិញគ្រប់ប្រភេទដែលនាំចេញត្រូវរាយការណ៍នៅការិយាល័យគយឬទីកន្លែងមួយតាមការកំណត់របស់នាយកទីចាត់ការគយនិងរដ្ឋាករ។[៣៤] ការនាំចេញពីប្រទេសកម្ពុជាត្រូវបែងចែកជាបីគឺផ្លូវសមុទ្រ/ផ្លូវទន្លេ តាមកុងតឺន័រ ផ្លូវអាកាសនិងផ្លូវគោក។នីតិវិធីនាំការនាំចេញទំនិញដោយបំពេញបែបបទនៅមាត់ច្រកផ្លូវសមុទ្រ/ផ្លូវទន្លេ ត្រូវការអ្នកនាំចេញ ឬតំណាងត្រូវធ្វើលិខិតស្នើសុំនាំចេញទំនិញទៅប្រធានអង្គភាពគយនិងរដ្ឋាករ មាត់ច្រកដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធប្រធានអង្គភាពគយនិងរដ្ឋាករមាត់ច្រកពិនិត្យលើពាក្យស្នើសុំនិងឯកសារភ្ជាប់ព្រមទាំងចុះហត្ថលេខាអនុញ្ញាតអោយនាំចេញតាមសំណើរប្រសិនបើពុំមានភាពមិនប្រក្រតី ក្រោយពេលទទួលបានការអនុញ្ញាតអោយនាំចេញ អ្នកនាំចេញឬតំណាងត្រូវបំពេញនីតិវិធីនាំការបំពេញប្រតិវេទន៍គយ។ការនាំចេញដោយកុងតឺន័រត្រូវស្កេនទាំងអស់លើកលែងតែទំនិញនាំចេញដែលជាផលិតផលសម្រេចរបស់វិនិយោគិនវិស័យកាត់ដេរដែលបានបំពេញបែបបទនៅសាខាគយនិងរដ្ឋាករនាំចេញទំនិញនាំចេញដែលត្រូវបានត្រួតពិនិត្យរូបវន្តដោយមន្ត្រីគយនៃអង្គភាពគយនិងរដ្ឋាករមាត់ច្រករួចនាពេលផ្ទុកចូលក្នុងកុងតឺន័រទំនិញនាំចេញសម្រាប់អង្គទូតឬអង្គការមានអភ័យឯកសិទ្ធិការទូត អង្គការអន្តរជាតិអង្គការក្រៅរដ្ឋាភិបាលនានាដែលត្រូវបានទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាលទំនិញដែលទទួលបានការអនុញ្ញាតដោយឡែកអោយរួចពីកាតព្វកិច្ចនេះពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកុងតឺន័រទទេ។ផ្លូវអាកាសទំនិញនាំចេញទាំងអស់ត្រូវរាយការណ៍នៅការិយាល័យគយឬទីកន្លែងផ្សេងទៀតទៅតាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា។ទំនិញទាំងនោះនឹងត្រូវរក្សាទុកបណ្តោះអាសន្ននៅទីកន្លែងដែលគ្រប់គ្រងដោយរដ្ឋបាលគយ រង់ចាំបំពេញបែបបទបញ្ចេញទំនិញពីគយមុននឹងអនុញ្ញាតយកទំនិញចេញ។នីតិវិធីនៃការនាំចេញទំនិញដោយបំពេញបែបបទនៅមាត់ច្រកផ្លូវគោកបែងចែកជាពីរគឺ អ្នកនាំចេញឬតំណាងត្រូវធ្វើលិខិតស្នើសុំនាំចេញទំនិញពីប្រទេសកម្ពុជាទៅក្រៅប្រទេសកម្ពុជាដោយយកពាក្យស្នើសុំនេះទៅប្រធានអង្គភាពដែលគ្រប់គ្រងនៅអង្គភាពគយនិងរដ្ឋាករមាត់ច្រកដែលខ្លួនយកទំនិញចេញពីប្រទេសកម្ពុជាទៅក្រៅប្រទេសកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនិងប្រធានអង្គភាពគយនិងរដ្ឋាគរមាត់ច្រកពិនិត្យលើពាក្យស្នើសុំនិងឯកសារភ្ជាប់ ក្រោយពេលដែលប្រធានអង្គភាពគយនិងរដ្ឋាករត្រួតពិនិត្យរួចហើយបញ្ជាក់ថាត្រឹមត្រូវទើបយល់ព្រមថែមទាំងចុះហត្ថលេខាអនុញ្ញាតអោយនាំចេញតាមសំណើប្រសិនបើពុំមានភាពមិនប្រក្រតី។

---

%E1%9E%94%E1%9F%86%E1%9E%96%E1%9F%81%E1%9E%89%E1%9E%94%E1%9F%82%E1%9E%94/%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%95%E1%9F%92%E1%9E%91%E1%9F%80%E1%9E%84%E1%9E%95%E1%9F%92%E1%9E%91%E1%9E%B6%E1%9E%8F%E1%9F%8B%E1%9E%8F%E1%9E%98%E1%9F%92%E1%9E%9B%E1%9F%83%E1%9E%82%E1%9E%B7%E1%9E%8F/

[៣៤] ច្បាប់ស្តីពីគយឆ្នាំ២០០៧ មាត្រា១៦

### ១.២.២.ប្រភពចំណូលបន្ទាប់បន្សំ

ក្រៅពីពន្ធដែលជាប្រភពចំណូលដ៏ធំរបស់រដ្ឋរួចហើយរដ្ឋក៏នៅមានប្រភពចំណូលផ្សេងទៀតដែលជាប្រភពចំណូលបន្ទាប់បន្សំ ប្រភពចំណូលបន្ទាប់បន្សំនេះអាចកត់សម្គាល់បានថាជាប្រភពចំណូលដែលបានមកក្រៅពីពន្ធ។ប្រភពចំណូលបន្ទាប់ប្រែក្លាចជាប្រភពចំណូលដែលសំខាន់នៅពេលដែលចំណូលដែលបានមកពីការប្រមូលពន្ធមិនគ្រប់គ្រាន់សំរាប់ចំណាយនៅឆ្នាំថវិកាបន្ទាប់ប៉ុន្តែសារសំខាន់នេះមិនមានជាយូរអង្វែងនេះទេ ព្រោះការប្រមូលពន្ធអាចទទួលថវិកាតិចអាចកើតមានឡើងតែម្តងម្កាល់នេះទេ។ប្រភពចំណូលបន្ទាប់បន្សំនេះមានដូចជាការវិនិយោគ ការខ្ចី ផលទុននៃទ្រព្យសម្បត្តិដែលរដ្ឋមាន និងអាជីវកម្មរបស់រដ្ឋ។ការវិនិយោគរបស់រដ្ឋ គឺជាការដែលរដ្ឋយកថវិកាដែលខ្លួនមានទៅវិនិយោគ ឬដាក់ទុនក្នុងអង្គភាពផ្សេងទេហើយអង្គភាពនេះអាចជាអង្គភាពឯកជន ឬសាធារណៈប៉ុន្តែតាមស្ថានភាពនៃប្រទេសកម្ពុជាបច្ចុប្បន្នមានត្រឹមការវិនិយោគក្នុងសហគ្រាសសាធារណៈតែប៉ុណ្ណោះ ជាឧទាហរណ៍ ការវិនិយោគរបស់រាជរដ្ឋាភិបាលប្រទេសកម្ពុជានៅក្នុងវិស័យទូរគមនាគមន៍កម្ពុជា(Telecom Cambodia)[៣៥]។ ការខ្ចីរបស់រដ្ឋ គឺជាការខ្ចីថវិកាមួយចំនួនពីប្រភពខាងក្រៅដើម្បីយកមកប្រើប្រាស់ក្នុងដំណើរការសកម្មភាពរបស់រដ្ឋពាក្យថាប្រភពខាងក្រៅនេះគឺសំដៅដល់អង្គភាពដែលមិនមែនជារាជរដ្ឋាភិបាលអាចជាអង្គភាពក្នុងស្រុកឬក្រៅស្រុកហើយអង្គភាពនេះទៀតអាចជាក្រុមហ៊ុនអង្គការពិភពលោក រដ្ឋជាដៃគូជាដើមបើសិនជាមានដំណាក់កាលសំខាន់អាចប្រមូលថវិកាជាអាជីវករដែលមានប្រាក់ពាក់លាននៅក្នុងប្រទេសកម្ពុជា។ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋគឺជាចំណូលបានពីការជួលនិងប្រើប្រាសទ្រព្យសម្បត្តិរដ្ឋមានដូចជា ផលសម្បទាន ផលពីនេសាទ ផលពីព្រៃឈើ សម្បទានប្រេងកាត សម្បទានរ៉ែ សម្បទានដីសេដ្ឋកិច្ច...។ល។ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាគឺជាចំណូលទទួលបានពីលក់និងជួលទ្រព្យសម្បត្តិនិងសេវា របស់រដ្ឋ។សំរាប់ការលក់គឺត្រឹមរបស់តូចតាចក្រៅពីអាគារ ដីធ្លី ចំណែកទ្រព្យសម្បត្តិនិងសេវាអាចធំ។ការលក់មានលក្ខណៈតូចតាចមានដូចជាតុទូកៅអីឯកសាររបស់រដ្ឋជាដើមប៉ុន្តែការជួលទ្រព្យសម្បត្តិមានដូចជាការជួលដីឬទីកន្លែងណាមួយរបស់រដ្ឋទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរីឯសេវាវិញដូចជាកម្រៃសេវានាំផ្លូវចុះចតហោះហើនៅអាកាសយានដ្ឋាននិងសេវានាំផ្លូវហោះឆ្លងកាត់ដែនអាកាសកម្ពុជាសេវាសោតទស្សន៍(ស្ថានីយវិទ្យុ ទូរទស្សន៍ ជាដើម)ការផ្គត់ផ្គង់អគ្គិសនីនិងទឹកជាដើម។នៅក្នុងផលទុកពីការលក់ជួលទ្រព្យសម្បត្តិនិងសេវាមានមាតិកាថវិកាជាច្រើនដូចជាផលទុននៃសកម្មភាពភាពយន្តផលទុននៃសកម្មភាពវប្បធម៌ផលទុពីប្រៃសណីយ៍និងទូរគមនាគមន៍ជាដើមផលទុននៃការលក់ផលិតផលកសិកម្ម...។ល។ចំណូលដែលរដ្ឋទទួលបានពីអាជីវកម្មផ្ទាល់ខ្លួនភាគច្រើនទទួលបានពីគ្រឹស្ថានសាធារណៈមួយចំនួនដែលរដ្ឋបានប្តូរពី

---

[៣៥] ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

គ្រឹះស្ថានសាធារណៈមិនរកចំណូលមកជាគ្រឹះស្ថានសធារណៈរកចំណូលឧទាហរណ៍សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចមុនដំបូងជាគ្រឹះស្ថានដែលបង្រៀនមិនយកលុយរហូតទទួលបានការកែប្រែទើបសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចទៅជាគ្រឹះស្ថានរកចំណូលហើយចំណូលដែលទទួលបានពីការបង់លុយសិក្សាការជួលតូបលក់អីវ៉ាន់ជាដើមជាចំណូលដែលរដ្ឋទទួលបានពីការធ្វើអាជីវកម្ម។ ហើយចំណូលដែលរដ្ឋទទួលបានពីគ្រឹះស្ថានសាធារណៈបែបនេះភាគច្រើនជាគ្រឹះស្ថានសាធារណៈបែបជាអប់រំដូចជា សាកលវិទ្យាល័យ វគ្គបណ្តុះបណ្តាលផ្សេងៗដែលរដ្ឋបានបង្កើតឡើង។

## ១.៣. ការគណនាពន្ធគយ

ការគណនាប្រាក់ពន្ធ អាករ ទៅលើទំនិញទូទៅត្រូវគណនាតាមលំដាប់លំដោយ ជាដំបូងត្រូវគណនាពន្ធនាំចូល រួចហើយអាករពិសេស(បើមាន)និងចុងក្រោយគឺអាករលើតម្លៃបន្ថែម។ពន្ធនាំចូល ត្រូវយក(តម្លៃគិតពន្ធគយxអត្រាពន្ធនាំចូល)។អាករពិសេសត្រូវយក(តម្លៃគិតពន្ធគយ+ពន្ធនាំចូល)xអត្រាអាករពិសេស។អាករលើតម្លៃបន្ថែមមានបែងចែកជាពីគឺទំនិញទូទៅមិនជាប់អាករពិសេសនិងទំនិញទូទៅដែលជាប់អាករពិសេស។ អាករលើតម្លៃបន្ថែមចំពោះទំនិញទូទៅដែលមិនជាប់អាករពិសេសត្រូវយក(តម្លៃគិតពន្ធគយ+ពន្ធនាំចូល)x ១០% រីឯអាករលើតម្លៃបន្ថែមចំពោះទំនិញទូទៅដែលជាប់អាករពិសេសត្រូវយក(ពន្ធនាំចូល+អាករពិសេស+អាករលើតម្លៃបន្ថែម)។ឧទាហរណ៍ក្រុមហ៊ុន ក នាំចូលបារីមកកម្ពុជាដែលមានតម្លៃគិតពន្ធគយស្មើនឹង១០លានរៀលចំពោះការនាំចូលស្រាបៀរត្រូវជាប់ពន្ធនាំចូលតាមអត្រា៣៥% អាករពិសេស២៥%និងអាករលើតម្លៃបន្ថែម ១០%ដូចនេះការគណនាត្រូវគិតពន្ធនាំចូល(10,000,000រៀលx 35%= 3,500,000រៀល)អាករពិសេស (10,000,000រៀល+3,500,000រៀល)x25%=3,375,000រៀលនិងចុងក្រោយគឺអាករលើតម្លៃបន្ថែម (10,000,000រៀល+3,500,000រៀន+3,375,000រៀល)x10%=168,750រៀលរួចហើយរកតម្លៃនៃការគណនានូវពន្ធនាំចូលអាករពិសេសអាករលើតម្លៃបន្ថែមទាំងបីបូកចូលគ្នា3,500,000+3,375,000+168,750 =7,043,750រៀល។ចំពោះប្រេងសាំងនិងម៉ាស៊ូតវិញការគណនាប្រាក់ពន្ធនិងអាករក៏ត្រូវគណនាតាមលំដាក់លំដោយជាដំបូងត្រូវគណនាពន្ធនាំចូល អាករបន្ថែម អាករពិសេស និងអាករលើតម្លៃបន្ថែម។ពន្ធនាំចូលស្មើត្រូវយកតម្លៃគិតពន្ធគយx អត្រាពន្ធនាំចូល។អាករបន្ថែមត្រូវបែងចែកជាពីរគឺចំពោះប្រេងសាំងនិងប្រេងម៉ាស៊ូត។ អាករបន្ថែមលើប្រេងសាំងត្រូវយកបរិមាណ(ចំនួនលីត្រ)x ០.០០២ដុល្លាx អត្រាការប្តូរប្រាក់ រីឯអាករបន្ថែមលើប្រេងម៉ាស៊ូតត្រូវយកបរិមាណ(ចំនួនលីត្រ)x០.០០៤ដុល្លាxអត្រាប្តូរប្រាក់។អាករពិសេសត្រូវយក(តម្លៃគិតពន្ធគយ+ពន្ធនាំចូល+អាករបន្ថែម)xអត្រាអាករពិសេស។អាករលើតម្លៃបន្ថែមត្រូវយក(តម្លៃគិតពន្ធគយ+ពន្ធនាំចូល+អាករបន្ថែម+អាករពិសេស)x១០%។ចំពោះប្រាក់ពន្ធ និងអាករសរុបត្រូវយកពន្ធនាំចូល+អាករបន្ថែម+អាករពិសេស+អាករលើតម្លៃបន្ថែម។

## ១.៤ ទោសបញ្ញត្តិលើការអនុវត្តថវិកា

បទល្មើសលើការអនុវត្តថវិកាគឺៈ (១)ការចំណាយដោយគ្មានទិដ្ឋាការ ឬក្នុងករណីដែលអភិបាលហិរញ្ញវត្ថុមិនព្រមឲ្យទិដ្ឋាការ(២)ការចំណាយដោយគ្មានប្រតិភូកម្ម(៣)ការចំណាយខុសខ្ទង់(៤)អំពើរបស់ភ្នាក់ងាររដ្ឋដែលបណ្តាលឲ្យជនណាមួយចំណេញលើខ្ទង់រដ្ឋ ឬស្ថាប័នដែលភ្នាក់ងារនោះតំណាង។[៣៦]

ទណ្ឌកម្មចំពោះបទល្មើសលើការអនុវត្តថវិកាគឺការពិន័យជនមានកំហុសដោយតុលាការតម្រូវឲ្យបង់ប្រាក់ចំនួនស្មើនឹងប្រាក់បៀវត្សមួយឆ្នាំយ៉ាងច្រើនប្រាក់ពិន័យនេះត្រូវបង្កើនឲ្យដល់ប្រាក់បៀវត្ស២ឆ្នាំបើសិនជាតុលាការរកឃើញថាកំហុសដែលបានប្រព្រឹត្តិនោះមានលក្ខណៈជាកំហុសរបស់ភ្នាក់ងាររដ្ឋដែលបណ្តាលឲ្យជនណាមួយចំណេញលើខ្ទង់រដ្ឋឬស្ថាប័នដែលភ្នាក់ងារនោះតំណាង។មាត្រា៨៥នៃប្រព័ន្ធច្បាប់ហិរញ្ញវត្ថុឆ្នាំ២០០៨ចែងថា"មន្ត្រីសាធារណៈគ្រប់ប្រភេទនិងគ្រប់ឋានៈដែលបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះក្នុងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួនដែលរដ្ឋបានប្រគល់ជូនត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទានគិតដល់ទោសព្រហ្មទណ្ឌនិងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត។ក្នុងករណីកំហុសរបស់មន្ត្រីសាធារណៈបានធ្វើឲ្យមានការប្រាក់បង់ប្រាក់កាសឬខូចខាតទ្រព្យសម្បត្តិសាធារណៈនោះតម្លៃនៃការបាត់បង់ឬខូចខាតរួមទាំងការប្រាក់លើតម្លៃបាត់បង់និងខូចខាតនិងក្លាយជាបំណុលចំពោះមន្ត្រីសាធារណៈនោះ ដែលត្រូវសងនិងបង់ចូលថវិការដ្ឋវិញ" ។

[៣៦] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៣

# ជំពូក២
# នីតិវិធីដំណើរការថវិកា

ឆ្លងតាមការបកស្រាយរបស់អត្ថបទខាងលើយើងអាចទទួលដឹងខ្លះៗថាថវិកាជាតិដែលប្រមូលបានពីប្រភពទាំងអស់ត្រូវយកទៅចំណាយប៉ុន្តែអ្វីដែលមិនទាន់បានបកស្រាយនេះគឺដំណើរការរៀបចំថវិកាសំរាប់ចំណាយព្រោះដំណើរការរៀបចំថវិកាសំរាប់ចំណាយនេះគឺជាប្រតិបត្តិការណ៍ការងារនៅចំចន្លោះកណ្តាលរបស់ដំណើរការថវិកាជាតិដូចនេះក្នុងមាតិកាស្តីពីដំណើរការថវិកានេះក្រុមយើងខ្ញុំនឹងលើកយកអ្វីទៅដំណើរការថវិកាហើយថវិកាជាតិជាអ្វីនឹងដំណើរការរៀបចំថវិកាសំរាប់ចំណាយគ្រប់ក្រសួងស្ថាប័នរដ្ឋទាំងអស់ទាំងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិមកបកស្រាយអោយបានក្បោះក្បាយ។

ដំណើរការថវិកាជាតិ គឺដំណើរការដែលធ្វើជារឿងរហូតមិនអាចបញ្ឈប់បានប៉ុន្តែដំណើរការថវិកានេះត្រូវធ្វើអោយមានរយៈពេលត្រឹមត្រូវហើយរយៈពេលដែលត្រូវធ្វើនេះគឺមានរយៈពេលមួយឆ្នាំនៅក្នុងដំណើរការនេះមានដូចជាការប្រមូលថវិកាការរៀបចំនិងចំណាយថវិកាឬក៏យើងអាចនិយាយអោយងាយយល់បានថាជាដំណើរការយកដែលរដ្ឋធ្វើការចំណូលសំរាប់ចំណាយហើយមានសកម្មភាពជាប្រព័ន្ធដោយប្រព័ន្ធនេះហៅថាដំណើរការថវិកាជាឧទាហរណ៍ដើមឆ្នាំ២០២០បានចាប់ផ្តើមរដ្ឋនឹងចាប់ផ្តើមធ្វើដំណើរការថវិកាជាតិឆ្នាំ២០២០ ក្រោយឆ្នាំ២០២០ត្រូវបានបញ្ចប់ហើយឆ្នាំ២០២១ចូលមករដ្ឋនឹងបិតបញ្ចប់ដំណើរកថវិកាឆ្នាំ២០២០រួចហើយចាប់ផ្តើមដំណើរការថវិកាឆ្នាំ២០២១។យើងក៏អាចនិយាយអោយសង្ខេបនៅដើមក្បាលនៃមាតិកានេះបានដែលថាដំបូងឡើយរដ្ឋធ្វើការប្រមូលថវិកាពីប្រភពដែលរដ្ឋមានចំពោះប្រភពថវិកាក្រុមយើងខ្ញុំបានបង្ហាញនៅអត្ថបទខាងលើរួចហើយក្រោយពីមានការប្រមូលរួចហើយក្រសួងនីមួយៗអាចទទួលបានកញ្ចប់ថវិកាជាតិយកទៅប្រើប្រាស់បានលុះត្រាតែឆ្លង់កាត់តាមនីតិវិធីនៃដំណើរការថវិកាជាតិមុននឹងក្រសួងទាំងនោះទទួលបានថវិកាជាតិយកទៅអនុវត្តក្នុងគម្រោងរបស់ពួកគេដំណាក់កាលដំបូងក្រសួងនីមួយៗត្រូវធ្វើផែនការអភិវឌ្ឍន៍របស់ខ្លួនដើម្បីបង្ហាញទៅរដ្ឋាភិបាលថាគម្រោងរបស់ខ្លួននឹងជួយដល់ប្រជាពលរដ្ឋនិងធ្វើការអភិវឌ្ឍប្រទេសឲ្យរីកចំរើន។គម្រោងនោះដូចជា ការធ្វើផ្លូវ ស្ពាន សាលារៀន សាងសង់មន្ទីពេទ្យជាដើម។ដំណាក់កាលបន្ទាប់ក្រសួងទាំងនោះត្រូវបញ្ជូនផែនការសកម្មភាពនោះទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចឆ្លងទៅគណៈរដ្ឋមន្ត្រីរដ្ឋសភាព្រឹទ្ធសភានិងចុងក្រោយត្រូវបញ្ជូនទៅព្រះមហាក្សត្រដើម្បីទទួលបានការចុះព្រះហត្ថលេខាឲ្យប្រើប្រាស់កញ្ចប់ថវិកាជាតិដែលស្នើសុំនោះ។ចំណែកការលម្អិតទៅលើដំណើរការថវិកាជាតិនឹងមានការបកស្រាយនៅអត្ថបទខាងក្រោមទៀតដោយមានការរៀបរាប់តាមលំដាប់លំដោយដោយស្របតាមនីតិវិធីនិងបទដ្ឋានគតិយុត្តិដែលមានចែងនៅក្នុងច្បាប់។ក្រោយការបកស្រាយខាងលើដែលមានអំណះអំណាងជាច្រើនមកយើងអាចទាញបានថាថវិកាជាតិ គឺចង់សំដៅដល់ចំណូលនិងចំណាយដែលដំណើរការជាប្រព័ន្ធនិងមានទំនាក់ទំនងនឹងគ្នាដែល

មិនអាចកាត់ផ្ដាច់បានហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។ពាក្យថាដំណើរការជាប្រព័ន្ធចង់និយាយដល់ការប្រមូលថវិការបស់រដ្ឋហើយរៀបចំថវិកាដែលប្រមូលបានមកនេះទៅចំណាយតាមកម្មវិធីឬគម្រោងដែលបានគ្រោងទុក។ចំណែកពាក្យថាទំនាក់ទំនងនឹងគ្នាដែលមិនអាចកាត់ផ្ដាច់បានបង្ហាញពីការផ្សារភ្ជាប់គ្នារវាងការរកថវិកាដើម្បីផ្គត់ផ្គង់ចំណាយនិងការដកយកថវិកាទៅចំណាយដើម្បីផ្គត់ផ្គង់ស្ថាប័ននៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។

## ២.១ រចនាសម្ព័ន្ធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងអោយ អនុក្រឹត្យលេខ ០៤ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០។



ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាស្ថាប័នរដ្ឋមួយដែលត្រូវបំពេញមុខងារជាសេនាធិការអោយរាជរដ្ឋាភិបាលលើបេសកម្មដឹកនាំនិងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជានាចក្រកម្ពុជាក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ចនិងលើកតម្កើងជីវភាពប្រជាជនដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារនិងសមធម៌សង្គមដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធ្វើបេសកម្មរបស់ខ្លួនបានតាយរយៈការរៀបចំនិងការអនុវត្តអោយបានត្រឹមត្រូវតាមគោលនយោបាយក្របខណ្ឌច្បាប់និងបទបញ្ញាទាំងឡាយដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈទ្រព្យសម្បត្តិរដ្ឋកិច្ចការវិនិយោគនិងឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់និងបញ្ញាក់ពាក់

ព័ន្ធផ្សេងទៀត។[៣៧]បើនិយាយអំពីមុខងារ និងភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ចវិញមានដូចជារៀបចំនិងតាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលគ្រប់គ្រងនិងសម្របសម្រួលនូវកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពង្រឹងអភិបាលកិច្ចល្អទៅលើអ្វីដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈវិភាគតាមដាននិងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លីមធ្យមនិងរយៈពេលវែង និងដាក់ចេញនូវវិធានការដើម្បីតម្រង់ទិសនិងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច។ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ត្រូវសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធដើម្បីដឹកនាំនិងចូលរួមក្នុងការរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើកិច្ចការសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងកិច្ចការសមាហរណកម្មកម្ពុជាទៅក្នុងសេដ្ឋកិច្ចពិភពលោកពិសេសកិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាក្នុងក្របខណ្ឌអាស៊ាន។ក្រសួងសេដ្ឋកិច្ចក៏ត្រូវកសាងប្រព័ន្ធហិរញ្ញវត្ថុអោយឯកភាពទូទាំងប្រទេសហើយធានាអនុវត្តប្រព័ន្ធនេះអោយបានត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនិងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗព្រមទាំងច្បាប់ពាក់ព័ន្ធនិងបទបញ្ញាដទៃទៀតធ្វើការបែងចែកនិងបែងចែកឡើងវិញនូវផលទុនជាតិតាមរយៈការប្រមូលចំណូលនិងកម្មវិធីនីយកម្មនិងថវិកានីយកម្មនៃចំណាយសាធារណៈ រៀបចំកសាងសេចក្តីព្រាងច្បាប់និងបទបញ្ញាផ្សេងៗសម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗឬជាលក្ខណៈអចិន្ត្រៃយ៍និងរៀបចំគ្រប់គ្រងថវិការដ្ឋរៀបចំនិងអនុវត្តគោលនយោបាយចំណូលថវិកាជាតិប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធបង់ចូលបេឡាថវិការដ្ឋធ្វើតារាងតុល្យភាពនិងវិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋចូលរួមកសាងនិងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានក្រៅប្រទេសនិងទទួលបន្ទុកគ្រប់គ្រងបំណុលសាធារណៈចូលរួមរៀបចំគោលនយោបាយនិងគ្រប់គ្រងកិច្ចការវិនិយោគពិនិត្យនិងចុះទិដ្ឋាការលើចំណាយរបស់ក្រសួងនិងស្ថាប័នរដ្ឋនានាគ្រប់គ្រងនិងត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈរបស់រដ្ឋតាមបណ្តាលក្រសួងស្ថាប័នរដ្ឋទាំងអស់ទទួលបន្ទុកដឹកនាំរៀបចំជំរុញអនុវត្តនិងតាមដានការអនុវត្តគោលនោយបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលវិភាគគ្រប់គ្រងនិងតាមដានការវិវត្តនៃវិស័យហិរញ្ញវត្ថុព្រមទាំងចូលរួមរៀបចំនិងអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យនៃវិស័យហិរញ្ញវត្ថុដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ អភិវឌ្ឍគ្រប់គ្រងនិងត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុរួមមានកិច្ចការធានារ៉ាប់រងនិងសោធនទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុចូលរួមរៀបចំនិងអនុវត្តគោលនយោបាយនិងក្របខណ្ឌនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មភ្នាល់គ្រប់ប្រភេទធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង ស្ថាប័នឬអង្គភាពសា

[៣៧] អនុក្រឹតលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧ ស្តីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាត្រា៤

ធារណៈប្រហាក់ប្រហែលសហគ្រាសសាធារណៈនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋបំពេញមុខងារជាបេឡាករនិងគណនេយ្យករសាធារណៈ របស់រាជរដ្ឋាភិបាលព្រមទាំងរៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យករសាធារណៈ បំពេញមុខងារសវនកម្មផ្ទៃក្នុងបណ្តុះបណ្តាលនិងធ្វើវិក្រឹតការប្រចាំនូវមុខជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដល់មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងស្ថាប័នពាក់ព័ន្ធអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។[៣៨] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបែងចែករចនាសម្ព័ន្ធរដ្ឋបាលរបស់ខ្លួនជាពីរគឺរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខុទ្ទកាល័យរដ្ឋមន្ត្រី**

ខុទ្ទកាល័យរដ្ឋមន្ត្រីជាអង្គភាពមួយនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកបេសកម្មសំរាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចជារ៉ាងរងទំនាក់ទំនងជាមួយនិងខុទ្ទកាល័យរបស់រដ្ឋមន្ត្រីនៃក្រសួងដ៏ទៃទៀតព្រមទាំងទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រនិងប្រព័ន្ធឃោសនាទាំងឡាយ ធ្វើការផ្តល់យោបល់ជូនរដ្ឋមន្ត្រីឬរដ្ឋលេខាធិការចំពោះកិច្ចការទូទៅក្នុងក្រសួង និងចំពោះសំណុំរឿងទាំងឡាយដែលប្រធានស្ថាប័នបានប្រគល់អោយពិនិត្យ។ភារកិច្ចផ្តល់យោល់នេះមិនផ្តល់សិទ្ធិអោយខុទ្ទកាល័យបំពេញការងារជំនួសអង្គភាពមានសមត្ថកិច្ចនៅក្នុងក្រសួងឬរដ្ឋលេខាធិការដ្ឋានឡើយចែកផ្សាយអំពីគោដៅរបស់ប្រធានស្ថាប័ននិងរៀបចំកាលវិភាគរបស់រដ្ឋមន្ត្រីនិងអង្គភាពចំពោះក្រសួងរួចតាមដានការអនុវត្តន៍ការងារទាំងនោះអោយស្របតាមកាលវិភាគដែលបានកំណត់រៀបចំសម័យប្រជុំការងារក្នុងក្រសួងផ្ទាល់ ព្រមទាំងកិច្ចប្រជុំការងារអន្តរក្រសួងបញ្ជូនបទបញ្ជារដ្ឋមន្ត្រីដល់អង្គភាពទាំងឡាយក្នុងក្រសួងតាមគំរិតដែលរដ្ឋមន្ត្រីប្រធានស្ថាប័នប្រគល់សិទ្ធិអោយតាមដាននិងសំរបសំរួលសកម្មភាពផ្សេងៗរបស់ក្រសួងឬរដ្ឋលេខាធិការដ្ឋានដើម្បីសំរួលការងារ និងតាមដានការអនុវត្តន៍បញ្ជារបស់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ។[៣៩]

**អគ្គលេខាធិកាដ្ឋាន**

អគ្គលេខាធិការដ្ឋានមានបេសកម្មដូចតទៅ ផ្តល់សេវាគាំទ្រសម្រាប់ប្រក្រតីភាពនៃដំណើរការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្របសម្រួលសកម្មភាពការងាររវាងថ្នាក់កណ្តាលនិងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួងពិសេសមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្តនិងធ្វើជាសេនាធីការអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

[៣៨] អនុក្រឹតលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧ ស្តីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាត្រា៥

[៣៩] អនុក្រឹត្យលេខ ២០ អនក្រ.បកចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៦ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន មាត្រា១៦

លើផ្នែករដ្ឋបាលហិរញ្ញវត្ថុបុគ្គលិកការបណ្តុះបណ្តាលនិងវិក្រឹតការនីតិកម្មព័ត៌មានវិទ្យានិងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។[៤០] ចំណែកភារកិច្ចមានដូចជាសម្របសម្រួលសកម្មភាពគ្រប់ថ្នាក់គ្រប់ផ្នែករបស់ក្រសួង នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋានក្រោមឱវាទក្រសួងលើកគម្រោងថវិកាក្រសួងប្រមូលផ្តុំនិងសម្របសម្រួលជំពូកថវិកាបម្រើអោយរាល់ចំណាយរបស់ក្រសួងគ្រប់គ្រងបុគ្គលិកមន្ត្រីរាជការរបស់ក្រសួងដោយទំនាក់ទំនងជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងស្ថាប័នរៀបចំតួនាទីនិងតំណែងឯកទេសរបស់ស្ថាប័ននិងធនធានមនុស្សវាយតម្លៃតម្រូវការបណ្តុះបណ្តាលបុគ្គលិកមន្ត្រីរាជការរបស់ក្រសួងសិក្សានិងវាយតម្លៃតម្រូវការសម្រាប់កសាងឡើងវិញនូវសមត្ថភាពធនធានមនុស្សនិងបង្កើតគុណភាពវិជ្ជាជីវៈផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំពោះមន្ត្រីក្រោមឱវាទក្រសួងនិងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធអនុវត្តការបណ្តុះបណ្តាលនិងធ្វើវិក្រឹតការជាប្រចាំដល់មន្ត្រីរាជការរបស់ក្រសួងនិងមន្ត្រីរាជការក្រសួងស្ថាប័នពាក់ព័ន្ធតាមផ្នែកជាមូលដ្ឋានគ្រឹះនិងជំនាញឯកទេសនានានៅក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាសមត្ថកិច្ចរបស់ក្រសួងណែនាំនិងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាសមត្ថកិច្ចរបស់ក្រសួងស្រាវជ្រាវចងក្រងនិងផ្សព្វផ្សាយកម្រងលិខិតបទដ្ឋានយុត្តជាសមត្ថកិច្ចរបស់ក្រសួងនិងតម្លាភាពអនុវត្តនិងគ្រប់គ្រងគម្រោងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈនៅគ្រប់ដំណាក់កាលដើម្បីធានាអោយបាននូវគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងនិងរាជរដ្ឋាភិបាលចូលរួមរៀបចំនិងអនុវត្តផែនការស្តីពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារគម្រោងអភិវឌ្ឍន៍ចូលរួមរៀបចំនិងអនុវត្តគម្រោងថវិកាសម្រាប់អនុវត្តផែនការស្តីពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារគម្រោងអភិវឌ្ឍន៍។[៤១]

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ**

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈមានតួនាទីនិងភារកិច្ចដូចតទៅរៀបចំ និងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលខ្លីរយៈពេលមធ្យមរយៈពេលវែងសិក្សានិងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូលវិស័យធំៗសូចនាករម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំខាន់ៗដើម្បីដាក់ចេញជាគោលនយោបាយយុទ្ធសាស្ត្រនិងអនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមដាននិងវិភាគការអនុវត្តនិងការប្រព្រឹត្តទៅនៃហិរញ្ញវត្ថុ

[៤០] អនុក្រឹតលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧ ស្តីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា៤

[៤១] អនុក្រឹតលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧ ស្តីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា១១

សាធារណៈនិងកម្មវិធីចំណូលនិងចំណាយសាធារណៈហើយផ្អែកលើមូលដ្ឋាននេះលើកជាយោបល់និងស្នើវិធានការជូនថ្នាក់ដឹកនាំក្រសួងអំពីការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអោយមានប្រសិទ្ធភាពតម្លាភាពគុណភាពនិងគណនេយ្យភាពរៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យមនិងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំរៀបចំនិងវិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈនិងស្ថិតហិរញ្ញវត្ថុរាជរដ្ឋាភិបាលផ្សព្វផ្សាយសកម្មភាពសេដ្ឋកិច្ចនិងទិន្នន័យនានាដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុសម្របសម្រួលនិងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រជាតិនានាជាមួយស្ថាប័នជាតិផ្សេងៗទៀតចូលរួមរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុចូលរួមរៀបចំគោលនយោបាយពាណិជ្ជកម្មនិងហិរញ្ញវត្ថុក្រៅប្រទេសនិងយុទ្ធសាស្ត្រសម្រាប់ចូលរួមការចរចារលើការបង្កើតតំបន់ពាណិជ្ជកម្មសេរីនិងយន្តការសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងទាំងនោះសម្របសម្រួលនិងតាមដានការងារពាក់ព័ន្ធកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុក្នុងតំបន់និងពិភពលោកធ្វើជាលេខាធិការដ្ឋានដើម្បីសម្របសម្រួលកម្រិតអគ្គនាយកដ្ឋាននិងនាយកដ្ឋានក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំពោះការអនុវត្តកាតព្វកិច្ចនានាពាក់ព័ន្ធជាមួយនឹងតំបន់ពាណិជ្ជកម្មសេរីការសម្រួលពាណិជ្ជកម្មនិងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុពិនិត្យនិងផ្ដល់អនុសាសន៍អំពីការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន។[៤២]

**អគ្គនាយកដ្ឋានថវិកា**

អគ្គនាយកដ្ឋានថវិកបំពេញមុខងារជាសេនាធិការអោយក្រសួងកិច្ចនិងហិរញ្ញវត្ថុលើបេសកម្មគ្រប់គ្រងថវិកាជាតិហិរញ្ញប្បទានសហប្រតិបត្តិការនិងបំណុលរដ្ឋក្នុងគោលដៅធានាអោយមានាករបែងចែកនិងប្រើប្រាស់ធនធានថវិការដ្ឋប្រកបដោយប្រសិទ្ធភាព ភាពស័ក្ដិសិទ្ធិ និងចីរភាព។[៤៣]អគ្គនាយកដ្ឋានថវិកាមានភារកិច្ចដូចជាតទៅកសាងសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងបទបញ្ញាហិរញ្ញវត្ថុសាធារណៈរៀបចំការអនុវត្តច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈច្បាប់ហិរញ្ញវត្ថុ បទបញ្ញាហិរញ្ញវត្ថុសាធារណៈនិងច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងការងារកសាងសេចក្ដីព្រាងច្បាប់ទូទាត់ថវិការៀបចំកម្មវិធីចំណាយសាធារណៈទៀតទាត់ដោយផ្អែកលើកម្មវិធីចំណូលសាធារណៈដែលត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុវត្តការផ្ដល់ហិរញ្ញប្បទានសម្រាប់ដំណើរការជាប្រចាំឆ្នាំច្បាប់កែតម្រូវ លិខតិបទដ្ឋានពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំដែលបានទទួលការអនុម័តរួម ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិចូលរួមសហការជាមួយក្រសួងស្ថាប័នក្នុងការត្រួតពិនិត្យនិង

---

[៤២] អនុក្រឹតលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧ ស្ដីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា១៥

[៤៣] អនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃតី១៦ ខែតុលាឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា១៨

តាមដានលើការអនុវត្តនីតិវិធីចំណាយរបស់រដ្ឋបាលថ្នាក់ជាតិរួមទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការរៀបចំអាទិភាពវិនិយោគប្រចាំឆ្នាំសម្រាប់គោលបំណងថវិកានីយកម្មលើគម្រោងវិនិយោគសាធារណៈដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធរៀបចំនិងចរចារលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណងការទទួលហិរញ្ញប្បទានឥតសំណង ការអោយប្រាក់គេខ្ចី ការខ្ចីប្រាក់ពីគេព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀតគ្រប់គ្រងនិងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការគ្រប់គ្រងបំណុលរបស់រដ្ឋចូលរួមក្នុងការរៀបចំនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឯកជនចូលរួមរៀបចំតាមដាននិងត្រួតពិនិត្យលើការអនុវត្តគម្រោងឬកិច្ចព្រមព្រៀងឬកិច្ចសន្យាពាក់ព័ន្ធនឹងការវិនិយោគឯកជនដែលមានការពាក់ព័ន្ធនឹងចមណាយថវិកាឯកាតព្វកិច្ចបំណុលរដ្ឋសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិជាមួយអង្គភាពពាក់ព័ន្ធនៃអង្គការហិរញ្ញវត្ថុអន្តរជាតិនិងដៃគូអភិវឌ្ឍនានា។[៤៤]

### អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

អគ្គនាយដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចដូចជាគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានីភ្នំពេញខេត្តហើយអគ្គនាយរដ្ឋាននេះបែងចែកជា៤នាយកដ្ឋានសំរាប់ការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុទៅតាមខេត្តនីមួយៗដោយក្នុងនេះមានមានតែនាយកដ្ឋានមួយទេដែលទទួលខុសត្រូវលើការងារគ្រង់គ្រងរដ្ឋបាលនិងបច្ចេកទេសចំនែក៣ទៀតគ្រប់គ្រងហិរញ្ញវត្ថុតាមខេត្ត។

### អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈទទួលបន្ទុកការងារ រៀបចំបង្កើត អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធត្រួតពិនិត្យនិងតាមដានលើរាល់កិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តដោយស្ថាប័នអនុវត្តលទ្ធកម្មពិនិត្យនិងលើកយោបល់លើតារាផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្មពិនិត្យនិងផ្តល់ទិដ្ឋានការលើឯកសារដេញថ្លៃពិនិត្យនិងលើកយោបល់លើសំណើរសុំគោលការណ៍អនុវត្តវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មពិនិត្យនិងលើកយោបល់លើសំណើរសុំប្រគលកិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្មគ្រប់គ្រងនិងតាមដានការអនុវត្តកិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្មគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃចូលរួមដោះស្រាយវិវាទលទ្ធកម្ម បណ្តុះបណ្តាលអំពីការអនុវត្តវិធាននិងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដ៏ទៃទៀតដល់មន្ត្រីលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មន្ត្រីពាក់ព័ន្ធដ៏ទៃទៀត អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់និងអ្នកទទួលការ។[៤៥]

### អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

---

[៤៤] នៃអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលាឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា១៩

[៤៥] អនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលាឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា២៦

នៅក្នុងអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជាបែងចែករដ្ឋបាលទៅ២គឺរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយនៅរដ្ឋបាលថ្នាក់ជាតិមាននាយកដ្ឋានជាសេនាធិការហើយរដ្ឋបាលថ្នាក់ក្រោមជាតិវិញមានសាខាគយនិងរដ្ឋាកររាជធានីខេត្តការិយាល័យគយនិងរដ្ឋាករត្រួតពិនិត្យបែបបទគយនិងបណ្ដាលការិយាល័យគយនិងរដ្ឋាករដ៏ទៃទៀតជាសេនាធិការ។អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានភារៈកិច្ចលើការងារសវនកម្មគយបង្ការនិងបង្រាបបទល្មើសគយការងារគយនិងរដ្ឋាករគ្រប់គ្រងតំបន់រួចពន្ធការងារសហប្រតិបត្តិការគយអន្តរជាតិ។ នៅក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក៏មានសាលាជាតិគយ ដែលបំពេញមុខងារជាសេនាធិការរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែលទទួលបន្ទុកទទួលខុសត្រូវបណ្ដុះបណ្ដាលមុខជំនាញទាក់ទងនឹងគយនិងរដ្ឋាករ។

**អគ្គនាយដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារជាអគ្គនាយដ្ឋានមួយដ៏សំខាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយក៏សំរាប់ជាតិផងដែលព្រោះថវិការដ្ឋភាគច្រើនទទួលបានពីពន្ធដែលត្រូវគ្រប់គ្រង់ដោយស្ថាប័ននេះ។អគ្គនាយកដ្ឋានពន្ធដារមានភារៈកិច្ចទទួលខុសត្រូវលើ ការងារនីតិកម្មគោលនយោបាយសារពើពន្ធសហប្រតិបត្តិការពន្ធដារអន្តរជាតិ គ្រប់គ្រងពន្ធចលនទ្រព្យនិងអចលទ្រព្យ ស៊ើបអង្កេទបទល្មើសពន្ធដារគ្រប់គ្រងអ្នកជាប់ពន្ធធំគ្រប់គ្រងសាខាពន្ធដារខេត្តខណ្ឌសវនកម្មសហគ្រាស។ នៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារក៏មានសាលាជាតិពន្ធដារផងដែរ ដោយសាលាជាតិពន្ធដារនេះទទួលបន្ទុកការងារបណ្ដុះបណ្ដាលមុខជំនាញទាក់ទងនឹងពន្ធដារ។ អគ្គនាយដ្ឋានពន្ធដារបែងចែកជាពីររដ្ឋបាលគឺរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់មូលដ្ឋានដោយរដ្ឋបាលថ្នាក់ជាតិមាននាយកដ្ឋានជាសេនាធិការ រីឯករដ្ឋបាលថ្នាក់ក្រោមជាតិមានសាខាពន្ធដារខេត្តសាខាពន្ធដារខណ្ឌការិយាល័យពន្ធដារស្រុកនិងការិយាល័យពន្ធដារក្រុង។

**អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធមានភារកិច្ចដូចជា រៀបចំសេចក្ដីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធគ្រប់គ្រង និងជំរុញការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ នៅទូទាំងប្រទេស ស្រាវជ្រាវនិងគ្រប់គ្រងទ្រព្យឥតម្ចាស់និងមរតឥតបណ្ដឹង គ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋនិងដើមទុនរបស់រដ្ឋ គ្រប់គ្រងសហគ្រាសសាធារណៈ អង្គភាពសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត ប្រមូលផ្ដុំព័ត៌មានពាក់ព័ន្ធការងារឯកនភាវូបនីយកម្ម ការជម្រះបញ្ជីសហគ្រាសសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត គ្រប់គ្រងនិងរៀបចំបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ សម្បទានរ៉ែ និងសម្បទានដទៃទៀតដែលបានផ្ដល់អោយវិស័យឯកជនរៀបចំនីតិវិធីវាយតម្លៃការដាក់ជួល លក់ ដូរ និងផ្ទេរសិទ្ធិទ្រព្យសម្បត្តិ

រដ្ឋ គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំផែនការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ មានលក្ខណៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លើការងារប្រមូលចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ រក្សាការពារទិន្នន័យនៃការគ្រប់គ្រងការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ និងបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ស្រាវជ្រាវរកប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ចូលរួមរៀបចមសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ។

**អគ្គនាយកដ្ឋានរតនាគារជាតិ**

អគ្គនាយដ្ឋានរតនាគារជាតិ ក៏ជាស្ថាប័នក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានបែងចែករដ្ឋបាលជាពីរ គឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរដ្ឋបាលថ្នាក់ជាតិមាននាយកដ្ឋានជាសេនាធិការរីឯរដ្ឋបាលថ្នាក់ក្រោមជាតិមានរតនាគាររាជធានី ខេត្តជាសេនាធិការ។អគ្គនាយកដ្ឋានរតនាគាជាតិមានភារកិច្ចទៅលើ ការងារចំណូលថវិកា និងការងាចំណាយថវិកា ការងារគណនេយ្យគ្រប់គ្រងរតនាគារថ្នាក់ក្រោមជាតិនិងសរុបស្ថិតិ ការងារបច្ចេកវិទ្យាព័ត៌មាន អធិការកិច្ចរតនាគារ គ្រប់គ្រងសាច់ប្រាក់និងវិភាគការអនុវត្តថវិកា។

**អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ គឺជាអង្គភាពមួយក្នុងក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានភារកិច្ចទទួលបន្ទុកការរៀបចំសម្របសម្រួលនិងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គ្រប់គ្រងនិងត្រួតពិនិត្យទីផ្សារធានារ៉ាប់រងនិងសោធនគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញប្បទានរបស់រដ្ឋ ដែលគាំទ្រការអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ សម្របសម្រួលលើការអនុវត្តគោលនយោបាយឥណទានអភិវឌ្ឍជនបទ គ្រប់គ្រងនិងត្រួតពិនិត្យសេវាកម្មវាយតម្លៃ សេវាកម្មទិញលក់ជួលអចលនវត្ថុនិងបុគ្គលអភិវឌ្ឍលំនៅឋានគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំទិញ-លក់ទ្រព្យបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានគ្រប់គ្រងត្រួតពិនិត្យនិងប្រមូលចំណូលពីអាជីវកម្មកាស៊ីណូនិងអាជីវកម្មភ្នាល់គ្រប់ប្រភេទដែលមានការអនុញ្ញាតពីរដ្ឋាភិបាលចូលរួមជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។[៤៦]នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុមាននាយកដ្ឋានបួន មានដូចជា នាយកដ្ឋានធានារ៉ាបរងនិងសោធន នាយកដ្ឋានទីផ្សារនិងហិរញ្ញវត្ថុ នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនាយដ្ឋានគ្រប់គ្រងអាជីវកម្មអចលវត្ថុបញ្ចាំនិងប្រាក់ប្រាតិភោគដោយអនុប្បទាន។

[៤៦] អនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលាឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា៤៩

**អគ្គាធិការដ្ឋាន**

អគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជាបែងចែកជា៤នាយកដ្ឋានមានដូចជានាយកដ្ឋានរដ្ឋបាលផែនការនិងស្រាវជ្រាវបណ្ដឹង នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី១ទី២និងទី៣។ដោយនាយកដ្ឋានរដ្ឋបាលផែនការនិងសិក្សាស្រាវជ្រាវបណ្ដឹ ទទួលបន្ទុកការងាររដ្ឋបាលផែនការនិងសិក្សាស្រាវជ្រាវបណ្ដឹង។រីឯនាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី១ ទី២និងទី៣ទទួលបន្ទុកការងារអធិការកិច្ចហិរញ្ញវត្ថុនៅតាមក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិទី១ ទី២និងទី៣។

**អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើបេសកកម្មពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងនាំមុខក្នុងការអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាលក្រសួង ស្ថាប័ននិងសហគ្រាសសាធារណៈ។[៤៧]

**មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្តជាអង្គភាពនៅក្រោមកការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប៉ុន្តែមានទីតាំងនៅតាមបណ្ដាលខេត្ត ក្រុងដោយបំពេញមុខងារជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការសម្របសម្រួលនិងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអភិបាលហិរញ្ញវត្ថុនៅរាជធានីខេត្តដោយធ្វើការសម្របសម្រួលរវាងរដ្ឋបាលថ្នាក់ជាតិផ្សេងទៀតនៅថ្នាក់មូលដ្ឋាននិងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គភាពថ្នាក់មូលដ្ឋាននិងអង្គភាពថ្នាក់កណ្ដាលទាំងឡាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[៤៨]អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ដឹកនាំអោយអគ្គលេខាធីការមួយរូបមានឋានៈស្មើអគ្គនាយកនិងអមដោយអគ្គលេខាធិការរងមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការ។អគ្គាធិកាដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយកនិងអមដោយអគ្គាធិការរងមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការ។ អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករដមួយចំនួនជាជំនួនការ។នាយកដ្ឋានដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។រីឯអង្គភាពថ្នាកក្រោមជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញដឹកនាំដោយ

[៤៧] ប្រកាសលេខ១៥៤៧ សហវ.ប្រកចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៣ស្ដីពីការការរៀបចំនិងការប្រព្រឹត្តិទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឪវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រការ៤

[៤៨] អនុក្រឹតលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧ ស្ដីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាត្រា៧០

ប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃនៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ខែតុលាឆ្នាំ២០១៣។ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុមាននាយកដ្ឋានថវិកាដែលជាអង្គការកណ្តាលមួយមានភារកិច្ចធ្វើការសិក្សានិងរៀបចំថវិការដ្ឋទាំងមូល ។

## ២.២ ដំណើរការថវិកា

### ២.២.១ ដំណើរការថវិកាថ្នាក់ជាតិ

ភ្ជាប់អត្ថន័យថវិកាជាតិពីខាងលើមក យើងអាចទាញជាខ្លឹបានថា ថវិកាជាតិជាពាក្យដែលគេសំដៅដល់ចំណូលនិងចំណាយដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋនិងដើម្បីផ្គត់ផ្គង់ស្ថាប័នរដ្ឋវិញ។ចំណូលជាតិឬធនធានអចិន្ត្រៃយ៍របស់របស់ជាតិគឺជាថវិការទាំងអស់ជាតិដែលរដ្ឋប្រមូលបានក្នុងរយៈពេលមួយឆ្នាំ។ថវិកាជាតិដែលរដ្ឋប្រមូលបានមានប្រភពមកពី ពន្ធដា ពន្ធអាករ ការធ្វើអាជីវកម្មរបស់រដ្ឋ និងចំណូលដែលបានមកពីទ្រព្យរបស់រដ្ឋផ្សេងៗ(ដូចជាចលនទ្រព្យ និងអចលនទ្រព្យ ឧទាហរណ៍ការជួលដីអោយនីតិបុគ្គលឯកជនសំរាប់ការធ្វើសម្បទាន)នៅមានប្រភពចំណូលជាច្រើនទៀតដែលរដ្ឋប្រមូលជាប្រចាំក្នុងរយៈពេលមួយឆ្នាំ ប៉ុន្តែនៅក្នុងចំណូលទាំងនេះត្រូវចែកជាក្រុម និងប្រភេទ។រដ្ឋបាលថ្នាក់ជាតិមាន ចំណូលចរន្ត និងចំណូលមូលធន។

ចំណូលចរន្តជាចំណូលរបស់រដ្ឋជាប្រក្រតី រឺជាប្រចាំដែលខិតខំកៀងគរក្នុងឆ្នាំថវិកានីមួយៗរបស់រដ្ឋដោយរដ្ឋប្រមូលតាមប្រភពចំណូលដែលមានក្នុងក្របខ័ណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំដែលច្បាប់នេះនឹងធ្វើឡើងជារៀងរាល់ឆ្នាំ។ចំពោះក្រុមទី១នៃចំណូលគឺជាចំណូលពិតដែលជាប្រភេទចំណូលដែលទទួលបានពីការប្រមូល ពន្ធដារ និងពន្ធគយផ្សេងៗដែលមាននៅក្នុងប្រទេសឬអាហៅម្យ៉ាងទៀតបានថាជាចំណូលសារពើពន្ធ។ នៅក្នុងចំណូលពិតនៅមានចំណូលដែលទទួលបានពីមកក្រៅពីពន្ធនិងអាករនៅក្នុងប្រទេសនេះគឺចំណូលមិនមែនសារពើពន្ធ។ចំណូលសារពើពន្ធជាចំណូលដែលទទួលបានពីពន្ធដារនិងពន្ធគយ។ចំពោះការប្រមូលនិងកំណត់ត្រូវកំណត់ក្នុងច្បាប់គ្មានស្ថាប័នឬអង្គភាពណាមួយអាចប្រមូល ឬកំណត់បានទេ។ចំណូលពីការប្រមូលពន្ធដារ មានពន្ធ និងអាករ ជាទឹកប្រាក់ដែលរដ្ឋបានបង្ខំអោយរូបវន្តបុគ្គល និងនីតិបុគ្គលបង់ជូនជាតិជាស្ថាពរគ្មានទទួលថ្នូលអ្វីទាំងអស់ដើម្បីយកទឹកប្រាក់ទាំងនោះទៅផ្គត់ផ្គង់ការបំរើសេវាសាធារណៈនិងស្ថាប័នក្រោមការគ្រប់គ្រងរបស់រដ្ឋទាំងអស់ពន្ធដែលរដ្ឋប្រមូលមានដូចជាពន្ធលើប្រាក់ចំណេញ ពន្ធលើឈ្នួលផ្ទះ និងពន្ធលើមធ្យោបាយយានជំនិះគ្រប់ប្រភេទ ពន្ធលើប្រាក់បៀវត្ស ពន្ធប្រថាប់ត្រា ពន្ធប៉ាតង់ ពន្ធតែមប្រ៍...ល។ចំណូលពីអាករគឺជាប្រាក់ដែលអ្នកប្រើប្រាស់បង់លើសេវាណាមួយដូចជាអាករលើសំរាប់ជាដើម។ពន្ធគយជាថវិកាដែលប្រមូលបានពីពន្ធនាំចូលឬនាំចេញនិងអាករទៅលើទំនិញទាំងឡាយដែលចូលមកក្នុងឬចេញទៅក្រៅដោយឆ្លងកាត់ដែនគយ។ទំនិញនាំចេញឬនាំចូលទាំងអស់គឺជាកម្មវត្ថុនៃការអនុវត្តតាមបញ្ញត្តិនៃ

ច្បាប់ស្តីពីគយ។[៤៩]ពន្ធគយអនុគ្រោះដែលចេញមកពីកាតព្វកិច្ចក្រោមការសន្យាកិច្ចព្រមព្រៀង សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិទាំងនេះត្រូវកំណត់ដោយអនុក្រឹត្យ[៥០]។ទំនិញនាំចូលគឺជាប្រភេទទំនិញទាំងឡាយណាដែលយកពីក្រៅប្រទេសចូលមកក្នុងប្រទេសកម្ពុជាហើយឆ្លងកាត់ដែនគយ។ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍ទៅការិយាល័យឬទីកន្លែងផ្សេងទៀតទៅតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ[៥១]។ ចំណែកឯទំនិញនាំចេញ គឺជាទំនិញទាំងឡាយណាដែលយកពីក្នុងប្រទេសកម្ពុជាទៅកាន់ប្រទេសក្រៅហើយឆ្លងកាត់ដែនគយ។ទំនិញនាំចេញក៏ដូចទៅនឹងទំនិញនាំចូលដែរត្រូវរាយការណ៍ទៅការិយាល័យគយឬទីកន្លែងណាមួយតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ[៥២]។រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាអ្នកចេញប្រកាសកំណត់ពេលវេលា របៀបរបបតម្រូវការ ឯកសារ កាលៈទេសៈនិងការលើលែងមួយចំនួនពាក់ព័ន្ធនឹងការរាយការណ៍ ចរាចរ សន្និធិនិងការដឹកជញ្ជូនទំនិញទាំងឡាយដែលត្រូវនាំចេញ។រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាដែលរដ្ឋបាលគយអាចអនុញ្ញាតអោយធ្វើការនាំចេញបណ្តោះអាសន្ននូវទំនិញនៅក្រៅដែនគយដើម្បីជួសជុល បំប្លែង ឬទទួលពលកម្មបន្ថែមព្រមទាំងបែបបទដែលទំនិញទាំងនោះត្រូវជាប់ពន្ធ និងអាករពេលនាំចូលត្រឡប់មកវិញ។នៅក្នុងចំណូលពិតមិនមែនមានតែចំណូលសារពើពន្ធតែមួយប្រភេទនេះទេនៅមានចំណូលប្រភេទទី២មួយទៀតគឺចំណូលមិនមែនសារពើពន្ធ។ចំណូលមិនមែនសារពើពន្ធគឺជាចំណូលដែលរដ្ឋប្រមូលបានមកពីការចាត់តែងទ្រព្យសម្បត្តិរដ្ឋ ការធ្វើអាជីវកម្មនិងការលក់ទ្រព្យសម្បត្តិរដ្ឋផលបានមកពីសម្បទានកម្រៃបានមកពីសេវាសាធារណៈផលពីការពិន័យ និងការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយផលហិរញ្ញវត្ថុផលផ្សេងៗដែលរដ្ឋមាននិងផលពិសេស។[៥៣] ចំណូលមិនមែសារពើពន្ធ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។ ចំណូលមិនមែនសារពើពន្ធ ត្រូវបានបែងចែកជា ៥ប្រភេទគឺ ចំណូលពីទ្រព្យសម្បត្តិរដ្ឋចំណូលពីសហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម ចំណូលមិនមែនសារពោះពន្ធផ្សេងទៀត។ចំណូលពីទ្រព្យសម្បត្តិរដ្ឋសំដៅដល់ចំណូលដែលទទួលបានពីការចាត់ចែងការធ្វើអាជីវកម្មនិងផលបានពីស្បទានលើទ្រព្យសម្បត្តិរដ្ឋរួមមាន ចំណូលពីការលក់និងជួលទ្រព្យសម្បត្តិរដ្ឋការផ្តល់សិទ្ធិសម្បទានានា(ឧទារហ៍ ផ្សារ កំពង់ផរ ចំណតរថយន្ត...)កម្រៃសួយសារនៃធនធានធម្មជាតិចំណែករបស់រដ្ឋតាមរយៈការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិជាមួយបុគ្គលឯកជនការផ្តល់សម្បទាន

[៤៩] ច្បាប់ស្តីពីគយ ឆ្នាំ២០០៧ មាត្រា៥

[៥០] ច្បាប់ស្តីពីគយ ឆ្នាំ២០០៧ មាត្រា៦

[៥១] ច្បាប់ស្តីពីគយ ឆ្នាំ២០០៧ មាត្រា១០

[៥២] ច្បាប់ស្តីពីគយ ឆ្នាំ២០០៧ មាត្រា១៦

[៥៣] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា១០

ធនធានធម្មជាតិនិងហេដ្ឋារចនាសម្ព័ន្ធនិងនៅមានចំណូលផ្សេងទៀតដែលមានចែងក្នុងកិចសន្យាកិច្ចព្រមព្រៀងសៀវភៅបន្ទុកឬលិខិតគតិយុត្តផ្សេងទៀត។ចំណូលពីសហគ្រាសសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតសំដៅដល់ចំណូលពីការបង់ភាគលាភ និងអតិរេកថវិកា(អតិរេកថវិកាគឺជាចំនួនទឹកប្រាក់ដែលត្រូវបង់ចូលថវិការដ្ឋតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលបន្ទាប់ពីមានការទទួលស្គាល់ពីអាណាព្យាបាលបច្ចេកទេសនិងអាណាព្យាបាលហិរញ្ញរបស់សហគ្រាសសាធារណៈ អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត[៥៤]។រីឯក្រុមទី២វិញមានតែចំណូលមួយប្រភេទទេគឺចំណូលតាមដីកា។ចំណូលតាមដីកាមិនមែនជាចំណូលជាសាច់ប្រាក់ទេពោលគឺជាចំណូលដែលចេញពីគណនីមួយទៅគណនីមួយទៀតតាមដីការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[៥៥]។ចំណូលមូលធន គឺជាប្រភេទថវិកាដែលរដ្ឋទទួលបានពីគណនីទាំងឡាយណាដែលទាក់ទងនឹងអចលកម្មហិរញ្ញវត្ថុហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ការខ្ចី និងចំណូលមូលធនផ្សេងទៀត។ចំណូលមូលធនត្រូវបែងចែកជាពីរទៀតមានចំណូលពិត និងចំណូលតាមដីកា។ចំណូលពិតជាសាច់ប្រាក់ជាក់ស្តែងហើយត្រូវបែងចែកជាពីរទៀត គឺចំណូលពីប្រភពផ្ទាល់និងចំណូលពីប្រភពខាងក្រៅ។ចំណូលពីប្រភពផ្ទាល់គឺជាថវិកាដែលទទួលបានពីប្រភពក្នុងស្រុកហើយចំណូលនេះទទួលបានមកពីប្រភពធំពីរគឺការវិនិយោគនិងអចលនកម្មហិរញ្ញវត្ថុផ្សេងៗ។ថវិកាដែលទទួលបានពីការវិនិយោគក្នុងចំណូលពីប្រភពផ្ទាល់នេះ មានដូចជាថវិកាបានមកពីការវិនិយោគក្នុងញាតិសម្ព័ន្ធថវិកាបានមកពីការវិនិយោគទុនរួមគ្នាថវិកាបានមកពីការវិនិយោគក្នុងសហគ្រាសសាធារណៈ។រីឯចំណូលដែលបានមកពីអចលនកម្មហិរញ្ញវត្ថុគឺជាប្រភេទនៃថវិកាចំណូលដែលបានមកវិញពីការអោយខ្ចីរបស់រដ្ឋ(ឧទាហរណ៍ការអោយខ្ចីរបស់រដ្ឋជាអ្វីក៏បាន អាចជាលុយ មូលប័ត្រឬវត្ថុផ្សេងៗនៅឆ្នាំ២០១៨រួចហើយក៏សង់មករដ្ឋវិញនៅឆ្នាំ២០២០ដូចនេះការសងជាចំណូលរបស់រដ្ឋ)ដែលយើងអាចហៅចំណូលប្រភេទនេះបានថា ចំណូលអចលនកម្មហិរញ្ញវត្ថុ។នៅក្នុងចំណូលអចលនកម្មហិរញ្ញវត្ថុមានបែងចែកជាចំណូលជាច្រើនទៀតមានជាអាទិ៍ថវិកាបានពីការអោយខ្ចី(ការសងវិញនូវមូលធន)ថវិកាទទួលបានពីការអោយខ្ចីទៅសហគ្រាសសាធារណៈថវិកាទទួលបានពីការអោយខ្ចីទៅសហគ្រាសឯកជនថវិកាទទួលបានពីការអង្គការមិនមែនរដ្ឋាភិបាល និងការអោយខ្ចីផ្សេងៗ។ចូលមកដល់ប្រភេទទី២ដែលស្ថិតនៅក្នុងក្រុមចំណូលពិតគឺចំណូលពីប្រភពខាងក្រៅ។ចំណូលពីប្រភពខាងក្រៅនេះសំដៅដល់ចំណូលដែលរដ្ឋទទួលបានពីប្រភពខាងក្រៅដែលមិនមែនជារដ្ឋខ្លួនឯងអាចជាការខ្ចីពីរដ្ឋជាគូអង្គការពិភពលោកឬក្រុមហ៊ុនឯកជនក្នុងនិងក្រៅស្រុកដូច

[៥៤] អនុក្រឹត្យលេខ៧២_អនក្រ_បកចុះថ្ងៃទី៧ ខែមិថុនាឆ្នាំ២០១៨ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

[៥៥] ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

នេះហើយបានជាជាក្នុងចំណូលពីប្រភពខាងក្រៅបែងចែកជាពីរថែមទៀតមានចំណូលពីការខ្ចីប្រាក់ក្នុងប្រទេស និងចំណូលពីការខ្ចីប្រាក់ក្រៅប្រទេស។

គ្រប់ថវិកាដែលរដ្ឋប្រមូលបានពីគ្រប់ប្រភពនៃចំណូលរដ្ឋត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនីនិងអាចលម្អិតជាងនេះទៅទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៥៦]។គ្មានបទប្បញ្ញត្តិណាមួយទោះជាប្រភេទណាក៏ដោយគ្មានអនុសញ្ញាអន្តរជាតិណាមួយដែលអាចធ្វើអោយមានការប្រែប្រួលនាំមកនូវការបាត់ចំណូលនោះឡើយ។ករណីខាងលើអាចប្រព្រឹត្តទៅបានលុះត្រាតែអនុវត្តតាមទម្រង់ច្បាប់ និងបទបញ្ញាដូចគ្នា ក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៥៧]។ចំណូលត្រូវកត់ត្រាចូលទាំងស្រុងហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ។ការបង្កើតដោយអាណាប័កនូវទឹកប្រាក់នៃ ឥណទានដែលបានអនុម័តដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយត្រូវបានហាមឃាត់ដាច់ខាត[៥៨]។ចំណូលទាំងមូលត្រូវវិភាជន៍សម្រាប់មុខសញ្ញាចំណាយទាំងអស់។ប៉ុន្តែចំណូលខ្លះអាចត្រូវវិភាជន៍សម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់និងក្រោមលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលើការលក់ ការជួល ការផ្ទេរនិងការចាត់ចែងដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋការផ្តល់ទ្រព្យសម្បត្តិរដ្ឋនិងផ្តល់សម្បទានផ្សេងៗរបស់រដ្ឋដែលមានការពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈត្រូវស្ថិតក្រោមការត្រួតពិនិត្យនិងការឯកភាពរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៥៩]។ក្រោមបទប្បញ្ញត្តិនៃមាត្រា១៩នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចំណូលទាំងអស់ដែលបានពីការចាត់ចែងនិងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋត្រូវបង់ចូលគណីទោលរតនាគារជាតិនៃថវិការដ្ឋដោយមិនអាចដកចំណូលនេះទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ[៦០]។

ចំណែកបន្ទុកអចិន្ត្រៃយ៍របស់រដ្ឋបាលថ្នាក់ជាតិគឺជា ការយកថវិកាដែលរដ្ឋប្រមូលបាននៅក្នុងឆ្នាំថវិកាពីប្រភពចំណូលដែលរដ្ឋមានទាំងអស់ទៅចំណាយដើម្បីដំណើរការស្ថាប័នរដ្ឋទាំងមូលក្នុងប្រទេស។ចំណូលដែលប្រមូលបានក្នុងរយៈពេលមួយឆ្នាំត្រូវយកទៅចំណាយនៅឆ្នាំក្រោយមួយទៀតដែលត្រូវចាត់ចែងជាកញ្ចប់។ការចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ជាតិត្រូវធ្វើឡើងជាកញ្ចប់ដោយទទួលបានការអនុញ្ញាត អនុម័ត ពិនិត្យនិងជាចុងក្រោយត្រូវចង់ក្រង់ជាច្បាប់(ឧទារហ៍ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ជាច្បាប់ដែលនិយាយពីចំណូលចំណាយសម្រាប់ឆ្នាំ២០២១)។ការចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ជាតិគឺ ដើម្បីបំរើ

[៥៦] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា១៣
[៥៧] ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា១៦
[៥៨] យោងតាមគោរការណ៍គន្លឹះទាំង១១យ៉ាងដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា៥
[៥៩] អនុក្រឹត្យលេខ ៤៨៨ អនក្រ.បកចុះថ្ងៃទី១៦ ខែតុលាឆ្នាំ២០១៣ស្តីពីការរៀបចំនឹងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច មាត្រា៤
[៦០] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា១៦

ប្រយោជន៍សាធារណៈចំពោះពាក្យថាប្រយោជន៍សាធារណៈនៅត្រង់នេះគឺសំដៅដល់ការអនុវត្តគម្រោងឬកម្មវិធីនយោបាយផ្សេងៗ(ឧទាហរហ៍គម្រោងសាងសងផ្លូវជាតិមួយខ្សែនឹងត្រូវចំណាយថវិកា១០០លានរៀលដូចនេះស្ថាប័នដែលទទួលបន្ទុកសាងសងផ្លូវជាតិមួយខ្សែនេះនឹងលើកសំណើរនេះទៅដល់រដ្ឋបាលថ្នាក់ជាតិហើយសុំការអនុម័តជាកញ្ចប់ថវិកាចំនួន១០០លានរៀលដើម្បីសាងសងក្នុងគោលបំណងធ្វើអោយប្រជាជនអាចធ្វើដំណើរដោយងាស្រួយឬក្នុងគោលបំណងសំរាប់ការដឹកទំនិញនាំចេញ នាំចូលជាដើម)។មិនខុសពីចំណូលរបស់រដ្ឋបាលថ្នាក់ជាតិនេះទេចំណាយរបស់រដ្ឋបាលថ្នាក់ជាតិក៏ត្រូវមានការកំណត់ជាក្រុម និងប្រភេទដែរ។ ប្រភេទចំណាយនីមួយៗត្រូវបានធ្វើចំណាក់ថ្នាក់ជាជំពូក គណនី  អនុគណីឬអាចលំអិតជាងនេះទៅតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៦១]។ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិត្រូវបែងចែកជាពីរ គឺចំណាយចរន្ត និងចំណាយមូលធន។

ចំណាយចរន្តជាកញ្ចប់ថវិកាដែលប្រើប្រាស់សំរាប់ដំណើរការក្រសួងស្ថាប័នជាប្រក្រតីដូចជាចំណាយលើប្រាក់បៀវត្សរបស់បុគ្គលិករាជការ ចំណាយលើសំភារៈផ្គត់ផ្គង់សេវាកម្មជាដើម។ចំណាយចរន្តត្រូវបានបែងចែកជា២ក្រុម និង៦ប្រភេទ។ក្រុមទី១នៃចំណាយចរន្តហៅថាចំណាយពិតដែលជាចំណាយជាសាច់ប្រាក់ជាក់ស្តែង រួមមាន ចំណាយមធ្យោបាយសេវា បន្ទុកហិរញ្ញវត្ថុ អន្តរាគមន៍សាធារណៈ ចំណាយផ្សេង និងការសងនិងការបង្វិលវិញ។ចំណាយប្រភេទី១នៃចំណាយពិត គឺចំណាយមធ្យោបាយសេវាដែលជាចំណាយដ៏សំខាន់សំរាប់ធ្វើអោយស្ថាប័ន និងសេវារបស់រដ្ឋដំណើរការជាប្រក្រតី។ចំណាយមធ្យោបាយសេវានេះមានការចំណាយធំៗចំនួន៣គឺ ចំណាយលើការទិញទំនិញ ចំណាយលើសេវាកម្ម ចំណាយលើបន្ទុករបស់បុគ្គលិក។ ចំណាយលើការទិញទំនិញ គឺជាការចំណាយសំរាប់ទិញសម្ភារសំរាប់ជាជំនួយឬការផ្គត់ផ្គង់ដំណើរការស្ថាប័នមានដូចជាម៉ាស៊ីនព្រីនកុំព្យូទ័រសម្ភារសុខាភិបាលគ្រឿងម៉ាស៊ីនផ្សេងៗចំពោះឧបករណ៍និងសម្ភារៈសំរាប់ការថែទាំងនិងផ្គត់ផ្គងផ្សេងៗក៏ត្រូវស្ថិតក្នុងចំណាយលើការទិញទំនិញដែរ។ចំណាយលើសេវាកម្មគឺជាចំណាយទាំងអស់ដែលរដ្ឋប្រើប្រាស់ឬទទួលបានការផ្គត់ផ្គង់សេវាពីប្រភពខាងក្រៅ។ចំពោះចំណាយលើសេវាកម្មដែលរដ្ឋប្រើប្រាស់គឺមានរយៈពេលខ្លីឬមួយចប់ការងារចំណែកឯចំណាយលើសេវាកម្មដែលរដ្ឋទទួលបានការផ្គល់ផ្គង់វិញវិញគឺជាចំនាយរយៈពេលវែង។ចំណាយលើសេវាកម្មរយៈពេលខ្លីរបស់រដ្ឋមានដូចជាការជួលម៉ាស៊ីនបោះពុម្ពសៀវភៅការជួយម៉ូតូរថយន្តការកាត់ឯកសណ្ឋានសំរាប់កងកំលាំងប្រដាប់អាវុធការជួលអ្នកជំនាញក្នុងគម្រោងមួយដែលមានរយៈពេលខ្លី ការជួលបន្ទុបស្នាក់នៅសំរាប់បុគ្គលិករដ្ឋចុះខេត្ត។ចំណាយលើសេវាកម្មរយៈពេលវែងមានដូចជាការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសធ្វើពិសោធន៍រយៈពេលវែងនិងការស្រាវជ្រាវរយៈពេលវែង។ចំណាយសំរាប់

[៦១] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា២២

បន្ទុកបុគ្គលិកជាកញ្ចប់ថវិកាទាំងឡាយណាដែលទុកសំរាប់តែមន្ត្រីក្របខ័ណ្ឌតែប៉ុណ្ណោះ។ ចំណាយសំរាប់បន្ទុកបុគ្គលិកនេះមានដូចជា ចំណាយលើលាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ ចំណាយលើប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ ចំណាយសំរាប់ប្រាក់បៀវត្សមូលដ្ឋាន ចំណាយលើប្រាក់បំណាច់មុខងារ ចំណាយលើការឈឺរបស់មន្ត្រី សម្រាលកូន មរណៈភាព...។ល។ ប្រភេទទី២នៃចំណាយពិតគឺ ចំណាយបន្ទុកហិរញ្ញវត្ថុគឺជាជំពូកកត់ត្រាចំណាយលើការប្រាក់នៃបំណុលការខ្ចីក្នុងប្រទេសនិងការប្រាក់នៃបំណុលក្រៅប្រទេស និងបន្ទុកហិរញ្ញវត្ថុផ្សេងទៀត និងការប្រាក់សម្រាប់ការបោះផ្សាយប័ណ្ណរតនាគារនិងសញ្ញាប័ណ្ណផ្សេងៗ។ចំណែកឯបន្ទុកដែលជាប់ពាក់ព័ន្ធនិងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងការអនុវត្តសេវាធនាគារ ត្រូវបានកត់ត្រានៅក្នុងគណនី សោហ៊ុយធនាគារ រីឯការសងវិញនូវប្រាក់ដើមនៃការខ្ចីត្រូវកត់ត្រានៅក្នុងចំណាយជាមូលធននៃការខ្ចី។[៦២] ប្រភេទី៣ដែលស្ថិតនៅក្នុងចំណាយពិត គឺចំណាយអន្តរាគមន៍សាធារណៈ។ចំណាយយអន្តរាគមន៍សាធារណៈគឺជាចំណាយសំរាប់អត្ថប្រយោជន៍សង្គម ឧបត្ថម្ភធន និងជំនួយសង្គម។អត្ថប្រយោជន៍សង្គម នៅចំនុចនេះចង់សំដៅដល់ សន្តិសុខសង្គម ជំនួយសង្គមដល់ប្រជាពលរដ្ឋ (មានដូចជាការផ្តល់អាហារ និងសម្ភារៈ ជួយជនរកគ្រោះធម្មជាតិ អាហរូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងនិងក្រៅប្រទេស) ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌(ឧបត្ថម្ភមណ្ឌលកុមារកំព្រា ឧបត្ថម្ភកាកបាទក្រហម សហគមន៍កីឡា និងវប្បធមន៍)ឧបត្ថម្ភដល់អង្គការមូលដ្ឋាននិងគាំទ្រកម្មវិធីផ្សេងៗចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច(ចំណាយទាក់ទងនឹងការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចដូចជាចំណាយឧបត្ថម្ភគាំទ្រដល់អាជីវកម្ម ដែលមានផលប្រយោជន៍ក្នុងមូលដ្ឋាន)។ប្រភេទទី៤នៃចំណាយពិត គឺចំណាយផ្សេងៗដែលជាចំណាយលើពន្ធនិងអាករ និងការសងនិងការបង្វិលវិញ។ក្រុមទី២នៃចំណាយចរន្ត គឺចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក។ ចំណាយតាមដីកាគឺជាចំណាយមិនឆ្លងកាត់សាច់ប្រាក់និងជាប្រតិបត្តិការនៃការបង្វែរ ឬផ្ទេរថវិកា។រីឯចំណាយមិនបានគ្រោងទុកវិញគឺជាចំណាយដែលបានអនុម័តសំរាប់រដ្ឋាភិបាលប្រើប្រាស់នៅពេលចាំបាច់ដូចជា គ្រោះធម្មជាតិជាដើម។ចំណែកចំណាយមូលធននៃថវិកា គឺកញ្ចប់ថវិកាសំរាប់ការទូទាត់ប្រាក់ខ្ចីឬបំណុលប្រហាក់ប្រហែលទាំងអស់របស់រដ្ឋ។នៅក្នុងចំណាយមូលធនបានបែងចែក២គឺចំណាយពិតនិងចំណាយតាមដីកា។ចំណាយពិតត្រូវបានបែងចែកជាពីរគឺចំណាយលើការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែលនិងចំណាយលើអចលកម្ម។ចំណាយលើប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែលនេះជាជំពូកនៃការកត់ត្រាការខ្ចីរបស់រដ្ឋនិងបំណុលហិរញ្ញវត្ថុប្រហាក់ប្រហែលនឹងការខ្ចីមានដូចជាការខ្ចីក្នុងប្រទេសការខ្ចីក្រៅប្រទេស។ការខ្ចីក្នុងប្រទេសគឺជាការខ្ចីទៅលើអង្គភាពណាមួយដែលមាននៅក្នុងប្រទេសដែលមិនមែនជារដ្ឋចំណែក

[៦២] ប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឲាយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា

ការខ្ចីក្រៅប្រទេសជាការខ្ចីទៅលើរដ្ឋ អង្គភាពឬស្ថាប័នក្រៅប្រទេសមានដូចជាការខ្ចីក្រៅប្រទេសពហុភាគីការខ្ចីក្រៅប្រទេសទ្វេភាគីអង្គការពិភពលោកជាដើម។ចំណាយលើអចលកម្មគឺជាចំណាយលើអចលកម្មអរូបី អចលកម្មរូបី ភាគកម្ម និងឥណទេយ្យពាក់ព័ន្ធទៅនឹងចលកម្មហិរញ្ញវត្ថុផ្សេងៗ។ចំណាលលើអចលកម្មអរូបីគឺជាចំណាយលើសោហ៊ុយលើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ប្រកាសនីយប័ត្រអាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល។ចំណាយលើអចលកម្មរូបីវិញគឺជាចំណាយលើការទិញដីធ្លី ដីរ៉ែធនធានធម្មជាតិផ្សេងៗការសាងសង់អាគារនិងហេដ្ឋារចនាសម្ព័ន្ធស្នាដៃសិល្បៈនិងការប្រមូល។ស្ថិតនៅក្នុងចំណាយមូលធនដដែលនៅមានចំណាយមួយទៀតគឺចំនាយតាមដីកា។ចំណាយតាមដីកាគឺជាចំណាយមិនឆ្លងកាត់សាច់ប្រាក់ គឺជាការបង្វែរ ឬការផ្ទេរនូវសមិទ្ធិផលដែលអនុវតដោយដៃគូអភិវឌ្ឍន៍។ប្រភេទចំណាយនីមួយៗត្រូវធ្វើចំណាត់ថ្នាក់ជា ជំពូក គណនី អនុគណនីនិងជាយថាហេតុអាចលម្អិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[៦៣]

ចំណាយចរន្តនៃប្រភេទ២ បន្ទុកហិរញ្ញវត្ថុនិងប្រភេទ៦ចំណាយមិនបានគ្រោងទុកមិនត្រូវបានបែងចែកអោយទៅក្រសួង ស្ថាប័នឬអង្គភាពសាធារណៈប្រហាក់ប្រហែលណាមួយឡើង។ចំណាយទាំងពីរប្រភេទនេះទុកសម្រាប់សងការប្រាក់នៃប្រាក់ខ្ចីនិងបន្ទុកហិរញ្ញវត្ថុផ្សេងៗព្រមទាំងឥណទានត្រៀមបម្រុងសម្រាប់ចំណាយផ្សេងៗលើមុខសញ្ញាដែលកើតឡើងជាយថាហេតុ។ថវិកាត្រៀមបម្រុងត្រូវបានអនុញ្ញាតសម្រាប់ការចំណាយទាំងឡាយណាដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់នៅពេលដែលឥណទាននោះត្រូវបានអនុម័ត។ការបែងចែកថវិកាត្រៀមបម្រុងទាំងនេះតាមក្រសួងស្ថាប័ននិងអង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រភេទ១នៃចំណាយមូលធនគឺសម្រាប់ការទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និងពីក្រៅប្រទេសនិងទូទាត់បំណុលប្រហាក់ប្រហែល។រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចីចំណាយផ្សេងៗចំណាយសំណងនិងចំណាយបង្វិលសងវិញព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេសនិងពីក្រៅប្រទេសនិងទូទាត់បំណុលប្រហាក់ប្រហែល។[៦៤] ការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ជាតិត្រូវធ្វើតាមប្រតិទិនដូចតទៅៈ

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនាដល់ខែឧសភា

នៅសប្តាហ៏ទីមួយ នៃខែមីនារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំក្របខ័ន្ឌគោលនយោបាយម៉ាគ្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដេលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍដើម្បីដាក់ជូនរាជរដ្ឋាភិបាលនិងសម្រេច។ក្រោយពីមានការសម្រេចពី

[៦៣] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា២៣
[៦៤] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា២៣

រាជរដ្ឋាភិបាលរួចហើយនៅក្នុងសប្តាហ៍ទីមួយនៃខែមេសារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់ឆ្នាំហើយសារាចរនេះត្រូវផ្អែកទៅតាមក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យមដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈបានសរសេរនិងទទួលបានការសម្រេចពីរាជរដ្ឋាភិបាលទៅដល់គ្រប់ស្ថាប័នរដ្ឋទាំងអស់អោយបានដឹងដើម្បីអោយស្ថាប័នទាំងនោះរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់ស្ថាប័នរបស់ខ្លួននៅឆ្នាំក្រោយ។ក្រោយពីបានទទួលសារាចរដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រកាសរួចហើយរដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានស្ថាប័នទាំងអស់និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ក្រសួងស្ថាប័នអង្គភាពសាធារណៈប្រហាក់ប្រហែលនិងរដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្អែកលើសារាចរដែលបានចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យនិងអង្គភាពសាធារណៈប្រហាក់ប្រហែលដែលបម្រើអោយគោលនយោបាយអាទិភាពរបស់វិស័យនិងគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ។ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥នៃខែឧសភា។

**ការរៀបចំកញ្ចប់ថវិកាពីខែមិថុនាដល់ខែកញ្ញា**

នៅសប្តាហ៍ទីមួយនៃខែមិថុនា ក្រោយពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបានផែនការយុទ្ធសាស្ត្រថវិកាពីរដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័ននិងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលបានផ្ញើមករួចរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាប់ផ្តើមរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាដោយបញ្ជាក់ជូននូវទម្រង់បែបបទនិងនីតិវិធីនៃការរៀបចំគម្រោងថវិកាព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធសំខាន់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចបន្ទាប់ពីរាជរដ្ឋាភិបាលសម្រេចរួចហើយរដ្ឋមន្ត្រីមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្ញើសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសដែលបានសម្រេចដោយរដ្ឋាភិបាលទៅអោយរដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័ននិងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលវិញដើម្បីអោយរដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័ននិងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលទាំងអស់ចាប់ផ្តើមរៀបចំគម្រោងចំណូលចំណាយថវិកាលម្អិតរបស់ខ្លួន។ក្រោយពីរដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័ននិងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលទទួលបានសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសដែលបានសម្រេចដោយរដ្ឋាភិបាលរួចហើយរដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័នរួមទាំងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលត្រូវរៀបចំនូវគម្រោងចំណូលចំណាយថវិកាលម្អិតរបស់ខ្លួនសម្រាប់រដ្ឋបាលផ្ទាល់ខ្លួនដោយយកសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកានិងអាទិភាពនៃគោលនយោបាយរបស់ខ្លួនជាមូលដ្ឋានសំរាប់ផ្អែក។គម្រោងថិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញ

វត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ខែកក្កដា។ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូលចំណាយថវិការបស់ក្រសួងស្ថាប័នរដ្ឋទាំងអស់ដែលបានស្នើឡើង។នៅក្នុងអំឡុងខែសីហាទាំងមូលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ននិងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលមកពិភាក្សាការពារគម្រោងថវិការបស់ខ្លួនដើម្បីសម្របសម្រួលនូវគម្រោងចំណូលចំណាយថវិកាទាំងនោះអោយបានសមស្របតាមបទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយណាមួយដែលមើលទៅមិនចាំបាច់និងបង្កើនចំណូលអោយបានសមស្រប។នៅក្នុងអំឡុងខែកញ្ញាទាំងមូលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុបចំណូលចំណាយរដ្ឋទាំងមូលដើម្បីតុល្យភាពថវិកាឡើងវិញរួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុនិងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ។

**ការអនុម័តថវិកាពីខែតុលាដល់ខែធ្នូ**

នៅសប្តាហ៏ទីមួយខែតុលាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបញ្ជូនសេចក្តីព្រាងច្បាប់នេះដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យរួចដាក់ជូនរដ្ឋសភានៅសប្តាហ៏ទីមួយនៃខែវិច្ឆិកាដើម្បីពិនិត្យអនុម័តនិងដាក់ជូនព្រឹទ្ធសភានៅសប្តាហ៏ទីមួយនៃខែធ្នូដើម្បីអោយសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី២៥ខែធ្នូ។

## ២.២.២ ដំណើរការថវិកាថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាពាក្យហៅកាត់នៅក្នុងក្របខ័ណ្ឌនៃច្បាប់ដែលសំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ជានីតិបុគ្គលនៃនីតិសាធារណៈដែលមានទ្រព្យសម្បត្តិធនធានហិរញ្ញវត្ថុ និងថវិការផ្ទាល់របស់ខ្លួន[៦៥]។សំរាប់ការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុនិងថវិការថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋានដូចមានចែងនៅក្នុងមាត្រា២ មាត្រា៥ និងមាត្រា៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ[៦៦]។រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុនិងថវិកាសមស្របដើម្បីអនុវត្តរាល់មុខងារភារកិច្ចសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំនិងអនុម័តប្រចាំឆ្នាំនីមួយរបស់ខ្លួនជារៀងរាល់ឆ្នាំតាមការិយបរិច្ឆេទនៃឆ្នាំថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាប់ផ្តើមនៅថ្ងៃទី០១ខែមករាហើយបញ្ចប់នៅថ្ងៃទី៣១ខែធ្នូ។ថវិការដ្ឋបាលថ្នាកក្រោមជាតិត្រូវរៀបចំ និងអនុម័ត ដោយមានតុល្យភាពពិតប្រាកដរវាងចំណូលនិងចំណាយទៅតាមទម្រង់និងចំណាត់ថ្នាក់ថវិកា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[៦៧]ការអនុម័តនិងអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិអាច

[៦៥] សៀវភៅហិរញ្ញវត្ថុសាធារណៈរបស់លោកបណ្ឌិត ហាន់ ជួន ណារ៉ុន

[៦៦] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨

[៦៧] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ មាត្រា១៨

ត្រូវរៀបចំលុះត្រាតែស្របតាមគោលការណ៍មួយចំនួនមានដូចជា ត្រូវផ្សព្វផ្សាយព័ត៌មានអោយបានពេញលេញអំពីការរៀបចំ និងការអនុម័តថវិកា រាល់ចំណូល និងចំណាយទាំងអស់ត្រូវតែជាផ្នែកនៃថវិកាឯកភាពតែមួយគត់ថវិកាត្រូវបញ្ចូលចំណូលនិងចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិចំណូលត្រូវប្រមូលនិងបង្ហាញជាទឹកប្រាក់សរុបដោយគ្មានការកាត់កងចំណាយណាមួយឡើយគ្មានចំណូលណាមួយត្រូវបានកំណត់សម្រាប់ការចំណាយជាក់លាក់ណាមួយឡើយលើកលែងតែមានការអនុញ្ញាតដែលកំណត់ដោយបទប្បញ្ញត្តិដោយឡែកសរុបគម្រោងចំណាយត្រូវធានាទាំងស្រុងដោយសរុបគម្រោងចំណូលគ្មានចំណូលឬចំណាយណាមួយត្រូវប្រមូល ឬប្រើប្រាស់ក្រៅពីខ្ទង់ថវិកាដែលមានអនុម័តឡើយ។រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំអនុម័តនិងអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។រដ្ឋបាលថ្នាក់ក្រោជាតិត្រូវគ្រប់គ្រងនិងប្រើប្រាស់ថវិការប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យចំពោះប្រជាជនរបស់ខ្លួមនិងចំពោះរាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ។[៦៨]រដ្ឋបាលថ្នាក់ក្រោមជាតិគ្មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេអោយប្រាក់គេខ្ចីបោះផ្សាយសញ្ញាប័ណ្ណមូលប័ត្រលិខិតធានានិងធ្វើទង្វើណាដោយផ្ទាល់ឬដោយប្រយោលដែលអាចនាំអោយកើតមាននូវបំណុល ឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀតដោយផ្ទាល់ ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។ ចំពោះការទទួលហិរញ្ញប្បទានឥតសំណងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានការឯកភាពជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[៦៩]។

***បន្ទុក និងធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ***

ទោះជារដ្ឋបាលថ្នាក់ក្រោមជាតិមិនមែនជារដ្ឋបាលកំពូលនិងមិនមានចំណូលចំណាយធំដូចទៅនឹងរដ្ឋបាលថ្នាក់ជាតិក៏ដោយតែក៏មិនមានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិមិនមានសារៈសំខាន់នេះទេដូចនេះហើយបានរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានជំពូកចំណូលនិងចំណាយដូចទៅនឹងរដ្ឋបាលថ្នាក់ជាតិរដ្ឋបាលថ្នាក់ក្រោមជាតិមានប្រភពចំណូលចំនួន៣ជំពូកគឺចំណូលពីប្រភពនៅមូលដ្ឋានចំណូលពីថ្នាក់ជាតិចំណូលផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិដ៏ទៃទៀត។

ជំពូកទី១ចំណូលពីប្រភពមូលដ្ឋានរួមមានចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ។ចំណូលសារពើពន្ធរបស់រដ្ឋបាលថ្នាកក្រោមជាតិគឺជាថវិកាដែលទទួលបានពីពន្ធនិងអាករ។ ពន្ធនិងអាករដែលរដ្ឋបានផ្តល់អោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រមូលនេះមានគោលបំណងផ្តក់គុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្នែកហិរញ្ញវត្ថុ។ចំណូលសារពើពន្ធរបស់ថ្នាក់ក្រោមជាតិមិនមានលក្ខណៈខុសគ្នាទៅតាមរដ្ឋបាលនីមួយមានឆ្នាំខ្លះចំណូលសារពើពន្ធរបស់រដ្ឋបាលថ្នាក់ ស្រុក ខណ្ឌ ឃុំនិងសង្កាត់មិនទទួលបានសូម្បីមួយភាគរយភាពច្រើន

[៦៨] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ មាត្រា២២

[៦៩] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ មាត្រា២១

ចំណូលសារពើពន្ធដែលទទួលបានច្រើនជាងគេគឺ រដ្ឋបាលរាជធានីភ្នំពេញ។ចំពោះចំណូលដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រមូលបានមានដូចជាអាការបំភ្លឺសាធារណៈ ពន្ធប៉ាតង ពន្ធប្រថាប់ត្រា...។ល។ខុសពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបានគ្រប់ឆ្នាំនិងគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់គ្រាន់តែតំបន់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានច្រើននិងតិចតែប៉ុណ្ណោះ។ ចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាថវិកាដែលរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានក្រៅពីពន្ធនិងអាករដែលមានជាតួយ៉ាងដូចជា ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងការផ្តល់សេវា(នៅក្នុងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានសេវាជាច្រើនដូចជា សេវាផ្ទៃករដ្ឋបាល សេវាសុរិយាដី សេវាសំណង់ជាដើម)។ការធ្វើប្រតិភូកម្មអំណាចនៃការគ្រប់គ្រងចំណូលពីសេវាឬចំណូលមិនមែនសារពើពន្ធនេះដោយរដ្ឋបាលថ្នាក់ជាតិមានគោលបំណងចង់លើកកម្ពស់នៃការគ្រប់គ្រប់ចំណូលពីសេវាដែលរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់អោយប្រជាជនខ្លួនឯងដោយមានប្រសិទ្ធភាពហើយគោលដៅចង់អោយរដ្ឋបាលថ្នាក់ក្រោមជាតិអាចកំណត់ពីការគ្រោង ការប្រមូល ការបែងចែក  ការបង់និងការប្រើប្រាស់ចំណូលថវិកាដែលខ្លួនទទួលបាន។

ជំពូកទី២នៃចំណូលរដ្ឋបាលថ្នាក់ក្រោមជាតិគឺចំណូលដែលរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានពីរដ្ឋបាលថ្នាក់ជាតិហើយចំណូលនេះមានបីប្រភេទគឺ ចំណូលចែករំលែក ចំណូលមូលនិធិផ្ទេរពីថវិកាថ្នាក់ជាតិ និងចំណូលថ្លៃសេវាបានមកពីមុខងារភ្នាក់ងារដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល។ប្រភេទចំណូលនេះរដ្ឋបង្កើតឡើងព្រោះតែរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅតាមតំបន់ដាច់ស្រយាសឹងតែមិនទទួលបានថវិកាពីចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធអ្វីទេ។ចំណូលចែករំលែកគឺជាចំណូលដែលត្រូវចែករំលែករវាងថ្នាក់ជាតិ ជាមួយរដ្ឋបាលថ្នាកក្រោមជាតិពាក់ព័ន្ធ។ ប្រភេទចំណូលនិងសមាមាត្របែងចែកត្រូវកំណត់ដោយច្បាប់ ឬអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ(ច្បាប់ស្តីអំពីរបបហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ)។សំរាប់មូលនិធិផ្ទេរពីថវិកាថ្នាក់ជាតិគឺជាថវិកាដែលរដ្ឋបាលថ្នាក់ជាតិផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបំពេញការងារឬមុខងាររបស់ខ្លួន។សំរាប់ការផ្ទេរពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិមានពីរប្រភេទគឺមូលនិធីផ្ទេរមានភ្ជាប់លក្ខខណ្ឌនិងមូលនិធីគ្មានភ្ជាប់លក្ខខណ្ឌ។មូលនិធីផ្ទេរមានភ្ជាប់លក្ខខណ្ឌ ជាថវិកាដែលថ្នាក់ជាតិផ្ទេរទៅថ្នាក់ក្រោមជាតិសំរាប់អោយរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញកាតព្វកិច្ច ឬមុខងាររបស់ខ្លួនយ៉ាងជាក់លាក់ និងមានការកំណត់ពីរដ្ឋបាលថ្នាក់ជាតិ(នៅក្នុងកាតព្វកិច្ចនោះអាចមានមួយឬច្រើន)ហើយលក្ខខណ្ឌត្រូវបានបែងចែកជាបីគឺ គ្រប់គ្រង ចាតចែងនិងអនុវត្តមុខងារជាកាតព្វកិច្ចមួយឬច្រើនដែលត្រូវបានផ្ទេរអោយរដ្ឋបាលថ្នាក់ក្រោមជាតិតាមការប្រគល់មុខងារឬការធ្វើប្រិតភូកម្មមុខងារដើម្បីបន្តគ្រប់គ្រងឬចាត់ចែងនិងអនុវត្តមុខងារជាជម្រើសមួយឬច្រើនដែលក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលបានធ្លាប់បានអនុវត្តនិងសំរាប់គោលបំណងជាកាតព្វកិច្ចមួយឬច្រើនដែលបានកំណត់។

សំរាប់មូលនិធីផ្ទេរពីរដ្ឋបាលគ្មានលក្ខខណ្ឌជាថវិកាដែលរដ្ឋបាលថ្នាក់ជាតិផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញកាតព្វកិច្ច ឬមុខងាររបស់ខ្លួនតែមិនមានការកំណត់ពីរដ្ឋបាលថ្នាក់ជាតិទេ។មូលនិធីផ្ទេរពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិមានដូចជា ថវិកាសំរាប់បំពេញភារកិច្ចតាមផ្លូវច្បាប់ បំពេញមុខងារភារកិច្ចក្នុងការបង្កើត ការជំរុញនិងការធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន ជ្រើសរើស គ្រប់គ្រង ចាត់ចែងនិងអនុវត្តមុខងារជាជម្រើនានា។សំរាប់មូលនិធីផ្ទេរគ្មានលក្ខខណ្ឌនេះដែលរដ្ឋាបាលថ្នាក់ក្រោមជាតិអាចស្នើសុំ និងទទួលថវិកាប្រភេទនេះពីរដ្ឋបាលថ្នាក់ជាតិជាប្រចាំឆ្នាំប្រសិនបើថ្នាក់ជាតិយល់ថាចាំបាច់និងមានសារសំខាន់សំរាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនិងរូបមន្តប្រកបដោយតម្លាភាព។

ទម្រង់បែបបទ វិធាននិងលក្ខខណ្ឌនៃការផ្ទេរមូលនិធីមានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃទម្រង់បែបបទវិធាននិងលក្ខខណ្ឌនៃការផ្ទេរមូលនិធីគ្មានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[៧០]

ជំពូកទី៣គឺ ចំណូលដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបានពីការអនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលផ្អែកទៅតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិដទៃទៀត។ការដែលរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវចំណូលអំពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមក្រសួងស្ថាប័ន ឬមន្ទីរអង្គភាពនានា របស់រដ្ឋបាលថ្នាក់ជាតិដើម្បីទទួលអនុវត្តនូវកិច្ចការអ្វីមួយតាមរយៈកិច្ចសន្យា ឬកិច្ចព្រមព្រៀងដែលក្នុងនោះបានកំណត់ច្បាស់អំពីកិច្ចការដែលត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត លទ្ធផលដែលត្រូវសម្រេចនិងប្រាក់កម្រៃដែលភ្នាក់ងារអនុវត្តត្រូវបានទទួល។ទម្រង់បែបបទនិងវិធានការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារខាងលើនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។យោងតាមតារាង ខ៣ នៃនៃច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ស្តីពីពីចំណាយថវិកាថ្នាក់ក្រោមជាតិបានបែងចែកការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាបីគឺចំណាយថវិការបស់រដ្ឋបាលថ្នាក់រាជធានីខេត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រុងនិងស្រុកនិងចំណាយថវិការបស់រដ្ឋបាលថ្នាក់ឃុំ សង្កាត់។ចំណាយថវិការបស់រដ្ឋបាលថ្នាក់រាជធានី ខេត្តត្រូវបានបែងចែកជាពីរគឺចំណាយចរន្ត និងចំណាយមូលធន។ ចំណាយចរន្តក្នុងរដ្ឋបាលថ្នាក់រាជធានីខេត្តមានជាអាទិ៍ការទិញ សេវាកម្មអត្ថប្រយោជន៍សង្គម ពន្ធ និងអាករ បន្ទុកបុគ្គលិក ឧបត្ថម្ភធន បន្ទុកហិរញ្ញវត្ថុនិងចំណាយមិនបានគ្រោងទុក។

[៧០] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ មាត្រា២៩

ចំណែកចំណាយទី២វិញគឺចំណាយមូលធនជាចំណាយទៅលើ អចលកម្មរូបី។រីឯចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រុង ស្រុកត្រូវបានបែងចែកពីរដូចគ្នាទៅនឹងចំណាយរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្តគឺចំណាយចរន្ត និងចំណាយមូលធន។ចំណែកឯចំនាយថវិការបស់រដ្ឋបាលឃុំ សង្កាត់វិញមានតែបីទេគឺចំណាយសង្កាត់រដ្ឋបាលចំណុះរាជធានីចំណាយរដ្ឋបាលសង្កាត់ចំណុះក្រុងនិងចំណាយរដ្ឋបាលឃុំ។គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំទៅតាមប្រតិទិនដូចខាងក្រោម៖

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(ពីខែមីនា ដល់ខែឧសភា)**

នៅសប្តាហ៏ទីមួយនៃខែមីនារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំក្របខ័ន្ឌគោលនយោបាយម៉ាគ្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដាក់ជូនរាជរដ្ឋាភិបាលនិងសម្រេច។

ក្រោយពីមានការសម្រេចពីរាជរដ្ឋាភិបាលរួចហើយនៅក្នុងសប្តាហ៏ទីមួយនៃខែមេសារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់ឆ្នាំហើយសារចរនេះត្រូវផ្អែកទៅតាមក្របខណ្ឌគោលនយោបាយម៉ាគ្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈបានសរសេរនិងទទួលបានការសម្រេចពីរាជរដ្ឋាភិបាលទៅដល់គ្រប់ស្ថាប័នរដ្ឋទាំងអស់អោយបានដឹងដើម្បីអោយស្ថាប័នទាំងនោះរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់ស្ថាប័នរបស់ខ្លួននៅឆ្នាំក្រោយ។

ក្រោយពីបានទទួលសារចរដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រកាសរួចហើយគ្រប់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់តំបន់ទាំងអស់ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំក្រោយរបស់ខ្លួនដោយផ្អែកលើសារាចរដែលបានចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ អង្គភាពសាធារណៈប្រហាក់ប្រហែលនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបម្រើអោយគោលនយោបាយអាទិភាពនិងគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ។ផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥នៃខែឧសភា។

**ការរៀបចំកញ្ចប់ថវិកា(ពីខែមិថុនា ដល់ខែកញ្ញា)**

នៅសប្តាហ៏ទីមួយនៃខែមិថុនា ក្រោយពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបានផែនការយុទ្ធសាស្ត្រថវិកាពីគ្រប់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានផ្ញើមករួចរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាប់ផ្តើមរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាដោយបញ្ជាក់ជូននូវទម្រង់បែបបទនិងនីតិវិធីនៃការរៀបចំគម្រោងថវិកាព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធសំខាន់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចបន្ទាប់ពីរាជរដ្ឋាភិបាលសម្រេចរួចហើយរដ្ឋមន្ត្រីមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹង

ផ្ញើសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសដែលបានសម្រេចដោយរដ្ឋាភិបាលទៅអោយថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់តំបន់ទាំងអស់វិញដើម្បីអោយថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់តំបន់ទាំងអស់ចាប់ផ្តើមរៀបចំគម្រោងចំណូលចំណាយថវិកាលម្អិតរបស់ខ្លួន។

ក្រោយពីថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់តំបន់ទាំងអស់ទទួលបានសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសដែលបានសម្រេចដោយរដ្ឋាភិបាលរួចហើយថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់តំបន់ទាំងអស់ត្រូវរៀបចំនូវគម្រោងចំណូលចំណាយថវិកាលម្អិតរបស់ខ្លួនសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិដោយយកសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកានិងអាទិភាពនៃគោលនយោបាយរបស់ខ្លួនជាមូលដ្ឋានសំរាប់ផ្អែក។គម្រោងថិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ខែកក្កដា។គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឡើងដោយអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដោយមានជំនួយពីប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សានិងមន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកានេះដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងដែលសមត្ថកិច្ចរបស់ខ្លួន រួចហើយត្រូវពិនិត្យ និងរៀបចំឡើងបិញនូវគម្រោងថវិកានេះដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិភាក្សានិងអនុម័តក្នុងកិច្ចប្រជុំជាសាធារណៈយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ខែមិថុនា។ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ក្រុង ស្រុករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មអោយអភិបាលខេត្តទទួលខុសត្រូវក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនានានៃច្បាប់នេះបទបញ្ជាបែបបទនិងនីតិវិធីនានាដែលកំណត់ដោយថ្នាក់ជាតិ។ អភិបាលនៃគណៈអភិបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការគាំទ្របច្ចេកទេសនេះ។អភិបាលនៃគណៈអភិបាលខេត្តត្រូវធានាថាមន្ត្រីនៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុបគម្រោងថវិការបស់ខេត្ត គម្រោងថវិការបស់ក្រុងគម្រោងថវិការបស់ស្រុកក្នុងខេត្តរបស់ខ្លួនចូលក្នុងទម្រង់ដែនកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយភ្ជាប់ជាមួយនូវគម្រោងថវិកា និងសេចក្តីអត្ថាធិប្បាយពន្យល់របស់ខេត្ត របស់ក្រុងរបស់ស្រុកហើយត្រូវផ្ញើគម្រោងនិងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា។

ក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុត្រូវធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំនីមួយៗ។ក្នុងអំឡុងខែសីហាទាំងមូលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យនីត្យានុកូលភាពនិងបញ្ជាក់អនុលោមភាពលើថវិការបស់រាជធានី ថវិការបស់ខេត្តថវិការបស់ក្រុងនិងថវិការបស់ស្រុក។រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មនូវការពិនិត្យនីត្យានុកូលភាពទៅដល់អង្គភាពជំនាញរបស់ខ្លួនឬ

អាជ្ញាធរណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់។ដំណើរការពិនិត្យនីត្យានុកូលភាពត្រូវមានការចូលរួមពីអភិបាលនៃគណៈអភិបាលរាជធានីខេត្ត ក្រុងនិងស្រុកដែលតំណាងអោយក្រុមប្រឹក្សាជាម្ចាស់ថវិកា តំណាងក្រសួងមហាផ្ទៃ និងសមាសភាពដទៃទៀតដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ក្នុងដំណើរការពិនិត្យនីត្យានុកូលភាពនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឬអាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់លើគោលការណ៍នៃការពិនិត្យនីត្យានុកូលភាពចំនួន៦គឺគោលការនីត្យានុកូលភាពទី១គម្រោងថវិកាបានរៀបចំឡើងទៅតាមទម្រង់ចំណាត់ថ្នាក់ថវិកាបែងបទ និងនីតិវិធីដែលបានកំណត់ គោលការនីត្យានុកូលភាពទី២មានការចូលរួមពីប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំថវិកាគោលការនីត្យានុកូលភាពទី៣ការគ្រោងឥណទានទៅតាមគោលការណ៍ចំណាយចាំបាច់គោលការនីត្យានុកូលភាពទី៤ គម្រោងថវិកាត្រូវគ្រោងតាមលក្ខខណ្ឌដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពជាក់លាក់ដែលបានកំណត់ទុកជាមុន គោលការនីត្យានុកូលភាពទី៥ធានាអោយមានតុល្យភាពពិតប្រាកដរវាងចំណូលនិងចំណាយថវិកាគោលការនីត្យានុកូលភាពទី៦មានការពិភាក្សាអនុម័តគម្រោងថវិកាក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា។

បើសិនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬអាជ្ញាធរដែលមានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការពិនិត្យទៅលើគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយប្រទះឃើញថាគម្រោងថវិកាមានការខុសទៅនឹងគោលការនីត្យានុកូលចាប់ពី១គោលការឡើងទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬអាជ្ញាធរដែលមានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសម្រេចកែសម្រួលនិងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអោយអភិបាលនៃគណៈអភិបាលធ្វើការកែសម្រួលឡើងវិញទៅតាមនីតិវិធីជាធរមាន។

**ការអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(ពីខែតុលា ដល់ខែធ្នូ)**

នៅសប្តាហ៍ទី១ ខែតុលាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាប់ផ្តើមរៀបចំនិងបញ្ចូលគម្រោងថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីធ្វើការពិនិត្យ សម្រេចរួចហើយដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី១នៃខែវិច្ឆិកាដើម្បីពិនិត្យអនុម័តក្រោយពីរដ្ឋសភាពិនិត្យនិងអនុម័តរួចហើយសេចក្តីព្រាងច្បាប់នេះនឹងត្រូវបញ្ជូលទៅព្រឹទ្ធសភានៅសប្តាហ៍ទី១នៃខែធ្នូដើម្បីធ្វើការពិនិត្យនិងកែសម្រួលរួចហើយទើបញ្ជូលមករដ្ឋសភាវីញដើម្បីអោយសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី២៥ខែធ្នូ។ប្រសិនបើគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមិនត្រូវបានអនុម័តមុនថ្ងៃទី១ខែមករានៃឆ្នាំសំរាប់ការិយបរិច្ឆេទដែលត្រូវអនុវត្តទេនោះអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិប្រមូលចំណូលតាមលក្ខខណ្ឌដែលបានអនុម័តដូចឆ្នាំមុននិងធានាចំណាយប្រចាំខែក្នុងកម្រិត១/១២ នៃថវិកាឆ្នាំមុន។

គួរកត់សំគាល់ថា ការពង្រាងថវិកាឆ្នាំ ២០២១ សម័យកាល កូវិតះ

មុនពេលមានការរីករាលដាលនូវជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានសំរេចដាក់អោយអនុវត្តចំណាយសំរាប់ឆ្នាំ២០២០ ដល់ទៅ៨ពាន់លានដុល្លាអាមេរិក។[៧១]ប៉ុន្តែការអនុវត្តចំណាយនេះបានអនុម័តមុនពេលដែលមានការរីករាលដាលនូវជំងឺកូវីដ-១៩ក្រោពេលដែលជំងឺនេះកើតមានឡើងនៅប្រទេសកម្ពុជាបានធ្វើអោយរាជរដ្ឋាភិបាលសំរាច់ថានឹងអនុម័តថវិកាសំរាប់ការចំណាយត្រឹមតែ៤ពាន់លានដុល្លាអាមេរិកតែប៉ុណ្ណោះហើយការចំណាយថវិកាត្រឹមតែ៤ពាន់លានដុល្លានេះនឹងធ្វើទៅចាប់ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៣។ការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាលនេះបានធ្វើអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការស្នើសុំទៅក្រសួងនិងស្ថាប័នទាំងអស់អោយសន្សំសំចៃក្នុងការចំណាយរបស់ក្រសួងស្ថាប័នផ្ទាល់ខ្លួនប៉ុន្តែការកាត់បន្ថយចំណាយនេះមិនធ្វើអោយប៉ះពាល់ដល់ប្រាក់ខែមន្ត្រីរាជការទេតែប្រាក់ខែមន្ត្រីរាជការក៏មិនមានការតម្លើងដែរ។[៧២] រីឯការជ្រើសរើសមន្ត្រីរាជការក៏មិនអាចធ្វើទៅច្រើនដូចមុនដែលដោយការជ្រើរើសមន្ត្រីរាជការត្រូវរើសអោយស្មើនឹងចំនួនមន្ត្រីដែលបានចូលនិវត្តន៍។

## ២.៣ សមត្ថកិច្ចរៀបចំថវិកាជាតិ ក្នុងប្រតិបត្តិការចំណាយ

### ២.៣.១. ថ្នាក់ខាររដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នៅក្នុងក្របខណ្ឌទិសដៅនយោបាយ រដ្ឋាភិបាលជាអ្នកកំណត់ឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវភារកិច្ចរៀបចំថវិកា ដោយសហការជាមួយរដ្ឋមន្ត្រីឯទៀត ។

មុខងាររបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុមានដូចជាអ្នកប្រមូលផ្តុំព័ត៌មាននិងស្ថិតិសេដ្ឋកិច្ចទាំងអស់ជាអ្នកកំណត់ចំណូលថវិកាទាំងមូលហើយធ្វើការសិក្សាលើឥទ្ធពលដែលជះទៅលើសេដ្ឋកិច្ចជាអ្នកប្រមូលគម្រោងថវិកាពីស្ថាប័ននានាដើម្បីយកមកពិនិត្យសម្រេច។ការប្រមូលផ្តុំព័ត៌មាននិងស្ថិតិសេដ្ឋកិច្ចទាំងអស់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាការទទួលបានព័ត៌មាននិងស្ថិតិសេដ្ឋកិច្ចពីក្រសួងស្ថាប័ននានាដូចជាអគ្គនាយដ្ឋានគយនិងរដ្ឋាករ អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលអគ្គនាយកដ្ឋាននិងនាយកដ្ឋានទាំងនេះមាននាទីព្យាករណ៍និងរៀបចំជារបាយការណ៍អំពីចំណូលដែលខ្លួនត្រូវប្រមូលដូចជាពន្ធ អាករ ចំណូលមិនមែនសារពើពន្ធ និងចំណូលដ៏ទៃទៀតដែលខ្លួនអាចប្រមូលបាននិងពួកមន្ទីរហិរញ្ញវត្ថុតាមខេត្ត-ក្រុងទាំងអស់ត្រូវធ្វើការព្យាករណ៍ចំណូលដែលត្រូវប្រមូលបានក្នុងដែនអំណាចរបស់ខ្លួន ហើយបញ្ជូនទៅនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីធ្វើសំយោគនិងធ្វើការព្យាករណ៍ទុកជាព័ត៌មាន។ក្រោយពីទទួលបានព័ត៌មានរួចហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋ

[៧១] តាមអត្ថបទចេញផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី១៣ ខែ០៦ឆ្នាំ២០២០
[៧២] យោងតាមការលើកឡើងរបស់អ្នកនាំពាក្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កិច្ច និងហិរញ្ញវត្ថុនឹងដើរតួជាអ្នកកំណត់ចំណូលថវិកាទាំងមូល ហើយធ្វើការសិក្សាលើឥទ្ធពលដែលជះលើសេដ្ឋកិច្ចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការសិក្សាទៅលើចំណូលដែលរដ្ឋទទួលបាន ធៀបទៅនឹងចំណាយដែលរដ្ឋត្រូវចំណាយរួចហើយធ្វើការកត់ចំណាំទៅលើកត្តាដែលអាចជះឥទ្ធពលទៅលើសេដ្ឋកិច្ចជាតិ ការសិក្សានេះត្រូវអាស្រ័យទៅលើ ទ្រឹស្តីសេដ្ឋកិច្ច និងហិរញ្ញវត្ថុជារួម ទិន្នន័យសេដ្ឋកិច្ចជាតិតាមផ្នែកសំខាន់ៗ បរិស្ថានផ្ទៃក្នុង និងបរិស្ថានខាងក្រៅនៃសេដ្ឋកិច្ចជាតិ បច្ចេកទេសស្ថិតិជាមូលដ្ឋាន។[៧៣] នៅពេលដែលរដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់គ្រងទិន្នន័យសេដ្ឋកិច្ចជាតិបានគ្រប់គ្រាន់ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដើរតួនាទីជាអ្នកប្រមូលគម្រោងថវិកាពីស្ថាប័ននានា ដើម្បីយកមកពិនិត្យសម្រេច។ ការងារមួយនេះរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើនៅពេលដែលក្រសួង ស្ថាប័ន ទាំងអស់របស់រដ្ឋបានធ្វើគម្រោងថវិកាតាមស្ថាប័នរបស់ខ្លួនរួចហើយ ក្រសួងស្ថាប័នទាំងនេះនឹងបញ្ចូលគម្រោងថវិការបស់ខ្លួនទៅអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយទទួលបានគម្រោងថវិកាពីគ្រប់ស្ថាប័នរដ្ឋទាំងអស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការពិនិត្យទៅលើគម្រោងថវិកាដោយផ្តោតលើទិន្នន័យដែលទទួលបាននៅពេលដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច និងហិរញ្ញវត្ថុជាដើរតួនាទីជាអ្នកប្រមូលផ្តុំព័ត៌មាននិងស្ថិតិសេដ្ឋកិច្ចហើយធ្វើការសិក្សាថាគម្រោងថវិកានេះអាចជះឥទ្ធិពលទៅលើសេដ្ឋកិច្ចជាតិឬទេបើសិនជាគម្រោងថវិកានេះមិនបានត្រឹមត្រូវឬអាចជិះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងមិនធ្វើការសម្រេចអោយនេះទេនិងបញ្ចូលឯកសារនេះទៅវិញហើយណែនាំអោយកែតម្រូវ។

ចំណាំ៖ ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ មាននាយកដ្ឋានថវិកាដែលជាអង្គការកណ្តាលមួយ មានភារកិច្ចធ្វើការសិក្សា និងរៀបចំថវិការដ្ឋទាំងមូល ។

### ២.៣.២. តួនាទីរបស់រដ្ឋមន្ត្រីដទៃទៀត

#### *ក. មុខនាយករដ្ឋមន្ត្រី*

នៅក្នុងការរៀបចំថវិកាជាតិ នាយករដ្ឋមន្ត្រីមានភារកិច្ចជាអ្នកណែនាំនិងតម្រង់ទិសដៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការងាររៀបចំគម្រោងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំបន្ទាប់ និងជាអ្នកសម្របសម្រួលនិងជួយដោះស្រាយរាល់ភាពមិនចុះសម្រុងគ្នារវាងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងនៅពេលប្រជុំស្តីពីអំពីកញ្ចប់ថវិកាមុននឹងដាក់អោយរដ្ឋសភាពិនិត្យ ។

#### *ខ.មុខងារគណៈរដ្ឋមន្ត្រី*

គណៈរដ្ឋមន្ត្រីទាំងអស់មានភារកិច្ចក្នុងការរៀបចំគម្រោងថវិការបស់ខ្លួនសំរាប់ឆ្នាំបន្ទាប់ដោយផ្អែកតាមមូលដ្ឋានសារាចរណែនាំបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ។ក្រោយពេលដែលគណៈរដ្ឋមន្ត្រីរៀបចំ

[៧៣] សៀវភៅហិរញ្ញវត្ថុសាធារណៈរបស់ បណ្ឌិត ហង់ ជួន ណារ៉ុន

គម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនរួចត្រូវបញ្ជូលទៅអោយក្រសួងសេដ្ឋកិច្ចដោយក្នុងនេះមានការការពារគម្រោងថវិកាចំណូល ចំណាយរបស់ខ្លួននៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយក៏មានការសម្រប់សម្រួលគម្រោងចំណូលចំណាយថវិកាទាំងអស់នេះអោយសមស្របតាមបញ្ញត្តិនៃការណែនាំថវិកាដោយមានកាត់បន្ថយចំណាយដែលមិនចាំបាច់និងបង្កើនចំណូលអោយបានសមស្រប។គណៈរដ្ឋមន្ត្រីក៏ត្រូវចូលរួមប្រជុំក្រោមអធិបតីភាពនាយករដ្ឋមន្ត្រីដោយកំណត់ទិសដៅថវិកានិងអនុម័តលើគម្រោងថវិកាមុននឹងបញ្ជូនទៅសភា។

## ២.៣.៣.បុគ្គលិកលក្ខណៈអ្នកអនុវត្តថវិកា

ដំណើរការថវិការបស់ជាតិមានការប្រព្រឹត្តទៅយ៉ាងច្បាស់លាស់ និងម៉ត់ចត់បំផុតដោយមានទាំងច្បាប់អនុក្រឹត្ត និងបទដ្ឋានគតិយុត្តិផ្សេងទៀតជាជំនួយក្នុងដំណើរថែមទាំងមានអង្គភាពជាច្រើនចូលរួមក្នុងការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់តាំងពីដំណាក់ចំណូលដល់ចំណាយប៉ុន្តែដំណើរការថវិកាជាតិនៅតែមានបញ្ហាកើតឡើងក្នុងការអនុវត្តព្រោះទាំងក្នុងដំណើរការប្រមូលចំណូលចូលឃ្លាំងជាតិនិងដំណើរការចំណាយសំរាប់មុខងារ ផែនការអភិវឌ្ឍន៍ផ្សេងៗដែលបញ្ហាទាំងអស់នេះបានក្លាយទៅកត្តាមួយធ្វើអោយរាជរដ្ឋាភិបាលពិបាកក្នុងការអនុវត្តដំណើរការថវិកាទើបយើងបានឃើញជារៀងរាល់ឆ្នាំថា រាជរដ្ឋាភិបាលបានចេញជាបទដ្ឋានគតិយុត្តិយុទ្ធិសាស្ត្រ កំណែទម្រង់ជាច្រើនដើម្បីធ្វើការកែប្រែបញ្ហាដែលកើតមានក្នុងដំណើរការថវិកាជាតិ និងដើម្បីកែលម្អចំនុចមួយចំនួនដែលជាឧបសគ្គដល់ដំណើរការថវិកាជាតិ។ បញ្ហាដែលកើតមានឡើងទាំងអស់នោះមានដូចជាជា ភាពមិនប្រក្រតីដែលកើតមានឡើងពីសំណាក់មន្ត្រីប្រមូលពន្ធ ការគេចពន្ធពីសំណាក់អាជីវករមួយចំនួន និងការខ្វះខាតធនធានក្នុងជួររាជរដ្ឋាភិបាលក្នុងការទាញយកកញ្ចប់ថវិការដ្ឋយកទៅអនុវត្តគម្រោងផ្សេងៗដែលរដ្ឋបានគ្រោងទុកសំរាប់ការអភិវឌ្ឍន៍អោយប្រទេសជាតិរីកចម្រើន ។

ភាពមិនប្រក្រតីដែលមានពីសំណាក់មន្ត្រីទទួលបន្ទុកប្រមូលពន្ធបានធ្វើអោយអាជីករមួយចំនួនដែលមានចិត្តចង់បង់ពន្ធចូលរដ្ឋមានការពិបាកក្នុងការបង់ពន្ធចូលរដ្ឋ និងធ្វើអោយបាត់បង់ថវិកាជាតិផងដែរ។ ដូចដែលយើងបានដឹងរួចហើយថាពន្ធជាប្រភពចំនូលដ៏ធំក្នុងដំណើរការថវិកាជាតិដែលពន្ធនេះជាចំនូលចំបងរបស់ជាតិ។ តាមការលើកឡើងរបស់ព្រឹត្តិប័ត្រ ស្តីពីបញ្ហាអាជីវកម្មបានលើកឡើងថា នីតិវិធីនៃការបង់ពន្ធគយដែលមានភាពស្មុគស្មាញមិនត្រឹមតែធ្វើអោយអ្នកបង់ពន្ធត្រូវចំណាយពេលវេលាច្រើននេះទេ ថែមទាំងបានផ្តល់ឪកាសដល់មន្ត្រីដែលទទួលបន្ទុកក្នុងការងារប្រមូលពន្ធអាចទារប្រាក់ពីអ្នកបង់ពន្ធផងដែរ នាំអោយក្រុមអាជីវករដែលជាអ្នកត្រូវបង់ពន្ធយល់ថាការបង់ពន្ធជាមួយបុគ្គលមានភាពងាយស្រួលជាងការបង់ពន្ធជាមួយរដ្ឋព្រោះតែការបង់ពន្ធចូលរដ្ឋនេះតម្រូវអោយបំពេញឯកសាររហូតដល់ ៤៥ខុសគ្នាៗនិងត្រូវចុះហត្ថលេខាជាច្រើន ហើយត្រូវបង់ថ្លៃឈ្នួលសំរាប់ហត្ថលេខាទាំងនេះហើយប្រសិនបើអាជីវករចង់បានការបង់ពន្ធឆាប់រហ័សត្រូវការប្រាក់ខ្លះសំរាប់មន្ត្រីប្រមូលពន្ធ។បើតាមការលើកឡើងរបស់លោក ឈឹម សុកននាយកក្រុមហ៊ុនសាខនត្រេនស្ព័តទៅអោ

យក្រុមការងារព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្មបានអោយដឹងថា នីតិវិធីនៃការបង់ពន្ធមានបទបញ្ញាត្តិច្រើនហួសហេតុនៅក្នុងនាយកដ្ឋានគយ ហើយពួកគេច្រើនតែសម្រេចចេញនូវរឿងថ្មីជានិច្ច ជួនកាលនៅពេលដែលមន្ត្រីគយណាម្នាក់មិនដឹងថាតើត្រូវយកអត្រាពន្ធណាមួយមកប្រើចំពោះផលិតផលនាំចូលមុខណាមួយ មន្ត្រីគយនោះកំណត់អត្រាពន្ធចំពោះផលិតផលនោះទៅតាមចិត្តចង់ដែលធ្វើអោយការបង់ពន្ធចូលរដ្ឋមិនត្រឹមត្រូវតាមការកំណត់របស់រដ្ឋ។បើយើងសង្កេតមើលធម្មតាយើងអាចមើលឃើញថាភាពមិនប្រក្រតីរបស់មន្ត្រីទទួលបន្ទុកប្រមូលពន្ធនេះមិនសូវប៉ះពាល់ដល់ការប្រមូលពន្ធជាតិនេះទេព្រោះតែអាជីវករមានការនាំចូលធម្មតាហើយប្រាក់ពន្ធបានទទួលធម្មតាប៉ុន្តែមានការយកប្រាក់បន្ថែមពីអាជីវករដែលចង់បានការបង់ពន្ធលឿន ការមើលឃើញធម្មតាបែបនេះពិតជាមិនត្រឹមត្រូវនេះទេ។បើយើងមើលតាមទិន្នន័យវិញទើបត្រឹមត្រូវដោយយោងតាមរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អាជ្ញាធរសវនកម្មជាតិឆ្នាំ២០១៦បានបង្ហាញនាយកដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលទទួលបន្ទុកការងារប្រមូលពន្ធមិនមានរបាយការណ៍ ឬកំណត់ហេតុស្តីពីការអនុវត្តការត្រួតពិនិត្យលើការអនុវត្តនីតិវិធីនិងបែបបទនៃការកំណត់ពន្ធ ការប្រមូលពន្ធ ការប្រមូលបំណុលពន្ធ ការបង់ប្រាក់ពន្ធចូលរតនាគារនិងធនាគារការត្រួតពិនិត្យលើការអនុវត្តនីតិវិធីគ្រប់ប្រភេទ និងការគ្រប់គ្រងពន្ធតាមរបបម៉ោងការ ស្ថិតិក្រុមអាជីវករដែលធ្វើការបង់ពន្ធចូលក្នុងរដ្ឋទាំងរាជធានី-ខេត្តនានាឡើយ។ នៅក្នុងរបាយការណ៍ក៏បានបន្ថែមទៀតថា ការអនុវត្តតួនាទីមិនបានពេញលេញអាចជាកត្តាជះឥទ្ធិពលដល់លទ្ធផលនៃការប្រមូលពន្ធចូលរដ្ឋ។ដូចនេះយើងអាចមើលឃើញថាការស៊ីសំនូករបស់មន្ត្រីដែលទទួលបន្ទុកក្នុងការប្រមូលពន្ធពិតជាជះឥទ្ធិពលដល់លទ្ធផលនៃការប្រមូលពន្ធចូលក្នុងឃ្លាំងជាតិ។

ការគេចពន្ធក៏ជាកត្តាបញ្ហាមួយក្នុងដំណើរការថវិកាជាតិផងដែរ ដោយធ្វើឡើងតាមរយៈអាជីវករមួយចំនួនដែលមានចិត្តចង់ចំណេញខ្ពស់ពីមុខជំនួញរបស់ខ្លួនភាគច្រើននៃការគេចពន្ធនេះកើតមានឡើងចំពោះការនាំចូលរថយន្តព្រោះរថយន្តជាយានយន្តពេញនិយមនិងបានតម្លៃខ្ពស់ហើយជាប់ពន្ធខ្ពស់ដូចនេះទើបអាជីវករធ្វើការគេចពន្ធក្នុងគោលបំណងយល់ចំណេញខ្ពស់។តាមការលើកឡើងរបស់ឯកឧត្តម គុណ ញឹមជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅទូរទស្សន៍BTV ថ្ងៃពុធ២១ ខែមិថុនា ឆ្នាំ២០១៧ស្តីពីលទ្ធផលប្រមូលពន្ធ អាករនិងបញ្ហាប្រឈមបានអោយដឹងថា ការគេចពន្ធមានពីររបៀបគឺតាមផ្លូវទឹក និងតាមផ្លូវគោគហើយភាគច្រើននៃការគេចពន្ធនេះតែងតែចូលតាមព្រំដែនខ្មែរនិងថៃ និងព្រំដែនខ្មែរនិងឡាវ។ ការគេចពន្ធតាមផ្លូវគោគភាគច្រើនជាប្រភេទទំនិញដែលជាប់ពន្ធអាករខ្ពស់ប៉ុន្តែមានទំហំតូច ដូចជាបារី ស្រាជាដើម។តាមស្ថានភាពព្រំដែនជាក់ស្តែងរបស់ប្រទេសកម្ពុជាបច្ចុប្បន្ននេះមិនមានរបង ឬការការពារត្រឹមត្រូវគ្រប់គ្រាន់នៅឡើយទេព្រោះស្ថានភាពនេះហើយបានធ្វើព្រំដែនប្រទេសកម្ពុជានិងប្រទេសជិតខាងមានច្រកគេចពន្ធរហូតទៅដល់២០០ច្រកកត្តានេះធ្វើអោយអគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករកម្ពុជាពិបាកក្នុងការតាមដាននិងការពារ។សំរាប់ផ្លូវទឹកវិញភាគ

ច្រើននៃការគេចពន្ធតាមរបៀបនេះតែងតែនាំចូលមកជាទំនិញធំៗហើយជាប់ពន្ធអាករខ្ពស់ដូចជាឡាន ម៉ូតូជាដើមដោយការដឹកនេះមិនមានចំនួនច្រើនទេចន្លោះពីមួយទៅពីរចំពោះឡាន និង១០ទៅ២០ចំពោះម៉ូតូ។ ការគេចពន្ធបានផ្លូវទឹកនេះ អគ្គនាយកដ្ឋានពន្ធគយមិនមានឧបករណ៍គ្រប់គ្រាន់សំរាប់ធ្វើការតាមដានដូចជាទូក កានូតជាដើម សំរាប់ធ្វើការប្រដាញតាមដូចនេះហើយទោះធ្វើអោយមានការនាំចូលទំនិញគេចពន្ធ។តាមការលើកឡើងដដែលពីឯលឧត្តម គុណ ញឹមបានអោយដឹងពន្ធគយបានដើរតួនាទីយ៉ាងសំខាន់ដល់ដំណើរការប្រមូលថវិកាជាតិដោយចំណូលជាតិជាង៥០%ជាចំណូលដែលបានមកពីពន្ធគយហើយនៅក្នុងពន្ធគយនេះទៀតការនាំចូលរថយន្តបានដើរតួជាង៤០%នៃថវិកាពន្ធគយសរុប។ដូចនេះយើងអាចមើលឃើញថាពន្ធគយមានសារៈសំខាន់ខ្លាំងណាច់ចំពោះថវិកាជាតិ ប៉ុន្តែមានអាជីវករមួយចំនួនមិនយល់ពីសារៈសំខាន់និងភាពចាំបាច់នៃចំណូលដែលបានមកពីពន្ធគយនេះចំពោះដំណើរការថវិកាជាតិហើយធ្វើការគេពន្ធតាមគ្រប់វិធីដើម្បីតែទទួលបានផលចំណាញខ្ពស់សំរាប់អាជីវកម្មរបស់ខ្លួនឯង។

ការខ្វះខាតធនធានមនុស្សនៅក្នុងជួររាជរដ្ឋាភិបាលនេះធ្វើដំណើរការថវិកាជាបញ្ហាសំរាប់ការអភិវឌ្ឍន៍គម្រោងរដ្ឋដោយធនធានមនុស្សមិនមានសមត្ថភាពគ្រប់គ្រាន់សំរាប់ការទាញយកកញ្ចប់ថវិកាពីរដ្ឋយកទៅអភិវឌ្ឍន៍ ដូចនេះធ្វើអោយថវិកាដែលបានគ្រោងទុកសំរាប់គម្រោងនេះមិនអាចទាញយកមកប្រើឬផ្លាស់ប្តូរបានព្រោះនៅក្នុងដំណើរការថវិការដ្ឋ កញ្ចប់ថវិកាដែលបានរៀបចំរួចហើយសំរាប់មុខចំណាយអ្វីមួយត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់នឹងម៉ត់ចត់សំរាប់មួយឆ្នាំដូចនេះមកថវិកានេះមិនអាចទាញយកទៅអភិវឌ្ឍន៍បានទេកញ្ចប់ថវិកានេះត្រូវតែទុកនៅកន្លែងដដែលវិញ។តាមឯកសារស្រាវជ្រាវសង្ខេបរបស់វិទ្យាស្ថានសភាកម្ពុជាស្តីពីទិដ្ឋភាពទូទៅលើការបែងចែកនិងទូទាត់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ការធ្វើផែនការអភិវឌ្ឍមូលដ្ឋានបានបង្ហាញថារដ្ឋមិនមានសមត្ថភាព និងធនធានមនុស្សគ្រប់គ្រាន់នៅឡើយទេសំរាប់ការទាញយកកញ្ចប់ថវិកាមកប្រើប្រាស់ជាពិសេសគឺរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំថវិកាផ្ទាល់ខ្លួនឯករាជ្យហើយបញ្ហាទាំងអស់នេះមិនអាចសម្រេចបានទេមុនឆ្នាំ២០២៥។ បើយោងតាមទិន្នន័យបឋមពីរតនាជាតិនៅខែមេសាឆ្នាំ២០១៩បានបង្ហាញថារដ្ឋបាលថ្នាក់ជាតិសម្រេចចំណាយសរុបបានត្រឹមតែ២០,១៨%ប៉ុណ្ណោះនៃច្បាប់ថវិកាឆ្នាំ២០១៩ដោយគិតចំណាយចាប់តាំងពីដើមឆ្នាំដល់ខែមេសាឆ្នាំ២០១៩ ហើយធៀបទៅឆ្នាំ២០១៨ដែលមានរយៈស្មើគ្នានេះមានការថយចុះ២,២៨%។ដូចនេះហើយអាចមើលឃើញថារាជរដ្ឋាភិបាលនៅខ្វះខាតធនធានមនុស្សក្នុងការទាញយកកញ្ចប់ថវិកាយកមកចំណាយតាមមុខងារដែលបានកំណត់ដោយច្បាប់នៃឆ្នាំថវិកា ហើយការដែលចំណាយមិនគ្រប់ទៅតាមមុខងារដែលត្រូវចំណាយនេះធ្វើការអភិវឌ្ឍន៍មិនបានគ្រប់ទៅតាមការចំណាយដែរ។បើយើងយោងថាតាមរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្ហាញឧទាហរណ៍ជាក់ស្តែងពីអគ្គនាយកដ្ឋានពន្ធដារដែលជាអង្គភាពនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុដោយសារតែការ

បង្កើតសាខាពន្ធដារនានា នៅតាមខណ្ឌនៃរាជធានីភ្នំពេញបានតម្រូវអោយមានការចែករំលែកធនធានមនុស្សមួយចំនួនធំពីថ្នាក់អគ្គនាយដ្ឋានទៅតាមបណ្តាលសាខាខណ្ឌនានាដែលជាហេតុបណ្តាលអោយមានការខ្វះខាតនូវធនធានមនុស្សនៅក្នុងនាយកដ្ឋានត្រួតពិនិត្យនៃអគ្គនាយកដ្ឋានពន្ធដារ។ ការខ្វះខាតនូវធនធានមនុស្សនេះបានធ្វើអោយមានផលប៉ះពាល់ដល់អវិជ្ជមានចំពោះតួនាទី និងភារកិច្ចស្នូលរបស់នាយកដ្ឋានត្រួតពិនិត្យ។ ទាំងនេះបាននាំអោយការងាររបស់អគ្គនាយកដ្ឋានពន្ធដារមានការថយចុះ ហើយស្តុងដារការងាររបស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុមានកម្រិត។

ការប្រមូលថវិកាចូលជាតិមានសារៈសំខាន់ណាស់សំរាប់ដំណើរការងារ ផែនការ គម្រោងអភិវឌ្ឍន៍ផ្សេងៗរបស់រដ្ឋប៉ុន្តែដំណើរការថវិកាជាតិនេះបែរជាជួបបញ្ហាតិចតួចដូចជាការ ភាពមិនប្រក្រតីពីសំណាក់មន្ត្រីប្រមូលពន្ធ ការគេចពន្ធ កង្វះខាតធនធានមនុស្សក្នុងការទាញយកថវិកាជាតិប៉ុន្តែក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែនបានខិតខំប្រឹងប្រែងក្នុងកែលម្អបញ្ហាដែលជះឥទ្ធផលដល់ដំណើរការថវិកាជាតិអោយបាត់បង់តាមរយៈអភិក្រមទាំង៥ និងបញ្ញត្តិទាំង១០ដើម្បីអោយការងារអភិវឌ្ឍនប្រទេសជាតិកាន់តែរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំ។

## ២.៤. ប្រតិបត្តិការចំណាយ

កិច្ចការប្រតិបត្តិការនៃចំណាយថវិកាជាតិ ត្រូវធ្វើក្នុងរយៈពេលជាកំណត់ច្បាស់លាស់ ហើយត្រូវបញ្ចប់ទាំងស្រុងនៅថ្ងៃទី ៣១ ធ្នូ។ កិច្ចប្រតិបត្តិការនៃការចំណាយថវិកាជាតិនេះ ត្រូវធ្វើតាម ៤ ដំណាក់កាលគឺ៖

ដំណាក់កាលទី ១ចំណាយតាមការភ្ជាប់សន្យា៖គឺជាអំពើគតិយុត្តដែលបង្កើតឲ្យបុគ្គលសាធារណៈមានកាតព្វកិច្ចត្រូវដោះស្រាយក្នុងបន្ទុកថវិកា។គំនិតផ្តើមចំណាយនេះ អាចមកពីការជ្រើសរើសភ្នាក់ងារសាធារណៈឬការចុះហត្ថលេខាលើកិច្ចសន្យារបស់រដ្ឋ។ការសន្យានេះជាការបង្កើតឡើងដោយរដ្ឋដើម្បីធ្វើការកំណត់សម្គាល់មួយថាខ្លួនមានភារកិច្ចទទួលបន្ទុកខុសត្រូវក្នុងបន្ទុកថវិកាមានតែអាណាប័កមួយដែលមានឋានៈអាចធ្វើការសន្យាចំណាយថវិការដ្ឋលើឥណទានដែលអាចវាយតម្លៃបាននិងត្រូវបានអនុញ្ញាតដោយច្បាប់។[៧៤]

ដំណាក់កាលទី២ ការជម្រះបញ្ជី៖ គឺជាការគណនាចំណាយដែលធ្វើឡើងដោយអាណាប័ក។ការជម្រះបញ្ជីមានគោលដៅផ្ទៀងផ្ទាល់ភាពពិតប្រាកដនៃបំណុលនិងបញ្ជប់ទឹកប្រាក់ចំណាយ រីឯកចំនុចសំខាន់នៃការជម្រះបញ្ជី គឺការបញ្ជាក់ពី សេវាដែលបានផ្គត់ផ្គង់គោលការណ៍ទូទៅថាការអនុវត្តមានភាពត្រឹមត្រូវបន្ទាប់ពីសេវាត្រូវបានផ្គត់ផ្គង់ ដូចជាំ បៀវត្សរ៍ ការផ្គត់ផ្គង់ទំនិញ និងសេវា។ល។[៧៥]

[៧៤] សៀវភៅនីតិថវិកា និងពន្ធដាររបស់សាកលវិទ្យាល័យន័រតុនឆ្នាំ២០១៤
[៧៥] សៀវភៅហិរញ្ញវត្ថុសាធារណៈរបស់បណ្ឌិតហង់ ជួនណារ៉ុន

ដំណាក់កាលទី៣ អាណាប័ណ្ណៈគឺជាលិខិតរដ្ឋបាលដែលអនុលោមទៅតាមលទ្ធផលនៃការជម្រះបញ្ជី បង្គាប់ការដល់គណនេយ្យករសាធារណៈឲ្យសងបំណុលរបស់បុគ្គលសាធារណៈដែលជំពាក់គេ។បើនិយាយអោយស្រួលស្តាប់វិញ អាណាប័ណ្ណគឺជាលិខិតដែលធ្វើឡើងដោយអាណាប័កនៅពេលដែលអាណាប័កចង់បានកញ្ចប់ថវិកាពីរដ្ឋយកទៅចំណាយលើមុខងាររបស់ខ្លួនដូចជា បេសកម្ម ផែនការអភិវឌ្ឍន៍ឬចំណាយក្នុងអង្គភាពរបស់អាណាប័កត្រូវធ្វើលិខតិមួយទៅរតនាគារដែលលិខិតនេះហៅថាអាណាប័ណ្ណនេះឯងដោយលិខិតនេះក្នុងគោលបំណងបើកយកថវិកាពីរតនាគារទៅចំណាយ។

ដំណាក់កាលទី៤ ការទូទាត់៖ គឺជាកិច្ចការប្រតិបត្តិសងប្រាក់ទៅឲ្យម្ចាស់បំណុលដោយគណនេយ្យករសាធារណៈ។អង្គភាពគ្រប់គ្រងបំណូលត្រូវបើគណនីសម្រាប់រាល់កម្ចីទាំងអស់និងកត់ត្រារាល់ប្រតិបត្តិការទាំងអស់ដែលពាក់ព័ន្ធនឹងកម្ចីដោយកត់ត្រានូវបរិមាណនៃកម្ចីដែលបានចុះកិច្ចសន្យាការប៉ានស្មានបើផ្តល់ក្នុងឆ្នាំបរិច្ឆេទដែលត្រូវសងដើមនិងការ។រីឯកម្ចីទាំងនេះត្រូវបែងចែកជាប្រភេទជាច្រើនទៅតាមកិចសន្យាដែលបានចុះហើយថវិកាដែលត្រូវសងវិញក៏ត្រូវធ្វើជាកញ្ចប់សំរាប់ប្រភេទនៃកម្ចីនីមួយៗផងដែរ។ការចំណាយថវិកាជាតិ ត្រូវធ្វើឡើង ក្នុងរយៈពេលដែលគេកំណត់ឲ្យចាប់ពីថ្ងៃទី១ មករាដល់ថ្ងៃ ៣១ធ្នូហើយឥណទាននេះមានប្រាក់សម្រាប់ចាយវាយផងដែរ។ប្រសិនបើក្រសួងប្រើអស់ឥណទានរបស់ខ្លួន នៅត្រឹមថ្ងៃទី១៥ ធ្នូក្រសួងនោះមិនអាចបញ្ជាចំណាយបានទៀតទេ។ផ្ទុយទៅវិញប្រសិនបើមិនបានប្រើអស់នូវឥណទានរបស់ខ្លួននៅថ្ងៃទី៣១ ធ្នូនោះទេក្រសួងត្រូវបង្វិលលុយដែលនៅសេសសល់ នោះទៅក្នុងថវិការដ្ឋវិញ ។

## ២.៥. សិទ្ធិអំណាច និងការទទួលខុសត្រូវ

ដើម្បីឲ្យដំណើរការថវិការបស់ជាតិមានការប្រព្រឹត្តទៅរលូននេះមួយផ្នែកនៃភាពរលូនក្នុងដំណើរការថវិការត្រូវទាក់ទងទៅនឹងមានផ្តល់សិទ្ធិអំណាចដល់បុគ្គលមួយចំនួនដែលច្បាប់បានកំណត់ដែលសិទ្ធិនោះបានកំណត់ដោយច្បាប់ព្រោះនៅក្នុងដំណើរការមួយមិនមានការត្រួតពិនិត្យមើលការខុសត្រូវនេះទេដំណើរការនេះនឹងមិនមានភាពរលូននេះទេ រីឯដំណើរការថវិកាក៏ដូចគ្នាចឹងដែរ។មួយវិញទៀតបុគ្គលដែលទទួលបានសិទ្ធិអំណាចដែលកំណត់ដោយច្បាប់ហើយត្រូវមានការទទួលខុសត្រូវក្នុងតួនាទីរបស់ខ្លួនឲ្យបានខ្ពស់។បុគ្គលដែលមានដែលទទួលបានសិទ្ធិដោយច្បាប់ ក្នុងដំណើរការថវិកាជាតិរួមមាន៖

### ២.៥.១. ភារកិច្ចរបស់រដ្ឋមន្រ្តី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចដូចជាទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូល និងចំណាយ ខ្ចីពីគេនិងការឲ្យគេខ្ចីនិងការធានារបស់រដ្ឋដែលត្រូវបានអនុញ្ញាតដោយច្បាប់[៧៦]ការគ្រប់គ្រងចំណូលនិងចំណាយ ខ្ចីពីគេអោយគេខ្ចីរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះគឺជាការរៀបថវិកាជាតិទៅតាម

[៧៦] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា៣៤

ទៅតាមចំណាត់ថ្នាក់ថវិការដ្ឋបាលលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលដោយអោយមានការរៀបចំចំណាយនិងចំណូលទៅតាមជំពូក គណនី អនុគណនីអោយត្រូវ។រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំការអនុវត្តការតាមដាននិងការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមនិងរយៈពេលវែងរបស់ព្រះរាជណាចក្រកម្ពុជា។[៧៧] មិនត្រឹមតែការគ្រប់គ្រង់ទៅលើគោនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសធារណៈ រយៈពេលមធ្យមនិងរយៈពេលវែងនេះទេរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ត្រូវរាយការណ៍ជូនរដ្ឋសភានិងព្រឹទ្ធសភាអំពីនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលព្រមទាំងអំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ននិងព្យាករណ៍សម្រាប់រយៈពេលមធ្យមផងដែរដោយការរាយការណ៍នេះរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរាយការណ៍ពីរដងក្នុងរយៈពេលមួយឆ្នាំគឺនៅពេលដែលរដ្ឋសភានិងព្រឹទ្ធសភាពធ្វើការពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងនៅពាក់កណ្តាលឆ្នាំ។រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏នៅមានតួនាទីមួយផ្សេងទៀតផងដែរគឺការដឹកនាំការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមការគោរពច្បាប់ហិរញ្ញវត្ថុ ព្រមទាំងធានាការត្រួតពិនិត្យជាប្រចាំលើការគ្រប់គ្រងថវិកា។[៧៨]

### ២.៥.២. ភារកិច្ចរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងថវិកានិងត្រួតពិនិត្យការអនុវត្តថវិការបស់ខ្លួនជាពិសេសត្រូវមានគណនេយ្យភាពចំពោះការកំណត់ និងលទ្ធផលនៃការអនុវត្តគោលនយោបាយនៅក្នុងវិស័យរបស់ខ្លួនដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នសាធារណៈនិងអភិបាលគ្រប់ខេត្តរាជធានីត្រូវមកពិភាក្សាការពារគម្រោងថវិការបស់ខ្លួននៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីធ្វើការសម្របសម្រួលគម្រោងចំណូលនិងចំណាយរបស់ខ្លួនអោយសមស្របទៅតាមបទបញ្ញត្តិនៃការណែនាំថវិកាដោយការពិភាក្សានេះក្នុងគោលបំណងកាតបន្ថយចំណាយដែលមិនបានការចោលនិងរកវិធីសាស្ត្រក្នុងការបង្កើតចំណូល។

### ២.៥.៣. ភ្នាក់ងារអនុវត្តថវិកា

ប្រតិបត្តិការហិរញ្ញវត្ថុរបស់ជាតិ និងគណនីពិសេសរបស់ធនាគារជាតិ ត្រូវបានអនុវត្តដោយភ្នាក់ងារប្រភេទគឺ អាណាប័កថវិកា និងគណនេយ្យករសាធារណៈ (ម. ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ឆ្នាំ ២០០៨) ។

[៧៧] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា៣៥

[៧៨] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា ៣៧

### ២.៥.៣.១. អាណាប័កថវិកា

អាណាប័កថវិកាគឺជាភ្នាក់ងារសាធារណៈ ដែលមានសមត្ថកិច្ចបញ្ជាចំណាយនិងចំណូលថវិការដ្ឋ ក្នុងក្របខណ្ឌនៃច្បាប់ហិរញ្ញវត្ថុ ។

### ក.ប្រភេទអាណាប័ក

អាណាប័កមានបីប្រភេទ ដូចជា៖

អាណាប័កដើមខ្សែ៖ គឺជាអ្នកបញ្ជាចំណូលនិងចំណាយថវិកាតាមផ្នែករៀងៗខ្លួនគឺរដ្ឋមន្ត្រីប្រធានស្ថាប័ននិងប្រធានអង្គភាពសាធារណៈ។អាណាប័កដើមខ្សែអាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់កិច្ចការប្រតិបត្តិការហិរញ្ញវត្ថុនៃដែនសមត្ថកិច្ចរបស់ខ្លួន ។

អាណាប័កផ្ទេរសិទ្ធិ៖គឺជាអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ(រាជធានី ខេត្ត)និងប្រធានមន្ទីរជំនាញខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌសម្រាប់កិច្ចការប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាបន្ទាប់ពីយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អាណាប័កជំនួស៖គឺជាប្រភេទមន្ត្រីរាជការដែលត្រូវបាន អាណាប័កដើមខ្សែឬអាណាប័កតាមការប្រទានសិទ្ធិជ្រើសតាំងជំនួសខ្លួនសម្រាប់កិច្ចការប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងពេលដែលខ្លួនអវត្តមានឬមានធុរៈបន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៧៩]។អាណាប័កជំនួសនេះអាចជារដ្ឋលេខាធិការ អភិបាលរងខេត្ត រាជធានី ។

### ខ. សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អាណាប័ក

អាណាប័កទាំងអស់ទាំងអាណាប័កដើមខ្សែនិងអាណាប័កផ្ទេរសិទ្ធមានកាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិការបស់ស្ថាប័នខ្លួន រីឯការប្រមូលចំណូលនិងការអនុវត្តចំណាយត្រូវធ្វើឡើងក្នុងដែនអំណាចរបស់ខ្លួនដោយមានការកំណត់នៃច្បាប់។ទោះជាអាណាប័កមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងលើថវិកាដែលស្ថាប័នរបស់ខ្លួនមានក៏ដោយប៉ុន្តែដោយស្ថិតក្រោមការកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រីមានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយគត់ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេការបោះផ្សាយមូលបត្ររដ្ឋការទទួលហិរញ្ញប្បទានឥតសំណងការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានានិងមានសិទ្ធិក្នុងការអោយប្រាក់គេខ្ចីទាំអក្នុងនិងក្រៅប្រទេស។គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័នប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិឬមន្ត្រីសាធារណៈណាមួយដែលទទួលបានសិទ្ធិជាអាណាប័កទោះជា អាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធក៏ដោយក៏គ្មានសិទ្ធិក្នុងការអោយប្រាក់គេខ្ចី ឬខ្ចីប្រាក់ពីគេឬចេញជាលិខិតធានាឬក៏ធ្វើទង្វើណាផ្សេងៗទៀត

[៧៩] ច្បាប់ស្ដីពីហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា ៦៣និង៦៤

ដោយផ្ទាល់ឬដោយប្រយោលដែលអាចនាំអោយកើតមាននូវបំណុលឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀតដោយផ្ទាល់ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។[៨០]អាណាប័កទាំងអស់ទាំងអាណាប័កដើមខ្សែនិងអាណាប័កផ្ទេរសិទ្ធិគ្មានសិទ្ធិក្នុងការរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេឬបំណុលដែលគេជំពាក់រដ្ឋទេការរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេ ឬបំណុលដែលគេជំពាក់រដ្ឋនេះស្ថិតនៅក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុនិងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រីមានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយគត់ដែលមានសិទ្ធិហើយការរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេឬបំណុលដែលគេជំពាក់រដ្ឋនេះត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។

### ២.៥.៣.២.គណនេយ្យករសាធារណៈ

គណនេយ្យករ គឺជាអ្នកធ្វើការទូទាត់ថវិកានិងធ្វើបេឡានិច្ឆ័យ។គណនេយ្យករណាបម្រើការងារក្នុងវិស័យសាធារណៈហៅថាគណនេយ្យករសាធារណៈឯគណនេយ្យករណាបម្រើការងារក្នុងវិស័យឯកជនហៅថាគណនេយ្យករឯកជន។គណនេយ្យករសាធារណៈត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយធ្វើសច្ចាប្រណិធានមុនចូលកាន់ដំណែងជាគណនេយ្យករសាធារណៈ។

គណនេយ្យករសាធារណៈជាមន្ត្រីសាធារណៈដែលទទួលខុសត្រូវនិងប្រមុខឡចំណូលដែលអាណាប័កបានប្រគល់អោយប្រមូលឥណទេយ្យដែលសង្កេតឃើញតាមកិច្ចសន្យាប្រមូលប័ត្រកម្មសិទ្ធិឬប្រមូលប័ត្រផ្សេងៗទៀតដែលគណនេយ្យករត្រូវធានារក្សាទុកដាក់ព្រមទាំងបញ្ចូលក្នុងបេឡានូវប្រាក់ពន្ធដារបង់ដល់ដៃនិងចំណូលគ្រប់ប្រភេទទាំងអស់ដែលរដ្ឋមាននីតិសម្បទាទទួលទូទាត់ចំណាយតាមបញ្ជាអាណាប័កដែលនៅអមជាមួយ ការពារនិងរក្សាទុកនូវមូលនិធី តម្លៃនានារបស់រដ្ឋនិងគ្រឹះស្ថានសាធារណៈផ្សេងទៀតកាន់កាប់មូលនិធីនិងចលនាគណនីប្រាក់ទំនេរ រក្សាទុកដាក់លិខិតយុត្តិកម្ម នៃកិច្ចប្រតិបត្តិការ និងឯកសារគណនេយ្យកាន់គណនេយ្យតាមដំណែងដែលខ្លួនដឹកនាំ។[៨១]មុនពេលដែលគណនេយ្យករសាធារណៈគ្រប់រូបចូលបំពេញការក្នុងស្ថាប័នរដ្ឋណាមួយគណនេយ្យករសាធារណៈត្រូវធ្វើសច្ចាប្រណិធានហើយគណនេយ្យករសាធារណៈទាំងនេះត្រូវតែងតាំងឡើងសំរាប់អមអាណាប័កហើយក្នុងករណីខ្លះអមគណនេយ្យករសាធារណៈដ៏ទៃទៀតដែលខ្លួនមានការទាក់ទង។គណនេយ្យសាធារណៈត្រូវផ្តល់របាយការណ៍យ៉ាងតិចមួយឆ្នាំម្តង។[៨២]គណនេយ្យសាធារណៈអាចប្រគល់សិទ្ធិទៅអោយអាជ្ញានុការីមួយរូប ឬច្រើនរូបដែលមានលក្ខណៈសម្បត្តិធ្វើការក្នុងនាមខ្លួន និងក្រោមការទទួលខុសត្រូវរបស់ខ្លួន។

---

[៨០] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា៧៦

[៨១] អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនាំគណនេយ្យសាធារណៈមាត្រា១២

[៨២] អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនាំគណនេយ្យសាធារណៈមាត្រា១៥

**ក.ភារកិច្ចនៃគណនេយ្យករសាធារណៈ**

គណនេយ្យករសាធារណៈត្រូវមានភារកិច្ចបីគឺ៖

ទី១ ក្នុងវិស័យចំណូល ត្រួតពិនិត្យភាពត្រឹមត្រូវ នៃដីកាចំណូល

ទី២ ក្នុងវិស័យចំណាយត្រួតពិនិត្យរួមមាន៖ (ក)លក្ខណៈសម្បត្តិរបស់អាណាប័ក (ខ)សំណល់ទំនេរនៃឥណទាន (គ)ការកំណត់ត្រឹមត្រូវពិតប្រាកដ ខ្ទង់ចំណាយតាមជំពូកដែលពាក់ព័ន្ធដល់រូបធាតុនិងមុខសញ្ញារបស់វា (ឃ)ការបញ្ជាក់ភាពត្រឹមត្រូវអំពីសេវាដែលបានធ្វើហើយនិងភាពប្រាកដប្រជានៃការគណនាជម្រះឥណទេយ្យ (ង)មានការបញ្ជាក់ទិដ្ឋការរបស់អភិបាលហិរញ្ញវត្ថុ លើកិច្ចសន្យា និងអាណត្តិ (ច)ផលិតកម្មនៃយុត្តិកម្មឥណទេយ្យ (ឆ)អនុវត្តវិធាន បទបញ្ញា ស្តីពីអាជ្ញាយុកាល និងការប្រាសចាកសិទ្ធិនៃឥណទេយ្យ ។

ទី៣ ក្នុងវិស័យបេតិកភណ្ឌ ត្រួតពិនិត្យរួមមាន៖ (ក)ការរក្សានូវសិទ្ធិ បុព្វសិទ្ធិនិងនិក្ខេម (ហ៊ីប៉ូតែក) (ខ)ការរក្សាទុកដាក់ទ្រព្យសម្បត្តិដែលមានចែងក្នុងគណនេយ្យរូបធាតុ។

**ខ.ប្រភេទនៃគណនេយ្យករសាធារណៈ**

គណនេយ្យករសាធារណៈមានពីរប្រភេទគឺ គណនេយ្យករសាធារណៈផ្ទាល់របស់រតនាគារ និងគណនេយ្យករសាធារណៈរដ្ឋបាលហិរញ្ញវត្ថុ ។ ប្រភេទទី១គឺ គណនេយ្យករសាធារណៈផ្ទាល់របស់រតនាគារ យើងអាចចាប់ទុកថាជាគណនេយ្យករសាធារណៈផ្ទាល់របស់រតនាគារបានលុះត្រាតែជាគណនេយ្យករនេះជាគណនេយ្យកររតនាគារជាតិដែលជាគណនេយ្យកណ្តាលនៃរតនាគារនៅភ្នំពេញហើយមានលក្ខណៈសម្បត្តិជាគណនេយ្យករដើមខ្សែ។គណនេយ្យករដើមខ្សែអនុវត្តកិច្ចប្រតិបត្តិការរបស់អាណាប័កដើមខ្សែនិងប្រមូលផ្តុំនូវរាល់កិច្ចប្រតិបត្តិការដែលធ្វើឡើងដោយគណនេយ្យកររតនាគារខេត្តក្រុងនិងគណនេយ្យករនៃអង្គការរដ្ឋបាលហិរញ្ញវត្ថុ។គណនេយ្យករដើមខ្សែនេះអនុវត្តនិងប្រមូលផ្តុំកិច្ចប្រតិបត្តិការរតនៈវត្ថុរបស់រដ្ឋជាមួយវិទ្យាស្ថានបោះប្រាក់និក្ខិត្តកររបស់រតនាគារ ដែលមានលក្ខណៈជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។គណនេយ្យនេះបង្កើតឡើងនូវគណនីប្រចាំឆ្នាំរបស់រដ្ឋក្រោមពេលដែលប្រមូលផ្តុំកិច្ចប្រតិបត្តិការថវិកាទូទៅនិងគណនីពិសេស។[៩៣]រីឯគណនេយ្យកររងវិញ គឺជាគណនេយ្យកររបស់រតនាគារខេត្ត - ក្រុងមានភារៈកិច្ចអនុវត្តកិច្ចប្រតិបត្តិការរបស់អាណាប័កតាមការប្រទានសិទ្ធិ នៅតាមបណ្តលខេត្ត-ក្រុងរបស់ខ្លួនកាន់កាប់។[៩៤]ក្រោមអំណាចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគណនេយ្យករផ្ទាល់របស់រតនាគារដើមខ្សែឬរងត្រូវអនុវត្តរាល់ប្រតិបត្តិការចំណូលឬចំណាយថវិកាទូទៅនិងគណនីពិសេសរបស់រតនាគាររាល់កិច្ចការប្រតិបត្តិការរតនៈវត្ថុនិងជាទូទៅរាល់កិច្ចការប្រតិបត្តិការហិរញ្ញវត្ថុដែលរដ្ឋទទួលបន្ទុក លើកលែងតែកិច្ចសហប្រតិបត្តិការណា ដែលមានការអនុវត្តត្រូវបាន

[៩៣] អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនាំគណនេយ្យសាធារណៈមាត្រា២០

[៩៤] អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនាំគណនេយ្យសាធារណៈមាត្រា២១

ប្រគល់ឲ្យគណនេយ្យករសាធារណៈផ្សេងទៀត ។[៥៩]រីឯវិញប្រភេទទី២គឺគណនេយ្យករសាធារណៈរដ្ឋបាលហិរញ្ញវត្ថុមានភារកិច្ចប្រមូលពន្ធដារ ពន្ធគយ បំណុលពន្ធ ផលិតផលនៃទ្រព្យសម្បត្តិរដ្ឋ និងចំណូលផ្សេងៗទៀត ព្រមទាំងការពិន័យសារពើពន្ធ និងសោហ៊ុយទារប្រាក់ពន្ធ និងសោហ៊ុយតុលាការដែលពាក់ព័ន្ធ ក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់និងបទបញ្ញារួចបង់ចូលទៅរតនាគារជាតិនូវប្រាក់ចំណូលដែលខ្លួនប្រមូលបានតាមការកំណត់របស់សារាចរ។គណនេយ្យករសាធារណៈរដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ មានដូចជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ២.៥.៤. នីតិវិធីត្រួតពិនិត្យថវិកា

នីតិវិធីនៃការត្រួតពិនិត្យថវិកាធ្វើឡើងទាំងក្នុងពេលអនុវត្តថវិកានិងនៅក្រោយពេលអនុវត្តថវិកា ដើម្បីតាមដានឲ្យដឹងថា ការប្រមូលចំណូលថវិកាជាតិរបស់អង្គភាពរដ្ឋ និងការចំណាយរបស់អង្គភាពរដ្ឋនីមួយៗបានធ្វើទៅតាមគម្រោងថវិកាដែលបានគ្រោងទុកដែរឬទេ? ហើយបើសិនការអនុវត្តមិនបានធ្វើទៅតាមអ្វីដែលបានគ្រោទុកក្នុងគម្រោងថវិការបស់រដ្ឋដេលមានការអនុម័តរួចហើយតើត្រូវមានទណ្ឌកម្មបែបណា?ការត្រួតពិនិត្យនេះមានលក្ខណៈផ្ទៃក្នុង និងផ្ទៃក្រៅ ។

#### ២.៥.៤.១. ការត្រួតពិនិត្យផ្ទៃក្នុង

ការត្រួតពិនិត្យផ្ទៃក្នុង ជាបន្ទុករបស់អំណាចឋានានុក្រមនៅក្នុងក្រសួងស្ថាប័ននីមួយៗ ឬបន្ទុកពិសេសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការត្រួតពិនិត្យនោះរួមមាន៖ (១) ការត្រួតពិនិត្យដោយអាណាប័កដើមខ្សែ (ខ)ការត្រួតពិនិត្យដោយអគ្គគណនេយ្យករ (គ) ការត្រួតពិនិត្យដោយអភិបាលហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចទទួលខុសត្រូវ ក្នុងការណែនាំអំពីការរៀបចំក្របខណ្ឌកិច្ចប្រតិបត្តិការនៃសវនកម្មផ្ទៃក្នុង និងធ្វើអធិការកិច្ចហិរញ្ញវត្ថុដល់រដ្ឋមន្ត្រី ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការត្រួតពិនិត្យផ្ទៃក្នុង ឬសវនកម្មផ្ទៃក្នុង ត្រូវបានធ្វើឡើងដោយសវនករនៅតាមបណ្តាស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ ។ អង្គភាពនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័នថ្នាក់ជាតិ ពោលគឺ តាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈស្របតាមមាត្រា ៤១ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០ ។

[៥៩] អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនាំគណនេយ្យសាធារណៈមាត្រា១៩

### ២.៥.៤.២. ការត្រួតពិនិត្យផ្ទៃក្រៅ

ការត្រួតពិនិត្យផ្ទៃក្រៅ គឺជាការពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចការបញ្ជីការគណនេយ្យ ប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រង ដោយអនុលោមតាមមាត្រដ្ឋាននៃការធ្វើសវនកម្មទូទៅ និងតាមមាត្រដ្ឋាននៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាល។[៨៦]

ការត្រួតពិនិត្យផ្ទៃក្រៅជាបន្ទុករបស់សភាជាតិ និងអាជ្ញាធរសវនកម្មជាតិ ។

ក.ការត្រួតពិនិត្យដោយសភាជាតិ

ការត្រួតពិនិត្យរបស់សភាមានពីរគឺ(១)ការត្រួតពិនិត្យថវិកាពេលកំពុងអនុវត្ត (២)ការត្រួតពិនិត្យថវិកាក្រោយពេលអនុវត្ត។ការត្រួតពិនិត្យថវិកាពេលកំពុងអនុវត្តរបស់សភាជាតិ អាចធ្វើទៅបានដោយការរាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលធ្វើជារបាយការណ៍ទៅអោយសភាជាតិ២ដងក្នុងមួយឆ្នាំ រីឯការត្រួតពិនិត្យថវិកាក្រោយពេលអនុវត្តរបស់សភាគឺជាការត្រួតពិនិត្យលើការប្រព្រឹត្តទៅនៃថវិកាតាមរយៈការអនុម័តច្បាប់ទូទាត់ថវិកាដោយការត្រួតពិនិត្យនេះត្រូវពិនិត្យទៅលើការកត់ត្រាចំនួនទឹកប្រាក់ដែលបានប្រមូលពីប្រភពថវិកានិងចំនួនទឹកប្រាក់ដែលបានចំណាយរបស់អាណាប័ក។

ខ.ការត្រួតពិនិត្យដោយអាជ្ញាធរសវនកម្មជាតិ

អាជ្ញាធរសវនកម្មជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ដែលជាស្ថាប័នសាធារណៈឯករាជ្យ ហើយត្រូវធ្វើរបាយការសវនកម្មជូនសភាជាតិផ្ទាល់។អាជ្ញាធរសវនកម្មជាតិនេះមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ។

អាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មក្នុងក្របខណ្ឌដែលមានចែងពីមាត្រា៥ ដល់មាត្រា១២ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០ ។

## ២.៦.គំហើញទាក់ទងការប្រមូលពន្ធ

ប្រភពចំណូលថវិកាជាតិជាកត្តាដ៏សំខាន់ក្នុងដំណើរការងាររបស់រដ្ឋទាំងអស់ដែលទាមទារប្រសិទ្ធភាពជាចំបាច់។តាមសេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលពន្ធប្រចាំខែមករាឆ្នាំ២០១៩ព្រមទាំងការកំណត់ទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយដ្ឋានពន្ធដារបានបង្ហាញថាឲ្យឃើញថាប្រភពចំណូលថវិកាជាតិមានការកើនឡើង៣៦,៨៥%ធៀបទៅនឹងឆ្នាំ២០១៨ ដែលស្មើនឹង៨,៥២%នៃផែនការថវិកាជាតិ។ការប្រមូលពន្ធកើនឡើងនេះបង្ហាញពីការរីកចម្រើននៃម៉ាក្រូសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ ក៏ដូចជាការកើនឡើងនៃថវិកាជាតិ។កញ្ចប់ថវិកាជាតិរីកធំធ្វើថវិកានេះយកទៅវិភាជន៍បានកាន់ច្រើនលើ

[៨៦] ច្បាប់សវនកម្មឆ្នាំ២០០០ មាត្រា៤

គ្រប់វិស័យរបស់ជាតិ និយាយជារួមគឺដំណើរការថវិកាជាតិមានការកើនឡើងកាន់ច្រើននឹងធ្វើអោយដំណើរការងារនិងការអភិវឌ្ឍន៍គ្រប់វិស័យរបស់រាជរដ្ឋាភិបាលកាន់តែមានការរីកចំរើនដូចគ្នា។

រីឯការបូកសរុបលទ្ធផលពន្ធគយវិញនៅថ្ងៃព្រហស្បតិ៍ទី២៧ខែកុម្ភៈឆ្នាំ២០២០អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០១៩ដោយក្នុងនេះលទ្ធផលប្រមូលពន្ធបានកើនឡើង៣០%ធៀបទៅនឹងឆ្នាំ២០១៨ ហើយលើសផែនការដែលរដ្ឋបានកំណត់ក្នុងច្បាប់ប្រមាណ៤២,៧%។នៅក្នុងពន្ធគយចំណូលតាមប្រភពពន្ធសំខាន់ៗមានការកើនឡើងដូចជាពន្ធនាំចូលកើនឡើង៣០,៧%អាករពិសេសកើនឡើង៣៣.៦% និងអាករលើតម្លៃបន្ថែមកើនឡើង ២៨,៨%។ បើតាមការពិនិត្យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានបង្ហាញថា នៅក្នុងចំណូលដែលមានការកើនឡើងនេះចំណូលតាមក្រុមទំនិញយានយន្តនិងគ្រឿងចក្របន្តជាប្រភពចំណូលដែលសំខាន់ដោយគ្រប់ដណ្តប់ប្រមាណ ៥២,៧%នៃចំណូលសរុប។

ក្រៅពីការកើនឡើងនូវចំណូលដែលទទួលបានពីពន្ធចំណូលមិនមែនសារពើពន្ធក៏មានការកើនឡើងដែរប៉ុន្តែមានភាពយឺតជាងចំណូលផ្សេងទៀតយោងតាមសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងថាចំណូលមិនមែនសារពើពន្ធមានការកើនឡើងត្រឹមតែ១០,៤%តែប៉ុណ្ណោះហើយភាគច្រើននៃចំណូលមិនមែនសារពើពន្ធនេះបានមកពីការជួលដីរដ្ឋចំណែកឯគណនីមួយចំនួននៅក្នុងជំពូកចំណូលមិនមែនសារពើពន្ធសឹងតែមិនទទួលបានចំណូលសោះ។ ទោះជាស្ថិតនៅក្នុងស្ថានភាពនៃការកើនឡើងនូវចំណូលរដ្ឋបែបនេះមែនតែក៏មានការបាត់បង់ថវិកាជាតិផងដែលការបាត់បង់នេះជាបញ្ហាប្រឈមដល់ដំណើរការថវិការដ្ឋដែលសព្វថ្ងៃរាជរដ្ឋាភិបាលកំពុងតែប្រឹតប្រែងដោះស្រាយ មានដូចជាការគេចពន្ធ ការស៊ីសំនូកក្នុងជួរមន្ត្រីប្រមូលពន្ធ។ការគេចពន្ធកើងឡើងទៅតាមកន្លែងដែលរាជរដ្ឋាភិបាលមិនអាចគ្រប់គ្រងបានដូចជាការនាំចូលទំនិញតាមច្រកព្រំដែលនៃប្រទេសកម្ពុជាជាពិសេសតាមផ្លូវទឹកដែលរាជរដ្ឋាភិបាលមិនមានឧបករណ៍គ្រប់គ្រាន់សំរាប់តាមចាប់បើតាមការលើកឡើងរបស់អគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករកម្ពុជា។ចំណែកការស៊ីសំណូកវិញគឺកើតឡើងតាមរយៈការធ្វើបាបរបស់មន្ត្រីប្រមូលពន្ធទៅលើអ្នកបង់ពន្ធដូចជាប្រាប់ថាឯកសារបង់ពន្ធខុសឬធ្វើអោយការបង់ពន្ធមានភាពយឺតយ៉ាវជាងធម្មតាឬផ្តល់ឯកសារបង់ពន្ធច្រើនពេកទៅដល់អ្នកបង់ពន្ធដែលឯកសារទាំងនេះមានមួយចំនួនអ្នកបង់ពន្ធមិនបានស្គាល់បើតាមការលើកឡើងរបស់ក្រុមអាជីវករមួយចំនួនប្រាប់ទៅIFCMPDFបាននិយាយថាខ្លួនត្រូវបំពេញឯកសារខុសៗគ្នារហូតដល់២២ឯកសារសំរាប់អ្នកនាំចូលវត្ថុធាតុដើមធម្មតាចំណែកឯអ្នកនាំចូលវត្ថុធាតុដើមដូចជាសំរាប់ការធ្វើបារី ស្រាជាដើមត្រូវបំពេញឯកសាររហូតដល់៤៥ឯកសារផ្សេងគ្នាដែលក្នុងនេះក្រុមអាជីវករមិនស្គាល់ឯកសារទាំងនេះអស់ផង។

ក្រៅពីប្រភពចំណូលជាតិនៅមានចំណាយជាតិមួយទៀតដែលជាចំនុចសំខាន់ផងដែរក្នុងដំណើរការថវិកាជាតិព្រោះបើការចំណាយរបស់រាជរដ្ឋាភិបាលមិនចំគោលដៅ និងមុខចំណាយច្បាស់លាស់ទេធ្វើអោយដំណើរការថវិកាជាតិមិនមានប្រសិទ្ធភាព និងមិនអាចទទួលបានលទ្ធផលខ្ពស់ចេញពីការងារផងដែរប៉ុន្តែបើយើងយោងទៅតាមសៀវភៅសមិទ្ធផល និងទិសដៅនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង់ហិរញ្ញវត្ថុសាធារណៈរយៈពេល៥ឆ្នាំរបស់គណៈកម្មធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុចេញផ្សាយនៅឆ្នាំ២០១៨បានអោយដឹងថា រាជរដ្ឋាភិបាលបានធ្វើអោយថវិកាកាន់តែមានភាពជឿទុកចិត្តដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈដោយសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧%ចំណូលមានការកើនឡើងក្នុងចន្លោះ១៥%-២០%ក្នុងរយៈពេល៥ឆ្នាំចុងក្រោយហើយថវិកាចំណាយសំរាប់ក្រសួង ស្ថាប័នរដ្ឋទាំងអស់មានការកើនឡើង១,៨ដងរាប់ចាប់ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៧ការគ្រប់គ្រងសាច់ប្រាក់មានប្រសិទ្ធភាពដោយគ្មានបំណុលកកស្ទះដោយក្នុងនោះបំណុលសាធារណៈត្រូវបានគ្រប់គ្រងត្រឹមត្រូវនិងនៅមានសមិទ្ធផលផ្សេងៗទៀត។ ការសម្រេចបានសមិទ្ធផលរបស់រាជរដ្ឋាភិបាលនេះបង្ហាញអោយយើងឃើញថាការងាររបស់រាជរដ្ឋាភិបាលពិតជាបានចំណាយចំគោលដៅនិងច្បាស់លាស់ទើបអាចធ្វើអោយការងាររបស់រាជរដ្ឋាភិបាលសម្រេចចេញមកនូវផ្លែផ្កាយ៉ាងល្អចំណែកឯគុណភាពការងារក៏កាន់តែរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំ។បើយោងតាមទិន្នន័យដែលបានបង្ហាញឃើញថាការចំណាយរបស់រាជរដ្ឋាភិបាលមានភាពល្អប្រសើរជារៀងរាល់ឆ្នាំព្រោះតែការសម្រេចបានសមិទ្ធផលការងារជាច្រើនប៉ុន្តែក៏នៅមានបញ្ហាប្រឈមសំរាប់រាជរដ្ឋាភិបាលផងដែរព្រោះតែការខ្វះខាតធនធានមនុស្សនៅក្នុងរាជរដ្ឋភិបាលមិនទាន់មានគ្រប់គ្រាន់សំរាប់ទាញយកកញ្ចប់ថវិកាយកទៅធ្វើការចំណាយសំរាប់ការអភិវឌ្ឍន៍បាន។ការខ្វះខាតធនធានមនុស្សនេះតែងតែកើតមានឡើងចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិបើតាមការលើកឡើងរបស់វិទ្យាស្ថានសភាកម្ពុជានៅក្នុងឯកសារស្រាវជ្រាវសង្ខេបស្តីពីទិដ្ឋភាពទូទៅលើការបែងចែកនិងទូទាត់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ការធ្វើផែនការអភិវឌ្ឍមូលដ្ឋាន។

# ជំពូក៣

# ពិភាក្សាលើដំណើរការថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជា

## ៣.១.ពិភាក្សាលើប្រសិទ្ធភាពប្រភពចំណូលថវិកា

ការសិក្សាពីដំណើរការថវិកា គឺសិក្សាពីចំណូលនិងចំណាយរបស់រដ្ឋ។បើនិយាយពីប្រភពចំណូលរបស់រដ្ឋ គឺមានប្រភពពីការប្រមូលពន្ធ និងពន្ធគយ។ តាមទ្រឹស្តីការប្រមូលពន្ធត្រូវប្រមូលទៅតាមបញ្ញត្តិរបស់ច្បាប់បានកំណត់ បើមិនមានការចែងកំណត់ពន្ធក្នុងច្បាប់ទេ មិនមានការយកពន្ធឡើយ។ផ្ទុយទៅវិញដោយសារការអនុវត្តច្បាប់ក្នុងការប្រមូលពន្ធនៅមានកម្រិត ដែលមានការខ្វះខាតបន្តិចបន្តួចដែលនាំឲ្យបាត់ថវិកាមួយចំនួនតូច ដូចជា ការគេចពន្ធលើទំនិញដែលមានពន្ធខ្ពស់ ឬជាប់អាករខ្ពស់ដោយមានក្រុមអាជីវករមួយចំនួនធ្វើការនាំចូលទំនិរតាមច្រកព្រំដែនដែលរាជរដ្ឋាភិបាលពិបាកក្នុងការពារ ការស៊ីសំណូករបស់មន្ត្រីប្រមូលពន្ធ ដោយយកឯកសារជាច្រើនទៅអោយបង់ពន្ធធ្វើការបំពេញដែលនាំអោយការបង់លុយជាមួយបុគ្គលមានភាពងាយស្រួល និងលឿនជាងបង់លុយចូលរដ្ឋ ។ ប៉ុន្តែក៏លទ្ធផលនៃការប្រមូលពន្ធបានកើនឡើងជារៀងរាល់ឆ្នាំ។ ជាក់ស្តែង ដូចជា ពន្ធនាំចូលកើនឡើង ៣០,៧% អាករពិសេសកើនឡើង៣៣.៦% និងអាករលើតម្លៃបន្ថែមកើនឡើង២៨,៨%។

ចំពោះគយវិញ ការប្រមូលពន្ធត្រូវធ្វើក្នុងដែនគយដែលមានចែងក្នុងច្បាប់ស្តីពីគយមាត្រា២ ហើយការប្រមូលពន្ធគយនេះ ត្រូវធ្វើឡើងដោយស្មើភាពដោយឥតយោគយល់ចំពោះបុគ្គលណាឡើយ និងមិនមានផ្តល់ជាឯកសិទ្ធិ ឬអោយរួចផុតការបង់ពន្ធនាំចេញនាំចូលក្នុងនាមរដ្ឋដូចគ្នា អោយតែទំនិញទាំងនាំចេញ និងនាំចូលដែលបានឆ្លងកាត់ដែនគយ ទាំងដែនដី ដែនទឹក ដែនអាកាស រាជរដ្ឋាភិបាលជាពិសេសគឺមន្ត្រីគយមានសិទ្ធិអនុវត្តការប្រមូលពន្ធ។ ទំនិញដែលនាំចេញ និងនាំចូលទាំងអស់ដែលបានឆ្លងកាត់ដែនគយត្រូវរាយការណ៍ទៅការិយាល័យគយ ឬទីកន្លែងផ្សេងទៀតទៅតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ។ប៉ុន្តែក៏មានទំនិញខ្លះត្រូវបានលើកលែងពន្ធគយផងដែរ លុះត្រាតែមានជាអនុក្រឹត្យដោយយោងតាមកិច្ចព្រមព្រៀងអន្តរជាតិណាមួយដែលប្រទេសកម្ពុជាបានលុះជាប្រទេសដ៏ទៃទៀត។ បើមើលតាមការប្រមូលពន្ធគយជាក់ស្តែងវិញ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានបែងចែពន្ធគយជាបី គឺទំនិញចំរុះ ទំនិញយានយន្ត និងទំនិញបែបជាថាមពល(ដូចជា ប្រេង សាំង អគ្គិសនីជាដើម)។ចំពោះទំនិញចំរុះបានដើរតួប្រហែលជា៣០%នៃថវិកាដែលប្រមូលបានពីពន្ធគយ ទំនិញយានយន្តបានដើរតួប្រហែលជា៤០%នៃថវិកាសរុបរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាប្រមូលបាន រីឯទំនិញបែបជាថាមពលអាចប្រមូលចន្លោះពី២១%ទៅ២៤%ក្រៅពីនេះមានប្រភេទទំនិញសំរាប់សំណង់មានការនាំចូលខ្លះដែលតែបានដើរតួប្រហែល៤%ទៅ៥%ប៉ុណ្ណោះ ចំពោះទំនិញសំរាប់សំណង់មិនមានការចាប់ជាចំណាក់ថ្នាក់ព្រោះនៅប្រទេសកម្ពុជាមានរោងចក្រខ្លះដែលអាចផលិត ដែកស៊ីម៉ងជា

ដើម។ ប៉ុន្តែដែនគយមានទំហំធំខ្លាំងពេក បូករួមទាំងរាជរដ្ឋាភិបាលមិនមានឧបករណ៍សំរាប់គ្រប់គ្រង់ដែនអំណាយរបស់ខ្លួនធ្វើអោយមានការគេចពន្ធ តាមច្រកព្រំដែនគយមួយចំនួនកើតឡើង។

ក្រៅពីប្រភពចំណូលសំខាន់ទាំងពីរមានពន្ធដា និងពន្ធគយ ក៏មានចំណូលមួយប្រភេទទៀតដែលបានដើរតួជាប្រភពចំនូលជាតិដែលគឺ ប្រភពចំណូលបន្ទាប់បន្សំ ឬអាចហៅបានម្យ៉ាងទៀតគឺប្រភពចំណូលដែលរដ្ឋទទួលប្រមូលបានក្រៅពីពន្ធ។យោងតាមសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងថាចំណូលមិនមែនសារពើពន្ធមានការកើនឡើងត្រឹមតែ១០,៤%តែប៉ុណ្ណោះហើយភាគច្រើននៃចំណូលមិនមែនសារពើពន្ធនេះបានមកពីការជួលដីរដ្ឋ ការធ្វើអាជីវកម្មរបស់រដ្ឋ ហើយមានគណនីចំណូលមួយចំនួនរបស់រដ្ឋសឹងតែមិនមានចំណូលសោះពេញមួយឆ្នាំ។

ដោយឡែកនៅចុងឆ្នាំ២០១៩ ដើមឆ្នាំ២០២០វិញ ការប្រមូលចំណូលរដ្ឋមានការធ្លាក់ចុះព្រោះតែវិបិត្តសេដ្ឋកិច្ចដែលមានការប៉ះទង្គិចធ្ងន់ធ្ងរដោយជំងឺកូវីដ-១៩។ ការរីករាលដាលរបស់ជំងឺកូវីដ-១៩នេះធ្វើអោយមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាមានការរង្គោះរង្គើ ធ្វើអោយវិស័យមួយចំនួនដែលធ្លាប់ជាកត្តាកំណើនសេដ្ឋកិច្ចជាតិមានការបាត់បង់ចំណូលមួយភាគ អត្រាអត់ការងារធ្វើមានការកើនឡើង ការបាត់បង់ចំណូល និងធ្លាក់ចូលក្នុងភាពក្រីក្រក៏មានការកើនឡើងដែរ ដែលនេះនឹងនាំមកនូវបញ្ហាប្រឈមដល់ការប្រមូលថវិកាចូលជាតិ។បើតាមការលើកឡើងជាក់ស្តែងរបស់ លោក កាំង ម៉ូនីកា អគ្គលេខាអិការនៃសមាគមរោងចក្រកាត់ដេរកម្ពុជាទៅអោយអ្នកសារព័ត៌មានថា គិតចាប់តាំងពីខែមេសាឆ្នាំ២០២០ មករោងចក្រកាត់ដេរមួយចំនួនមិនអាចនាំទំនិញចេញហើយរោងចក្រចំណែកឯរោងចក្រមួយចំនួនទៀតធ្លាក់ចុះនូវការនាំចេញយ៉ាងខ្លាំង រីឯការលើកឡើងរបស់លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រាប់ទៅ ព័ត៌មានរ៉យទ័រថា មានរោងចក្រចំនួន៩១ ដែលមានទីតាំងនៅតាមខេត្ត និងក្រុងនៃប្រទេសកម្ពុជា និងបុគ្គលិកដែលបំរើការងារក្នុងរោងចក្រចំនួន៦១៥០០ នាក់ត្រូវបានព្យួរការងារ ដែលកត្តាទាំងនេះហើយដែលធ្វើអោយបាត់បង់ពន្ធមួយដូចជាពន្ធ លើប្រាក់បៀវត្ស ពន្ធលើការនាំចេញ និងនាំចូលជាដើមដែលពន្ធទាំងអស់នេះជាប្រភពចំនូលរបស់រដ្ឋ។ ប៉ុន្តែទោះជាមានការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយក៏រាជរដ្ឋាភិបាលបានសម្រេចការប្រមូលចំនួល១៣១%នៃច្បាប់ថវិកាជាតិឆ្នាំ២០១៩ បើយោងតាមសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយដៃគូអភិវឌ្ឍន៍ឆ្នាំ២០២០។

### ៣.២.ពិភាក្សាលើប្រសិទ្ធភាពបែងចែកថវិកា

ការបែងចែកថវិការបស់រដ្ឋ គឺដើម្បីយកទៅអនុវត្តលើការងារ បេសកម្ម ផែនការ គម្រោងផ្សេងៗដែលស្ថិតនៅក្នុងគោលបំណងចង់ទទួលបានមកវិញនូវការអភិវឌ្ឍន៍សំរាប់ជាតិ។ ប៉ុន្តែការបែងចែកថវិកាជាតិនេះបែរ

ជាមានភាពពិបាកជាតិការប្រមូលថវិកាជាតិទៅ ដោយភាពពិបាកនេះធ្វើអោយដំណើរការថវិកាបាត់បង់ប្រសិទ្ធភាពទៅតាមនឹងដែរ។ ការបែងចែកថវិកាជាតិនេះ ធ្វើអោយដំណើរការងាររបស់រាជរដ្ឋាភិបាលមានភាពរលូនទៅមុខបានយ៉ាងល្អ ដែលសម្រេចបាននូវ សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសង្គមបើតាមការលើកឡើងរបស់រាជរដ្ឋាភិបាលបានបង្ហាញថា អត្រាបទល្មើខុសច្បាប់មានការធ្លាក់ចុះ១៤% សណ្តាប់ធ្នាប់សាធារណៈក្នុងសង្គមទាំងមូលបានយ៉ាងល្អ។ ប៉ុន្តែទោះជាការបែងចែកថវិកាមានភាពល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ ក៏នៅតែមានបញ្ហាដែលបានកើតឡើងនៅក្នុងដំណើរការថវិកា ដែលធ្វើអោយប្រសិទ្ធភាពនៃការបែងចែកថវិកាមិនទាន់បានល្អគ្រប់ជ្រុងជ្រោយនៅឡើងទេ ការខ្វះខាតធនធានមនុស្សនៅក្នុងដំណើរការថវិកា គឺជាបញ្ហាមួយដែលបានកើតឡើង និងធ្វើអោយការបែងចែកថវិកាបាត់បងប្រសិទ្ធិភាពអស់មួយផ្នែក។ ធនធានមនុស្សនៅក្នុងដំណើរការបែងចែកថវិកាមិនមានគ្រប់គ្រាន់សំរាប់ការទាញយកថវិកាពីគម្រោងដែលបានបង្កើតហើយត្រៀមលុយរួចស្រេច ដែលធ្វើអោយថវិកាដែលបានរៀបចំទុកសំរាប់គម្រោងមិនមានដំណើរនាំអោយថវិកាមានការជាប់នៅមួយកន្លែង ហើយការអភិវឌ្ឍន៍ក្នុងប្រទេសក៏មិនភាពរីកចម្រើន។ ការដែលថវិកានៅក្នុងគម្រោងមួយមិនមានការទាញយកទៅប្រើប្រាស់ ឬអាចនិយាយបានយ៉ាងងាយថាមិនមានការទាញយកទៅអភិវឌ្ឍន៍នេះបើមើលពីខាងក្រៅទៅវាប៉ះពាល់តែគម្រោងឬការអភិវឌ្ឍន៍តែក្នុងមួយវិស័យនេះទេ តែបើយើងមើលអោយតាមធំជាងនេះទៅទៀតយើងអាចឃើញវាបើក្រុមនៃគម្រោងមួយមិនអាចទាញយកថវិកាដែលបានគ្រោងទុកនេះទៅអភិវឌ្ឍន៍នេះទេគួរតែកុំស្នើថវិកា គួរតែទុកថវិកាដែលបានស្នើនេះទៅអោយផ្នែកផ្សេងវិញនៅក្នុងអំឡុងពេលស្នើរថវិកាព្រោះថវិកាដែលបានស្នើរនេះក៏អាចយើងទៅត្រៀមសំរាប់គម្រោងផ្សេងទៀតផងដែល។ ងាយមកការខ្វះខាតធនធានមនុស្សក្នុងការទាញយកថវិកាទៅប្រើប្រាសវិញ ឃើថាភាកច្រើននៃការខ្វះខាតធនធានមនុស្សនេះតែងតែកើតមានឡើងចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិបើតាមការលើកឡើងរបស់វិទ្យាស្ថានសភាកម្ពុជានៅក្នុងឯកសារស្រាវជ្រាវសង្ខេបស្តីពីទិដ្ឋភាពទូទៅលើការបែងចែក និងទូទាត់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ការធ្វើផែនការអភិវឌ្ឍមូលដ្ឋាន នៅក្នុងអត្ថបទស្រាវជ្រាវរបស់វិទ្យាស្ថានសភាកម្ពុជាក៏បានលើកឡើងដែរថា ការជួបប្រទះនឹងការលំបាក នេះមានទាំងសមត្ថភាពរបស់បុគ្គលិកដែលកំពុងបំរើការ និងធនធានមនុស្សមិនទាន់បានគ្រប់គ្រាន់ហើយក៏មិនទាន់អាចសំរេចបាននៅត្រឹមឆ្នាំ២០២៥បានឡើយ។ដូចនេះយើងដឹងថា មុនឆ្នាំ២០២៥ បញ្ហានៃការខ្វះខាតធនធានមនុស្សក្នុងការទាញយកថវិកាមកអនុវត្តនូវគម្រោងអភិវឌ្ឍន៍ប្រទេសនៅតែពិបាក បញ្ហាមួយមិនទាន់បានបញ្ចប់ផងនៅចុងឆ្នាំ២០១៩ដើមឆ្នាំ២០២០ប្រទេសកម្ពុជាក៏មានការរីករាលដាលនូវជំងឺកូវីដ ថែមទៀតកាន់តែធ្វើអោយដំណើរការបែងចែកថវិកាកាន់តែមួយជួបបញ្ហាថែមទៀត។ ក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវិដនៅប្រទេសកម្ពុជានេះ រាជរដ្ឋាភិបាលបានរៀបផែនការផ្ទេកចំណាយជាកញ្ចប់មួយចំនួនដើម្បីធ្វើការបែងចែកទៅតាមស្ថានភាពបច្ចុប្បន្ន ដូចជាការត្រៀមកញ្ចប់ថវិកាសម្រាប់ដោះស្រាយតម្រូវការបន្ទាប់ និងចាំបាច់

ភ្លាមៗ ក្នុងវិបត្តិជំងឺកូវីដ ដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច និងជួយគាំទ្រទាន់ពេលវេលាលើកម្មវិធីសំណាញ់សុវត្ថិភាពដល់ក្រុមអ្នកងាយរងគ្រោះ និងរក្សាលំនឹងការងារជូនប្រជាពលរដ្ឋដែលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ បើតាមការលើកឡើងរបស់អ្នកនាំពាក្យក្រសួងសុខាភិបាលក្នុងសន្និសីទសារព័ត៌មានដើម្បីបំភ្លឺសំណួរពាក់ព័ន្ធនឹងជំងឺ និងការធ្វើតេស្តកូវីដ កាលពីខែកុម្ភៈ ឆ្នាំ២០២០ បានបង្ហាញថារដ្ឋាភិបាលបានត្រៀមលុយ៣០លានដុល្លា ដើម្បីទប់ស្កាត់ក្នុងស្ថានភាពនេះ ប៉ុន្តែក្នុងការត្រៀមថវិកានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការស្នើសុំអោយក្រសួង ស្ថាប័នទាំងអស់ធ្វើការសន្សំសំចៃថវិការដ្ឋ កាត់បន្ថយចំណាយដែលមិនចាំបាច់ ឬមិនទាន់ចាំបាច់ ដោយក្នុងនេះក្រសួង ស្ថាប័នរដ្ឋទាំងអស់ត្រូវបានកាត់បន្ថយចំណាយតាមស្ថាប័នផ្ទាល់ខ្លួន៥០% លើកលែងតែស្ថាប័នបីតែប៉ុណ្ណោះដែលកាត់បន្ថយចំណាយត្រឹមតែ២៥% មានដូចជាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម និងទីស្តីការគណៈរដ្ឋមន្ត្រី។ បើតាមពត៌មានចុងក្រោយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅសន្និសីទសារពត៌មានស្តីវិធានការរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញកន្លងមកក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ១៩ នៅថ្ងៃទី០៨ខែកក្កដាឆ្នាំ២០២០ បានអោយដឹងថាកម្ពុជាបានចំណាយថវិកាជាង១ពាន់ដុល្លាអាមេរិកក្នុងការប្រយុទ្ធប្រឆាំង ស្តារសេដ្ឋកិច្ច និងសង្គមដែលរងការប៉ះពាល់រួចទាំងការបណ្តុះបណ្តាលជំនាញផងដែរ។ការរីករាលនៃជំងឺកូវីដនេះបានធ្វើអោយប៉ះពាលដល់សេដ្ឋកិច្ចជាតិដែលកំពុងមានការរីកចំរើន និងថវិកាជាតិមួយចំនួនដែលរដ្ឋត្រៀមសំរាប់អភិវឌ្ឍន៍ត្រូវយកទៅទប់ទល់នឹងជំងឺនេះផងដែរ។

### ៣.៣.ពីនាក្យលើចំណុចខ្លាំង និងចំនុចខ្សោយនៃដំណើរការថវិកាជាតិ

ក្រោមពីបានស្រាវជ្រាវលើប្រធានបទស្តីពីដំណើរការថវិការដ្ឋនៃព្រះរាជណាចក្រកម្ពុជារួចហើយក្រុមរបស់ខ្ញុំសង្កេតឃើញថាដំណើរការថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជាមានទាំងចំនុចខ្លាំងនឹងចំនុចខ្សោយ។

នៅក្នុងចំណុចខ្លាំងនៃដំណើរការថវិកាជាតិ ក្រុមរបស់យើងខ្ញុំបានបែងចែកចេញជាពីចំនុចគឺចំណុចខ្លាំងក្នុងការប្រមូលចំណូល និងចំនុចខ្លាំងក្នុងការរៀបចំចំណាយ។ចំនុចខ្លាំងនៃដំណើរការថវិកាជាតិនៃព្រះរាជណាចក្រកម្ពុជាក្នុងការប្រមូលថវិកា គឺការប្រមូលចំណូលពីគ្រប់ផ្នែក គណនី អនុគណនីបានយ៉ាងល្អ។ពន្ធដារនៅប្រទេសកម្ពុជាមានការកើនឡើងជារៀងរាល់ឆ្នាំ បើតាមកិច្ចប្រជុំបូកសរុបទិន្នន័យលទ្ធផលប្រមូលពន្ធប្រចាំខែធ្នូឆ្នាំ២០១៩បានបង្ហាញថា កម្ពុជាប្រមូលបានពន្ធបានលើពីផែនការប្រចាំឆ្នាំរហូលដល់៨,៥២% បើធៀបទៅនឹងឆ្នាំ២០១៨ ចំនូលពន្ធមានការកើនឡើងរហូតដល់ ៣៦,៨៥% ចំពោះស្ថានភាពប្រទេសកម្ពុជានៅពេលបច្ចុប្បន្នដែលជាសម័យកូវីដ-១៩ វិញ បើតាមកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលពន្ធប្រចាំខែមីថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២០របស់អគ្គនាយកដ្ឋានពន្ធដារវិញបានបង្ហាញថា កម្ពុជាប្រមូលពន្ធបាន ៥៩,០៩%នៃផែនការប្រចាំឆ្នាំ២០២០ បើយកទៅធៀបនឹងឆ្នាំ២០១៩ឆមាសទី១ដូចគ្នាឃើញថាចំណូលពន្ធមានការកើនឡើងបាន១២% ដោយនៅក្នុងនេះចំណូលដែលនៅរក្សាកំណើនគួរអោយកត់សម្គាល់នេះគឺ ចំណូលដែល

ទទួលបានពីអាករតម្លៃបន្ថែម និងចំណូលបានពីពន្ធលើប្រាក់ចំណូល បើទោះបីជាកម្ពុជាស្ថិតនៅក្នុងស្ថានភាពកូវីដក៏ដោយ នេះគ្រាន់តែយើងលើកយកផ្នែកពន្ធដារមួយមកបកស្រាយ។ក្នុងការប្រមូលចំនូលរបស់រាជរដ្ឋាភិបាលមានការកើនឡើងនូវចំនួនជាតួលេខជាប្រចាំឆ្នាំនិងមានឆ្នាំខ្លះមានការកើនឡើងរហូតដល់លើសពីការរំពឹងទុករបស់ច្បាប់ថវិកាប្រចាំឆ្នាំទៅទៀត ដូចជាករណីជាក់ស្តែងក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានប្រមូលចំនូលសរុបលើសពីច្បាប់ថវិកាប្រចាំឆ្នាំ១៣១% បើទោះជានៅចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០នេះមានការរីករាលដាលនូវជំងឺកូវីដ-១៩ក៏ដោយក៏ការប្រមូលថវិកាជាតិក្នុងដំណើរការថវិការដ្ឋមានការកើនឡើងផងដែរ ដោយនេះយើងអាចទាញបានថាដំណើរការថវិកាជាតិមានភាពរឹងមាំងនិងធុនល្អទោះជាមានការកើតឡើងនូវបញ្ហាប្រឈមមួយចំនួនកើតឡើងចេញពីកត្តាខាងក្រៅ ឬកត្តាដែលមិនអាចរំពឹងទុកជាមុនក៏ដោយ។ ចំណែកចំនុចខ្លាំងនៅក្នុងដំណើរការចំណាយរបស់រាជរដ្ឋាភិបាលវិញ គឺថា រាជរដ្ឋាភិបាលបានយកថវិកាដែលប្រមូលបានទៅរៀបចំចំណាយតាមមុខងាររបស់ក្រសួងនីមួយៗបានយ៉ាងល្អប្រសើរ ដោយថវិកានេះបានយកទៅចំណាយចំគោលដៅ គោលបំណង និងទិសដៅដែលបានកំណត់រួចហើយផ្តល់ផលមកវិញបានយ៉ាងល្អ ដោយយើងអាចមើលឃើញតាមរយៈការកែប្រែប្រទេសកម្ពុជាអោយមានរចនាសម្ព័ន្ធកាន់តែប្រសើរពីមួយឆ្នាំទៅមួយហើយការកែប្រែរចនាសម្ពន្ធ័នេះអាចធ្វើទៅបានលុះត្រាតែមានថវិកាជាស្ថានចំលងផងដែរ។

មិនខុសពីចំនុចខ្លាំងប៉ុន្មាននេះទេនៅក្នុងចំនុចខ្សោយវិញ ក្រុមរបស់យើងខ្ញុំក៏បានបែងចែកចំនុចខ្សោយក្នុងដំណើរការថវិកាជាតិជាពីរផងដែរ គឺចំនុចខ្សោយក្នុងដំណើរការប្រមូលចំណូលថវិកាជាតិ និងចំនុចខ្សោយក្នុងចំណាយថវិកាជាតិ។ ទោះជាក្នុងដំណើរការប្រមូលចំណូលថវិកាជាតិ មានការកើនឡើងជារៀងរាល់ឆ្នាំដែលយើងមើលទៅមានភាពខ្លាំងក្លាយមែន ប៉ុន្តែនៅតែមានចំនុចខ្សោយក្នុងនេះផងដែរ។ យើងត្រូវដឹងថាការប្រមូលពន្ធមិនទាន់មានភាពល្អគ្រប់ជ្រុងជ្រោយនៅឡើងទេ ដោយមានការគេចពន្ធពីសំណាក់អ្នកជាប់ពន្ធ និងអាជីវករមួយចំនួន និងភាពមិនប្រក្រតីពីសំណាក់មន្ត្រីដែលទទួលខុសត្រូវក្នុងការទទួលប្រាក់បង់ពន្ធពីអ្នកបង់ពន្ធ ដែលករណីទាំងនេះធ្វើអោយបាត់បង់ចំណូលជាតិបើទោះជាយើងដឹងថាចំណូលជាតិមានការកើនឡើងជារៀងរាល់ឆ្នាំក៏ដោយ ទោះបីជាចំណូលជាតិមានការកើនឡើងមែនតែការបាត់បងចំណូលមិនគួរមានជាដាច់ខាត ព្រោះថវិកាទាំងអស់ដែលបានបាត់បង់នេះក៏ជាថវិកាជាតិដែរ។ការបាត់បង់ចំណូលក្នុងដំណើរការថវិកាជាតិនេះកើតចេញពីកត្តាធនធាននៅក្នុងរាជរដ្ឋាភិបាលបើយើងងាកទៅមើលការធ្វើបទសម្ភាសន៍រវាង ទូរទស្សន៍BTV នឹងអគ្គនាយកដ្ឋានពន្ធគយនិងរដ្ឋាករកម្ពុជាស្តីពីលទ្ធផលប្រមូលពន្ធ អាករ និងបញ្ហាប្រឈមបានលើកឡើងថា កម្ពុជាមិនទាន់ឧបករណ៍ និងធនធានគ្រប់គ្រាន់សំរាប់ការការពារការគេចពន្ធដែលកើតមានឡើង។ ការខ្វះខាតធនធានក្នុងរាជរដ្ឋាភិបាលមិនមែនកើតមានឡើងតែនៅក្នុងការប្រមូលថវិកានេះទេ ដោយការខ្វះខាតធនធាននេះក៏កើតមានឡើងក្នុងដំណើរការបែងចែកថវិកាដែរ។បើយើងងាកមកមើលស្ថានភាពបច្ចុប្បន្នវិញ ដែល

ប្រទេសកម្ពុជាកំពុងតែស្ថិតនៅក្នុងស្ថានភាពជំងឺកូវីដ-១៩ ដែលធ្វើអោយក្រុមហ៊ុន រោងចក្រមួយចំនួនត្រូវបិទទ្វា រួមទាំងមានកម្មករខ្លះត្រូវបានបញ្ឈប់ពីការងារ ដែលនឹងនាំអោយការប្រមូលពន្ធលើប្រាក់បៀវត្ស ពន្ធប្រាក់ចំណាញ ពន្ធប៉ាតង់និងពន្ធផ្សេងទៀតត្រូវបាត់បង់ផងដែរ។ រីឯចំនុចខ្សោយក្នុងចំណាយថវិកាជាតិវិញ គឺខ្វះខាតធនធានមនុស្សនៅក្នុងដំណើរការថវិកាដែលធ្វើអោយដំណើរការងាររបស់រាជរដ្ឋាភិបាលទាំងអស់មិនបានដំណើរការនាំអោយការអភិវឌ្ឍន៍ប្រទេសជាតិមិនមានភាពរីកចំរើនដែលមិនអាចទាញយកនូវកញ្ចប់ថវិកាដែលបានរៀបចំទុកយកមកប្រើប្រាស់ក្នុងការអភិវឌ្ឍន៍បាន ដែលក្នុងនេះភាគច្រើននៃកង្វះខាតធនធានមនុស្សតែងតែកើតមាននៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្របពេលប្រទេសកម្ពុជាកំពុងតែធ្វើការតស៊ូប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩ ការបែងចែកចំណាយក៏ត្រូវកាត់មួយចំនែកដើម្បីធ្វើជាថវិកាបំរុងសំរាប់ការទប់ស្កាត់ ដូចនេះធ្វើអោយការបែងចែកថវិកាសំរាប់ការអភិវឌ្ឍន៍ប្រទេសកាន់តែបាត់បង់មួយចំណែកទៀត។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវខាងលើដែលមានទាំងចំនុចខ្លាំង និងចំនុចខ្សោយរួចហើយយើងអាចសន្និដ្ឋានបានថាប្រធានបទស្តីពីដំណើរការថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជានេះ បានបង្ហាញអោយយើងឃើញថាដំណើរការនៃការប្រមូលចំណូលថវិការដ្ឋពិតជាមានភាពល្អ និងប្រសិទ្ធភាពព្រោះក្នុងការប្រមូលចំណូលរបស់រដ្ឋជារៀងរាល់ឆ្នាំមានការកើនឡើងទាំងពន្ធដា និងពន្ធគយរួមទាំងចំណូលមួយចំនួនទៀតរបស់រាជរដ្ឋាភិបាលមិនមែនជាពន្ធក៏មានការកើនឡើងផងដែរ។យោងតាមទិន្នន័យនៃសេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលរបស់អគ្គនាយកដ្ឋានពន្ធបានបង្ហាញថា ពន្ធដាមានការកើនឡើង៣៦,៨៥%នៅក្នុងឆ្នាំ២០១៩ដែលធៀបទៅឆ្នាំ២០១៨ ហើយលើសពីផែនកាថវិកាជាតិ៨,៥២%។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក៏បានបើកកិច្ចប្រជុំបូកសរុបការងារគយនិងរដ្ឋាករសម្រាប់ឆ្នាំ២០១៩ហើយក៏បានបង្ហាញថា ពន្ធគយមានការកើនឡើង៣០%ធៀបទៅនឹងឆ្នាំ២០១៨ហើយលើសពីផែនការថវិកាដែលបានកំណត់ប្រមាណ ៤៣,៧%។បើតាមទិន្នន័យក៏បានបង្ហាញដែលថាពន្ធគយដែលប្រមូលបានមានពន្ធនាំចូលកើនឡើង ៣០,៧% អាករពិសេសកើនឡើង៣៣,៦% អាករលើតម្លៃបន្ថែមមានការកើនឡើង២៨,៨%បើពិនិត្យចំណូលតាមមុខទំនិញវិញ មុខទមនិញយានយន្តនិងគ្រឿងចក្របន្តជាប្រភពចំណូលសំខាន់ដោយក្របដណ្តបប្រមាណ ៥២,៧%នៃចំណូលពន្ធគយសរុប នៅក្នុងកិច្ចប្រជុំក៏មានការបញ្ជាក់ដែលថាប្រមូលដែលប្រមូលបានក្នុងឆ្នាំ២០១៩នេះមានកម្រិតខ្ពស់ជាងគេក្នុងរយៈពេល២០ឆ្នាំកន្លងមកក្នុងបិរការណ៍ដែលការអនុគ្រោះពន្ធអាករ។ចំណែកចំណូលមិនមែនសារពើពន្ធវិញក៏មានការកើនឡើងផងដែរប៉ុន្តែមានភាពយឺតជាងចំណូលដែលទទួលបានពីពន្ធយោងតាមសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងថាចំណូលមិនមែនសារពើពន្ធមានការកើនឡើងត្រឹមតែ១០,៤%តែប៉ុណ្ណោះហើយភាគច្រើននៃចំណូលមិនមែនសារពើពន្ធនេះបានមកពីការជួលដីរដ្ឋចំណែកឯគណនីមួយចំនួននៅក្នុងជំពូកចំណូលមិនមែនសារពើពន្ធសឹងតែមិនទទួលបានចំណូលសោះ។ដោយមានកើនឡើងនូវគណនីនៃចំណូលដែលរដ្ឋមានសឹងតែគ្រប់មុខងារទាំងអស់នេះយើងក៏អាចមើលឃើញការរីកចំរើនចំណូលនៃថវិកាជាតិប្រចាំឆ្នាំថាមានការកើនឡើងផងដែរ តាមរយៈលទ្ធផលប្រមូលថវិកាប្រចាំឆ្នាំ២០១៩បានបង្ហាញថាប្រទេសកម្ពុជាបានប្រមូលថវិកាជាតិសរុប១៣១% លើលពីផែនការថវិកាជាតិរហូតដល់៣១%។បើទោះបីជានៅចុងឆ្នាំ២០១៩និងដើមឆ្នាំ២០២០នេះប្រទេសកម្ពុជាកំពុងតែជួបនិងប្រយុទ្ធប្រឆាំងនូវវិបត្តិជំងឺកូវីដ-១៩ដែលស្ថិតនៅក្នុងស្ថានភាពនេះមានការបិតក្រុមហ៊ុន និងការផ្អាកក្រុមហ៊ុនមួយចំនួនដែលធ្វើអោយគណនីចំណូលរដ្ឋមួយចំនួនបានការថយចុះ ឬមានការបាត់បងប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជានៅតែធ្វើអោយចំណូលជាតិ

មានការកើនឡើង។ ការសម្រេចបាននូវការងារប្រមូលពន្ធដ៏ល្អនេះព្រោះតែមានថ្នាក់ដឹកនាំនៃក្រសួង និងស្ថាប័នរដ្ឋទាំងអស់ចូលរួមក្នុងការប្រមូលចំណូលជាពិសេសគឺថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងអាណាប័កដើមខ្សែរដែលគ្រប់គ្រងរដ្ឋបាលថ្នាកជាតិ និងអាណាប័កផ្ទេរសិទ្ធិដែលគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការគៀងគរចំណូលរដ្ឋមានការកើនឡើងជារៀងរាល់ឆ្នាំដែលបង្ហាញអោយឃើញថាចំណូលរបស់រដ្ឋមានភាពល្អប្រសើរនិងរីកចំរើនប៉ុន្តែទោះជាការប្រមូលចំណូលជាតិមានភាពល្អក៏ពិតមែនតែមិនទាន់ល្អប្រសើរ និងគ្រប់ជ្រុងជ្រោលនៅឡើយទេ ព្រោះនៅក្នុងដំណើរការប្រមូលថវិកាជាតិនេះមានការគេចពន្ធពីសំណាក់អ្នកជាប់ពន្ធមួយចំនួនភាគច្រើននៃការគេចពន្ធនេះតែងតែកើតមានឡើងទៅលើទំនិញដែលជាប់ពន្ធអាករខ្ពស់ដូចជារថយន្តជាដើមភាគច្រើននៃការគេចពន្ធនេះតែងតែកើតមានចំពោះមុខទំនិញដែលជាប់ពន្ធខ្ពស់។ហើយការគេចពន្ធនេះតែងតែធ្វើឡើងតាមព្រំដែនទឹកនិងពេលយប់ដែលដែលរដ្ឋាភិបាលពិបាកក្នុងគ្រប់គ្រង។ក្រៅពីការគេចពន្ធដែលជាបញ្ហាដល់ដំណើរនៃការប្រមូលពន្ធ ក៏មានភាពមិនប្រក្រតីពីសំណាក់មន្ត្រីប្រមូលពន្ធទៅលើអាជីវករផងដែរភាគច្រើននៃមន្ត្រីប្រមូលពន្ធនេះតែងតែប្រគល់ឯកសារច្រើនពេកទៅអោយអ្នកបង់ពន្ធធ្វើការបំពេញដែលមានឯកសារខ្លះអ្នកបង់ពន្ធសឹងមិនស្គាល់ដែលធ្វើអោយអ្នកបង់ពន្ធយល់ថាការបង់ពន្ធជាមួយបុគ្គលមានភាពងាយស្រួលជាងការបង់ពន្ធជាមួយនឹងរដ្ឋ។

ការអនុវត្តចំណាយក្នុងដំណើរការថវិកាក៏ជាចំនុចសំខាន់មួយក្នុងប្រធានបទមួយនេះដែរយើងអាចឃើញថា ការចំណាយក្នុងដំណើរការថវិកាជាតិមានដំណើរការល្អជារៀងរាលឆ្នាំដោយសារក្រោយពីរដ្ឋប្រមូលថវិកាបានរួចហើយរដ្ឋបានរៀបចំថវិការបស់ខ្លួនយ៉ាងយកចិត្តទុកដាក់មានការរៀបចំគោលដៅសំរាប់ ការរៀបចំជាគម្រោងផែនការសំរាប់អភិវឌ្ឍន៍ ការកាត់ចំណាយដែលមិនចំបាច់និងមានការពិភាក្សាត្រួតពិនិត្យច្រើនដំនាក់កាលមុនពេលយកថវិកាដែលប្រមូលបានទៅចំណាយតាមមុខងារដូចនេះហើយធ្វើអោយការចំណាយចំគោលដៅ មានប្រសិទ្ធភាពខ្ពស់និងទទួលបានសមិទ្ធផលមកវិញយ៉ាងល្អដោយយើងអាចឃើញតាមរយៈសៀវភៅសមិទ្ធផល និងទិសដៅនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង់ហិរញ្ញវត្ថុសាធារណៈរយៈពេល៥ឆ្នាំរបស់គណៈកម្មធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុចេញផ្សាយនៅឆ្នាំ២០១៨បានអោយដឹងថា រាជរដ្ឋាភិបាលបានធ្វើអោយថវិកាកាន់តែមានភាពជឿទុកចិត្តដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈដោយសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧%ចំណូលមានការកើនឡើងក្នុងចន្លោះ១៥%-២០%ក្នុងរយៈពេល៥ឆ្នាំចុងក្រោយហើយថវិកាចំណាយសំរាប់ក្រសួង ស្ថាប័នរដ្ឋទាំងអស់មានការកើនឡើង១,៨ដងរាប់ចាប់ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៧ការគ្រប់គ្រងសាច់ប្រាក់មានប្រសិទ្ធភាពដោយគ្មានបំណុលកកស្ទះដោយក្នុងនោះបំណុលសាធារណៈត្រូវបានគ្រប់គ្រងត្រឹមត្រូវ សមិទ្ធផលដែលសម្រេចបានរបស់រាជរដ្ឋាភិបាលនេះព្រោះតែ

រាជរដ្ឋាភិបាលមានការចំណាយចំគោលដៅដែលបានកំណត់យ៉ាងច្បាស់លាស់ធ្វើអោយមានការលើកកម្ពស់គុណភាពការងារនិងការពង្រីកវិសាលភាពនៃសេវាសាធារណៈ។

ការអនុវត្តចំណាយរបស់រាជរដ្ឋាភិបាលមានភាពល្អនិងចំគោលដៅក្តីតែមិនទាន់មានភាពល្អគ្រប់ជ្រុងជ្រោលនៅឡើងទេ ព្រោះតែកត្តាធនធាននៅក្នុងរាជរដ្ឋាភិបាលមិនទាន់មានសមត្ថភាព និងចំនួនគ្រប់គ្រាន់សំរាប់ការទាញយកកញ្ចប់ថវិកាដែលផ្តល់ដោយរដ្ឋយកទៅធ្វើការអភិវឌ្ឍន៍ក្នុងគម្រោងដែលរដ្ឋបានរៀបចំធ្វើអោយថវិកាជាតិដែលបានរៀបចំនេះមិនអាចយកទៅប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍បានជាហេតុនាំអោយការអភិវឌ្ឍន៍ ឬគម្រោងសកម្មភាពទាំងអស់នេះមិនមានសកម្មភាពហើយថវិកាក៏ត្រូវជាប់នៅមួយកន្លែងមិនអាចដកយកទៅប្រើប្រាស់សំរាប់គ្រោងឬផែនការផ្សេងទៀតបាន។ ស្របពេលប្រទេសកម្ពុជាកំពុងតែធ្វើការតស៊ូប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការបែងចែកចំណាយក៏ត្រូវកាត់មួយចំនែកដើម្បីធ្វើជាថវិកាបំរុងសំរាប់ការទប់ស្កាត់ដូចជាការកាត់បន្ថយចំណាយតាមក្រសួង ធ្វើអោយការបែងចែកថវិកាសំរាប់ការអភិវឌ្ឍន៍ប្រទេសកាន់តែបាត់បង់មួយចំណែកទៀតហើយថវិកាដែលយកទៅចំណាយសំរាប់ការទប់ស្កាត់ជំងឺនេះក៏មិនអាចមកវិញដែរ។

# អនុសាសន៍

ឆ្លងតាមសន្និដ្ឋានខាងលើយើងអាចមើលឃើញប្រទេសកម្ពុជានៅមានចំនុចខ្វះខាតខ្លះក្នុងដំណើរការថវិកាជាតិដោយក្នុងនេះមានដូចជា ការគេចពន្ធ និងការស៊ីសំណូកក្នុងដំណើរការប្រមូលថវិកាជាតិ និងការខ្វះខាតធនធានមនុស្សក្នុងការទាញយកកញ្ចប់ថវិការដ្ឋក្នុងដំណើរការចំណាយថវិកា ដូចនេះរាជរដ្ឋាភិបាលគួរតែចាប់នីតិវិធីដូចជា៖

+ចំពោះកត្តាធនធានមនុស្ស រដ្ឋគួរតែត្រួតពិនិត្យទៅលើមន្ត្រីដែលមិនមានសមត្ថភាពផ្នែកសេដ្ឋកិច្ចយកទៅសិក្សានិងបណ្តុះបណ្តាលអោយមានសមត្ថភាពគ្រប់គ្រាន់អាចទាញយកកញ្ចប់ថវិការបស់ដើម្បីធ្វើការអភិវឌ្ឍន៍ជាតិ និងបណ្តុះបណ្តាលទាំងឆន្ទះបំរើប្រទេសជាតិដើម្បីលុបបំបាត់ភាពមិនប្រក្រតីក្នុងការប្រមូលពន្ធ

+រដ្ឋគួរតែដកមន្ត្រីដែលមានសមត្ថភាពខ្លះពីរដ្ឋបាលថ្នាក់ជាតិអោយទៅបំរើការនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធ្វើការអភិវឌ្ឍន៍តាមរយៈការទាញកញ្ចប់ថវិកាបើទោះបីជារដ្ឋបាលថ្នាក់ជាតិមានសារៈសំខាន់ក៏ពិតមែនតែរដ្ឋបាលថ្នាក់ក្រោមជាតិក៏សំខាន់ផងដែរ

+រដ្ឋគួរតែធ្វើការផ្សព្វផ្សាយអំពីពន្ធអោយបានច្រើនតាមដែលអាចធ្វើបាន និងតាមគ្រប់វិធីដើម្បីអោយអាជីវករយល់ដឹងអំពីការបង់ពន្ធនិងមិនអាចអោយមន្ត្រីដែលទទួលបន្ទុកបង់ពន្ធធ្វើការស៊ីសំនូកទៅលើក្រុមអាជីវករទាំងអស់នេះ

+រដ្ឋគួរតែជំរុសចោលឬដកចេញពីដំណែកចំពោះមន្ត្រីណាដែលធ្វើការប្រមូលពន្ធចូលរដ្ឋមិនមានភាពប្រក្រតីដែលនាំអោយបាត់បងចំណូលរដ្ឋ

+រដ្ឋគួរតែពង្រីកការគ្រប់គ្រង និងទិញយកនូវឧបករណ៍ដែលសំខាន់សំរាប់ប្រើប្រាស់ពីបរទេសដើម្បីអោយមន្ត្រីមានទាំងឧបករណ៍នឹងបច្ចេកទេសគ្រប់គ្រាន់សំរាប់តាមដាន់ការគេចពន្ធដែលចេញពីព្រំដែន។តាមដានទំនិញដែលមានចរាចរណ៍នៅលើទីផ្សារបើតាមការខុសទិន្នន័យរដ្ឋគួរតែចុះទៅស្រាវជ្រាវដើម្បីការពារទំនិញគេចពន្ធចូលមកក្នុងទីផ្សារបានសម្រេច

+រដ្ឋគួរតែធ្វើគ្រប់វិធីដើម្បីអោយអាជីវកម្មដែលមានទំនិញគេចពន្ធនៅក្នុងដៃធ្វើការបង់ពន្ធចូលរដ្ឋក្រោយពេលដែលទំនិញនេះមកក្នុងប្រទេសកម្ពុជារួចហើយដូចជាការសម្រាលទោសចំពោះការគេចពន្ធ ការណែនាំមិនអោយធ្វើការគេចពន្ធ ឬការយកពន្ធស្មើតម្លៃនៃការគណនាពន្ធដើម

# ឯកសារពិគ្រោះ

- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
- ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨
- ច្បាប់ស្តីពីគយឆ្នាំ២០០៧
- ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិកម្ពុជាឆ្នាំ១៩៩៦
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៣
- អនុក្រឹត្យលេខ ៨២ អនក្រ.បកចុះថ្ងៃទី១៦ ខែវិច្ឆិកាឆ្នាំ១៩៩៥ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បទបញ្ជាស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធឆ្នាំ២០០៦
- អនុក្រឹត្យលេខ២៥ អនក្រ.បកចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ស្តីពីការគ្រប់គ្រង់ចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត
- អនុក្រឹត្យលេខ៧២ អនក្រ.បកចុះថ្ងៃទី៧ ខែមិថុនាឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុក្រឹត្យលេខ ០៤ អនក្រ.បកចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៤៨៨ អនក្រ.បកចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៧៥ អនក្រ.បកចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ
- អនុក្រឹត្យលេខ ០៩ អនក្រ.បកចុះថ្ងៃទី១៣ ខែកុម្ភៈឆ្នាំ២០២០ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំនិងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

- សេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមិថុនា និងឆមាសទី១ឆ្នាំ២០១៩ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយដ្ឋានពន្ធដាររបស់អគ្គនាយដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយដៃគូអភិវឌ្ឍន៍ឆ្នាំ២០២០
- ប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ស្តីពីការដាក់អោយអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- ប្រកាសលេខ ១៨៩០ សហវ.ប្រកចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៥ស្តីពីនីតិវិធីនាំការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៣៨៧ សហវ.គរចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០០៨ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភាឆ្នាំ២០១៧ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១៥២១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូឆ្នាំ២០១៣ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមគណនីនិងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- ប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈឆ្នាំ២០១៣ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០
- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- គោលការណ៍ណែនាំ ស្តីពីកិច្ចបញ្ជីកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេ និងគណនេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា របស់នាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០១០

- ថវិកាសង្ខេប ឆ្នាំ២០២០របស់នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយដ្ឋានថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីថវិកាកម្មវិធី
- បទបង្ហាញដោយបណ្ឌិតស្រី វុធអនុប្រធាននាយកដ្ឋានហិរញ្ញកិច្ច អគ្គនាយដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចស្តីនីតិវិធីអនុវត្តថវិកាចរន្តតាមកម្មវិធី
- បទបង្ហាញរបស់បណ្ឌិត ឱ សុវណ្ណនៃអគ្គនាយដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធីហិរញ្ញវត្ថុ និងសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បទបង្ហាញរបស់នាយកដ្ឋានថវិកានីយកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីអង្គភាពថវិកាឆ្នាំ២០១៦
- សៀវភៅណែនាំស្តីពីពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៣
- សៀវភៅណែនាំស្តីពីពន្ធលើប្រាប់ចំណេញរបស់អគ្គនាយដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៣
- សៀវភៅណែនាំស្តីពន្ធលើអចលទ្រព្យរបស់អគ្គណាយដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៣
- ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៩
- សៀវភៅណែនាំស្តីពីការត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សៀវភៅណែនាំអំពីថវិកាជាតិដែលផលិតឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលដោយសហការពីវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០៧
- សិក្ខាសាលា របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រោមប្រធានបទទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ធ្វើនៅឆ្នាំ២០១៥
- សៀវភៅរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិស្តីពីគណនេយ្យ និងរការរាយការណ៍ស្តីពីផែនការអត្ថប្រយោជន៍និវត្តន៍ភាពឆ្នាំ២០១៥
- សៀវភៅមេរៀនពន្ធរបស់សាស្ត្រាចារ្យ ទូរ សុខុម៉ា

- សៀវភៅនីតិថវិកា និងពន្ធដាររបស់សាកលវិទ្យាល័យ ន័រតុន
- សៀវភៅហិរញ្ញវត្ថុសាធារណៈ របស់បណ្ឌិត ហង់ ជួនណារ៉ុន
- សៀវភៅមេរៀននីតិរដ្ឋបាលរបស់ សាស្ត្រាចារ្យ យូ តូនី
- បទវិចារណកថា របស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៃកម្ពុជារបស់សមាគមសាលាត្រាជូឆ្នាំ២០១៩
- https://www.mef.gov.kh/institutional-structure.html
- http://www.customs.gov.kh/faq
- https://www.youtube.com/watch?v=S73BmDiUlfo
- https://www.youtube.com/watch?v=Ct5s9HSTToQ
- https://www.youtube.com/watch?v=wj10U_hw5ow
- http://www.customs.gov.kh/patrol-boat-anti-smuggling/
- http://cambodiapolice.com/policekh/11141
- http://www.customs.gov.kh/home_video

# ឧបសម្ព័ន្ធ

នស/រកម/០៥០៨/០១៦

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានអនុម័តកាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE ROYAL

# ច្បាប់

# ស្តីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ មានគោលដៅកំណត់គោលការណ៍ជាមូលដ្ឋានសម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល និង សម្រាប់រៀបចំច្បាប់ហិរញ្ញវត្ថុជាពិសេសសម្រាប់ដំណាក់កាលនីមួយៗនៃដំណើរការរៀបចំ អនុម័ត និង អនុវត្តថវិកា ការត្រួតពិនិត្យលទ្ធផលថវិកា ការកំណត់មុខងារ ការទទួលខុសត្រូវ ព្រមទាំងកម្មវិបាកលើកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលគ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគោរពគោលការណ៍បូរណភាព អាជ្ញាភាព ឯកត្តភាព សមាគតភាព សកលភាព សង្គតិភាព គណនេយ្យភាព តម្លាភាព ស្ថិរភាព ភាពគ្រប់ជ្រុងជ្រោយ និង សមិទ្ធកម្ម ។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះគ្របដណ្តប់ទាំងហិរញ្ញវត្ថុសាធារណៈជាតិ ទាំងទំនាក់ទំនង និង អន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និង ហិរញ្ញវត្ថុឯកជនអន្តរជាតិ ហើយត្រូវធានាការគោរពគោលការណ៍ថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ភាពផ្សាភ្ជាប់គ្នារវាងថវិកា និង គោលនយោបាយ និង គណនេយ្យភាពចំពោះសមិទ្ធកម្ម ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពជាច្បាប់គោល ដែលត្រូវយកធ្វើជាមូលដ្ឋាន និង ត្រូវគោរពអនុវត្តតាម សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។



**មាត្រា ៤.-**

សម្រាប់ប្រើប្រាស់នៅក្នុងច្បាប់នេះ វាក្យស័ព្ទខាងក្រោមមានន័យ ដូចតទៅ :

**ច្បាប់ហិរញ្ញវត្ថុ** សំដៅដល់ច្បាប់ដែលគ្រោងចំណូល និង ចំណាយប្រចាំឆ្នាំរបស់រដ្ឋ បទប្បញ្ញត្តិ ពាក់ព័ន្ធទៅនឹងវិស័យហិរញ្ញវត្ថុ និងការទូទាត់ផ្សេងៗ ដែលត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្តមុខងារ កម្មវិធី និង ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង បទប្បញ្ញត្តិស្តីពីវិស័យហិរញ្ញវត្ថុដែលច្បាប់កំណត់ ។

**ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** គ្រោង និង អនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋ ។

**ច្បាប់កែតម្រូវ** សំដៅដល់ច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ច្បាប់ទូទាត់ថវិកា** សំដៅដល់ច្បាប់ត្រួតពិនិត្យ និង វាយតម្លៃលទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល** សំដៅដល់ក្រសួង ស្ថាប័ន ឬ អង្គភាព ដែលទទួលហិរញ្ញប្បទានទាំងស្រុង ឬ មួយផ្នែកនៃថវិកាជាតិ ឬ/ និង ដែលគ្រប់គ្រងទ្រព្យសកម្ម និង បំណុលរបស់រដ្ឋ ឬ/ និង គណនេយ្យ ដែលច្បាប់បង្កើត ព្រមទាំងគ្រប់គ្រងចាត់ចែងសកម្មភាពទាំងឡាយណាដែលនាំឱ្យរដ្ឋជាប់កាតព្វកិច្ចហិរញ្ញវត្ថុ ឬ បំណុលផ្សេងៗ ។

**រយៈពេលមធ្យម** សំដៅដល់រយៈពេលដែលមិនតិចជាង ៣ ឆ្នាំ និង មិនលើសពី ៥ ឆ្នាំ ។

**របៀបវារៈគោលនយោបាយ** សំដៅដល់យុទ្ធសាស្ត្រសម្រាប់សម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលឆ្លុះបញ្ចាំងនៅក្នុងផែនការរដ្ឋ ដែលរួមមានគោលនយោបាយជាតិ គោលនយោបាយតាមវិស័យ និង តាមអនុវិស័យ ។

**កម្មវិធី** សំដៅដល់ក្រុមនៃអនុកម្មវិធី ឬ/និង ក្រុមនៃចង្កោមសកម្មភាពដែលមានលក្ខណៈឯករាជ្យ តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយត្រូវបានរៀបចំឡើងដើម្បីរួមចំណែកសម្រេចបាននូវគោលបំណង គោលនយោបាយរួមមួយ និងមានបញ្ជាក់ពីសកម្មភាព

ដែលត្រូវអនុវត្តលទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ ព្រមទាំងសូចនាករដែលជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ។ កម្មវិធីអាចត្រូវបានបែងចែកជាអនុកម្មវិធី ។

**ភាពគ្រប់ជ្រុងជ្រោយនៃថវិកា** សំដៅដល់ថវិកាពេញលេញដែលឆ្លុះបញ្ចាំងគ្រប់ប្រភពចំណូល និង គ្រប់មុខសញ្ញាចំណាយ ។

**តម្លាភាព** សំដៅដល់រាល់ច្បាប់ បទប្បញ្ញត្តិ គោលការណ៍ នីតិវិធី និង ការអនុវត្តទាំងឡាយ ត្រូវផ្សព្វផ្សាយ ដោយទូលាយសម្រាប់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ និង សាធារណជន ។

**គណនេយ្យភាព** សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និង បុគ្គល ចំពោះមុខងារ និងភារកិច្ចដែលបានទទួលអនុវត្តតាមរយៈប្រព័ន្ធរបាយការណ៍ ។

**សង្គតិភាព** សំដៅដល់គ្រប់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តគោលការណ៍តែមួយដោយប្រទាក់ក្រឡាគ្នា ។

**សកលភាពនៃថវិកា** សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់អាចប្រើប្រាស់សម្រាប់រាល់មុខចំណាយដោយគ្មានលក្ខខណ្ឌ ។

**សមាគតភាពនៃថវិកា** សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់ និងគ្រប់មុខសញ្ញាចំណាយទាំងអស់ត្រូវបង់ និងទូទាត់តាមរយៈប្រព័ន្ធគណនីទោលរបស់រតនាគារជាតិ ។

**ឯកភាព** សំដៅដល់ហិរញ្ញវត្ថុសាធារណៈមានប្រព័ន្ធតែមួយ ដែលមានលក្ខណៈពេញលេញ គ្រប់ជ្រុងជ្រោយ គ្មានការប្រទាំងប្រទើសទាំងផ្នែកគោលនយោបាយ ទាំងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន ហើយដែលមិនអាចរំលោភបំពានបាន ។

**រដ្ឋបាលថ្នាក់ជាតិ** សំដៅដល់ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។

**ថវិកា** សំដៅដល់សិលាហ៊ុំនៃគណនីដែលពិពណ៌នាសម្រាប់ឆ្នាំនីមួយៗអំពីធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ឬ របស់ស្ថាប័ន ឬ របស់អង្គភាពណាមួយ ។

**ថវិកាជាតិ ឬ ថវិការដ្ឋ** សំដៅដល់គម្រោងតុល្យភាពនៃធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ។ ថវិកាជាតិ ឬ ថវិការដ្ឋ រួមមានថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ ។ ថវិកាថ្នាក់ជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ជាតិ ។ ថវិកាថ្នាក់ក្រោមជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**អចលកម្មហិរញ្ញវត្ថុ** សំដៅដល់ការវិនិយោគលើមូលបត្រ ឬ មូលបត្រ ដែលបានមកពីការចូលរួមទុនជាមួយសហគ្រាស ឬ ក្រុមហ៊ុន ។ អចលកម្មហិរញ្ញវត្ថុនេះ ជាទ្រព្យសកម្មហិរញ្ញវត្ថុថេរមិនចរន្ត ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាអចលកម្មហិរញ្ញវត្ថុ រួមមានមូលបត្រគ្រប់ប្រភេទទាំងអស់ វិញ្ញាបនបត្រផ្ញើប្រាក់ ប័ណ្ណសន្យាសងប់រង ផលប័ត្រពាណិជ្ជកម្ម ប័ណ្ណសងតាមបញ្ជា រូបិយណត្តិ និង មូលប្បទានបត្រជាដើម ។

**ផលហិរញ្ញវត្ថុ** សំដៅដល់ផលហិរញ្ញវត្ថុទាំងអស់ដែលបានមកដោយការយកអតិរេកសាច់ប្រាក់បណ្តោះអាសន្ន ទៅវិនិយោគលើមូលបត្រអាចជួញដូរបាន និង ក្នុងរយៈពេលខ្លី ។ ផលហិរញ្ញវត្ថុនេះមានជាអាទិ៍ អត្រាការប្រាក់លើបំណុលប្រាក់ចំណេញ ដែលបានមកពីការវិនិយោគក្នុងរយៈពេលមួយយប់លើប័ណ្ណរតនាគារបរទេស ផលដែលបានមកពីការធានាឱ្យមានសំវិធានធន និង កម្រៃផ្សេងទៀត ដែលបានមកពីប្រតិបត្តិការហិរញ្ញវត្ថុ ។

**មាត្រា ៥.-**

ថវិកាត្រូវមានគោលការណ៍គន្លឹះ ១១ យ៉ាង ដែលត្រូវអនុវត្តជាចំខាតគឺ :

១- ភាពជាអាជ្ញា

២- ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ

៣- ភាពគ្រប់ជ្រុងជ្រោយ

ROYAUME DU CAMBODGE · LE MIN... ROYAL · ព្រះរាជក្រឹត្យ

៤- ឯកត្តភាព

៥- សកលភាព

៦- វិសេសភាព

៧- តុល្យភាព

៨- គណនេយ្យភាព

៩- តម្លាភាព

១០- ស្ថិរភាព

១១- សមិទ្ធកម្ម ។

**មាត្រា ៦.-**

រដ្ឋបាលថ្នាក់ជាតិ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលដែលជាមន្ត្រីសាធារណៈ និង ប្រតិបត្តិករនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល ត្រូវប្រកាន់ខ្ជាប់នូវមូលដ្ឋាននៃគោលការណ៍បូរណភាព សមាគតភាព សង្គតិភាព គណនេយ្យភាព តម្លាភាពនិងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងវិសាលភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល និងគោលការណ៍គន្លឹះទាំង ១១ យ៉ាងនៃថវិកា ។

**មាត្រា ៧.-**

ដើម្បីធានាការអនុវត្តច្បាប់នេះ និង បទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធផ្សេងទៀតប្រកប ដោយប្រសិទ្ធភាព ត្រូវចេញអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និង សារាចរណែនាំដោយរាជរដ្ឋាភិបាល ព្រមទាំងប្រកាស និង សារាចរណែនាំផ្សេងៗទៀត ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៨.-**

ច្បាប់ដែលមានលក្ខណៈជាច្បាប់ហិរញ្ញវត្ថុរួមមាន :

១- ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

២- ច្បាប់កែតម្រូវ

៣- ច្បាប់ទូទាត់ថវិកា ។

មាត្រា ៩.-

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ គ្រោង និង អនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាននិងបន្ទុកដែលត្រូវចំណាយសរុបរបស់រដ្ឋ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវន្ត ពិសេសតាមរយៈការធានាឱ្យបាននូវតុល្យភាពថវិកា ។

មាត្រា ១០.-

ក្រៅពីអ្វីដែលមានចែងក្នុងច្បាប់នេះ របបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុនៃច្បាប់ដោយឡែក ។

មាត្រា ១១.-

ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ។

## ជំពូកទី ២
## រចនាសម្ព័ន្ធថវិកា និង សិទ្ធិអំណាច

### ផ្នែកទី ១
### រចនាសម្ព័ន្ធថវិកា

មាត្រា ១២.-

ថវិកាត្រូវរៀបចំ ទៅតាមចំណាត់ថ្នាក់រដ្ឋបាលដែលផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ចំណាត់ថ្នាក់សេដ្ឋកិច្ចដែលផ្អែកទៅលើប្រភេទចំណាយ ចំណាត់ថ្នាក់មុខងារដែលផ្អែកទៅលើគោលបំណង និង ចំណាត់ថ្នាក់តាមកម្មវិធី ។

ROYAUME DU CAMBODGE · LE MINISTRE · ROYAL
ព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៣.-**

ធនធានអចិន្ត្រៃយ៍របស់រដ្ឋមាន ចំណូលចរន្ត និង ចំណូលមូលធន ។

- ចំណូលចរន្ត ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :
  - ក្រុមទី ១ : ចំណូលពិត
    - ប្រភេទទី ១ : ចំណូលសារពើពន្ធ
    - ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ
  - ក្រុមទី ២ : ចំណូលតាមដីកា
    - ប្រភេទទី ៣ : ចំណូលតាមដីកា
- ចំណូលមូលធន ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :
  - ក្រុមទី ១ : ចំណូលពិត
    - ប្រភេទទី ១ : ចំណូលពីប្រភពផ្ទាល់
    - ប្រភេទទី ២ : ចំណូលពីប្រភពខាងក្រៅ
  - ក្រុមទី ២ : ចំណូលតាមដីកា
    - ប្រភេទទី ៣ : ចំណូលតាមដីកា

ប្រភេទចំណូលនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៤.-**

គណនីថវិការួមមាន ថវិការដ្ឋ ថវិកាឧបសម្ព័ន្ធ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និង គណនីពិសេសរតនាគារជាតិ ។ គណនីថវិកាផ្សេងៗទៀត អាចបង្កើតបានក្នុងច្បាប់ហិរញ្ញវត្ថុ ។

ថវិកាឧបសម្ព័ន្ធអនុវត្តចំពោះអង្គភាពរដ្ឋ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ដែលមិនមែនជានីតិបុគ្គល ។ ថវិកាឧបសម្ព័ន្ធ ត្រូវបង្កើត ឬ លុបចោល ដោយច្បាប់ហិរញ្ញវត្ថុ ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធ ត្រូវប្រព្រឹត្តទៅក្នុងលក្ខខណ្ឌ និង តាមវិធានដូចគ្នានឹងកិច្ចប្រតិបត្តិការថវិការដ្ឋដែរ ។

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត ។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមាន ចំណូលផ្ទាល់ និង ជាយថាហេតុ មានការឧបត្ថម្ភ ធុញ្ញភាព ដោយថវិការដ្ឋ ។ រីឯចំណាយជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និង ការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់ថវិការដ្ឋដែរ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃថវិកាឧបសម្ព័ន្ធ និង ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៥.-**

ចំណូលសារពើពន្ធរួមមានចំណូលបានមកពីពន្ធ និង អាករក្នុងប្រទេស និង ពន្ធ និង អាករលើពាណិជ្ជកម្មក្រៅប្រទេស និង ចំណូលសារពើពន្ធដទៃទៀត ។

ចំណូលមិនមែនសារពើពន្ធរួមមានចំណូលបានមកពីការចាត់ចែង ការធ្វើអាជីវកម្មនិង ការលក់ទ្រព្យសម្បត្តិរដ្ឋ ផលបានមកពីសម្បទាន កម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យ និង ការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយ ផលហិរញ្ញវត្ថុ ផលផ្សេងៗ និងផលពិសេស និង ចំណូលមិនមែនសារពើពន្ធដទៃទៀត ។

ចំណូលមូលធនរួមមានចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ ហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ការខ្ចី និង ចំណូលមូលធនផ្សេងទៀត ។

**មាត្រា ១៦.-**

ពន្ធ អាករ និង ចំណូលសារពើពន្ធផ្សេងៗ ត្រូវកំណត់ដោយច្បាប់ និង ត្រូវប្រមូល និង ត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អត្រាពន្ធ អាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និងវិវាទ ដែលទាក់ទងនឹងការកំណត់ការប្រមូល និង ការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និង តាមបែបបទ ដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និង អាករនីមួយៗ ។

គ្មានបទប្បញ្ញត្តិណាមួយ ទោះជាប្រភេទណាក៏ដោយ គ្មានអនុសញ្ញាអន្តរជាតិណាមួយ ដែលអាចធ្វើឱ្យមានការប្រែប្រួលនាំមកនូវការ ចាត់ចំណូលនោះឡើយ ។ ករណីខាងលើអាច

ROYAUME DU CAMBODGE - ROYAL

ប្រព្រឹត្តទៅបានលុះត្រាតែអនុវត្តតាមទម្រង់ច្បាប់ និង បទបញ្ញាដូចគ្នា ក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

ទ្រព្យសម្បត្តិរដ្ឋ ដែលរួមមាន ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវចាត់ចែង និង គ្រប់គ្រងយ៉ាងត្រឹមត្រូវទៅតាមបទប្បញ្ញត្តិនៃច្បាប់ និង បទបញ្ញាជាធរមាន ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលើការលក់ ការជួល ការផ្ទេរ និង ការចាត់ចែងដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ព្រមទាំងការធ្វើបញ្ជីសារពើភណ្ឌ ។ រាល់ការចុះកិច្ចសន្យាលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង ផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ដែលមានការពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និង ការឯកភាពរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ក្រោមបទប្បញ្ញត្តិនៃមាត្រា ១៩ នៃច្បាប់នេះ ចំណូលទាំងអស់ដែលបានពីការចាត់ចែង និង គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបង់ចូលគណនីទោលរបស់រតនាគារជាតិនៃថវិការដ្ឋ ដោយមិនអាចដកចំណូលនេះ ទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ ។

**មាត្រា ១៨.-**

សេវាបង់ថ្លៃរបស់រដ្ឋ គឺជាសេវា ដែលផ្តល់ដោយអង្គភាពសេវាសាធារណៈរបស់រដ្ឋទៅឱ្យឯកជន និង អង្គការតតិយ ។ កម្រៃសេវារបស់រដ្ឋ ត្រូវស្ថិតនៅក្រោមអានុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងតាមយោបល់របស់ក្រសួង និង ស្ថាប័នដែលពាក់ព័ន្ធ ។

ចំពោះកម្រៃសេវាសាធារណៈរបស់រដ្ឋ ដែលមានលក្ខណៈតូចតាច មានជាអាទិ៍កម្រៃពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល ប័ណ្ណចូលទស្សនារមណីយដ្ឋាន សារមន្ទីរ វិក្កយបត្រ

ពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការ ពាក់ព័ន្ធ ។

**មាត្រា ១៩.-**

ចំណូលត្រូវកត់ត្រាចូលទាំងស្រុងហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ ។ ការបង្កើនដោយអាណាប័កនូវទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយ ត្រូវបានហាមឃាត់ដាច់ខាត ។

**មាត្រា ២០.-**

ចំណូលទាំងមូល ត្រូវវិភាជន៍សម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់ ។ ប៉ុន្តែចំណូលខ្លះ អាចត្រូវវិភាជន៍ សម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់ និង ក្រោមលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ២១.-**

បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមាន ចំណាយចរន្ត និង ចំណាយមូលធន ។ បន្ទុកនេះ ត្រូវបានចែកជាក្រុម និង ប្រភេទ ។

**មាត្រា ២២.-**

ចំណាយចរន្តនៃថវិកាត្រូវបានបែងចែកជា ២ ក្រុម និង ៦ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត
  - ប្រភេទទី ១ : មធ្យោបាយសេវា
  - ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ
  - ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ
  - ប្រភេទទី ៤ : ចំណាយផ្សេងៗ
- ក្រុមទី ២ : ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក
  - ប្រភេទទី ៥ : ចំណាយតាមដីកា

-ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក

ប្រភេទចំណាយនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៣.-**

ចំណាយមូលធននៃថវិកា គឺសម្រាប់ការអនុវត្តកម្មវិធី ការអនុវត្តគម្រោងវិនិយោគ ការចូលរួមភាគកម្ម និង ការទូទាត់បំណុល ។

ចំណាយមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត
  - ប្រភេទទី ១ : ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល
  - ប្រភេទទី ២ : អចលកម្ម
- ក្រុមទី ២ : ចំណាយតាមដីកា
  - ប្រភេទទី ៣ : ចំណាយតាមដីកា

ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស គឺជាឥណទានមានលក្ខណៈជាប់ស្ពាន ហើយពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពទៅប្រភេទចំណាយណាមួយផ្សេងទៀតបានឡើយ ។

**មាត្រា ២៤.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ វិភាជន៍ឥណទានទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវថវិកាឧបសម្ព័ន្ធ និង ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលទៅតាមប្រភេទចំណាយចរន្ត និង ចំណាយមូលធន ។ ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលទាំងនោះ ប្រមូលផ្តុំឥណទានទាំងអស់សម្រាប់បម្រើការងាររបស់ខ្លួននៅរដ្ឋបាលថ្នាក់ជាតិ ។

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជន៍ឥណទានជាកញ្ចប់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២៥.—**

ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលម្អិតនៅក្នុងផ្ទៃក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និង គោលដៅនៃឥណទានថវិកា ។ ឥណទានទាំងនេះ អាចធ្វើជាកម្មវត្ថុសម្រាប់ការរៀបចំថវិកាតាមកម្មវិធី និង ការប្រមូលផ្តុំតាមវិស័យផងដែរ ។ ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ចំណាយចរន្តនៃប្រភេទ ២ "បន្ទុកហិរញ្ញវត្ថុ" និង ប្រភេទ ៦ "ចំណាយមិនបានគ្រោងទុក" មិនត្រូវបានបែងចែកឱ្យទៅក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលណាមួយឡើយ ។ ឥណទាននេះ ទុកសម្រាប់សងការប្រាក់នៃប្រាក់ខ្ចី និង បន្ទុកហិរញ្ញវត្ថុផ្សេងៗ ព្រមទាំងឥណទានត្រៀមបម្រុងសម្រាប់ចំណាយផ្សេងៗលើមុខសញ្ញាដែលកើតឡើងជាយថាហេតុ ។ ឥណទានត្រៀមបម្រុង ត្រូវបានអនុញ្ញាតសម្រាប់ការចំណាយទាំងឡាយណាដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់ នៅពេលដែលឥណទាននោះ ត្រូវបានអនុម័ត ។ ការបែងចែកឥណទានត្រៀមបម្រុងទាំងនេះ តាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រភេទ ១ នៃចំណាយមូលធន គឺសម្រាប់ការទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និង ទូទាត់បំណុលប្រហាក់ប្រហែល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗ ចំណាយសំណង និង ចំណាយបង្វិលសងវិញ ព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និង ទូទាត់បំណុលប្រហាក់ប្រហែល ។

**មាត្រា ២៦.—**

ឥណទានថវិកាមានពីរប្រភេទគឺ កំហិតកំណត់ និង ប៉ាន់ប្រមាណ ។ ឥណទានកំហិតកំណត់គឺត្រូវបានផ្តល់ជាការសន្យា និង ការអនុញ្ញាតត្រឹមកម្រិតខ្ពស់បំផុតមួយ ដែលចំណាយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ប្រភេទនេះ ត្រូវបានកំណត់ជាមុន ។ ចំណាយបែបនេះ អាចបង្កើនបានតែតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតែមួយប៉ុណ្ណោះ ។ ឥណទានចាំបាច់ប្រមាណ គឺត្រូវបានអនុញ្ញាតសម្រាប់ចំណាយចាំបាច់ និង ក្នុងករណីដែលការគ្រោងមិនគ្រប់គ្រាន់នៅក្នុងដំណាក់កាលបន្ទាប់ពីការអនុម័តថវិកា ។ ចំណាយនៃឥណទានប្រភេទនេះ អាចនឹងត្រូវបានប្រើប្រាស់លើសពីឥណទាន ដែលបានគ្រោងនៅក្នុងជំពូកថវិកាពាក់ព័ន្ធ ។ ឥណទានប្រភេទនេះ កើតមានលើបំណុលសាធារណៈ បៀវត្សរ៍ ប្រាក់បំណាច់របស់បុគ្គលិក វិភាគទានសមាជិកភាព ចំពោះស្ថាប័នអន្តរជាតិ ឬ អន្តររដ្ឋាភិបាល និង ចំណាយផ្សេងទៀត ដែលត្រូវកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ២៧.-**

ឥណទានចំណាយចរន្ត ត្រូវបែងចែកជាឥណទានសម្រាប់សកម្មភាពការងារ ដែលបានអនុម័ត និង ឥណទានសម្រាប់វិធានការថ្មី ។

ឥណទានសម្រាប់សកម្មភាពការងារដែលបានអនុម័ត រួមមានឥណទានដែលបានកំណត់នៅក្នុងថវិកាចំណាយចរន្តនៃឆ្នាំមុន ដកទាយជ្ជទាន និង ឥណទានសម្រាប់សកម្មភាពការងារ ដែលនឹងមិនកើតឡើងវិញនៅក្នុងឆ្នាំគ្រោងថវិកា បូកបន្ថែមឥណទាន សម្រាប់ការកែតម្រូវតាមស្ថានភាពជាក់ស្តែង ។

ឥណទានសម្រាប់សកម្មភាពការងារដែលបានអនុម័ត ត្រូវស្ថិតក្នុងកម្រិតអប្បបរមាចាំបាច់ ដែលត្រូវការសម្រាប់ដំណើរការសកម្មភាពការងារនៅក្នុងលក្ខខណ្ឌនៃឆ្នាំមុន ។

ការកែតម្រូវតាមស្ថានភាពជាក់ស្តែង ត្រូវគិតអំពីផលប៉ះពាល់ដែលបានកើតឡើងនៅក្នុងឆ្នាំមុន ព្រមទាំងការវិវត្តនៃបន្ទុកសាធារណៈខ្លះទៀត ដែលអាចកើតឡើងដោយសារវិធានការដែលបានអនុម័តនៅក្នុងឆ្នាំមុន ។

វិធានការថ្មី គឺទាក់ទងទៅនឹងការសម្រេចទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ហិរញ្ញវត្ថុបន្ថែមទៀតទៅលើថវិកា ។



មាត្រា ២៨.-

ឥណទានចំណាយមូលធន គឺជាឥណទានវិនិយោគដែលត្រូវបែងចែកជាឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ ឥណទានវិនិយោគ កំណត់លើកម្មវិធី ឬ គម្រោងការទាំងឡាយដែលរដ្ឋបានផ្តួចផ្តើមនៅក្នុងឆ្នាំ និងគណនាតម្រូវការចំណាយសរុប ។ ឥណទានវិនិយោគគ្រោងមូលនិធិភ្ជាប់សន្យាសម្រាប់ប្រតិបត្តិការទាំងស្រុងនៃគម្រោងការ ដោយមិនតម្រូវឱ្យមានការវិនិយោគបន្ថែមសម្រាប់បញ្ចប់នោះទេ ។ ទោះជាយ៉ាងនោះក្តី ឥណទានវិនិយោគអនុញ្ញាតឱ្យរាជរដ្ឋាភិបាលធ្វើការសន្យាត្រឹមតែក្នុងរង្វង់នៃឥណទានភ្ជាប់សន្យា ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតែប៉ុណ្ណោះ ។

ឥណទានភ្ជាប់សន្យា ត្រូវដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តកិច្ចវិនិយោគ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។ ឥណទានទូទាត់ ត្រូវប្រើប្រាស់សម្រាប់ចេញបញ្ជាចំណាយដែលជាបន្ទុករបស់រដ្ឋ នៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា ។

មាត្រា ២៩.-

ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល ។ ឥណទាននេះ ត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបបំបាត់ជាយថាហេតុ ។ ឥណទានទូទាត់ ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង (បញ្ចប់ឆ្នាំ) ត្រូវបានលុបចោល និង អាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់ ។

មាត្រា ៣០.-

គ្មានវិធានការជាបទប្បញ្ញត្តិ បទបញ្ជា ឬ រដ្ឋបាលណាមួយអាចត្រូវបានអនុម័តទទួលស្គាល់ ឬ សម្រេចបានទេ ប្រសិនបើតម្រូវការចំណាយនៃបន្ទុកថ្មីដែលនឹងកើតឡើងនោះ មិនត្រូវបានវាយតម្លៃ ព្យាករណ៍ និង អនុញ្ញាតមុនពេលគ្រោង និង កំណត់ថវិកា ។ ការបង្កើតនិងការប្តូរមុខរបរក៏ដូចជាការប្រឡងជ្រើសរើស អាចកើតមានតែពីតារាងមុខរបរដែលបានកំណត់ដោយរដ្ឋបាល ឬ អង្គភាព និង បានគ្រោងនៅក្នុងថវិកា ។ ការដំឡើងឋានៈ ការផ្តល់បុព្វលាភ

ROYAUME DU CAMBODGE · LE MINISTRE ROYAL ·
ប្រជុំមហោស្រព

ថ្មី ឬ ការបង្កើន លាភការ មិនអាចសម្រេចបានទេ បើប្រសិនណាវិធានការទាំងនេះមិនបាន បំពេញ ដោយឥណទានគ្រប់គ្រាន់ជាមុននៅក្នុងថវិការដ្ឋ ។

**មាត្រា ៣១.-**

គណនីពិសេសរបស់រតនាគារជាតិ គឺជាគណនីដែលបានបើកក្នុងលេខនារបស់រតនាគារជាតិទុកសម្រាប់:

១-ចុះកិច្ចបញ្ជីការចំណូលដោយឡែកជាហិរញ្ញប្បទានជាក់លាក់ដល់កិច្ចប្រតិបត្តិការសេវាសាធារណៈទាំងឡាយ ដែលហៅថាគណនីចាត់ចែងពិសេស ។

២-បង្ហាញចំណាយមានលក្ខណៈបណ្តោះអាសន្នរបស់រដ្ឋ ដែលហៅថាគណនីបុរេប្រទាន ។

៣-កត់ត្រាប្រតិបត្តិការទាំងអស់មានលក្ខណៈឧស្សាហកម្ម ឬ ពាណិជ្ជកម្មដែលបានធ្វើដោយរដ្ឋជាលក្ខណៈបន្ទាប់បន្សំ ដែលហៅថាគណនីពាណិជ្ជកម្ម ។

គណនីពិសេសរបស់រតនាគារជាតិ ត្រូវបានបង្កើត ឬ លុបចោលដោយច្បាប់ហិរញ្ញវត្ថុ ក្រោមលក្ខខណ្ឌនៃបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣២.-**

ចំណូល និង ចំណាយទាំងអស់នៃគណនីពិសេសរបស់រតនាគារជាតិ ត្រូវបានគ្រោង និង អនុញ្ញាតក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងប្រតិបត្តិការទូទៅនៃថវិការដ្ឋដែរ ។

**មាត្រា ៣៣.-**

ប្រតិបត្តិការចំណាយ ដែលអាចកត់ត្រាក្នុងគណនីពិសេសរបស់រតនាគារជាតិ ត្រូវប្រព្រឹត្តទៅដូចជាថវិការដ្ឋដែរ ក្រោមលក្ខខណ្ឌនៃចំណុចដោយឡែកដូចតទៅ:

១-ចំណាយសរុបដែលបានសន្យា ឬ បានចេញអាណត្តិទៅឱ្យគណនីពិសេសរបស់រតនាគារជាតិ មិនអាចលើសពីធនធានសរុបរបស់គណនីនេះទេ

២-ក្នុងពេលគ្រប់គ្រង ប្រសិនបើចំណូលនៃគណនីពិសេសរបស់រតនាគារជាតិ

បានស្តែងឡើងខ្ពស់ជាងចំណាយប៉ាន់ប្រមាណដែលបានគ្រោងទុក នោះឥណទាននៃគណនីនេះ អាចត្រូវបានតម្លើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងកម្រិតនៃចំណូលដែលលើសនោះ ។

៣-សមតុល្យឥណទានៃគណនីពិសេសរបស់រតនាគារជាតិ អាចយោងពីមួយឆ្នាំទៅមួយឆ្នាំ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ ។

៤-ហាមកត់ត្រាក្នុងគណនីពិសេសរបស់រតនាគារជាតិនូវចំណាយណាដែលមិនចូលក្នុងក្របខ័ណ្ឌនៃកម្មវត្ថុរបស់គណនីនេះ មានជាអាទិ៍ ប្រាក់បៀវត្សរ៍ ឬ ប្រាក់បំណាច់ ។

## ផ្នែកទី ២

## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូល ចំណាយ ការខ្ចី ការឱ្យខ្ចី និង ការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់ ។

**មាត្រា ៣៥.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ការអនុវត្ត ការតាមដាន និង ការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និង រយៈពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៦.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរាយការណ៍ជូនរដ្ឋសភា និង ព្រឹទ្ធសភាអំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋា-

ភិបាល ព្រមទាំងអំពីស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈនាពេលបច្ចុប្បន្ន និង ព្យាករណ៍សម្រាប់រយៈពេលមធ្យម ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ការគោរពច្បាប់ហិរញ្ញវត្ថុ ព្រមទាំងធានាការត្រួតពិនិត្យជាប្រចាំលើការគ្រប់គ្រងថវិកា ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចផ្តល់របាយការណ៍អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ស្ថានភាពហិរញ្ញវត្ថុសាធារណៈជូនរដ្ឋសភា និង ព្រឹទ្ធសភាពីរដងក្នុង ១ ឆ្នាំ គឺនៅពេលពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និង នៅពាក់កណ្តាលឆ្នាំ ។

**មាត្រា ៣៨.-**

រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងថវិកា និង ការត្រួតពិនិត្យការអនុវត្តថវិការបស់ខ្លួន ជាពិសេសត្រូវមានគណនេយ្យភាពចំពោះការកំណត់ និង លទ្ធផលនៃការអនុវត្តគោលនយោបាយនៅក្នុងវិស័យរបស់ខ្លួន ដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣

## ការរៀបចំថវិកា

### ផ្នែកទី ១

### ក្របខ័ណ្ឌនៃការរៀបចំថវិកា

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រតិទិនដូចខាងក្រោមនេះ :

**១-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែ មីនា ដល់ ខែ ឧសភា)**

នៅសប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ។

នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលបានកំណត់ដោយរាជរដ្ឋាភិបាល ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និង ផែនការសកម្មភាពជាអាទិភាពរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់វិស័យ និង គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ។ ផែនការយុទ្ធសាស្ត្រថវិកា ទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

**២-ការរៀបចំកញ្ចប់ថវិកា (ពីខែ មិថុនា ដល់ ខែកញ្ញា)**

នៅសប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើគំណត់បង្ហាញនិងឯកសារពាក់ព័ន្ធ ដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ហើយផ្ញើជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនូវគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គម្រោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូលចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ខេត្ត និង រាជធានីដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលព្រមទាំងអភិបាលគ្រប់ខេត្ត និង រាជធានី មកពិភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូល ចំណាយថវិកាទាំងនោះឱ្យបានសមស្របតាមបទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និងបង្កើនចំណូលឱ្យបានសមស្រប ។

នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញរួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

**៣-ការអនុម័តថវិកា (ពីខែ តុលា ដល់ខែ ធ្នូ)**

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេចរួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និង ដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទីមួយនៃខែធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

## ផ្នែកទី ២
## ដំណើរការនៃការរៀបចំថវិកា

**មាត្រា ៤០.-**

ការរៀបចំថវិកា ត្រូវគោរពបទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា ១ មាត្រា ២ និង មាត្រា ៦ នៃច្បាប់នេះ ។

**មាត្រា ៤១.-**

ការគ្រោងចំណូលចរន្ត ត្រូវឈរលើមូលដ្ឋាននៃប្រភពធនធានដែលបានមកពីចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ។

១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវគ្រោងដោយផ្ទាល់នូវចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ដែលជាកម្មវត្ថុនៃការប្រមូលនៅក្រោមសមត្ថកិច្ចរបស់ខ្លួន និង គ្រោងចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធបានមកពីសហគ្រាសសាធារណៈ ។

២-រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលគ្រប់ខេត្ត និង រាជធានី ដែលមានចំណែកក្នុងការគ្រប់គ្រងចំណូលក្រោមសមត្ថកិច្ចរបស់ខ្លួន ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវបញ្ជីរាយគ្រប់មុខចំណូល និង បញ្ជីប៉ាន់ស្មានចំណូលទាំងអស់ ដើម្បីកត់ត្រាក្នុងគម្រោងចំណូលនៃថវិកាឱ្យបានពេញលេញ និង ត្រឹមត្រូវ ។ ចំណូលទាំងនេះជាចំណែក មិនអាចបំបែកបាននៃចំណូលសរុបនៃថវិការដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវគ្រោងចំណូលមូលធនដោយឈរលើមូលដ្ឋាននៃប្រភពធនធានបានមកពី :

១-ចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ

២-ការសងបំណុល និង សងបុរេប្រទានដោយសហគ្រាសសាធារណៈ ដែលត្រូវ

កត់ត្រាឱ្យបានត្រឹមត្រូវក្នុងតារាងវិលស់

៣-រាល់ប្រភពចំណូលពីការខ្ចីក្នុងប្រទេស ដោយមានការសម្រេចយល់ព្រមពីរាជរដ្ឋាភិបាល ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវវាយតម្លៃ និងវិភាគលើស្ថានការណ៍សេដ្ឋកិច្ច និង ចរិតនៃការខ្ចី ដោយសហការជាមួយទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

៤-ហិរញ្ញប្បទានក្រៅប្រទេស ក្រោមរូបភាពជាហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ឬ ការខ្ចី ដែលត្រូវកត់ត្រាក្នុងគម្រោងចំណូលទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។ ធនធានសម្រាប់ទ្រទ្រង់ថវិកា និង សម្រាប់គម្រោង ត្រូវវាយតម្លៃទៅតាមលំហូរមូលនិធិ និង វឌ្ឍនភាពនៃការអនុវត្តគម្រោង ។ មូលនិធិបដិភាគក្រោមរូបភាពជាទំនិញត្រូវគ្រោងជាចំណូលនៃថវិការដ្ឋនូវចំនួនទឹកប្រាក់ដែលរំពឹងទុកតាមកម្មវិធីនៃការនាំចូលទំនិញទាំងនោះ

៥-ចំណូលមូលធនផ្សេងទៀត ។

**មាត្រា ៤៣.—**

គម្រោងចំណាយចរន្ត និង ចំណាយមូលធន ត្រូវរៀបចំឡើងដោយរដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គ្រប់សេវា និង សកម្មភាពទាំងមូល ។

**មាត្រា ៤៤.—**

ការគ្រោងនៃតម្រូវការថវិកាត្រូវផ្អែកលើគោលការណ៍ច្បាប់ និង គោលបំណងនៃគោលនយោបាយ កម្មវិធី សកម្មភាព និង លទ្ធផលរំពឹងទុក ដោយហ្មត់ចត់ និង ច្បាស់លាស់ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបង្កើតនិយាម និង ឯកតារង្វាស់សម្រាប់រាល់សកម្មភាពការងារ ដែលមានលក្ខណៈផ្សេងៗគ្នា ព្រមទាំងសម្រាប់ទ្រព្យ និង សេវា ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា ៤៥.-**

ចំណាយមូលធន ត្រូវផ្អែកលើកម្មវិធី ឬ គម្រោងដោយឡែកៗ ដែលមានការយល់ព្រមជាមុន និង ដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបាននូវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ កម្មវិធី ឬ គម្រោងទាំងអស់នោះគឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយមូលធនសរុបរបស់កម្មវិធី និង គម្រោង និង សម្រាប់កំណត់រយៈពេលនៃការសន្យា និង ការទូទាត់សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ ។

**មាត្រា ៤៦.-**

ដើម្បីគោរពតាមប្រតិទិននៃមាត្រា ៣៩ នៃច្បាប់នេះ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិក្នុងការគ្រោងចំណូលចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនបានលើកគម្រោងចំណូល ចំណាយរបស់ខ្លួនតាមកាលកំណត់ ដោយផ្អែកលើលទ្ធផលនៃឆ្នាំកំពុងអនុវត្ត ។

**មាត្រា ៤៧.-**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវ :

១-របាយការណ៍វិភាគពីនិន្នាការ និង ការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និង ការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្តពិសេសតុល្យភាពថវិកា ។

២-របាយការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងនិន្នាការចំណាយចរន្តដោយវិភាគ និង បង្ហាញពីស្ថានភាពឥណទានពាក់ព័ន្ធនឹងការអនុម័តឆ្នាំមុនទៅនឹងតម្រូវការ និង វិធានការថ្មី ដែលមានសារសំខាន់ចាំបាច់សម្រាប់ការគ្រប់គ្រងថ្មី ។

៣-កម្រងកម្មវិធី និង គម្រោងចំណាយមូលធន ដែលរំលេចនូវឥណទានវិនិយោគឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់សម្រាប់កម្មវិធី និង គម្រោងក្នុងឆ្នាំ ការគ្រោងសម្រួលឥណទានដែលមានប្រភេទដូចគ្នាចាំបាច់សម្រាប់បន្តកម្មវិធី និង គម្រោងទាំងនេះ និង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ការវិភាគកម្មវិធី និង គម្រោងថ្មី ព្រមទាំងតម្រូវការឥណទានសម្រាប់កម្មវិធី និង គម្រោងថ្មីទាំងនេះ ដោយកំណត់តាមប្រតិទិនប្រើប្រាស់ដែលបានគ្រោងទុក ។

៤-ឯកសារពាក់ព័ន្ធផ្សេងៗទៀត ដែលចាំបាច់សម្រាប់ជាព័ត៌មាន និង សម្រាប់ការត្រួតពិនិត្យរបស់រដ្ឋសភា និង ព្រឹទ្ធសភា ។

**មាត្រា ៤៨.-**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ចែកចេញជាពីរផ្នែក :

ផ្នែកទី ១ សេចក្តីព្រាងច្បាប់អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានសាធារណៈ និង កំណត់ធនធានទាំងនោះ ជាទឹកប្រាក់សរុប ។ សេចក្តីព្រាងច្បាប់ត្រូវកំណត់ទិសដៅ និង មធ្យោបាយអនុវត្តចំពោះចំណាយមូលធន ។ សេចក្តីព្រាងច្បាប់បានកំណត់នូវឥណទានត្រូវផ្តល់ខ្ពស់បំផុត ដែលជាគុណប្រយោជន៍ដល់ថវិការដ្ឋ និង គណនីពិសេសរបស់រតនាគារជាតិ ។ សេចក្តីព្រាងច្បាប់រួមមានបទប្បញ្ញត្តិទាំងឡាយ ដែលទាក់ទងដល់ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលមូលធន និង ទាក់ទងដល់គ្រប់បទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត ។

ផ្នែកទី ២ រួមមានតារាងបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ដែលទាក់ទងដល់ចំណូលនៃថវិការដ្ឋ ។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយចរន្តរបស់ថវិការដ្ឋ បែងចែកទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ហើយបែងចែកទៅតាមប្រភេទចំណាយ ដែលត្រូវអនុម័ត ។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយមូលធន បែងចែកទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល និង ជាជំពូកដែលចែកចេញជា ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ សេចក្តីព្រាងច្បាប់ត្រូវកំណត់បញ្ជីគណនីពិសេសរបស់រតនាគារជាតិ ដែលមានលក្ខណៈរដ្ឋបាល និង កំណត់គណនីពិសេសនីមួយៗនូវចំនួនទឹកប្រាក់ចំណូល និង ចំនួនទឹកប្រាក់ចំណាយ ។

**មាត្រា ៤៩.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវអនុម័តដោយរដ្ឋសភា និង ពិនិត្យដោយព្រឹទ្ធសភា និង ត្រូវ

ប្រកាសឱ្យប្រើដោយព្រះរាជក្រម ហើយត្រូវបោះផ្សាយឱ្យអនុវត្តជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥០.-**

ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែមករានៃឆ្នាំការិយបរិច្ឆេទទេនោះ ថវិកាឆ្នាំមុនត្រូវបានបន្តដោយស្របច្បាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម :

១-ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និង ចំណូលគ្រប់ប្រភេទផ្សេងទៀតត្រូវបានអនុញ្ញាត និង បន្តឱ្យប្រមូលក្នុងលក្ខខណ្ឌ និង តាមបែបបទដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និង ក្នុងក្របខ័ណ្ឌច្បាប់ ព្រមទាំងបទបញ្ជាដែលមានជាធរមាន

២-ចំណាយចរន្ត ក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ដោយគិតតាមវិធីមួយភាគដប់ពីរជាបណ្តោះអាសន្នក្នុងខែនីមួយៗ រហូតដល់ថវិកាថ្មីត្រូវបានអនុម័ត

៣-ចំណាយមូលធននៃថវិកាក្រៅពីរំលស់បំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ក្នុងក្របខ័ណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយអាចលើសពីនេះប្រសិនបើចាំបាច់ ដោយមិនឱ្យការទូទាត់នោះលើសពីកម្រិតឥណទានភ្ជាប់សន្យាដែលបានអនុម័តក្នុងថវិកាឆ្នាំមុន ។

៤-ចំណាយទាំងឡាយ ដែលជាកាតព្វកិច្ចទាក់ទងទៅនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិ និង អន្តររដ្ឋាភិបាល និង កាតព្វកិច្ចទាក់ទងទៅនឹងបន្ទុកបំណុលសាធារណៈរួមមានការរំលស់ប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ ឬ ការបង់ពិន័យជាយថាហេតុ ត្រូវបានរ៉ាប់រងជាបន្តមិនឱ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន ។

ROYAUME DU CAMBODGE · MINISTERE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

## ផ្នែកទី ៣
## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៥១.–**

ច្បាប់ហិរញ្ញវត្ថុ ត្រូវអនុម័តក្នុងលក្ខខណ្ឌដូចគ្នានឹងច្បាប់ដទៃទៀតដែរ លើកលែងតែករណីពិសេសដូចខាងក្រោម :

-គម្រោងចំណូល ត្រូវអនុម័តសរុបជាកញ្ចប់ទាំងសម្រាប់ចំណូលចរន្តទាំងសម្រាប់ចំណូលមូលធន

-គម្រោងចំណាយ ត្រូវអនុម័តជាសរុបទាំងប្រភេទ ចំណាយចរន្ត ទាំងប្រភេទចំណាយមូលធនលើបញ្ជីក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល

-ចំពោះគណនីពិសេសរបស់រតនាគារជាតិ ត្រូវអនុម័តសរុបជាកញ្ចប់លើបញ្ជីនៃគណនីទាំងអស់ដែលមាន

-បទប្បញ្ញត្តិទាំងអស់នៃច្បាប់ហិរញ្ញវត្ថុជាកម្មវត្ថុនៃការអនុម័តចុងក្រោយបង្អស់ ។

**មាត្រា ៥២.–**

គ្មានវិសោធនកម្មណាមួយ លើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអាចត្រូវបានអនុញ្ញាតឱ្យធ្វើនោះទេ ប្រសិនបើវិសោធនកម្មនោះធ្វើឱ្យប៉ះពាល់ដល់តុល្យភាពនៃគម្រោងថវិកាដែលបានស្នើឡើង ។ វិសោធនកម្មប្រភេទនេះ អាចធ្វើទៅបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម :

- សំណើចំណាយថ្មី ត្រូវបានប៉ះប៉ូវដោយការលុបចេញ ឬ បន្ថយចំណាយណាមួយផ្សេងទៀត ដើម្បីរក្សាតុល្យភាពថវិកា

- សំណើចំណាយថ្មីត្រូវបានធ្វើឡើង ដោយមានភ្ជាប់ជាមួយនូវសំណើសន្សំសំចៃលើប្រភេទចំណាយណាមួយដែលបានស្នើឡើងរួចហើយ ដើម្បីរក្សាតុល្យភាពថវិកា

- សំណើចំណាយថ្មី ត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវសំណើបង្កើតមុខចំណូលថ្មី ឬ បង្កើនចំណូល ដើម្បីរក្សាតុល្យភាពថវិកា

ស៊ី

វិសោធនកម្មដែលធ្វើឡើងផ្ទុយនឹងបទប្បញ្ញត្តិខាងលើនៃមាត្រានេះ នឹងត្រូវបានបដិសេធ ហើយទុកជាមោឃៈ ។

**មាត្រា ៥៣.—**

ការបែងចែកឥណទានជាជំពូក ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។ អនុក្រឹត្យបែងចែកនេះ មិនអាចនាំឱ្យមានការប្រែប្រួលឥណទាន ដែលត្រូវបានកំណត់ដោយច្បាប់ ។

**មាត្រា ៥៤.—**

ការបែងចែកឥណទានលម្អិតនៅក្នុងជំពូក ជាគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## ការអនុវត្តថវិកា

### ផ្នែកទី ១
### ក្របខ័ណ្ឌនៃការអនុវត្តថវិកា

**មាត្រា ៥៥.—**

ការផ្ទេរឥណទានពីក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយពីស្ថាប័ន ឬ ពីអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ដោយភាពចាំបាច់នៃការងារពង្រឹងរចនាសម្ព័ន្ធ ឬ រដ្ឋបាលរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងករណីការផ្ទេរឥណទាននេះ មិនកែប្រែមុខចំណាយ និង ការបែងចែកឥណទានតាមជំពូកនីមួយៗទេ ។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL *

**មាត្រា ៥៦.-**

ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយ នៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវធ្វើឡើងដោយអនុក្រឹត្យ ក្នុងករណីមិនកែប្រែឥណទានចំណាយមូលធនសម្រាប់វិនិយោគទៅជាឥណទានចំណាយចរន្តសម្រាប់ដំណើរការ ។

**មាត្រា ៥៧.-**

ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬ ពីអនុគណនីមួយទៅអនុគណនីមួយ នៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៥៨.-**

អនុក្រឹត្យ ដែលធ្វើឡើងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចបែងចែកឥណទានថវិកា ដែលកត់ត្រានៅក្នុងចំណាយមិនបានគ្រោងទុកក្រោមរូបភាពនៃឥណទានបន្ថែមជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលនានា ។

**មាត្រា ៥៩.-**

ឥណទានដែលលែងមានមុខសញ្ញាប្រើប្រាស់ នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា អាចត្រូវបានលុបចោលដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រោយពីបានទទួលព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ៦០.-**

នៅពេលដែលការវិវត្តនៃចំណូល និង ចំណាយស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចចេញជាប្រកាស ដើម្បីបង្កកមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។ ក្នុងករណីដែលការបាត់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចធ្វើនីតិវិធីតាមអនុក្រឹត្យ

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ៦១.-**

ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬ ភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យបន្ថែមឥណទានដើម្បីប្រើប្រាស់ ។ ឥណទាននេះ ត្រូវអនុម័តដោយច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលត្រូវសុំការយល់ព្រមពីរដ្ឋសភា និង ព្រឹទ្ធ-សភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់ ។

ដោយបដិបញ្ញត្តិនៃកថាខណ្ឌខាងលើនៃច្បាប់នេះ បើច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុនេះ ពុំអាចធ្វើទៅកើតក្នុងត្រីមាសទី៤ នៃការិយបរិច្ឆេទនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ឥណទានទាំងនេះជាកម្មវត្ថុនៃនិយ័តភាវូបនីយកម្មក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់ ។

**មាត្រា ៦២.-**

ការកែប្រែផ្សេងៗទៀតលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និង ព្រឹទ្ធសភាអនុម័តដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។

## ផ្នែកទី ២
## ដំណើរការនៃការអនុវត្តថវិកា

**មាត្រា ៦៣.-**

ការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ និង គណនីពិសេសរបស់រតនាគារជាតិជាភារកិច្ចរបស់អាណាប័ក និង គណនេយ្យករសាធារណៈ ។ អាណាប័ក និង គណនេយ្យករសាធារណៈ មានមុខងារវិសមិតភាពនឹងគ្នា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និង ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមខ្សែបណ្តោយដែលស្ថិតក្រោមឱវាទ ។ អាណាប័កដើមខ្សែជាអ្នកបញ្ជាចំណូល និង បញ្ជាចំណាយថវិកាតាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទ ប្រធានមន្ទីរជំនាញខេត្ត និង រាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្នុងករណីអាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិ អវត្តមាន ឬ មានធុរៈ អាចជ្រើសតាំងប្រភេទមន្ត្រីរាជការ ដើម្បីផ្ទេរសិទ្ធិ ឬ ជំនួសខ្លួន ដោយផ្អែកលើបទបញ្ជាគណនេយ្យសាធារណៈ ។ ការផ្ទេរសិទ្ធិ ឬ ការចុះហត្ថលេខា ត្រូវធ្វើឡើងដោយប្រកាសបន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### មាត្រា ៦៤.-

ចំណាយលើថវិការដ្ឋ និង លើគណនីពិសេសរបស់រតនាគារជាតិ ជាកម្មវត្ថុនៃការឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានទទួលការតែងតាំងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ គោលបំណង និង ហេតុផលជាក់ស្តែងនៃការត្រួតពិនិត្យនេះ ព្រមទាំងវិធីសាស្ត្រនៃកិច្ចប្រតិបត្តិការ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

CAMBODGE PALAIS ROYAL

**មាត្រា ៦៥.-**

ចំណាយថវិការដ្ឋរួមទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ និង ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងគណនីពិសេសរបស់រតនាគារជាតិក្នុងការទិញ ការជួសជុល ការសាងសង់ និង ការផ្តល់សេវា ត្រូវអនុវត្តតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវបានកំណត់ដោយច្បាប់ និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

## ផ្នែកទី ៣

## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៦៦.-**

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលព្រមទាំងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិការបស់ខ្លួន ។ ចំពោះការប្រមូលចំណូល និង ការអនុវត្តចំណាយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួនដែលច្បាប់បានកំណត់ ។

**មាត្រា ៦៧.-**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និង ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រីមានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមួយគត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា និង ការសន្យាផ្នែកហិរញ្ញវត្ថុនានា និង មានសិទ្ធិ ក្នុងការឱ្យប្រាក់គេខ្ចីទាំងក្នុង និង ក្រៅប្រទេស ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ មន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬ ឱ្យប្រាក់គេខ្ចី ឬ ចេញជាលិខិតធានា ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀតដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជា បាន

**មាត្រា ៦៨.-**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និង ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេ ឬ បំណុលដែលគេជំពាក់រដ្ឋ ។ ការរៀបចំកម្មវិធីដោះស្រាយបំណុល ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

**មាត្រា ៦៩.-**

លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និង ទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេនៃការឱ្យប្រាក់គេខ្ចីនៃការបោះផ្សាយមូលបត្ររដ្ឋ នៃការធានា និង នៃការសន្យាផ្នែកហិរញ្ញវត្ថុនានា ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

**មាត្រា ៧០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈ និងណែនាំក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ។ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ស្ថាប័នថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និង សហគ្រាសសាធារណៈ ត្រូវគោរពតាមច្បាប់ អនុក្រឹត្យ ប្រកាស និង សេចក្តីណែនាំទាំងឡាយស្តីពីលទ្ធកម្មសាធារណៈ ។

## ជំពូកទី ៥

## គណនេយ្យ និង ការត្រួតពិនិត្យលទ្ធផល

### ផ្នែកទី ១

### ក្របខ័ណ្ឌគណនេយ្យ និង ការទូទាត់ថវិកា

**មាត្រា ៧១.-**

គោរពតាមគោលការណ៍គណនេយ្យភាព រដ្ឋមន្ត្រី ប្រធានស្ថាប័ន ប្រធានអង្គភាពសា-ធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចរៀបចំ និង

ផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវរបាយការណ៍ស្តីពីការអនុវត្តថវិកា របាយការណ៍ស្តីពីការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់គេ ការបោះផ្សាយមូលបត្ររដ្ឋ ការធានា និង ការសន្យានានាផ្នែកហិរញ្ញវត្ថុ ការទទួលហិរញ្ញប្បទានឥតសំណង និង ដែលពាក់ព័ន្ធនឹងចំណូលមានប្រភពមកពីការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ និង ព័ត៌មានចាំបាច់ផ្សេងៗទៀតតាមតម្រូវការរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចកំណត់កាលបរិច្ឆេទនៃការផ្តល់និងគំរូនៃរបាយការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌខាងលើនៃមាត្រានេះ ដើម្បីជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌ និង គ្រប់គ្រងកិច្ចប្រតិបត្តិការការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាភាពត្រឹមត្រូវ និង ស្របតាមបទដ្ឋាន បទប្បញ្ញត្តិ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។

ដោយឡែក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការណែនាំអំពីការរៀបចំក្របខ័ណ្ឌ កិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ៧៣.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យសាធារណៈទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រមូលផ្តុំនៅរតនាគារជាតិ និង អនុវត្តដោយគណនេយ្យករសាធារណៈ ។

**មាត្រា ៧៤.-**

ប្រព័ន្ធគណនេយ្យសាធារណៈ ត្រូវមានសង្គតិភាពទៅនឹងនិយាមគណនេយ្យអន្តរជាតិដែលមានការទទួលស្គាល់ជាទូទៅ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ប្រព័ន្ធគណនេយ្យនេះ ។

**មាត្រា ៧៥.-**

បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់គ្រប់លក្ខខណ្ឌ ដែលធ្វើឱ្យប្រតិបត្តិការគណនេយ្យ និង ហិរញ្ញវត្ថុ អាចកត់ត្រា វិភាគ និង គ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រកបដោយគណនេយ្យភាព ភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព ។

**មាត្រា ៧៦.-**

ការទូទាត់ថវិកា គឺជាកម្មវត្ថុនៃច្បាប់ ។

**មាត្រា ៧៧.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ពិនិត្យកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលក្នុងគណនីទោលរបស់រតនាគារជាតិ និង អាណាប័ណ្ណចំណាយដែលបានប្រព្រឹត្តទៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា ។ សេចក្តីព្រាងច្បាប់នេះទុកជាមោឃៈនូវឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងឱ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុង "គណនីលទ្ធផល" របស់រតនាគារជាតិ ។

**មាត្រា ៧៨.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទៅតាមមាតិកាថវិកានីមួយៗ ដោយផ្អែកលើទិន្នន័យចំណូល ចំណាយ ដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយអាណាប័កពាក់ព័ន្ធ ។

**មាត្រា ៧៩.-**

ក្របខ័ណ្ឌ និង កិច្ចដំណើរការនៃសវនកម្មផ្ទៃក្រៅត្រូវអនុវត្តតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨០.-**

ប្រតិបត្តិការ ដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវឆ្លុះបញ្ចាំងនូវវិធានគណនេយ្យសាធារណៈតាមលំនាំដូចខាងក្រោម៖

១-ចំពោះចំណូល៖ ការគ្រោងទុកដើមគ្រា ព្រមទាំងការកែប្រែ និង ចំណូលជាក់ស្តែង ដែលបែងចែកតាមក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ។

២-ចំពោះចំណាយ៖ ការគ្រោងទុកដើមគ្រា ការអនុញ្ញាតថ្មី និង ចំណាយជាក់ស្តែងនៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមមាតិកាថវិកា ។

៣-ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និង ចំណាយ និងការកែប្រែដែលបានធ្វើ ប្រសិនបើមានជាមួយនឹងលទ្ធផលចុងក្រោយនៃថវិការបស់រដ្ឋបាលសាធារណៈនីមួយៗ ។

ប្រតិបត្តិការ ដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ទាំងថវិការដ្ឋ និង ទាំងគណនីពិសេសរបស់រតនាគារជាតិ ត្រូវបង្ហាញជាលម្អិតនូវឥណទានដែលបានអនុម័តដើមឆ្នាំ និងឥណទានកែតម្រូវទៅតាមមាតិកាថវិកា ។

**មាត្រា ៨១.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ដែលត្រូវដាក់ជូនរដ្ឋសភាសុំការអនុម័ត និង ព្រឹទ្ធសភាសុំការពិនិត្យ ត្រូវភ្ជាប់ជាមួយនូវ៖

១-របាយការណ៍វិភាគស្តីពីលទ្ធផលនៃការប្រមូលចំណូល និង ស្ថានភាពនៃការអនុវត្តចំណាយថវិកា ។

២-របាយការណ៍ស្តីពីស្ថានភាពទូទៅនៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅក្នុងឆ្នាំអនុវត្តនិង

ស្តីពីស្ថានភាពនៃការសម្រេចបាននូវតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ។

៣-តារាងតុល្យការរបស់រាជរដ្ឋាភិបាល ។

ក្រោយពី បានប្រកាសឱ្យប្រើច្បាប់ទូទាត់ថវិកា ត្រូវបោះផ្សាយដូចគ្នានឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។

## ផ្នែកទី ២
## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

### មាត្រា ៨២.-

គណនេយ្យករសាធារណៈ ទទួលបន្ទុកប្រមូលចំណូល ទូទាត់ចំណាយរក្សាទុកដាក់មូលនិធិមូលបត្រ ផលិតផល និង សម្ភារៈដែលជាកម្មសិទ្ធិរបស់ស្ថាប័នសាធារណៈ ។ មានតែគណនេយ្យករសាធារណៈមួយគត់ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តប្រតិបត្តិការទាំងឡាយ និង ដោះស្រាយបញ្ហាមូលនិធិពាក់ព័ន្ធដទៃទៀតជាមួយចំណូល និង ចំណាយ ។

ក្នុងសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈ មានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និង ជាប្រាក់កាស ។

### មាត្រា ៨៣.-

គណនេយ្យករសាធារណៈ ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ។ គណនេយ្យករសាធារណៈមានអំណាចពិសេសរបស់ខ្លួន ។ មុនចូលកាន់តំណែង គណ-នេយ្យករសាធារណៈ ត្រូវតែធ្វើសច្ចាប្រណិធានជាផ្លូវការតាមបែបបទត្រឹមត្រូវនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ។ អាណាប័កដើមខ្សែ និង អាណាប័កផ្ទេរសិទ្ធិព្រមទាំងគណនេយ្យករសាធារណៈដទៃទៀត ត្រូវទទួលស្គាល់គណនេយ្យករសាធារណៈ ដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៨៤.-**

រាល់ការអនុវត្តចំណូល និង ចំណាយនៃថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញត្តិ និង សេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រាល់ការកត់ត្រា ចំណូល និង ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមប្លង់គណនេយ្យ និង មាតិកាថវិកា ហើយរាល់របាយការណ៍គណនេយ្យ និង ហិរញ្ញវត្ថុ ត្រូវមានតម្លាភាព និង ផ្សព្វផ្សាយជាសាធារណៈ ។

រាល់ប្រតិបត្តិការហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាន និង ទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំទូទាត់ថវិកាប្រចាំឆ្នាំ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ៨៥.-**

មន្ត្រីសាធារណៈគ្រប់ប្រភេទ និង គ្រប់ឋានៈ ដែលបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និង ភារកិច្ចរបស់ខ្លួន ដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និង ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។ ក្នុងករណីកំហុសរបស់មន្ត្រីសាធារណៈនោះ បានធ្វើឱ្យមានការបាត់បង់ប្រាក់កាស ឬ ខូចខាតទ្រព្យសម្បត្តិសាធារណៈ នោះតម្លៃនៃការបាត់បង់ ឬ ការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬ ខូចខាតនេះ នឹងក្លាយជាបំណុលចំពោះមន្ត្រីសាធារណៈនោះដែលត្រូវសង និង បង់ចូលថវិការដ្ឋវិញ ។

**មាត្រា ៨៦.-**

មន្ត្រីសាធារណៈ ដែលបញ្ជាក់នៅក្នុងមាត្រា ៨៥ នៃច្បាប់នេះ រួមបញ្ចូលទាំងមន្ត្រីសា-ធារណៈដែលកំពុងបម្រើការងារ និង មន្ត្រីសាធារណៈដែលធ្លាប់បានបម្រើការងារ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៨៧.-**

បទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធផ្សេងទៀត ដែលផ្អែកលើមូលដ្ឋានច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ព្រមទាំង អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល និង ប្រកាសសារាចរណែនាំផ្សេងៗរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលជាបទដ្ឋានគតិយុត្តគាំទ្រសម្រាប់ការអនុវត្តច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុខាងលើមានសុពលភាព អនុវត្តរហូតដល់មានបទប្បញ្ញត្តិនៃច្បាប់ អនុក្រឹត្យ.សេចក្តីសម្រេច បទបញ្ជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល និង ប្រកាសសារាចរណែនាំផ្សេងៗរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមកជំនួសថ្មី ស្របតាមស្មារតីនៃច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៨៨.-**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតមិនស្របគ្នានឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៨៩.-**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ ត្រូវជំនួសច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងបទប្បញ្ញត្តិទាំងឡាយដែលជាវិសោធនកម្មនៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩១.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៧.០៥០៥.៥៣៣ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ ៤៩៤ ច.ល
**ដើម្បីចម្លងចែក**
ភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុន ជិនកេន**

# ព្រះរាជក្រម

នស/រកម/០៦១១/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# របបហិរញ្ញវត្ថុ

# និងការគ្រប់គ្រងទ្រព្យសម្បត្តិ

# របស់

# រដ្ឋបាលថ្នាក់ក្រោមជាតិ

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់អំពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងបង្កើតនូវប្រភពធនធានហិរញ្ញវត្ថុ ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពសមស្រប ក្នុងការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាព និង លើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មិនមានវិសាលភាពអនុវត្តចំពោះរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់ទេ លើកលែងតែមានបទប្បញ្ញត្តិដែលចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ហៅកាត់ថា "រដ្ឋបាលថ្នាក់ក្រោមជាតិ" គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានទ្រព្យសម្បត្តិ ធនធានហិរញ្ញវត្ថុ និង ថវិកាផ្ទាល់របស់ខ្លួន ។

នៅក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ពាក្យថា "រដ្ឋបាលថ្នាក់ក្រោមជាតិ" គឺសំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៥.-**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋាន ដូចមានចែងនៅក្នុង មាត្រា ២ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

Kse

## ជំពូកទី ២
## សមត្ថកិច្ច និង ការគ្រប់គ្រងហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិ
## របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៦.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និង ធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋ និងត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និង ចាត់ចែងកិច្ចការហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និង ចំពោះរាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការ ។

**មាត្រា ៧.-**

ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវទទួលខុសត្រូវ ដូចខាងក្រោម :

- ពិនិត្យ និង អនុម័តផែនការអភិវឌ្ឍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ពិនិត្យ និង អនុម័តផែនការយុទ្ធសាស្ត្រថវិកា និង គម្រោងថវិកាប្រចាំឆ្នាំដែលដាក់ជូនដោយអភិបាល និង មានសិទ្ធិក្នុងការផ្លាស់ប្តូរថវិកា ក្នុងករណីការផ្លាស់ប្តូរមិនរំលោភច្បាប់ បទបញ្ញា ឬ គោលការណ៍នៃការរៀបចំថវិកា
- ពិនិត្យ និង អនុម័តការកែសម្រួលថវិកាទៅតាមសំណើរបស់អភិបាល
- ពិនិត្យ និង អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យ និង អនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមវិធាន និង បទបញ្ញាជាធរមាន
- តាមដានត្រួតពិនិត្យការអនុវត្តហិរញ្ញវត្ថុ និង ថវិការបស់អភិបាល
- ពិនិត្យ និង អនុម័តកិច្ចសន្យាកិច្ចព្រមព្រៀងដែលបង្កើតការសន្យាហិរញ្ញវត្ថុ ឬ អត្ថប្រយោជន៍លើសពីឆ្នាំថវិកាកំពុងអនុវត្ត ។

**មាត្រា ៨.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីជាតំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។ នៅក្នុងវិស័យ

ហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ជាអ្នកប្រតិបត្តិផ្ទាល់តាមដីកា និង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តច្បាប់នេះ។

**មាត្រា ៩.-**

អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវចំពោះកិច្ចការដូចខាងក្រោម :

- រៀបចំផែនការអភិវឌ្ឍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ
- អនុវត្តផែនការសកម្មភាព និង គម្រោងថវិកាប្រចាំឆ្នាំ ដែលក្រុមប្រឹក្សាបានអនុម័តស្របទៅតាមវិធាននិងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុជាធរមាន
- រាយការណ៍ជាទៀងទាត់ជូនក្រុមប្រឹក្សាអំពីការអនុវត្តផែនការសកម្មភាព និង គម្រោងថវិកាប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍អនុវត្តចំណូលចំណាយថវិកាប្រចាំឆ្នាំ និង របាយការណ៍ផ្សេងៗទៀតដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តតាមកាលកំណត់
- រាយការណ៍ជាទៀងទាត់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័នពាក់ព័ន្ធអំពីការអនុវត្ត និង ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោយពេលដែលរបាយការណ៍នានាបានអនុម័តដោយក្រុមប្រឹក្សារួចហើយ
- គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និង ថែរក្សាទ្រព្យសម្បត្តិដែលថ្នាក់ជាតិប្រគល់ឲ្យកាន់កាប់នៅក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ១០.-**

ប្រធានហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការជួយក្រុមប្រឹក្សា និង អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យសម្រេចបាននូវរាល់ភារកិច្ចដូចបានបញ្ជាក់ក្នុង មាត្រា ៧ និង មាត្រា ៩ នៃច្បាប់នេះ ។

ប្រធានហិរញ្ញវត្ថុត្រូវបំពេញតួនាទីខាងលើនេះ ដោយមានការសម្របសម្រួលពីនាយករដ្ឋបាល និង មានកិច្ចសហការជាមួយអង្គភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ប្រធានហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្រោមសិទ្ធិអំណាចអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ប្រធានហិរញ្ញវត្ថុត្រូវបានតែងតាំងដោយក្រុមប្រឹក្សា បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការជ្រើសរើស តែងតាំង និង ការកំណត់លក្ខណៈសម្បត្តិប្រធានហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១១.-**

ចំពោះវិស័យហិរញ្ញវត្ថុនៅក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកទី ៣ នៃច្បាប់នេះ អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សាគឺជាអាណាប័កដើមខ្សែ ជាអ្នករៀបចំ និង អនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ក្នុងការអនុវត្តថវិកាស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សាជាអ្នកបញ្ជាចំណូល សន្យាចំណាយ ជម្រះបញ្ជី និង បញ្ជាចំណាយដោយផ្អែកលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុម័ត និង ជាអ្នកគ្រប់គ្រង បង្កើត និង បញ្ឈប់គណនីរដ្ឋបាល។

**មាត្រា ១២.-**

អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរក្នុងការសម្រេចលើថវិកាឲ្យទៅអភិបាលរងណាម្នាក់ ជាអាណាប័កផ្ទេរសិទ្ធិដែលធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និង ត្រួតពិនិត្យរបស់អភិបាល ។ អាណាប័ក និង អាណាប័កផ្ទេរសិទ្ធិត្រូវតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករសាធារណៈ ។

**មាត្រា ១៣.-**

ខណ្ឌ និង សង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួនស្ថិតនៅក្នុងថវិការបស់រាជធានី ។ អភិបាលខណ្ឌ និង ចៅសង្កាត់របស់រាជធានី ជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលរាជធានីចំពោះថវិការបស់ខ្លួន ។

សង្កាត់ចំណុះក្រុងត្រូវមានថវិការបស់ខ្លួនស្ថិតនៅក្នុងថវិការបស់ក្រុង ។ ចៅសង្កាត់របស់ក្រុងជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលក្រុងចំពោះថវិការបស់ខ្លួន ។

ទម្រង់រចនាសម្ព័ន្ធ និង នីតិវិធីនៃការដាក់បញ្ចូលថវិកាខណ្ឌ និង សង្កាត់ ទៅក្នុងថវិការាជធានី និង ថវិកាសង្កាត់ទៅក្នុងថវិកាក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤.-**

ការកាន់កាប់ប្រាក់កាសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធានាដោយគណនេយ្យករសាធារណៈផ្ទាល់របស់រតនាគារ ដែលទទួលអនុវត្តពីអាណាប័កនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគោរពយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍ត្រួតពិនិត្យ និង គ្រប់គ្រងគណនេយ្យសាធារណៈជាធរមាន ។

**មាត្រា ១៥.-**

រតនាគារនៅថ្នាក់ក្រោមជាតិ ត្រូវបំពេញមុខងារជាគណនេយ្យករសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវអនុវត្តភារកិច្ចទាំងឡាយ ដូចខាងក្រោម :

- ប្រមូលឬទទួលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទូទាត់ចំណាយដែលបានចេញអាណត្តិដោយអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រង និងបើកផ្តល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់
- ថែរក្សាទុកដាក់រាល់ឯកសារ សក្ខីបត្រ និង បញ្ជីគណនេយ្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៦.-**

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានរតនាគារ ប្រធានសាខាឬស្នាក់ការពន្ធដារដែលបោះទីតាំងនៅថ្នាក់ក្រោមជាតិជាអ្នកទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជួយដល់ក្រុមប្រឹក្សា និង អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តច្បាប់នេះ ។

## ជំពូកទី ៣
## ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
### ផ្នែកទី ១
### គោលការណ៍គ្រប់គ្រងថវិកា

**មាត្រា ១៧.-**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុ និង ថវិកាសមស្រប ដើម្បីអនុវត្តរាល់មុខងារភារកិច្ចសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ប្រចាំឆ្នាំត្រូវបានគ្រោង និង អនុញ្ញាតនូវប្រភពធនធាន និង បន្ទុកទាំងអស់ដោយត្រូវធានាឲ្យបាននូវតុល្យភាពនៃថវិកា ។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**មាត្រា ១៨.-**

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និង អនុម័តប្រចាំឆ្នាំនីមួយៗ ។ ការិយបរិច្ឆេទនៃឆ្នាំថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ។

ថវិកាដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ និង អនុម័តដោយមានតុល្យភាពពិតប្រាកដរវាងចំណូល និង ចំណាយទៅតាមទម្រង់ និង ចំណាត់ថ្នាក់ថវិកា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១៩.-**

ថវិកាដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ អនុម័ត និង អនុវត្តស្របតាមគោលការណ៍ ដូចខាងក្រោម :

- ត្រូវផ្សព្វផ្សាយព័ត៌មានឲ្យបានពេញលេញអំពីការរៀបចំ និងការអនុម័តថវិកា
- រាល់ចំណូល និងចំណាយទាំងអស់ត្រូវតែជាផ្នែកនៃថវិកាឯកភាពតែមួយគត់
- ថវិកាត្រូវបញ្ចូលចំណូល និងចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចំណូលត្រូវប្រមូល និងបង្ហាញជាទឹកប្រាក់សរុបដោយគ្មានការកាត់កងចំណាយណាមួយឡើយ
- គ្មានចំណូលណាមួយត្រូវបានកំណត់សម្រាប់ការចំណាយជាក់លាក់ណាមួយឡើយ លើកលែងតែមានការអនុញ្ញាតដែលកំណត់ដោយបទប្បញ្ញត្តិដោយឡែក
- សរុបគម្រោងចំណាយត្រូវធានាទាំងស្រុងដោយសរុបគម្រោងចំណូល
- គ្មានចំណូល ឬ ចំណាយណាមួយត្រូវប្រមូល ឬ ប្រើប្រាស់ក្រៅពីខ្ទង់ថវិកាដែលបានអនុម័តឡើយ។

**មាត្រា ២០.-**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំ អនុម័ត និង អនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ត្រូវបញ្ជាក់អំពីការព្យាករណ៍ដែលមានលក្ខណៈប្រាកដប្រជាលើមូលដ្ឋានចំណូលសម្រាប់រយៈពេលមធ្យម និង វិធានដែលចំណូលទាំងនេះត្រូវបានបែងចែកទៅតាមខ្ទង់ចំណាយនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទម្រង់បែបបទសម្រាប់ការរៀបចំ និង ការអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២១.-**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឲ្យប្រាក់គេខ្ចី បោះផ្សាយសញ្ញាប័ណ្ណ ផ្តល់ការធានាជាលិខិតជានា និង ធ្វើទង្វើណាដោយផ្ទាល់ ឬ ដោយប្រយោលដែលអាចនាំឲ្យកើតមាន

នូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀតដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជា បានទេ ។

ចំពោះការទទួលហិរញ្ញប្បទានឥតសំណង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានការឯកភាពជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២២.-**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រប់គ្រង និង ប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និង ចំពោះរាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការ ។

## ផ្នែកទី ២
## បន្ទុក និង ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ២៣.-**

ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :

- ចំណាយប្រតិបត្តិការរដ្ឋបាល
- ចំណាយក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច
- ចំណាយក្នុងការអនុវត្តមុខងារជាជម្រើស និង
- ចំណាយក្នុងការអនុវត្តតួនាទី ភារកិច្ចផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត ។

**មាត្រា ២៤.-**

ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :

- ចំណូលពីប្រភពនៅមូលដ្ឋាន
- ចំណូលពីថ្នាក់ជាតិ
- ចំណូលផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា ២៥.-**

ចំណូលពីប្រភពនៅមូលដ្ឋានរួមមាន ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ :

១- ចំណូលសារពើពន្ធនៅមូលដ្ឋានជាចំណូលពន្ធ និង អាករដែលត្រូវបង្កើត និង កំណត់ដោយច្បាប់ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសារពើពន្ធ ដើម្បីជាគុណប្រយោជន៍ទាំងស្រុងដល់ថវិកា

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ការបែងចែកប្រភេទ និង សមាមាត្រចំណូលពន្ធ និង អាករនៅមូលដ្ឋានរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានរួមមាន :

- ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កម្រៃសេវា និងចំណូលផ្សេងៗ

- ការបែងចែកចំណូលមិនមែនសារពើពន្ធ នៅមូលដ្ឋានរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និង តារាងតម្លៃអតិបរមាសម្រាប់ការប្រមូលចំណូលពីកម្រៃសេវា និង ចំណូលផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- អំណោយដែលបានមកពីប្រភពខាងក្នុង និង ខាងក្រៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ

- ចំណូលពីប្រភពផ្សេងៗដែលកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា ២៦.-**

ប្រភពចំណូលពីថ្នាក់ជាតិ រួមមាន :

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថវិកាថ្នាក់ជាតិ និង
- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៧.-**

ចំណូលចែករំលែកគឺជាចំណូលដែលត្រូវចែករំលែករវាងថ្នាក់ជាតិ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។ ប្រភេទចំណូល និង សមាមាត្របែងចែកត្រូវកំណត់ដោយច្បាប់ ឬ អនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៨.-**

មូលនិធិផ្ទេរពីថវិកាជាតិ រួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និង មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលពីថវិកាជាតិប្រចាំឆ្នាំ នូវមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និង មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ដែលត្រូវធ្វើឡើងជាដំណាក់កាលៗសម្រាប់ឆ្នាំនីមួយៗ ។

នីតិវិធី និង បែបបទនៃការផ្ទេរមូលនិធិពីថវិកាជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៩.-**

មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ ជាមូលនិធិដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ :

- ដើម្បីគ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារជាកាតព្វកិច្ចមួយ ឬ ច្រើនដែលត្រូវបានផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ឬ
- ដើម្បីបន្តគ្រប់គ្រង ឬ ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយ ឬ ច្រើនដែលក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ
- សំរាប់គោលបំណងជាកាតព្វកិច្ចមួយឬច្រើនដែលបានកំណត់ ។

ទម្រង់បែបបទ វិធាន និង លក្ខខណ្ឌនៃការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៣០.-**

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ជាមូលនិធិដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ដើម្បី :

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារភារកិច្ចក្នុងការបង្កើត ការជំរុញ និង ការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារជាជម្រើសនានា ។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលពីថវិកាជាតិប្រចាំឆ្នាំ នូវមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និងរូបមន្តប្រកបដោយតម្លាភាព ។

ទម្រង់បែបបទ វិធាន និង លក្ខខណ្ឌនៃការផ្ទេរមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៣១.-**

ត្រូវបង្កើតឲ្យមានមូលនិធិក្រុង ស្រុក ដែលមានគណនីដោយឡែកនៅរតនាគារជាតិ ដើម្បីទទួលមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថវិកាជាតិ និង ទទួលធនធានពីប្រភពផ្សេងៗទៀតសម្រាប់ជា

ROYAUME DU CAMBODGE · LE MINISTRE DU PLAN

ប្រយោជន៍ដល់ថវិកាថ្នាក់រដ្ឋបាលក្រុង និង ស្រុក ។

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌដែលត្រូវផ្ទេរពីថវិកាជាតិទៅមូលនិធិក្រុង ស្រុក ត្រូវធ្វើឡើងជាដំណាក់កាលៗក្នុងឆ្នាំនីមួយៗ តាមរូបមន្ត ឬ អត្រាជាក់លាក់ និង អាចប៉ាន់ប្រមាណបានសម្រាប់រយៈពេលមធ្យម។

ការវិភាជន៍ធនធានពីមូលនិធិក្រុង ស្រុកជូនទៅ រដ្ឋបាលថ្នាក់ក្រុង ស្រុកនីមួយៗ ត្រូវធ្វើឡើងប្រចាំឆ្នាំដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និង រូបមន្តប្រកបដោយតម្លាភាព ។

ការបង្កើត និង វិធានអនុវត្តរបស់មូលនិធិក្រុង ស្រុក ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៣២.-**

រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបាននូវចំណូលអំពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣៣.-**

រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបាននូវមុខងារជាភ្នាក់ងារក្នុងនាមរាជរដ្ឋាភិបាល ឬ ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយផ្អែកទៅតាមច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

រដ្ឋបាលថ្នាក់ក្រោមជាតិអាចពិភាក្សាឯកភាពគ្នាជាមួយក្រសួងស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រដ្ឋបាលថ្នាក់ជាតិ ដើម្បីទទួលអនុវត្តនូវកិច្ចការអ្វីមួយតាមរយៈកិច្ចសន្យា ឬ កិច្ចព្រមព្រៀងដែលក្នុងនោះបានកំណត់ច្បាស់អំពីកិច្ចការដែលត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត លទ្ធផលដែលត្រូវសម្រេច និង ប្រាក់កម្រៃដែលភ្នាក់ងារអនុវត្តត្រូវបានទទួល ។

ទម្រង់បែបបទ និង វិធាននៃការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៣
## ការរៀបចំ និង ការអនុម័តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៣៤.-**

ផែនការយុទ្ធសាស្ត្រថវិកា និង គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយអភិបាលនៃគណៈអភិបាល និង អនុម័តដោយក្រុមប្រឹក្សា ទៅតាមនីតិវិធីដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ គឺជាកញ្ចប់ថវិកាមួយដែលត្រូវបញ្ជូនមកពិនិត្យអនុម័តដោយរដ្ឋសភា និង ព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌនៃការពិនិត្យ និង អនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។ ក្រោយពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានពិនិត្យ និង អនុម័តពីរដ្ឋសភា និងព្រឹទ្ធ-សភារួចហើយ កញ្ចប់ថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកទៅតាមក្រុមប្រឹក្សានីមួយៗ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៣៥.-**

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំទៅតាមប្រតិទិនដូចខាងក្រោម :

**១- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែមីនា ដល់ខែឧសភា)**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំយុទ្ធសាស្ត្រថវិកា ដល់គ្រប់ក្រសួងស្ថាប័ន អង្គភាពទាំងអស់ដើម្បីជូនដំណឹងដល់ក្រុមប្រឹក្សានីមួយៗនូវកម្មវិធី និង គម្រោងថវិកាក្នុងវិស័យរបស់ខ្លួន ដែលត្រូវអនុវត្តនៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។ ក្នុងនាមក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ដោយឈរលើមូលដ្ឋានផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួចហើយដាក់ជូនក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ ពិភាក្សា និងអនុម័តហើយត្រូវផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបូកសរុបផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

**២- ការរៀបចំកញ្ចប់ថវិកា (ពីខែមិថុនា ដល់ខែកញ្ញា)**

នៅសប្តាហ៍ទី ១ នៃ ខែ មិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ពីទម្រង់បែបបទនីតិវិធីនៃការរៀបចំគម្រោងថវិកា និង ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ ហើយផ្ញើទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន ។ អភិបាលនៃគណៈអភិបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពគោលនយោបាយនៃរដ្ឋបាលរបស់ខ្លួន ដោយដាក់បញ្ចូលនូវរាល់ប្រភពថវិកាទាំងអស់ដែលត្រូវអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងដោយអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដោយមានជំនួយពីប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា និង មន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកានេះដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួចហើយត្រូវ

ពិនិត្យ និង រៀបចំឡើងវិញនូវគម្រោងថវិកានេះ ដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំជាសាធារណៈយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ ខែ មិថុនា ។

ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មឲ្យអភិបាលនៃគណៈអភិបាលខេត្តទទួលខុសត្រូវ ក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ បទបញ្ជា បែបបទ និងនីតិវិធីនានា ដែលកំណត់ដោយថ្នាក់ជាតិ ។ អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការគាំទ្របច្ចេកទេសនេះ ។

អភិបាលនៃគណៈអភិបាលខេត្ត ត្រូវជានាថាមន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការបូកសរុបគម្រោងថវិការបស់ខេត្ត គម្រោងថវិការបស់ក្រុង គម្រោងថវិការបស់ស្រុកក្នុងខេត្តរបស់ខ្លួនចូលក្នុងទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយភ្ជាប់ជាមួយនូវគម្រោងថវិកា និងសេចក្តីអត្ថាធិប្បាយពន្យល់របស់ខេត្ត របស់ក្រុង របស់ស្រុក ហើយត្រូវផ្ញើគម្រោង និងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំនីមួយៗ ។

ក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យនីត្យានុកូលភាព និង បញ្ជាក់អនុលោមភាពលើថវិការបស់រាជធានី ថវិការបស់ខេត្ត ថវិការបស់ក្រុង និងថវិការបស់ស្រុក ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មនូវការពិនិត្យនីត្យានុកូលភាពទៅដល់អង្គភាពជំនាញរបស់ខ្លួន ឬ អាជ្ញាធរណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់ ។

ដំណើរការពិនិត្យនីត្យានុកូលភាព ត្រូវមានការចូលរួមពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង និង ស្រុកដែលតំណាងឲ្យក្រុមប្រឹក្សាជាម្ចាស់ថវិកា តំណាងក្រសួងមហាផ្ទៃ និង សមាសភាពដទៃទៀតដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ក្នុងដំណើរការពិនិត្យនីត្យានុកូលភាពនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់លើគោលការណ៍នៃការពិនិត្យនីត្យានុកូលភាព ដូចខាងក្រោម :

- គម្រោងថវិកាបានរៀបចំឡើងទៅតាមទម្រង់ចំណាត់ថ្នាក់ថវិកាបែបបទ និង នីតិវិធីដែលបានកំណត់
- មានការចូលរួមពីប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំថវិកា
- ការគ្រោងឥណទានទៅតាមគោលការណ៍ចំណាយចាំបាច់
- គម្រោងថវិកាត្រូវគ្រោងតាមលក្ខខណ្ឌដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពផ្សេងៗដែលបានកំណត់ទុកជាមុន

- ធានាឲ្យមានតុល្យភាពពិតប្រាកដរវាងចំណូល និង ចំណាយថវិកា

- មានការពិភាក្សាអនុម័តគម្រោងថវិកាក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ។

ក្នុងករណីដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យឃើញថាគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនស្របទៅនឹងគោលការណ៍ពិនិត្យនីត្យានុកូលភាពដូចបានចែងខាងលើ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវសម្រេចកែសម្រួល និង ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំកែសម្រួលឡើងវិញទៅតាមនីតិវិធីជាធរមាន ។

**៣- ការអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ពីខែតុលា ដល់ខែធ្នូ)**

នៅសប្តាហ៍ទី ១ នៃ ខែ តុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបញ្ជូនគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ សម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី ១ នៃ ខែ វិច្ឆិកា ដើម្បីពិនិត្យអនុម័តនិងដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទី ១ នៃ ខែ ធ្នូ ដើម្បីសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

**មាត្រា ៣៦.-**

ប្រសិនបើគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែ មករា នៃឆ្នាំសារពើពន្ធការិយបរិច្ឆេទដែលត្រូវអនុវត្តទេនោះ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិប្រមូលចំណូលតាមលក្ខខណ្ឌដែលបានអនុម័តដូចឆ្នាំមុន និង ធានាចំណាយប្រចាំខែ ក្នុងកម្រិត ១/១២ នៃថវិកាឆ្នាំមុន ។

## ផ្នែកទី ៤
## ការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៣៧.-**

ដើម្បីបម្រើឲ្យប្រតិបត្តិការចំណូល ចំណាយថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបើកគណនីប្រាក់បញ្ញើនៅធនាគារថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ។

**មាត្រា ៣៨.-**

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិអាចត្រូវបានកែតម្រូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃ

ចំណូល និង ចំណាយ ។ ការកែតម្រូវថវិកាត្រូវរៀបចំពិនិត្យ អនុម័ត និង បញ្ជាក់ទទួលស្គាល់តាមនីតិវិធី ដូចមានចែងនៅក្នុង មាត្រា ៣៥ នៃច្បាប់នេះ ។

**មាត្រា ៣៩.-**

ចលនាឥណទានផ្ទៃក្នុងនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងក្នុងលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើនិយ័តកម្មឥណទានរបស់ខ្លួន ដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់បន្ទាន់ ។

**មាត្រា ៤០.-**

ប្រភេទឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក អាចត្រូវបានប្រើប្រាស់សម្រាប់ធានាចំពោះចំណាយទាំងឡាយណាដែលការវិភាជន៍មិនបានកំណត់ជាក់លាក់ នៅពេលឥណទានត្រូវបានអនុម័ត ឬ សម្រាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

អភិបាលត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ពេលមានតម្រូវការប្រើប្រាស់ឥណទានចំណាយថវិកាមិនបានគ្រោងទុក ។

**មាត្រា ៤១.-**

គម្រោង ឬ កម្មវិធីដែលអនុវត្តមិនទាន់ចប់នៅក្នុងឆ្នាំថវិកា ត្រូវបានដាក់បញ្ចូលដើម្បីបន្តអនុវត្តដោយលើកគម្រោងចំណាយទៅក្នុងថវិកានៃឆ្នាំបន្ទាប់ ។

**មាត្រា ៤២.-**

ក្នុងករណីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឲ្យលេចចេញនូវឱនភាព រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវម្ចាស់ការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីធានាតុល្យភាពថវិកាឡើងវិញ ។ នៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានកើនលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបានគ្រោងទុក ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ឬ ធ្វើនិយ័តកម្មទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនានា ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទៅតាមកម្រិតចំណូលលើសដែលបានបញ្ជិកា ។ នៅដំណាច់ឆ្នាំ ថវិកាអតិរេកថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកត់ត្រាចូលគណនីលទ្ធផលនៃរតនាគារជាតិ ។

### មាត្រា ៤៣.-

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុសំរាប់ធ្វើអធិការកិច្ច និង សវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច ។ គោលបំណងនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និង សវនកម្ម គឺ សំដៅធានានូវតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព នៃប្រភពព័ត៌មានហិរញ្ញវត្ថុ និង ការវាយតម្លៃ នៃការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

របាយការណ៍អធិការកិច្ចហិរញ្ញវត្ថុ និង សវនកម្ម ដែលរួមមានបញ្ចូលនូវមតិយោបល់របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

### មាត្រា ៤៤.-

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យ ត្រូវប្រតិបត្តិតាមវិធានទាំងឡាយស្ដីពីការត្រួតពិនិត្យហិរញ្ញវត្ថុ ការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ដែលត្រូវកំណត់ដោយច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

### មាត្រា ៤៥.-

ការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជាជំពូកមួយនៃច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ។ គោរពតាមគោលការណ៍គណនេយ្យឯកភាព អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចរៀបចំ និង ផ្ដល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវរបាយការណ៍ស្ដីពីការអនុវត្តថវិកា និង ព័ត៌មានចាំបាច់ផ្សេងៗទៀតនៅពេលដំណាច់ឆ្នាំថវិកានីមួយៗ ។

### មាត្រា ៤៦.-

នៅដំណាច់ឆ្នាំថវិកា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវធ្វើការផ្ទៀងផ្ទាត់គណនេយ្យរដ្ឋបាលរបស់ខ្លួនជាមួយនឹងគណនីគ្រប់គ្រងដោយគណនេយ្យករសាធារណៈរបស់រតនាគារ និង រៀបចំរបាយការណ៍ស្ដីពីការអនុវត្តថវិកា ព្រមទាំងព័ត៌មានចាំបាច់ផ្សេងៗទៀត ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និង អនុម័ត និង ផ្ញើជូនមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការបូកសរុបជារបាយការណ៍រួមរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ រួចផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបូកសរុបជាសេចក្ដីព្រាងនៃការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និង ដាក់បញ្ចូលទៅក្នុងជំពូកមួយនៃសេចក្ដីព្រាងច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ដែលត្រូវដាក់ទៅសុំការពិនិត្យ និង អនុម័តពីរដ្ឋសភា និង ព្រឹទ្ធសភា ។

## ជំពូកទី ៤
## ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៤៧.-**

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមានទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឲ្យ និង ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង ។ រដ្ឋផ្ទេរ និង ប្រគល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិកាន់កាប់ និង ប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋមួយចំនួនដែលជាអចលនវត្ថុ ហើយស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗទៅតាមការកំណត់របស់រដ្ឋ ។

ការផ្ទេរ ប្រគល់ទ្រព្យសម្បត្តិរបស់រដ្ឋទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ការផ្ទេរ ប្រគល់ ត្រូវបានប្រតិបត្តិក្នុងលក្ខណៈដែលអាចដកហូតយកមកវិញបាន ។

**មាត្រា ៤៨.-**

ការផ្ទេរទ្រព្យសម្បត្តិពីថ្នាក់ជាតិដើម្បីជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ប្រើប្រាស់ជាសាធារណៈ ឬ សម្រាប់បំពេញនូវតម្រូវការនៃសេវាសាធារណៈ ត្រូវសមស្របទៅនឹងមុខងារ ដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

**មាត្រា ៤៩.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវបានផ្ទេរប្រគល់ឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ប្រើប្រាស់ និង ទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវថែរក្សាការពារឲ្យបានគង់វង្ស និង គ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

**មាត្រា ៥០.-**

ទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ជាកម្មសិទ្ធិផ្ទាល់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រង និង ប្រើប្រាស់ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ នៅក្នុងក្របខ័ណ្ឌដែលត្រូវកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា ៥១.-**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋ ។

## ជំពូកទី ៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៥២.-**

ក្នុងការអនុវត្តច្បាប់នេះដើម្បីឲ្យស្របទៅតាមតម្រូវការចាំបាច់ និង ផ្អែកតាមស្ថានភាព ជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួមទាំងរដ្ឋបាលឃុំ សង្កាត់ផង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើឡើងនូវអនុក្រឹត្យ ឬ ចេញប្រកាសដោយឡែកៗសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនោះ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ៥៣.-**

សមាជិកក្រុមប្រឹក្សា និង មន្ត្រីសាធារណៈគ្រប់ប្រភេទ និង គ្រប់ឋានៈដែលកំពុងបម្រើការងារ និង អ្នកដែលធ្លាប់បានបម្រើការងារកន្លងមក ហើយរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និង ភារកិច្ចរបស់ខ្លួនដែលបានប្រគល់ជូន នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាន ដោយមិនគិតដល់ទោសព្រហ្មទណ្ឌ និង ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ព្រមទាំងត្រូវសងបង់ចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិវិញ នូវរាល់តម្លៃបាត់បង់ខូចខាតទ្រព្យសម្បត្តិ ឬ ប្រាក់កាសសាធារណៈរួមទាំងការប្រាក់លើតម្លៃបាត់បង់ខូចខាត ដែលបង្កឡើងដោយកំហុសឆ្គងនេះ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៤.-**

ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលអនុវត្តកន្លងមកនៅមានសុពលភាពរហូតដល់មានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តថ្មីមក

ជំនួសស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ច្បាប់នេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៥៥.-**

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ បទប្បញ្ញត្តិទាំងឡាយដែលជាវិសោធនកម្មនៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង និង បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.១១០៦.៥៩៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**
**គាត ឈន់**

26/20

លេខៈ ៥៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

**យ៉ុន ជិនភេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៩ អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**តារាងគាតនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ**

**និងតារាងគាតនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.- គោលបំណង**

អនុក្រឹត្យនេះ មានគោលបំណងកំណត់តារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ។

**មាត្រា ២.- គោលដៅ**

អនុក្រឹត្យនេះ មានគោលដៅកំណត់ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល និងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជន។

**មាត្រា ៣.- វិសាលភាព**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់បៀវត្ស។

**មាត្រា ៤.- តារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ**

អនុលោមតាមមាត្រា ២០ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងតារាងខាងក្រោម÷

| ល.រ | ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ១ | ពី | 0៛ | ដល់ | ១៦ 000 000៛ | 0% |
| ២ | ពី | ១៦ 000 00១៛ | ដល់ | ២៤ 000 000៛ | ៥% |
| ៣ | ពី | ២៤ 000 00១៛ | ដល់ | ១0២ 000 000៛ | ១0% |
| ៤ | ពី | ១0២ 000 00១៛ | ដល់ | ១៥0 000 000៛ | ១៥% |
| ៥ | | | លើសពី | ១៥0 000 000៛ | ២0% |

**មាត្រា ៥.- តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ**

អនុលោមតាមមាត្រា ៤៧ ថ្មី (បី) នៃច្បាប់ស្តីពីសារពើពន្ធ និយោជិតនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្សប្រចាំខែ និងត្រូវបានកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងតារាងខាងក្រោម÷

| ល.រ | ភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ១ | ពី | 0៛ | ដល់ | ១ ៣00 000៛ | 0% |
| ២ | ពី | ១ ៣00 00១៛ | ដល់ | ២ 000 000៛ | ៥% |
| ៣ | ពី | ២ 000 00១៛ | ដល់ | ៨ ៥00 000៛ | ១0% |
| ៤ | ពី | ៨ ៥00 00១៛ | ដល់ | ១២ ៥00 000៛ | ១៥% |
| ៥ | | | លើសពី | ១២ ៥00 000៛ | ២0% |

**មាត្រា ៦.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៤ អនក្រ.បក

ថ្ងៃទី 26.01.00
លេខ 1312D

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និង ការប្រព្រឹត្តទៅនៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*** + ***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២ប អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០០០

# សម្រេច

*** + ***

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះកំណត់ការរៀបចំអង្គភាពនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង កំណត់បេសកកម្មរបស់ក្រសួង និង មុខការនៃអគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន និង នាយកដ្ឋាននានា ។

## ជំពូកទី ២
## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា២ .-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និង គ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច និង លើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និង សមធម៌សង្គម ។ បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំ និង ការអនុវត្តអោយបានត្រឹមត្រូវ នូវគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និង បទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និង ឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់ និង បទបញ្ញាពាក់ព័ន្ធផ្សេងទៀត ។

មាត្រា៣ .-

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានមុខងារ និង ភារកិច្ចដូចតទៅ÷

- រួមចំណែក រៀបចំ អនុវត្ត និង តាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល
- គ្រប់គ្រង និង សំរបសំរួល កិច្ចការកែទំរង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ពង្រឹងអភិបាលកិច្ចល្អ ទៅលើអ្វីដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ
- ធ្វើការបែងចែក និង បែងចែកឡើងវិញនូវផលទុនជាតិ តាមរយៈការប្រមូលចំណូល និង កម្មវិធីនីយកម្ម និង ថវិកានីយកម្មនៃចំណាយសាធារណៈ
- កសាងប្រព័ន្ធហិរញ្ញវត្ថុ អោយឯកភាពទូទាំងប្រទេស ហើយធានាអនុវត្តប្រព័ន្ធនេះ អោយបានត្រឹមត្រូវ តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និង ច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំនិមួយៗ ព្រមទាំងច្បាប់ពាក់ព័ន្ធ និង បទបញ្ញាផ្សេងទៀត
- រៀបចំកសាងសេចក្តីព្រាងច្បាប់ និង បទបញ្ញាផ្សេងៗ សំរាប់ការគ្រប់គ្រងម៉ាក្រូ-សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬ ជាលក្ខណៈអចិន្ត្រៃយ៍
- រៀបចំ និង គ្រប់គ្រងថវិការដ្ឋ
- រៀបចំ និង អនុវត្តគោលនយោបាយចំណូលថវិកាជាតិ
- ប្រមូលចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និង វិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ
- ពិនិត្យ និង ចុះទិដ្ឋាការ លើចំណាយរបស់ក្រសួង និង ស្ថាប័នរដ្ឋនានា
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- វិភាគតាមដាន និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង និង ដាក់ចេញនូវវិធានការដើម្បីតម្រង់ទិស និង កែលំអការគ្រប់គ្រងសេដ្ឋកិច្ច
- ចូលរួមចំណែកអភិវឌ្ឍ គ្រប់គ្រង និង ត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុ រួមមានកិច្ចការធានារ៉ាប់រង ទីផ្សារ មូលប័ត្រ ឆ្នោត ឡូតូ កាស៊ីណូ បេឡាសោធននិវត្តន៍ និង សេវាហិរញ្ញវត្ថុផ្សេងៗទៀត
- សហការជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ និង ចូលរួមក្នុងការរៀបចំ អនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល លើកិច្ចការសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង កិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចពិភពលោក ពិសេសកិច្ចការសមាហរណកម្មសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌអាស៊ាន
- ចូលរួមក្នុងការងារកៀងគរជំនួយ ព្រមទាំងរៀបចំផែនការខ្ចី និង សងបំណុលបរទេស ហើយតាមដាន និង ត្រួតពិនិត្យលើការអនុវត្តផែនការទាំងនោះ
- គ្រប់គ្រង និង ត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈនៃបណ្តាក្រសួង ស្ថាប័ន និង ខេត្ត- ក្រុង ព្រមទាំងស្ថាប័នរដ្ឋកាន់កាប់ ឬ ស្វ័យគ្រប់គ្រង
- ចូលរួមរៀបចំគោលនយោបាយ និង គ្រប់គ្រងកិច្ចការវិនិយោគ
- បំពេញមុខងារអធិការកិច្ច លើផ្នែកហិរញ្ញវត្ថុសាធារណៈ

- បណ្ដុះបណ្ដាល និងធ្វើក្រឹតការជាប្រចាំនូវមុខជំនាញសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដល់មន្ត្រីក្រសួង និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

មាត្រា៤ . -

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធដូចតទៅ÷

១- ថ្នាក់កណ្ដាល

ក- អគ្គលេខាធិការដ្ឋាន

ខ- ខុទ្ទកាល័យរដ្ឋមន្ត្រី

គ- អគ្គាធិការដ្ឋាន

ឃ- នាយកដ្ឋានពន្ធដារ

ង- ទីចាត់ការគយ និង រដ្ឋាករ

ច- រតនាគារជាតិ

ឆ- នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច

ជ- នាយកដ្ឋានលទ្ធកម្មសាធារណៈ

ឈ- នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ

ញ- នាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច

ដ- នាយកដ្ឋានវិនិយោគនិង សហប្រតិបត្តិការ

ឋ- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន

ឌ- នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

ឍ- នាយកដ្ឋានបុគ្គលិក

ណ- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

ត- នាយកដ្ឋាននីតិកម្ម

ថ- វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២- អង្គភាពមូលដ្ឋាន

- មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត ក្រុង
- រតនាគារខេត្ត ក្រុង " ថ្នាក់ស្មើការិយាល័យនៅថ្នាក់កណ្ដាល"
- សាខាពន្ធដារខេត្ត ក្រុង " ថ្នាក់ស្មើការិយាល័យនៅថ្នាក់កណ្ដាល " និង ស្នាក់ការពន្ធដារខ័ណ្ឌ ស្រុក " ថ្នាក់ស្មើការិយាល័យនៅខេត្ត ក្រុង "
- សាខាគយ និង រដ្ឋាករ ខេត្ត ក្រុង " ថ្នាក់ស្មើការិយាល័យនៅថ្នាក់កណ្ដាល " និង ស្នាក់ការគយ និង រដ្ឋាករ តាមមាត់ច្រកព្រំដែន" ថ្នាក់ស្មើការិយាល័យនៅខេត្ត ក្រុង " ។

៣- ក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ

អង្គការលេខរបស់ក្រសួងជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣
## អគ្គលេខាធិការដ្ឋាន

មាត្រា៥.-

អគ្គលេខាធិការដ្ឋានមានភារកិច្ចធ្វើជាលេខាធិការឱ្យក្រសួងលើការងារ ÷

- ធានានិរន្តរភាពនៃការងាររបស់ក្រសួង
- គ្រប់គ្រង សំរបសំរួល និង តាមដានកិច្ចការរបស់នាយកដ្ឋាន និង អង្គភាពទាំងឡាយរបស់ក្រសួង
- ធ្វើជាលេខាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើឡើងនូវគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និង តាមដានការអនុវត្តកិច្ចការកំណែទំរង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ក្នុងឋានៈជាផែនការគោល- នយោបាយរបស់ក្រសួង
- សំរបសំរួលកិច្ចការសហប្រតិបត្តិការអន្តរជាតិ និង សមាហរណកម្មសេដ្ឋកិច្ច
- សំរបសំរួលការងាររបស់ក្រុមទីប្រឹក្សាសេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងក្របខ័ណ្ឌនៃការអនុវត្តអនុក្រឹត្យ លេខ ២៥អនក្រ. បក ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃ ១០/០៦/១៩៩៧
- អគ្គលេខាធិការបំពេញមុខងារជាឧត្តមមន្ត្រីហិរញ្ញវត្ថុ សំរាប់អាស៊ាន

អគ្គលេខាធិការដ្ឋាន ដឹកនាំដោយអគ្គលេខាធិការមួយរូបនិង មានអគ្គលេខារងមួយចំនួនជាជំនួយការ ។

## ជំពូក ទី៤
## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា៦.-

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យ លេខ ២០អនក្រ-បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល

## ជំពូក ទី៥
## អគ្គាធិការដ្ឋាន

មាត្រា៧.-

អគ្គាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷ -

ក- អធិការកិច្ចផ្ទៃក្នុងក្រសួង

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយ និង លើកវិធានការកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- សហប្រតិបត្តិការជាប្រចាំជាមួយអាជ្ញាធរសវនកម្ម លើរាល់កម្មវត្ថុ ដែលពាក់ព័ន្ធទៅនឹង ហិរញ្ញវត្ថុសាធារណៈ

ខ- អធិការកិច្ចក្រសួង ស្ថាប័នខេត្ត ក្រុងនានា

- ធ្វើអធិការកិច្ចទូទៅលើគ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ពីវិន័យក្នុងកិច្ចប្រតិបត្តិការចំណូល- ចំណាយថវិកាជាតិ និង ពីការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ
- ធ្វើអធិការកិច្ចលើរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់បណ្តាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល និង គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនចំរុះ អង្គការនានា និង ក្រុមហ៊ុនឯកជន ដែលបានទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ទោះជាតាមរូបភាពណាក៏ដោយ
- ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ា និង បរិហាររបស់ពលរដ្ឋដែលទាក់ទងការគ្រប់គ្រងសេដ្ឋកិច្ច ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូបអមដោយអគ្គាធិការរងមួយចំនួនជាជំនួយការ ។

## ជំពូកទី ៦
## នាយកដ្ឋានពន្ធដារ

មាត្រា៨.-

នាយកដ្ឋានពន្ធដារមានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷

- លើកគោលនយោបាយសារពើពន្ធ និង ក្នុងការប្រមូលពន្ធដារគ្រប់ប្រភេទប

ចូលថវិកាជាតិ

- រៀបចំគោលនយោបាយ សេចក្ដីព្រាងច្បាប់ និង លិខិតបទដ្ឋានសារពើពន្ធ កំណត់បញ្ជីឯកសារចាំបាច់នានា និង លិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុកត្រូវកាន់រក្សាទុក និង ផ្ដល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និង ជុំពតិមាន
- គណនា និង ប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ពន្ធប្រថាប់ត្រា ការប្រាក់ និង ចំណូលផ្សេងៗ
- កសាងកម្មវិធី និង អនុវត្តការងារត្រួតពិនិត្យសារពើពន្ធលើលិខិតស្នាម និងពិនិត្យបញ្ជីគណនេយ្យសហគ្រាស
- ទទួលបន្ទុកសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តវិធានការពិន័យតាមច្បាប់ ចំពោះអ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុក
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

នាយកដ្ឋានពន្ធដារមានប្រព័ន្ធចាត់តាំង គ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំ និង ត្រួតពិនិត្យលើរាល់អង្គភាពពន្ធដារ ពីថ្នាក់កណ្ដាលរហូតដល់មូលដ្ឋានខេត្ត ក្រុងតាមការកំណត់របស់ក្រសួង ។

នាយកដ្ឋានពន្ធដារ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

## ជំពូក ទី៧ 3

## ទីចាត់ការគយនិងរដ្ឋាករ

មាត្រា៩. -

ទីចាត់ការគយ និង រដ្ឋាករមានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷

- លើកសំណើគោលនយោបាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មក្រៅប្រទេស សេចក្ដីព្រាងច្បាប់ និង បទបញ្ញត្តិពីការងារប្រមូល ពន្ធនាំចេញ-នាំចូលគ្រប់ប្រភេទ ពិសេសពិនិត្យពិចារណាកសាងអនុវត្តតារាងពន្ធគយ និង របបប្រមូលពន្ធនិងថ្លៃឈ្នួល ដែលទាក់ទងនឹងការងារគយរដ្ឋាករ លើមុខទំនិញគ្រប់ប្រភេទ អោយបានសមស្រប ទៅតាមដំណោក់កាលនីមួយៗ ÷

- គ្រប់គ្រងទំនិញនាំចេញ- នាំចូល
- លើកវិធានការរាំងខ្ទប់ និង ចាប់យាត់ទំនិញគេចពន្ធគយគ្រប់ប្រភេទ
- អនុវត្តការប្រមូលពន្ធលើទំនិញនាំចេញ- នាំចូលគ្រប់ប្រភេទ
- ត្រួតពិនិត្យតាមដាន និង គ្រប់គ្រងការនាំចេញ- នាំចូល ទំនិញ ឥវ៉ាន់អ្នកដំណើរ វប្បធម៌ លោហធាតុ ត្បូងថ្មមានតំលៃ បិតិកភ័ណ្ឌវប្បធម៌ កញ្ចប់ និង កញ្ចប់ប្រៃសណីយ៍ ព្រមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ
- លើកគំរោងបណ្តុះបណ្តាលជំនាញបច្ចេកទេស ដល់មន្ត្រី បុគ្គលិក និង ភ្នាក់ងារគយ រដ្ឋាករ
- អនុវត្តគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ច និង សហប្រតិបត្តិការជាមួយ បរទេសក្នុងផ្នែកការងារគយ- រដ្ឋាករ
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

អគ្គនាយកដ្ឋានគយ និង រដ្ឋាករ មានប្រព័ន្ធចាត់តាំងគ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំ និង ត្រួតពិនិត្យលើរាល់អង្គភាពគយ និង រដ្ឋាករ ពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋាន ខេត្ត ក្រុង តាមការកំណត់របស់ក្រសួង។

អគ្គនាយកដ្ឋានគយ និង រដ្ឋាករ ដឹកនាំដោយអគ្គនាយកមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាន និង មាននាយករងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ ។

## ជំពូកទី ៨ ៤

## ធនាគារជាតិ

មាត្រា១០. -

ធនាគារជាតិមានភារកិច្ចធ្វើជាលេខាធិការ ឱ្យក្រសួងលើការងារ ÷
- គ្រប់គ្រងបេឡា ថវិកាជាតិ ថវិកាស្វយ័ត និង គណនីក្រៅថវិកា
- ធ្វើតុល្យភាព និង គ្រប់គ្រងចំណូល- ចំណាយនៃថវិកាជាតិ
- រួមចំណែកក្នុងការតំរង់ទិសការអនុវត្តគោលនយោបាយរូបិយវត្ថុ
- តំរង់ទិស និង តាមដានការអនុវត្តគោលនយោបាយហិរញ្ញប្បទាន និងបំណុលសាធារណៈ
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋ និង គណនីពិសេសនៃធនាគារ
- កាន់កាប់ និង តាមដានការអនុវត្តគណនេយ្យទូទៅ និង មជ្ឈការគណនី

- រៀបចំគោលការណ៍ និង បទបញ្ញាគណនេយ្យ
- ធានាតុល្យភាពទូទៅនៃគណនី
- ផ្តល់សេវាដល់គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង លើការទូទាត់ការចំណាយផ្សេងៗ ការ-បើកបៀវត្ស និងការប្រមូលចំណូលស្របតាមច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- គ្រប់គ្រងប័ណ្ណរតនាគារជាតិដោយសហការជាមួយផ្នែកពាក់ព័ន្ធនៃធនាគារជាតិនៃកម្ពុជា
- គ្រប់គ្រងបេឡាប្រាក់បញ្ញើឯកជន
- ធ្វើទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តនយោបាយរូបិយវត្ថុ
- គ្រប់គ្រងគណនីរូបិយប័ណ្ណនៅធនាគារជាតិនៃកម្ពុជា
- ចូលរួមរៀបចំតារាងប្រតិបត្តិការហិរញ្ញវត្ថុ
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ។

រតនាគារជាតិមានប្រព័ន្ធចាត់តាំង និង គ្រប់គ្រងឯកភាពទូទាំងប្រទេសក្នុងការដឹកនាំ និង ត្រួតពិនិត្យមើលរតនាគារគ្រប់ខេត្ត ក្រុង តាមការកំណត់របស់ក្រសួង។

រតនាគារជាតិ ដឹកនាំដោយនាយកមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាន និង មាននាយករង មួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ ។

### ជំពូកទី ៩
### នាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច

មាត្រា១១.-

នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ចមានភារកិច្ចធ្វើជាលេខាធិការឱ្យក្រសួង លើការងាររៀបចំ និង អនុវត្តថវិកាជាតិ ដោយផ្អែក ទៅតាមភារកិច្ចដូចខាងក្រោម :

ក- ការកសាងសេចក្តីព្រាងច្បាប់ និង បទបញ្ញាហិរញ្ញវត្ថុសាធារណៈ
- រៀបចំកម្មវិធីចំណាយសាធារណៈ
- ស្រាវជ្រាវ និង បង្កើតបទដ្ឋានចំណូល- ចំណាយ ដើម្បីធ្វើជាមូលដ្ឋានក្នុងការកសាងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំនីមួយៗ និង បទបញ្ញានានា
- រៀបចំទូវត្ថលេខត្រួតពិនិត្យចំណូល- ចំណាយដល់បណ្តាខេត្ត ក្រុង
- ជួយណែនាំដល់បណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ក្នុងការរៀបចំ ការអនុវត្ត និង ការទូទាត់ថវិកាប្រចាំឆ្នាំ

ខ- ការចាត់តាំងអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំនីមួយៗ និង ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត- ក្រុង

- រៀបចំសន្ទស្សន៍ចំណូល ចំណាយថវិកា អោយបណ្តាក្រសួងស្ថាប័ន និង ខេត្ត ក្រុង ដើម្បីអនុវត្ត

- បើកផ្តល់ថវិកាអោយក្រសួងស្ថាប័នថ្នាក់កណ្តាល និង ខេត្ត ក្រុង ទៅតាមប្រភេទខ្ទង់ ប្រការ ជំពូក នៃតារាងរាយនាមថវិកាជាតិ

- កត់ត្រាចុះបញ្ជីគណនេយ្យថវិកាជាតិ ដើម្បីឆ្លុះបញ្ចាំងនូវសភាពការណ៍អនុវត្តថវិកា ប្រចាំថ្ងៃ សប្តាហ៍ ខែ ត្រីមាស ឆមាស និង ឆ្នាំ

- ជំរុញការរៀបចំរបាយការណ៍ប្រញាប់ របាយការណ៍គណនេយ្យ និង ចូលរួមកសាងតារាងប្រតិបត្តិការហិរញ្ញវត្ថុ ប្រចាំខែ

- ណែនាំអំពីមុខជំនាញបច្ចេកទេសហិរញ្ញវត្ថុ ថវិកាដល់បណ្តាអង្គភាពជំនាញ ទៅតាមបណ្តាក្រសួងស្ថាប័ន និង ខេត្ត ក្រុង

- តាមដានការអនុវត្តចំណូល ចំណាយថវិកាជាតិរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ។

គ- ការកសាងសេចក្តីព្រាងច្បាប់សំរាប់ទូទាត់ថវិកាជាតិប្រចាំឆ្នាំ

- រៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាជាតិរបស់ស្ថាប័ននៅថ្នាក់កណ្តាល និង ខេត្ត ក្រុង

- បូកសរុបរាល់សភាពការណ៍អនុវត្តថវិកា ប៉ាន់ស្មានការអនុវត្តន៍ដើម្បីធ្វើការវិភាគ និង វាយតំលៃអំពីសភាពការណ៍សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នាឆ្នាំខាងមុខ

ឃ- ផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ

- អនុវត្តអនុក្រឹត្យលេខ ៨១ អនក្រ. បក ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល និង អនុក្រឹត្យលេខ ៨២ អនក្រ. បក ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ អោយបានត្រឹមត្រូវ

- គ្រប់គ្រងសកម្មភាពសំរបសំរួល និង តាមដានការអនុវត្តរបស់អភិបាលហិរញ្ញវត្ថុ

- កសាងជារៀងរាល់ខែនូវកិច្ចសន្យាចំណាយ ដើម្បីផ្ទៀងផ្ទាត់ជាមួយគណនេយ្យរដ្ឋបាលរបស់អាណាប័ក និង ជាមួយគណនេយ្យចំណូល- ចំណាយ ដែលធ្វើឡើងដោយផ្នែកនានារបស់រតនាគារជាតិ

- កសាងកម្មវិធីត្រួតពិនិត្យជាមុន ចំពោះអភិបាលហិរញ្ញវត្ថុអំពីល័ក្ខខ័ណ្ឌនៃការអនុវត្តប្រសិទ្ធិភាពចំណាយ និង ចំណូល ព្រមទាំងស្នើឡើងនូវវិធានការកែតំរូវចាំបាច់ និង កសាងកម្មវិធីត្រួតពិនិត្យតាមក្រោយ ដោយសហការជាមួយអគ្គាធិការដ្ឋាន តាមរយៈនាយកដ្ឋានថវិកា ចំពោះកម្មវត្ថុដែលមានចែងក្នុងវាក្យខ័ណ្ឌនេះ

- ត្រួតពិនិត្យ និង ផ្តល់ទិដ្ឋាការនៃកិច្ចសន្យាចំណាយ

- ជំរុញ និង តាមដានការបង់ចំណូលមិនមែនសារពើពន្ធចូលក្នុងថវិកាជាតិ

- ផ្តល់ទិដ្ឋាការលើអណត្តិកិច្ច
- ផ្តល់យោបល់បច្ចេកទេសដល់អាណាប័កក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ
- ចូលរួមក្នុងការរៀបចំថវិកា និង ច្បាប់ហិរញ្ញវត្ថុ
- ចូលរួមជាសមាជិក ក្នុងគណៈកម្មាធិការលទ្ធកម្មសាធារណៈ

នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ចដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

## ជំពូកទី ១០

## នាយកដ្ឋានលទ្ធកម្មសាធារណៈ

មាត្រា១២. -

នាយកដ្ឋានលទ្ធកម្មសាធារណៈមានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ដូចមានចែងក្នុងមាត្រា ១៤ ១៥ ១៦ នៃអនុក្រឹត្យលេខ ៦០ អនក្រ. បក ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ជាអាទិ៍ :

- ត្រួតពិនិត្យលើការងារលទ្ធកម្មសាធារណៈនៃបណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង អង្គភាពស្វ័យគ្រប់គ្រង សហគ្រាសសាធារណៈទទួលបន្ទុកការងារបែងចែកប្រភេទ ចំណាត់ថ្នាក់ និង ការចុះបញ្ជី អ្នកទទួលការសាងសង់ និង ចុះទិដ្ឋាការលើឯកសារដេញថ្លៃ មុនពេលប្រកាសដាក់អោយដេញថ្លៃ
- ស្នើផ្តល់អនុសាសន៍ប្រគល់កិច្ចសន្យា ដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សំរេច
- ត្រួតពិនិត្យការអនុវត្តវិធាន និង បទប្បញ្ញត្តិ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅ តាមក្រសួង ស្ថាប័ន ខេត្ត ក្រុង អង្គភាពស្វ័យគ្រប់គ្រង សហគ្រាសសាធារណៈ និង ដាក់ចេញនូវវិធានការទាំងឡាយ ដើម្បីកាត់បន្ថយជាអប្បបរមានូវលទ្ធកម្មទាំងឡាយណាដែលមានទំនាស់ ក្នុងនោះ ត្រូវបង្កើអោយកសាងសំណុំរឿង និង ផ្តល់ពត៌មានផ្សេងៗ ដែលទាក់ទិនដល់ករណីទំនាស់ និង មានវិធានការចំពោះស្ថាប័នដែលបានប្រព្រឹត្តរំលោភលើវិធាន និង បទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ ដើម្បីដាក់ចេញនូវដំណោះស្រាយសមស្រប ។

នាយកដ្ឋានលទ្ធកម្មសាធារណៈដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង ប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

## ជំពូកទី ១១
## នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ

មាត្រា១៣. -

នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ មានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷

- គ្រប់គ្រងទ្រព្យ សម្បត្តិរដ្ឋ ផ្អែកលើមូលដ្ឋានច្បាប់ និង បទបញ្ញាជាធរមាន
- ពិនិត្យ រៀបចំបញ្ជី និង គ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ស្រាវជ្រាវ និង គ្រប់គ្រងទ្រព្យឥតម្ចាស់ និង មរតកឥតបណ្តឹង
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋ និង ដើមទុនរបស់រដ្ឋ
- គ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ
- ប្រមូលផ្តុំពត៌មានពាក់ព័ន្ធទៅនឹងការងារឯកជនភាវូបនីយកម្ម និង ការជំរះបញ្ជីសហគ្រាសសាធារណៈ
- រៀបចំសេចក្តីព្រាងច្បាប់ និង បទបញ្ញានានាដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រៀបចំបញ្ជីសម្បទានដី ព្រៃឈើ រ៉ែ និង ទ្រព្យសម្បត្តិរដ្ឋដទៃទៀតអោយផ្ទែកឯកជន
- រៀបចំនីតិវិធី វាយតំលៃការដាក់ជួល លក់ ផ្ទេរសិទ្ធិ ទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

## ជំពូក ទី១២
## នាយកដ្ឋានវិភាគ និងព្យាករណ៍សេដ្ឋកិច្ច

មាត្រា១៤. -

នាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច មានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷

- រៀបចំ និងតាមដាន ការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសំរាប់រយៈពេលខ្លី រយៈពេលមធ្យម និង រយៈពេលវែង

- ប្រមូលផ្តុំ និង ធ្វើសំយោគទិន្នន័យចាំបាច់នានា ដើម្បីធ្វើការវិភាគ និង ព្យាករណ៍អំពីស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាតិ និង អន្តរជាតិ ហើយផ្អែកលើមូលដ្ឋាននេះ ធ្វើការតាមដាន និង វាយតំលៃអំពីការវិវត្តនៃសកម្មភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងប្រទេស និង រៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសំរាប់ការប្រើប្រាស់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសំរាប់ការរៀបចំថវិកាជាតិ
- ទទួលបន្ទុករៀបចំ និង វិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ
- តាមដាន និង វិភាគការអនុវត្ត និង គោលប្រព្រឹត្តទៅនៃហិរញ្ញវត្ថុសាធារណៈ និង កម្មវិធីចំណាយសាធារណៈ ហើយផ្អែកលើមូលដ្ឋាននេះ លើកយោបល់ និង ស្នើវិធានការជូនថ្នាក់ដឹកនាំក្រសួង ដើម្បីកែលំអការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អោយមានប្រសិទ្ធភាព និង មានតុល្យភាព
- ទទួលបន្ទុកសំរបសំរួល និង តាមដានការអនុវត្ត «កម្មវិធីកែតម្រូវរចនាសម្ព័ន្ធ» ជាពិសេសក្នុងក្របខ័ណ្ឌសហប្រតិបត្តិការខាងផ្នែកកែទំរង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយនឹងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដែលក្នុងនោះមាន មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ជាដើម
- ទទួលបន្ទុកផ្សព្វផ្សាយអំពីសកម្មភាពសេដ្ឋកិច្ច និង ទិន្នន័យនានាដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ

នាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ចដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

## ជំពូកទី ១៣
## នាយកដ្ឋានវិនិយោគនិង សហប្រតិបត្តិការ

មាត្រា១៥ . -

នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ មានភារកិច្ចធ្វើជាលេខាធិការ ឱ្យក្រសួងលើការងារ ÷

- បំពេញតួនាទី ក្នុងការគ្រប់គ្រងវិនិយោគសាធារណៈ ក្នុងក្របខ័ណ្ឌប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ និង រៀបចំអាទិភាព វិនិយោគប្រចាំឆ្នាំសំរាប់គោលបំណងថវិកានីយកម្មលើគំរោងវិនិយោគសាធារណៈ ដោយសហការជាមួយក្រសួង ពាក់ព័ន្ធ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសំរាប់គំរោងវិនិយោគសាធារណៈ ដោយផ្អែកលើកម្មវិធីចំណាយសាធារណៈ និង កម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំដែលបានអនុម័តរួចហើយ
- ចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈចំពោះគំរោងវិនិយោគសាធារណៈដែលបានអនុម័តអោយវិនិយោគហើយ
- ចូលរួមរៀបចំគោលនយោបាយគ្រប់គ្រងការវិនិយោគឯកជន
- ចូលរួមក្នុងការងារពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគទុន និង ការតាមដាន ឃ្លាំមើលការអនុវត្តគំរោងវិនិយោគទុនឯកជន
- ពិនិត្យការផ្តល់ការលើកទឹកចិត្តក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ
- ចូលរួមតាមដានការប្រើប្រាស់ សំភារៈ វត្ថុធាតុដើម ដែលបំរើអោយការវិនិយោគឯកជន
- តាមដាន និង ចូលរួមគ្រប់គ្រងការអនុវត្តគំរោងដែលហិរញ្ញប្បទានដោយបរទេសតាមរយៈ
    - ការត្រួតពិនិត្យ ការទូទាត់ និង ការងារលទ្ធកម្ម(ចំពោះគំរោងដែលត្រូវអនុវត្តនីតិវិធីអ្នកផ្តល់ជំនួយ)
    - តាមដាន និង ត្រួតពិនិត្យការប្រើប្រាស់មូលនិធិបរិភាគ និងការគ្រប់គ្រងគណនីជំនួយបរទេស
    - ការត្រួតពិនិត្យជាប្រចាំលើគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុ

- សហប្រតិបត្តិការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអន្តរជាតិជាមួយអង្គការហិរញ្ញវត្ថុអន្តរជាតិ និង ប្រទេសនានា
- រៀបចំ និង ចរចារាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ស្តីពីការផ្តល់ជំនួយ ការខ្ចី និងការធានា
- កសាងផែនការចំណូលពីជំនួយ និង ការខ្ចីបរទេស
- គ្រប់គ្រងបំណុលរបស់រដ្ឋ តាមរយៈការព្យាករណ៍លើការខ្ចី និង សេវាទូទាត់ បំណុល និង ការប្រាក់ ។ ល ។
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ

នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាន

នាយកដ្ឋានមួយចំនួន ជាជំនួយការ ។

## ជំពូកទី ១៤
## នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន

មាត្រា១៦.-

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន មានភារៈកិច្ចធ្វើជាសេនាធិការឱ្យក្រសួងលើការងារ ÷

- រៀបចំតាមដាន និង អនុវត្តគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក ពិសេសសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងក្របខ័ណ្ឌអាស៊ាន
- បំពេញតួនាទីជាអង្គភាពបច្ចេកទេសក្នុងការរៀបចំ ពិនិត្យ និង ផ្តល់យោបល់លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង អនុស្សារណៈ និង ឯកសារសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងឯកសារច្បាប់ផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងកិច្ចការសមាហរណកម្មសេដ្ឋកិច្ច
- សំរបសំរួលការអនុវត្តកម្មវិធីកែទំរង់ និង ចូលរួមដឹកនាំការរៀបចំការងារបច្ចេកទេសនានា ដែលបំរើអោយទិសដៅសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និង ក្នុងពិភពលោក
- រួមចំណែកបំពេញភារកិច្ចទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិ ជាមួយសមភាគីបរទេសក្នុងផ្នែកកិច្ចការសមាហរណកម្មសេដ្ឋកិច្ច មានជាអាទិ៍ ជាមួយអាស៊ាន និង ដៃគូសន្ទនាទាំងឡាយរបស់អាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក អង្គការសហប្រតិបត្តិការអាស៊ីប៉ាស៊ីហ្វិច សហគមន៍អឺរ៉ុប តំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង ទីភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ ព្រមទាំងជាមួយដៃគូពហុភាគី និង ទ្វេភាគីផ្សេងទៀត ។

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន ដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

## ជំពូកទី ១៥
## នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

មាត្រា១៧.-

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងលើការងារ

- រួមចំណែកលើកគោលនយោបាយរូបិយវត្ថុ និង ក្នុងការគ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុនានា និង ការគ្រប់គ្រងទីផ្សារហិរញ្ញវត្ថុ

- រៀបចំសេចក្តីព្រាងច្បាប់ និង បទបញ្ញានានា សំរាប់ការគ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុ និង ទីផ្សារហិរញ្ញវត្ថុ

- គ្រប់គ្រងការងារមូលប័ត្រ បេឡាសោធននិវត្តន៍ កាស៊ីណូ ឡូតូ ឆ្នោត និង សេវាហិរញ្ញវត្ថុផ្សេងៗទៀត

- ចូលរួមក្នុងការងារគ្រប់គ្រងទីផ្សារមូលប័ត្រ និង សេវាហិរញ្ញវត្ថុ ដូចពោលខាងលើ

- គ្រប់គ្រងការងារធានារ៉ាប់រង

- គ្រប់គ្រង និង តាមដានលើការហូរមូលធនចូល និង ចេញពីប្រទេសកម្ពុជា ។

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

## ជំពូក ទី ១៦

## នាយកដ្ឋានរដ្ឋបាល

មាត្រា១៨ ..-

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷

ក/វិស័យរដ្ឋបាល

- សំរបសំរួលសកម្មភាពគ្រប់ថ្នាក់ គ្រប់ផ្នែករបស់ក្រសួង នៅថ្នាក់កណ្តាល និង រវាងថ្នាក់កណ្តាល និង ថ្នាក់អង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង

- គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង

- ធានាប្រសិទ្ធភាព សុវត្ថិភាព រដ្ឋបាលអោយបានទាន់ពេលវេលា

- សរុប និង ធ្វើរបាយការណ៍ការងារ និង សកម្មភាពផ្សេងៗរបស់ក្រសួង

- ចាត់ចែងការងារពិធីការ និង សហការរៀបចំទិវាបុណ្យជាតិ និង អន្តរជាតិនានា និង ពិធីផ្សេងៗរបស់ក្រសួង

ខ/វិស័យហិរញ្ញវត្ថុ

- លើកគំរោងថវិកាក្រសួង និង តាមដានវិលើកពីការប្រតិបត្តិ

- ប្រមូលផ្តុំ និង សំរបសំរួលជំពូកថវិកា បំរើអោយរាល់ចំណាយរបស់ក្រសួង

- គ្រប់គ្រងអង្គភាពលទ្ធកម្មប្រចាំក្រសួង និង នីតិវិធីលទ្ធកម្មសាធារណៈសំរាប់ក្រសួង

- ប្រមូលផ្ដុំតម្រូវការ និង ធ្វើកម្មវិធីចំណាយរបស់ក្រសួង ព្រមទាំងធ្វើការបែងចែកប្រេងឥន្ធនៈ និង គ្រឿងបន្លាស់នានា សំរាប់បំពេញសេចក្ដីត្រូវការរបស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សំភារៈ ធ្វើបញ្ជីសារពើភ័ណ្ឌ និង គ្រប់គ្រងការប្រើប្រាស់ ការរៀបចំជួសជុលសំភារៈបរិក្ខាររបស់ក្រសួង
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និង គណនេយ្យរូបធាតុ
- បោះពុម្ពផ្សាយជាតិ និង ឯកសារបច្ចេកទេស ឯកសារពេតិមាន ឯកសារគោលនយោបាយផ្សេងៗរបស់ក្រសួង និង របស់ស្ថាប័ននានា ដែលមានការពាក់ព័ន្ធ
- លើកគំរោងចំណាយថវិកាប្រចាំឆ្នាំ ធ្វើកម្មវិធីចំណូល ចំណាយថវិកាប្រចាំខែ និង ធ្វើរបាយការណ៍សំរេចទូទាត់ចំណូល ចំណាយថវិកាប្រចាំឆ្នាំរបស់ក្រសួង ។

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

## ជំពូកទី ១៧
## នាយកដ្ឋានបុគ្គលិក

**មាត្រា១៩. -**

នាយកដ្ឋានបុគ្គលិក មានភារកិច្ចធ្វើជាលេខាធិការ ឱ្យក្រសួងលើការងារ ÷
- គ្រប់គ្រងមន្ត្រីបុគ្គលិកាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ
- រៀបចំ និង ចាត់ការអនុវត្តរាល់លិខិតបទដ្ឋានរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព
- រៀបចំតួនាទី និងតំណែងឯកទេសរបស់ស្ថាប័ន និង ធនធានមនុស្ស
- ចូលរួមវាយតំលៃតម្រូវការក្នុងការបណ្ដុះបណ្ដាលមន្ត្រីបុគ្គលិករាជការរបស់ក្រសួង
- រៀបចំ និង គ្រប់គ្រងស្ថិតិលើទិន្នន័យបុគ្គលិក និង តារាងពេតិមានប្រតិបត្តិ
- ទទួលខុសត្រូវការងារផ្លាស់ប្ដូរភារកិច្ចមន្ត្រី ការដំឡើងឋានៈ និង ការបន្ថយឋានៈមន្ត្រីរាជការ ក្រោមឱវាទក្រសួង
- រៀបចំការងារបៀវត្ស គ្រប់ទ័ណ្ឌប្រាក់កំរៃ និង របបឧបត្ថម្ភបន្ទុកគ្រួសារ គោលនយោបាយធានារ៉ាប់រងសង្គម របបសំរាកលំហែ
- ពិនិត្យសំណើសុំអនុញ្ញាតច្បាប់ឈប់សំរាកប្រចាំឆ្នាំ ឈប់សំរាកព្យាបាលជំងឺ និង ឈប់សំរាកលួសុខទុក្ខលហព័ន្ធ

- ពិនិត្យគ្រប់សកម្មភាពបេសកកម្មរបស់មន្ត្រី បុគ្គលិករាជការ ស្ថិតក្រោមឱវាទក្រសួង
- រៀបចំគោលនយោបាយលើកសរសើរ ផ្តល់កិត្តិយស ដាក់វិន័យ ស្តីបន្ទោស ឬ ព្រមាន ដល់មន្ត្រីរាជការក្រោមឱវាទក្រសួង ដោយផ្អែកលើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រង និង រក្សាសំណុំឯកសារបុគ្គលិក ។

នាយកដ្ឋានបុគ្គលិកដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

## ជំពូកទី ១៨
## នាយកដ្ឋាននីតិកម្ម

មាត្រា២០.-

នាយកដ្ឋាននីតិកម្ម មានភារកិច្ចធ្វើជាលេខាធិការ ឱ្យក្រសួងលើការងារ ÷
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីស្រាវជ្រាវស្រង់ចងក្រង និង រៀបចំអត្ថបទសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ច្បាប់ផ្សេងៗទៀតដែលទាក់ទងដល់ការងាររបស់ក្រសួង និង សន្ធិសញ្ញាស្តីពីវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ណែនាំ និង តាមដានការអនុវត្តច្បាប់ហិរញ្ញវត្ថុ និង ច្បាប់ផ្សេងៗដែលទាក់ទងដល់ការងាររបស់ក្រសួង និង សន្ធិសញ្ញាស្តីពីវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ទទួលពាក្យបណ្តឹងតវ៉ា និង បរិហាររបស់ពលរដ្ឋដែលទាក់ទងការងារដែលនៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ក្រសួង
- សិក្សា ស្រាវជ្រាវ កសាងសំណុំឯកសារច្បាប់នានា ហើយដាក់ជូនក្រសួង ដើម្បីផ្សព្វ-ផ្សាយ និង ណែនាំអនុវត្ត
- រៀបចំរបាយការណ៍ជូនរដ្ឋមន្ត្រី ស្តីពីការអនុវត្តច្បាប់ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុ-ក្រឹត្យ សារាចរណែនាំ ប្រកាស និង សន្ធិសញ្ញាស្តីពីវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមដាន និង ជំរុញអង្គភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការផ្សព្វផ្សាយអត្ថបទច្បាប់នៅក្នុងរាជកិច្ច
- តម្កល់ឯកសារច្បាប់ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ ប្រកាស និង សេចក្តីណែនាំផ្សេងៗ នៅក្នុងមជ្ឈមណ្ឌលឯកសាររបស់ក្រសួង និង ណែនាំដល់គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទក្រសួង អំពីរបៀបគ្រប់គ្រង និង ថែរក្សាឯកសារ

នាយកដ្ឋាននីតិកម្មដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

## ជំពូក ទី១៩
## វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

មាត្រា២១.-

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចធ្វើជាលេខាធិការ ឱ្យក្រសួងលើការងារ ÷

- សិក្សា និងវាយតំលៃតំរូវការសំរាប់កសាងឡើងនូវសមត្ថភាពធនធានមនុស្ស និង បង្កើននូវគុណភាពវិជ្ជាជីវៈផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំពោះមន្ត្រីក្រោមឱវាទក្រសួង និង មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ
- អនុវត្តការបណ្តុះបណ្តាល និង ធ្វើវិក្រឹតការជាប្រចាំ ដល់មន្ត្រីរាជការរបស់ក្រសួង និង មន្ត្រីរាជការក្រសួង ស្ថាប័នពាក់ព័ន្ធ តាមផ្នែកជាមូលដ្ឋានគ្រឹះ និង ជំនាញឯកទេសនានា នៅក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយផ្តោតទៅលើការអនុវត្តជាក់ស្តែង
- សិក្សាស្រាវជ្រាវសំរាប់អនុវត្ត នៅក្នុងផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរកហេតុផល និង កត្តាសំខាន់ៗ សំរាប់កំណត់គោលនយោបាយគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅកម្ពុជា
- ជ្រើសរើស និង វាយតំលៃសមត្ថភាពមន្ត្រីរាជការក្រោមឱវាទក្រសួង ដើម្បីបណ្តុះ-បណ្តាល នៅក្នុង និងក្រៅប្រទេស
- អនុវត្តការបណ្តុះបណ្តាលរយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង ដោយសហការជាមួយស្ថាប័ន អង្គការជាតិ និង អន្តរជាតិ
- រៀបចំកម្មវិធីដ៏ទូលាយមួយដើម្បីធ្វើការហ្វឹកហ្វឺនមន្ត្រីថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវមុខវិជ្ជាដែលពាក់ព័ន្ធទៅនឹងផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ផ្នែកពតិមានវិទ្យា និង ភាសាបរទេស សំរាប់បំពីអោយការងារគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដឹកនាំដោយនាយកមួយរូបដែលមានឋានៈស្មើនឹងប្រធាននាយកដ្ឋាន និង អមដោយនាយករងមួយចំនួនមានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋានជាជំនួយការ ។

## ជំពូក ទី២០
## អង្គភាពមូលដ្ឋាន

មាត្រា២២.-

នៅតាមបណ្ដាខេត្ត ក្រុង និង រាជធានី មានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារសាខាពន្ធដារខេត្តក្រុងនិងរាជធានី និង សាខាគយ និងរដ្ឋាករខេត្តក្រុងសាខាគយដែលទទួលបន្ទុកសំរបសំរួល និងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមការកំណត់របស់ក្រសួង ។

## ជំពូក ទី២១
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា២៣.-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិកាតាមបណ្ដាក្រសួង ។

## ជំពូកទី ២២
## អន្តរប្បញ្ញត្តិ

មាត្រា២៤.-

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩៩ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៨

ត្រូវបំពេញភារកិច្ចរបស់ខ្លួន ក្រោមការដឹកនាំផ្ទាល់ របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសំរបសំរួលការងារជាមួយនឹងអគ្គលេខាធិការក្រសួង ។

## ជំពូក ទី ២៣
## អវសានប្បញ្ញត្តិ

**មាត្រា២៥.-**

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា២៦.-**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ននៃស្ថាប័នដទៃនោះ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសហការគ្នាដើម្បីបែងចែកការទទួលខុសត្រូវនិងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត

អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន :

សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង និង រាជធានីភ្នំពេញ
- ដូចមាត្រា ២៨
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធអនុក្រឹត្យលេខ. ០៤ អនក្រ.បក       ចុះថ្ងៃ ២០ ខែ មករា ឆ្នាំ ២០០០

# អង្គភាពលេខរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*** + ***



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៨៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចខាងក្រោម ៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋាន ដោយគ្របដណ្តប់លើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា៤.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារនិងសមធមិសង្គម។

បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និងឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់និងបទបញ្ញាពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៥.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមុខងារនិងភារកិច្ចដូចតទៅៈ

- រៀបចំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងនិងសម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពង្រឹងអភិបាលកិច្ចល្អ ទៅលើអ្វីដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- វិភាគតាមដាន និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង និងដាក់ចេញនូវវិធានការ ដើម្បីតម្រង់ទិសនិងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច
- សហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំនិងចូលរួមក្នុងការរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល លើកិច្ចការសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកិច្ចការសមាហរណកម្មកម្ពុជា ទៅក្នុងសេដ្ឋកិច្ចពិភពលោក ពិសេស កិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាក្នុងក្របខណ្ឌអាស៊ាន
- កសាងប្រព័ន្ធហិរញ្ញវត្ថុឱ្យឯកភាពទូទាំងប្រទេស ហើយធានាអនុវត្តប្រព័ន្ធនេះ ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ព្រមទាំងច្បាប់ពាក់ព័ន្ធនិងបទបញ្ញាដទៃទៀត
- ធ្វើការបែងចែក និងបែងចែកឡើងវិញ នូវផលទុនជាតិ តាមរយៈការប្រមូលចំណូល និងកម្មវិធីនីយកម្ម និងថវិកានីយកម្មនៃចំណាយសាធារណៈ
- រៀបចំនិងកសាងសេចក្តីព្រាងច្បាប់និងបទបញ្ញាផ្សេងៗ សម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬជាលក្ខណៈអចិន្ត្រៃយ៍
- រៀបចំនិងគ្រប់គ្រងថវិការដ្ឋ
- រៀបចំនិងអនុវត្តគោលនយោបាយចំណូលថវិកាជាតិ
- ប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និងវិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ

- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមកសាងនិងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានពីក្រៅប្រទេស និងទទួលបន្ទុកគ្រប់គ្រងបំណុលសាធារណៈ
- ចូលរួមរៀបចំគោលនយោបាយ និងគ្រប់គ្រងកិច្ចការវិនិយោគ
- ពិនិត្យនិងចុះទិដ្ឋាការលើចំណាយរបស់ក្រសួងនិងស្ថាប័នរដ្ឋនានា
- គ្រប់គ្រងនិងត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈនៃបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពរដ្ឋដទៃទៀត និងដៃគូឯកជនសាធារណៈ
- ទទួលបន្ទុកដឹកនាំ រៀបចំ ជំរុញអនុវត្ត និងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- វិភាគ គ្រប់គ្រង និងតាមដានការវិវត្តនៃវិស័យហិរញ្ញវត្ថុ ព្រមទាំងចូលរួមរៀបចំនិងអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យនៃវិស័យហិរញ្ញវត្ថុ ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ
- អភិវឌ្ឍ គ្រប់គ្រង និងត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុ រួមមាន កិច្ចការធានារ៉ាប់រងនិងសោធន ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយនិងក្របខណ្ឌនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- គ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មភ្នាល់គ្រប់ប្រភេទ
- ធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ
- បំពេញមុខងារជាបេឡាករនិងគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងរៀបចំគោលការណ៍ និងបទបញ្ញាគណនេយ្យករសាធារណៈ
- បំពេញមុខងារសវនកម្មផ្ទៃក្នុង
- បណ្តុះបណ្តាលនិងធ្វើវិក្រឹតការជាប្រចាំនូវមុខជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដល់មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- អនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា៦.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

**ក- ថ្នាក់កណ្តាល**

១- ខុទ្ទកាល័យរដ្ឋមន្ត្រី

២- អគ្គលេខាធិការដ្ឋាន

៣- អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

៤- អគ្គនាយកដ្ឋានថវិកា

៥- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

៦- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

៧- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៨- អគ្គនាយកដ្ឋានពន្ធដារ

៩- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

១០- អគ្គនាយកដ្ឋានរតនាគារជាតិ

១១- អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

១២- អគ្គាធិការដ្ឋាន

១៣- អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ខ- ថ្នាក់មូលដ្ឋាន**

១- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

២- សាខាគយនិងរដ្ឋាករាជធានី ខេត្ត ការិយាល័យគយនិងរដ្ឋាករត្រួតពិនិត្យបែបបទគយ និង បណ្ដាការិយាល័យគយនិងរដ្ឋាករដទៃទៀត

៣- សាខាពន្ធដារខេត្ត ខណ្ឌនានានៃរាជធានី និងស្នាក់ការពន្ធដារក្រុង ស្រុក

៤- រតនាគាររាជធានី ខេត្ត

**មាត្រា៧.-**

អគ្គលេខាធិការដ្ឋាន ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គលេខា-ធិការរងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

វិទ្យាស្ថាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួន ឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ។

អង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។

អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពនានា ក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់ដោយអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

# ជំពូកទី៤

## អគ្គលេខាធិការដ្ឋាន

**មាត្រា១០.-**

អគ្គលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅៈ

- ផ្តល់សេវាគាំទ្រសម្រាប់ប្រក្រតីភាពនៃដំណើរការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលសកម្មភាពការងាររវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ពិសេសមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- ធ្វើជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ការបណ្តុះបណ្តាលនិងវិក្រឹតការ នីតិកម្ម ព័ត៌មានវិទ្យា និងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។

**មាត្រា១១.-**

អគ្គលេខាធិការដ្ឋាន មានភារកិច្ចដូចតទៅ÷

- សម្របសម្រួលសកម្មភាពគ្រប់ថ្នាក់ គ្រប់ផ្នែករបស់ក្រសួង នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ក្រោមឱវាទក្រសួង
- លើកគម្រោងថវិកាក្រសួង ប្រមូលផ្តុំនិងសម្របសម្រួលជំពូកថវិកា បម្រើឱ្យរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបុគ្គលិក មន្ត្រីរាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័ន
- រៀបចំតួនាទីនិងតំណែងឯកទេសរបស់ស្ថាប័ន និងធនធានមនុស្ស
- វាយតម្លៃតម្រូវការបណ្តុះបណ្តាលបុគ្គលិក មន្ត្រីរាជការរបស់ក្រសួង
- សិក្សានិងវាយតម្លៃតម្រូវការសម្រាប់កសាងឡើងវិញនូវសមត្ថភាពធនធានមនុស្សនិងបង្កើនគុណភាពវិជ្ជាជីវៈផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះមន្ត្រីក្រោមឱវាទក្រសួង និងមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ
- អនុវត្តការបណ្តុះបណ្តាលនិងធ្វើវិក្រឹតការជាប្រចាំ ដល់មន្ត្រីរាជការរបស់ក្រសួង និងមន្ត្រីរាជការក្រសួងស្ថាប័នពាក់ព័ន្ធ តាមផ្នែកជាមូលដ្ឋានគ្រឹះនិងជំនាញឯកទេសនានា នៅក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាសមត្ថកិច្ចរបស់ក្រសួង
- ណែនាំនិងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាសមត្ថកិច្ចរបស់ក្រសួង
- ស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយកម្រងលិខិតបទដ្ឋានគតិយុត្តជាសមត្ថកិច្ចរបស់ក្រសួង
- រៀបចំ បង្កើត និងពង្រឹងយុទ្ធសាស្ត្រនិងគោលនយោបាយបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ ដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាពនិងតម្លាភាព
- អនុវត្តនិងគ្រប់គ្រងគម្រោង "ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ" នៅគ្រប់ដំណាក់កាល ដើម្បីធានាឱ្យបាននូវគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង និងរាជរដ្ឋាភិបាល
- ចូលរួមរៀបចំនិងអនុវត្តផែនការស្តីពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គម ដោយសារគម្រោងអភិវឌ្ឍន៍
- ចូលរួមរៀបចំនិងអនុវត្តគម្រោងថវិកាសម្រាប់អនុវត្តផែនការស្តីពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គម ដោយសារគម្រោងអភិវឌ្ឍន៍។

**មាត្រា១២.-**

អគ្គលេខាធិការដ្ឋាន មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានព័ត៌មានវិទ្យា
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
- វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គលេខាធិការដ្ឋាន ទទួលបន្ទុកសម្របសម្រួលមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដែលជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្នាក់មូលដ្ឋាន។

**មាត្រា១៣.-**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងាររដ្ឋបាលនិងហិរញ្ញវត្ថុ។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបុគ្គលិក។

នាយកដ្ឋាននីតិកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារនីតិកម្ម។

នាយកដ្ឋានព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារព័ត៌មានវិទ្យា។

នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបណ្តុះបណ្តាលនិងវិក្រឹតការលើមុខជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារសម្របសម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង ព្រមទាំងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

**មាត្រា១៤.-**

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ៖

- រៀបចំនិងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាននិងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោកក្នុងកម្រិតវិស័យធំៗ ស្ទួចនាករ ម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំខាន់ៗ
- ចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយពាណិជ្ជកម្មនិងហិរញ្ញវត្ថុក្រៅប្រទេសនិងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុក្នុងតំបន់និងពិភពលោក។

**មាត្រា១៥.-**

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈមានតួនាទីនិងភារកិច្ចដូចតទៅ÷

- រៀបចំនិងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- សិក្សានិងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូល វិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំខាន់ៗ ដើម្បីដាក់ចេញជាគោលនយោបាយ យុទ្ធសាស្ត្រ និងអនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាននិងវិភាគការអនុវត្តនិងការប្រព្រឹត្តទៅនៃហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីចំណូលនិងចំណាយសាធារណៈ ហើយផ្អែកលើមូលដ្ឋាននេះ លើកជាយោបល់និងស្នើវិធានការជូនថ្នាក់ដឹកនាំក្រសួង អំពីការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាព តម្លាភាព តុល្យភាព និងគណនេយ្យភាព
- រៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យមនិងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ
- រៀបចំនិងវិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈនិងស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល
- ផ្សព្វផ្សាយសកម្មភាពសេដ្ឋកិច្ចនិងទិន្នន័យនានាដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលនិងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រជាតិនានា ជាមួយស្ថាប័នជាតិផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុ
- ចូលរួមរៀបចំគោលនយោបាយពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេសនិងយុទ្ធសាស្ត្រសម្រាប់ចូលរួមការចរចាលើការបង្កើតតំបន់ពាណិជ្ជកម្មសេរី និងយន្តការសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងទាំងនោះ
- សម្របសម្រួលនិងតាមដានការងារពាក់ព័ន្ធកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុក្នុងតំបន់និងពិភពលោក
- ធ្វើជាលេខាធិការដ្ឋាន ដើម្បីសម្របសម្រួលកម្រិតអគ្គនាយកដ្ឋាននិងនាយកដ្ឋានក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការអនុវត្តកាតព្វកិច្ចនានាពាក់ព័ន្ធជាមួយនឹងតំបន់ពាណិជ្ជកម្មសេរី ការសម្រួលពាណិជ្ជកម្មនិងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ
- ពិនិត្យនិងផ្ដល់អនុសាសន៍អំពីការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន។

**មាត្រា១៦.-**

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ មាននាយកដ្ឋានក្រោមឱវាទចំនួន ៣ ដូចតទៅ÷

- នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ
- នាយកដ្ឋានស្ថិតិ
- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន។

**មាត្រា១៧.-**

នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ លើការងារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ។

នាយកដ្ឋានស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ លើការងារស្ថិតិ។

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ លើការងារសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន។

## ជំពូកទី៦

## អគ្គនាយកដ្ឋានថវិកា

**មាត្រា១៨.-**

អគ្គនាយកដ្ឋានថវិកាបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងថវិកាជាតិ ហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋ ក្នុងគោលដៅធានាឱ្យមានការបែងចែកនិងប្រើប្រាស់ធនធានថវិការដ្ឋ ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។

**មាត្រា១៩.-**

អគ្គនាយកដ្ឋានថវិកា មានភារកិច្ចដូចតទៅ៖

- កសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងបទបញ្ញាហិរញ្ញវត្ថុសាធារណៈ
- រៀបចំការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុ បទបញ្ញាហិរញ្ញវត្ថុសាធារណៈ និងច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀត
- ចូលរួមក្នុងការងារកសាងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា
- រៀបចំកម្មវិធីចំណាយសាធារណៈទៀងទាត់ ដោយផ្អែកលើកម្មវិធីចំណូលសាធារណៈ ដែលត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់ដំណើរការជាប្រចាំ និងសម្រាប់គម្រោងវិនិយោគសាធារណៈ របស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលបានទទួលការអនុម័តរួច
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ចូលរួមសហការជាមួយក្រសួង ស្ថាប័ន ក្នុងការត្រួតពិនិត្យនិងតាមដានលើការអនុវត្តនីតិវិធីចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ រួមទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ
- រៀបចំអាទិភាពវិនិយោគប្រចាំឆ្នាំ សម្រាប់គោលបំណងថវិកានីយកម្មលើគម្រោងវិនិយោគសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំនិងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណង ការទទួលហិរញ្ញប្បទានឥតសំណង ការឱ្យប្រាក់គេខ្ចី ការខ្ចីប្រាក់ពីគេ ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀត
- គ្រប់គ្រងនិងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ
- គ្រប់គ្រងបំណុលរបស់រដ្ឋ
- ចូលរួមក្នុងការរៀបចំនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឯកជន
- ចូលរួមរៀបចំ តាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោង ឬកិច្ចព្រមព្រៀង ឬកិច្ចសន្យាពាក់ព័ន្ធនឹងការវិនិយោគឯកជន ដែលមានការពាក់ព័ន្ធនឹងចំណាយថវិការដ្ឋឬកាតព្វកិច្ចបំណុលរបស់រដ្ឋ
- សហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិ ជាមួយអង្គភាពពាក់ព័ន្ធនៃអង្គការហិរញ្ញវត្ថុអន្តរជាតិនិងដៃគូអភិវឌ្ឍនានា។

**មាត្រា២០.-**

អគ្គនាយកដ្ឋានថវិកា មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម៖

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានថវិកានីយកម្ម
- នាយកដ្ឋានហិរញ្ញកិច្ច
- នាយកដ្ឋានវិនិយោគ
- នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល។

**មាត្រា២១.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារគ្រប់គ្រងកិច្ចការទូទៅ។

នាយកដ្ឋានថវិកានីយកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារថវិកានីយកម្ម។

នាយកដ្ឋានហិរញ្ញកិច្ច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារហិរញ្ញកិច្ច។

នាយកដ្ឋានវិនិយោគ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារវិនិយោគ។

នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល។

## ជំពូកទី៧

## អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា២២.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា២៣.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចដូចតទៅ÷

- រៀបចំការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋាន នាយកដ្ឋានជំនាញនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការផ្ទេរមុខងារនិងធនធាន ព្រមទាំងរៀបចំលិខិតបទដ្ឋាននានា សម្រាប់បម្រើដល់ការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមជាមួយអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំសារាចររបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំថវិកា និងការអនុវត្តថវិកា
- សម្របសម្រួលជាមួយអង្គភាពនានា នៃក្រសួង ស្ថាប័ន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រួមចំណែកក្នុងការកៀរគរចំណូលពីប្រភពនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន សម្រាប់រួមចំណែកដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- កសាងសមត្ថភាពនិងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដល់ការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រួតពិនិត្យ តាមដានការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដានលំហូរធនធានទៅក្នុងមូលនិធិនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីដៃគូអភិវឌ្ឍ និងសប្បុរសជន
- សម្របសម្រួលជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ក្នុងការរៀបចំ អនុម័ត និងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៤.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

- នាយកដ្ឋានគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។

**មាត្រា២៥.-**

នាយកដ្ឋានគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។

## ជំពូកទី៨

## អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**មាត្រា២៦.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៧.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានភារកិច្ចដូចតទៅ÷

- រៀបចំ បង្កើត អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ត្រួតពិនិត្យនិងតាមដានលើរាល់កិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តដោយស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើតារាងផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម

- ពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃ
- ពិនិត្យនិងលើកយោបល់លើសំណើសុំគោលការណ៍អនុវត្តវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើសំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងនិងតាមដានការអនុវត្តកិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ
- ចូលរួមដោះស្រាយវិវាទលទ្ធកម្ម
- បណ្តុះបណ្តាលអំពីការអនុវត្តវិធាននិងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ដល់មន្ត្រីលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មន្ត្រីពាក់ព័ន្ធដទៃទៀត អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ។

**មាត្រា២៨.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម ÷

- នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ
- នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ។

**មាត្រា២៩.-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងាររៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ ការងាររដ្ឋបាល បុគ្គលិក បញ្ជិកាអ្នកដេញថ្លៃ ផែនការលទ្ធកម្ម និងការងារគ្រប់គ្រងកិច្ចសន្យាលទ្ធកម្ម។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មទំនិញ ដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពរដ្ឋដទៃទៀត និងដៃគូឯកជនសាធារណៈ។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពរដ្ឋដទៃទៀត និងដៃគូឯកជនសាធារណៈ។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារត្រួតពិនិត្យនិងដោះស្រាយវិវាទពាក់ព័ន្ធលទ្ធកម្មសាធារណៈ។

## ជំពូកទី៩
## អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**មាត្រា៣០.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ៖

- ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូល ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិផ្សេងទៀត ដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល ការធ្វើចរាចរ និងការធ្វើសន្និធិទំនិញ
- ដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬនាំចូល
- ជំរុញការបង្ការ និងការបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ
- ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ជំរុញការអនុវត្តតាមស្តង់ដារអន្តរជាតិ និងឧត្តមានុវត្តន៍ដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យ គយ និងការសម្រួលពាណិជ្ជកម្ម ជាពិសេស ការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការធ្វើស្វ័យប្រវត្តិកម្មគយ។

**មាត្រា៣១.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- លើកសំណើគោលនយោបាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិ រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងារប្រមូលពន្ធ និងអាករនាំចេញ-នាំចូលគ្រប់ប្រភេទ ជាពិសេស ពិនិត្យពិចារណាក្នុងការកសាងនិងអនុវត្តតារាងពន្ធគយនិងនីតិវិធីទាំងឡាយ ដែលទាក់ទងនឹងការងារគយនិងរដ្ឋាករ លើមុខទំនិញគ្រប់ប្រភេទឱ្យបានសមស្របទៅតាមដំណាក់កាលនីមួយៗ នៃការវិវត្តសេដ្ឋកិច្ច
- ជាស្ថាប័នតំណាងមុខតែមួយគត់ដែលទទួលខុសត្រូវលើការត្រួតពិនិត្យទំនិញនាំចេញឬនាំចូល នៅមាត់ច្រកព្រំដែន និងមានភារកិច្ចសម្របសម្រួលឱ្យមានការត្រួតពិនិត្យរួមគ្នាតែមួយលើក ក្នុងករណីដែលតម្រូវឱ្យមានការត្រួតពិនិត្យដោយស្ថាប័នផ្សេងទៀត ស្របតាមការកំណត់រកឃើញហានិភ័យ
- គ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តការប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូលគ្រប់ប្រភេទ
- លើកវិធានការរាំងខ្ទប់ និងចាប់យាត់ទំនិញរត់ពន្ធគយគ្រប់ប្រភេទ
- ត្រួតពិនិត្យ តាមដាន និងគ្រប់គ្រងការនាំចេញ-នាំចូលទំនិញគ្រប់ប្រភេទ ទោះមានឬគ្មានលក្ខណៈពាណិជ្ជកម្មក្តី ដោយរាប់បញ្ចូលទាំងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរឬផ្លាស់ប្តូរលំនៅដ្ឋាន រូបិយប័ណ្ណ លោហធាតុ-ត្បូងថ្មមានតម្លៃ បេតិកភណ្ឌវប្បធម៌ និងភណ្ឌិកាប្រៃសណីយ៍ ព្រមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ
- លើកគម្រោងជ្រើសរើស និងបណ្តុះបណ្តាលជំនាញបច្ចេកទេស មន្ត្រី បុគ្គលិក និងភ្នាក់ងារគយនិងរដ្ឋាករ
- អនុវត្តគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធនឹងការងារគយនិងរដ្ឋាករ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- អនុវត្តនូវភារកិច្ចផ្សេងទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣២.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានប្រព័ន្ធចាត់តាំងគ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំ និងត្រួតពិនិត្យលើរាល់អង្គភាពគយនិងរដ្ឋាករពីថ្នាក់កណ្ដាល រហូតដល់ថ្នាក់មូលដ្ឋានរាជធានី ខេត្ត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៣.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មាននាយកដ្ឋានក្រោមឱវាទចំនួន ៧ និងលេខាធិការដ្ឋានមួយ នៅថ្នាក់កណ្ដាល និងអង្គភាពថ្នាក់មូលដ្ឋានមួយចំនួនដូចខាងក្រោម ÷

**ក- ថ្នាក់កណ្ដាល**

- នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង
- នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ
- នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស
- នាយកដ្ឋានរដ្ឋាករ
- នាយកដ្ឋានរបបគយ
- នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ
- លេខាធិការដ្ឋាន

**ខ- ថ្នាក់មូលដ្ឋាន**

អង្គភាពថ្នាក់មូលដ្ឋាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមមានជាអាទិ៍ សាខាគយនិងរដ្ឋាកររាជធានី ខេត្ត ការិយាល័យគយនិងរដ្ឋាករត្រួតពិនិត្យបែបបទគយ និងបណ្ដាការិយាល័យគយនិងរដ្ឋាករដទៃទៀត។

**មាត្រា៣៤.-**

នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររដ្ឋបាលនិងគ្រប់គ្រង។

នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ។

នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយក-ដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ។

នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារបង្ការនិងបង្ក្រាបបទល្មើស។

នាយកដ្ឋានរដ្ឋាករ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររដ្ឋាករ។

នាយកដ្ឋានរបបគយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររបបគយ។

នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារគ្រប់គ្រងតំបន់រួចពន្ធ។

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារលេខាធិការដ្ឋានរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

## ជំពូកទី១០

## អគ្គនាយកដ្ឋានពន្ធដារ

**មាត្រា៣៥.–**

អគ្គនាយកដ្ឋានពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មធ្វើឱ្យសម្រេចនូវការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដូចតទៅ៖

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌ តាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវានិងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរពនិងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធីនិងកិច្ចដំណើរការរបស់ខ្លួន ធ្វើឱ្យមានភាពសាមញ្ញ ចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

**មាត្រា៣៦.–**

អគ្គនាយកដ្ឋានពន្ធដារ មានភារកិច្ចជាអាទិ៍ដូចតទៅ៖

- រៀបចំគោលនយោបាយសារពើពន្ធនិងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដោយផ្អែកលើការអង្កេតនិងផ្ទុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ពន្ធប្រថាប់ត្រា ការប្រាក់ និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ ចំពោះអ្នកជាប់ពន្ធនិងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

**មាត្រា៣៧.-**

អគ្គនាយកដ្ឋានពន្ធដារ គឺជារដ្ឋបាលសារពើពន្ធ ដែលមានប្រព័ន្ធចាត់តាំងឯកភាព ទទួលខុសត្រូវគ្រប់គ្រងទូទាំងប្រទេស និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៨.-**

អគ្គនាយកដ្ឋានពន្ធដារ រួមមាននាយកដ្ឋានក្រោមឱវាទចំនួន ៧ នៅថ្នាក់កណ្តាល និងអង្គភាពថ្នាក់មូលដ្ឋានដូចខាងក្រោម ÷

**ក-ថ្នាក់កណ្តាល**

- នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលហិរញ្ញវត្ថុ
- នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ
- នាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ
- នាយកដ្ឋានត្រួតពិនិត្យ
- នាយកដ្ឋានព័ត៌មានវិទ្យា
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានសវនកម្មសហគ្រាស

**ខ-ថ្នាក់មូលដ្ឋាន**

នៅខេត្តនីមួយៗ និងនៅខណ្ឌនានានៃរាជធានីភ្នំពេញ មានសាខាពន្ធដារខេត្ត និងសាខាពន្ធដារខណ្ឌដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន នៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួន ឋានៈស្មើប្រធានការិយាល័យ នៅថ្នាក់កណ្តាល ជាជំនួយការ។

នៅស្រុក ក្រុង មានស្នាក់ការពន្ធដារស្រុក ក្រុង មានថ្នាក់ស្មើការិយាល័យនៃសាខាពន្ធដារខេត្ត ខណ្ឌ និងដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

**មាត្រា៣៩.-**

នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារបុគ្គលិកនិងរដ្ឋបាលហិរញ្ញវត្ថុ។

នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារច្បាប់ វិវាទ និងស្ថិតិ។

នាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ។

នាយកដ្ឋានត្រួតពិនិត្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារត្រួតពិនិត្យ។

នាយកដ្ឋានព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារព័ត៌មានវិទ្យា។

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងអ្នកជាប់ពន្ធធំ។

នាយកដ្ឋានសវនកម្មសហគ្រាស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសវនកម្មសហគ្រាស។

## ជំពូកទី១១
## អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

**មាត្រា៤០.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

**មាត្រា៤១.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានភារកិច្ចដូចតទៅ៖

- រៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងនិងជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ នៅទូទាំងប្រទេស
- ស្រាវជ្រាវនិងគ្រប់គ្រងទ្រព្យឥតម្ចាស់ និងមរតកឥតបណ្តឹង
- គ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋនិងដើមទុនរបស់រដ្ឋ
- គ្រប់គ្រងសហគ្រាសសាធារណៈ អង្គភាពសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- ប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធការងារឯកជនភាវូបនីយកម្ម ការជម្រះបញ្ជីសហគ្រាសសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- គ្រប់គ្រងនិងរៀបចំបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ សម្បទានរ៉ែ និងសម្បទានដទៃទៀតដែលបានផ្តល់ឱ្យវិស័យឯកជន
- រៀបចំនីតិវិធីវាយតម្លៃការដាក់ជួល លក់ ដូរ និងផ្ទេរសិទ្ធិទ្រព្យសម្បត្តិរដ្ឋ
- ស្រាវជ្រាវរកប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ។

**មាត្រា៤២.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម៖

- នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលសាធារណៈ
- នាយកដ្ឋានសហគ្រាសសាធារណៈ។

**មាត្រា៤៣.-**

នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ។

នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ។

នាយកដ្ឋានចំណូលសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលសាធារណៈ។

នាយកដ្ឋានសហគ្រាសសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសហគ្រាសសាធារណៈ។

## ជំពូកទី១២

## អគ្គនាយកដ្ឋានរតនាគារជាតិ

**មាត្រា៤៤.-**

អគ្គនាយកដ្ឋានរតនាគារជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ៖

- ជាបេឡាករនិងជាគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋនិងគណនីពិសេសនៃរតនាគារ
- រៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យសាធារណៈ
- កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី
- ធានាតុល្យភាពទូទៅនៃគណនី
- តម្រង់ទិស និងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ
- សហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

**មាត្រា៤៥.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងបេឡាថវិកាថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន និងថវិកាស្វយ័ត
- គ្រប់គ្រងគណនីរបស់ក្រសួង ស្ថាប័នថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន គណនីប្រាក់បញ្ញើឯកជន គណនីក្រៅថវិកានិងគណនីពិសេសរបស់រតនាគារ
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋ មូលបត្ររដ្ឋ និងសញ្ញាបណ្ណរដ្ឋ
- ធ្វើតុល្យភាពសាច់ប្រាក់ និងគ្រប់គ្រងចំណូល-ចំណាយថវិកាជាតិ
- រួមចំណែកក្នុងការតម្រង់ទិសការអនុវត្តគោលនយោបាយរូបិយវត្ថុ
- តម្រង់ទិសនិងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ
- កាន់កាប់និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី
- រៀបចំគោលការណ៍ និងបិទបញ្ជីគណនេយ្យសាធារណៈ
- ធានាតុល្យភាពទូទៅនៃគណនី
- ផ្តល់សេវាដល់គ្រប់ក្រសួង-ស្ថាប័នថ្នាក់កណ្តាលនិងរដ្ឋបាលថ្នាក់មូលដ្ឋាន លើការទូទាត់ ការចំណាយផ្សេងៗ ការបើកបៀវត្សរ៍ និងការប្រមូលចំណូល ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ

- កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

**មាត្រា៤៦.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក. ថ្នាក់កណ្តាល**

- នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក
- នាយកដ្ឋានចំណូលនិងចំណាយថវិកា
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគ្រប់គ្រងបេឡានិងបំណុល
- នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ
- នាយកដ្ឋានព័ត៌មានវិទ្យា
- អធិការកិច្ចរតនាគារ ថ្នាក់ស្មើនាយកដ្ឋាន។

**ខ. ថ្នាក់មូលដ្ឋាន**

នៅរាជធានី ខេត្ត មានរតនាគាររាជធានី ខេត្ត ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន នៅថ្នាក់កណ្តាល អមដោយអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យ នៅថ្នាក់កណ្តាល។

**មាត្រា៤៧.-**

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងាររដ្ឋបាលនិងបុគ្គលិក។

នាយកដ្ឋានចំណូលនិងចំណាយថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារចំណូលនិងចំណាយថវិកា។

នាយកដ្ឋានគណនេយ្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគណនេយ្យ។

នាយកដ្ឋានគ្រប់គ្រងបេឡានិងបំណុល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងបេឡានិងបំណុល។

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ។

នាយកដ្ឋានព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារព័ត៌មានវិទ្យា។

អធិការកិច្ចរតនាគារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារអធិការកិច្ចរតនាគារ។

## ជំពូកទី១៣

## អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

**មាត្រា៤៨.-**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងនិងត្រួតពិនិត្យទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ អាជីវកម្មភ្នាល់គ្រប់ប្រភេទ អាជីវកម្មអចលនវត្ថុ និងចូលរួមប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា៤៩.-**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- រៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- គ្រប់គ្រងនិងត្រួតពិនិត្យទីផ្សារធានារ៉ាប់រងនិងសោធន
- ចូលរួមគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញប្បទានរបស់រដ្ឋ ដែលគាំទ្រការអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងសម្របសម្រួលលើការអនុវត្តគោលនយោបាយឥណទានអភិវឌ្ឍជនបទ
- គ្រប់គ្រង ត្រួតពិនិត្យ ចុះបញ្ជី និងរក្សាបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ
- គ្រប់គ្រងនិងត្រួតពិនិត្យសេវាកម្មវាយតម្លៃ សេវាកម្មទិញ លក់ ជួលអចលនវត្ថុ និងបុគ្គលអភិវឌ្ឍលំនៅឋាន
- គ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ ទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- គ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលចំណូលពីអាជីវកម្មកាស៊ីណូ និងអាជីវកម្មភ្នាល់គ្រប់ប្រភេទដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល
- ចូលរួមជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា៥០.-**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម៖

- នាយកដ្ឋានធានារ៉ាប់រងនិងសោធន
- នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។

**មាត្រា៥១.-**

នាយកដ្ឋានធានារ៉ាប់រងនិងសោធន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លើការងារធានារ៉ាប់រងនិងសោធន។

នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លើការងារគ្រប់គ្រងនិងត្រួតពិនិត្យទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងការងារត្រួតពិនិត្យនិងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លើការងារគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លើការងារគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។

## ជំពូកទី១៤

## អគ្គាធិការដ្ឋាន

**មាត្រា៥២.-**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើអភិក្រម អធិការកិច្ចផ្អែកលើហានិភ័យ និងអធិការកិច្ចផ្អែកលើករណីសង្ស័យឬបណ្តឹងតវ៉ាជាក់ស្តែង។

**មាត្រា៥៣.-**

អគ្គាធិការដ្ឋានមានភារកិច្ចដូចតទៅ÷

- ចុះធ្វើអធិការកិច្ចទូទៅលើកិច្ចដំណើរការរដ្ឋបាលថ្នាក់ជាតិ គ្រប់ក្រសួង ស្ថាប័ន អង្គភាព និងកិច្ចដំណើរការរដ្ឋបាលថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងវិន័យ និងការអនុវត្តនីតិវិធីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ចំណូល-ចំណាយថវិកាជាតិ និងការទទួលខុសត្រូវការគ្រប់គ្រងការប្រើប្រាស់ប្រាក់កាសសាធារណៈ
- ចុះធ្វើអធិការកិច្ចរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ របស់អង្គភាពសាធារណៈ គ្រប់អាជ្ញាធរ សហគ្រាសនានា សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រុមហ៊ុនសម្បទានដែលបានទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ទោះបីជាតាមរូបភាពណាក៏ដោយ
- ធ្វើអធិការកិច្ចលើរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ របស់សហគមន៍ សមាគម អង្គការក្រៅរដ្ឋាភិបាល អង្គការនានា គ្រឹះស្ថានឥណទាន ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនឯកជន ដែលបានទទួលផលប្រយោជន៍ហិរញ្ញវត្ថុសាធារណៈ ទោះបីជាតាមរូបភាពណាក៏ដោយ
- ធ្វើអធិការកិច្ចហិរញ្ញវត្ថុ ក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ថវិកាសម្រាប់បើកផ្តល់មុន និងក្រោយចំណាយលើគ្រប់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ អង្គភាពសាធារណៈ អង្គការ សមាគម សហគមន៍ និងក្រុមហ៊ុនខាងលើ តាមបទដ្ឋាននិងបទប្បញ្ញត្តិច្បាប់ជាធរមាន
- ចុះផ្សព្វផ្សាយនិងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិនានា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់មន្ត្រី ដែលកំពុងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទទួលខុសត្រូវតាមវិធានការវិន័យរដ្ឋបាលនិងតុលាការ
- ជំរុញពង្រឹងគៀរគរចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលផ្សេងៗ ដោយតម្រូវឱ្យមានការបំពេញកាតព្វកិច្ចបង់ចំណូលចូលថវិកាជាតិ ឱ្យបានគ្រប់ចំនួននិងទាន់ពេលវេលា
- ធ្វើអធិការកិច្ចត្រួតពិនិត្យឯកសារពាក់ព័ន្ធ លើករណីដែលមានការកិបកេង ការក្លែងបន្លំឯកសារនានាពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រភពធនធានរដ្ឋ និងធនធានហិរញ្ញវត្ថុសាធារណៈ ដើម្បីទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ
- ធ្វើអធិការកិច្ចត្រួតពិនិត្យការគ្រប់គ្រងមូលនិធិសាធារណៈ ប្រភពទុន ប្រភពធនធានជាតិនិងប្រភពមូលនិធិដែលមានការចូលរួមពីសង្គម សាធារណជននានា ស្ថិតក្រោមប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ានិងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ដែលទាក់ទងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ច ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៤.-**

អគ្គាធិការដ្ឋាន មាននាយកដ្ឋានក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ជាតិ
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៥.-**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋាន លើការងាររដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង។

នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋាន លើការងារអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ជាតិ។

នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋាន លើការងារអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី១៥

## អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៥៦.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ។

**មាត្រា៥៧.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងមានភារកិច្ចដូចតទៅ÷

- រៀបចំនិងអនុវត្តគោលការណ៍ណែនាំ ផែនការ នីតិវិធី និងស្តង់ដារ ពាក់ព័ន្ធសវនកម្មផ្ទៃក្នុង
- តាមដានដំណើរការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាល ពាក់ព័ន្ធការអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុង ឱ្យស្ថិតក្នុងកម្រិតឧត្តមានុវត្តន៍
- វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំដៅពង្រឹងអភិបាលកិច្ចល្អ
- ធ្វើរបាយការណ៍ត្រង់ទៅប្រធានស្ថាប័ន ដោយផ្ញើច្បាប់ចតចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា។

**មាត្រា៥៨.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មាននាយកដ្ឋានក្រោមឱវាទចំនួន ២ ដូចខាងក្រោម÷

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្តាល
- នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន។

**មាត្រា៥៩.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្តាល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង លើការងារសវនកម្មផ្ទៃក្នុង នៅតាមអង្គភាពនានាក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅអង្គភាពថ្នាក់កណ្តាល។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង លើការងារសវនកម្មផ្ទៃក្នុងនៅតាមអង្គភាពនានាក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅអង្គភាពថ្នាក់មូលដ្ឋាន។

## ជំពូកទី១៦

## អង្គភាពមូលដ្ឋាន

**មាត្រា៦០.-**

អង្គភាពមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានជាអាទិ៍ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត, សាខាគយនិងរដ្ឋាកររាជធានី ខេត្ត, ការិយាល័យគយនិងរដ្ឋាករត្រួតពិនិត្យបែបបទគយ និងបណ្តាទីស្នាក់ការគយនិងរដ្ឋាករ, សាខាពន្ធដារខេត្ត ខណ្ឌនានានៃរាជធានី និងស្នាក់ការពន្ធដារក្រុង ស្រុក, រតនាគាររាជធានី ខេត្តនិងអង្គភាពមូលដ្ឋានផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អង្គភាពមូលដ្ឋាន ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ទទួលបន្ទុកសម្របសម្រួលនិងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ជំពូកទី១៧

## អន្តរប្បញ្ញត្តិ

**មាត្រា៦១.-**

ប្រកាសពាក់ព័ន្ធនឹងការបង្កើត ឬការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលកំពុងអនុវត្ត ត្រូវបន្តអានុភាពអនុវត្ត រហូតដល់មានប្រកាសថ្មីរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១៨

## អវសានប្បញ្ញត្តិ

**មាត្រា៦២.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម÷

- អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- អនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ស្ដីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..៤៨៨..អនក្រ. បក
ចុះថ្ងៃទី..១៦... ខែ...តុលា.... ឆ្នាំ២០១៣

# អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រាមួយ.-**

មាត្រា៤ មាត្រា៦ និងមាត្រា៧ នៃជំពូកទី២ បេសកកម្មនិងរចនាសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា៤ ថ្មី.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ចនិងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារនិងសមធម៌សង្គម។

បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខ័ណ្ឌច្បាប់និងបទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និងឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់និងបទបញ្ញាពាក់ព័ន្ធផ្សេងទៀត។

ក្នុងគោលដៅលើកកម្ពស់អភិបាលកិច្ចល្អ ក្រុមប្រឹក្សានីតិកម្មត្រូវបង្កើតឡើងក្រោមការដឹកនាំដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានបេសកកម្មធានានីត្យានុកូលភាព និងសង្គតិភាពនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្ត, រៀបចំនិងដាក់ឱ្យអនុវត្តឧបករណ៍ការងារគតិយុត្ត, លើកកម្ពស់ការយល់ដឹងនិងប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងផ្តល់ដំណោះស្រាយយុត្តិធម៌ ឬសមធម៌ ដល់វិវាទ ឬបណ្តឹងនានាពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦ ថ្មី.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

**ក-ថ្នាក់កណ្តាល**

១-ខុទ្ទកាល័យរដ្ឋមន្ត្រី

២-អគ្គលេខាធិការដ្ឋាន

៣-អគ្គនាយកដ្ឋានគោលនយោបាយ

៤-អគ្គនាយកដ្ឋានថវិកា

៥-អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

៦-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

៧-អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៨-អគ្គនាយកដ្ឋានពន្ធដារ

៩-អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

១០-អគ្គនាយកដ្ឋានរតនាគារជាតិ

១១-អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

១២-អគ្គាធិការដ្ឋាន

១៣-អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

១៤-អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍

១៥-អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល

១៦-វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ខ-ថ្នាក់មូលដ្ឋាន**

១-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

២-សាខាគយនិងរដ្ឋាកររាជធានី ខេត្ត ការិយាល័យគយនិងរដ្ឋាករត្រួតពិនិត្យបែបបទគយ និងបណ្ដាការិយាល័យគយនិងរដ្ឋាករដទៃទៀត

៣-សាខាពន្ធដារខេត្ត ខណ្ឌនានា នៃរាជធានី និងការិយាល័យពន្ធដារស្រុក ក្រុង

៤-រតនាគាររាជធានី ខេត្ត។

**មាត្រា៧ ថ្មី.-**

អគ្គលេខាធិការដ្ឋាន ដឹកនាំដោយអគ្គលេខាធិការមួយរូបមានឋានៈស្មើអគ្គនាយក និងអមដោយអគ្គលេខាធិការរងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួនឋានៈស្មើអគ្គនាយករង ជាជំនួយការ។

វិទ្យាស្ថាន ដឹកនាំដោយនាយកមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយនាយករងមួយចំនួន មានឋានៈ ស្មើអគ្គនាយករង ជាជំនួយការ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គភាពថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។

អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រាពីរ.-**

មាត្រា១២ និងមាត្រា១៣ នៃជំពូកទី៤ អគ្គលេខាធិការដ្ឋាន នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

**ជំពូកទី៤**

**អគ្គលេខាធិការដ្ឋាន**

**មាត្រា១២ ថ្មី.-**

អគ្គលេខាធិការដ្ឋានមានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក

- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានបណ្ណសារ។

អគ្គលេខាធិការដ្ឋាន ទទួលបន្ទុកសម្របសម្រួលមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដែលជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្នាក់មូលដ្ឋាន។

**មាត្រា១៣ ថ្មី.-**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការ ឱ្យអគ្គលេខាធិការដ្ឋាន លើការងាររដ្ឋបាលនិងហិរញ្ញវត្ថុ។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបុគ្គលិក។

នាយកដ្ឋាននីតិកម្ម បំពេញមុខងារជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សានីតិកម្ម និងសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារនីតិកម្ម។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានបណ្ណសារ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបណ្ណសារ។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារសម្របសម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង ព្រមទាំងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រាបី.-**

មាត្រា១៤ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ នៃជំពូកទី៥ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី៥

## អគ្គនាយកដ្ឋានគោលនយោបាយ

**មាត្រា១៤ ថ្មី.-**

អគ្គនាយកដ្ឋានគោលនយោបាយ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ÷

- រៀបចំនិងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាននិងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ក្នុងកម្រិតវិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំខាន់ៗ
- ចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយពាណិជ្ជកម្មនិងហិរញ្ញវត្ថុក្រៅប្រទេសនិងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុក្នុងតំបន់និងពិភពលោក។

**មាត្រា១៥ ថ្មី.-**

អគ្គនាយកដ្ឋានគោលនយោបាយ មានតួនាទីនិងភារកិច្ចដូចតទៅ÷

- រៀបចំនិងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង

- សិក្សានិងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូល វិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំខាន់ៗ ដើម្បីដាក់ចេញជាគោលនយោបាយ យុទ្ធសាស្ត្រ និងអនុសាសន៍ ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាននិងវិភាគការអនុវត្តនិងការប្រព្រឹត្តទៅ នៃហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីចំណូលនិងចំណាយសាធារណៈ ហើយផ្អែកលើមូលដ្ឋាននេះ លើកយោបល់និងស្នើវិធានការជូនថ្នាក់ដឹកនាំក្រសួង អំពីការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាព តម្លាភាព តុល្យភាព និងគណនេយ្យភាព
- រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ
- រៀបចំ និងវិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល
- ផ្សព្វផ្សាយសកម្មភាពសេដ្ឋកិច្ចនិងទិន្នន័យនានា ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលនិងតាមដាន ការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រជាតិនានា ជាមួយស្ថាប័នជាតិផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ
- ចូលរួមរៀបចំគោលនយោបាយពាណិជ្ជកម្មនិងហិរញ្ញវត្ថុក្រៅប្រទេស និងយុទ្ធសាស្ត្រសម្រាប់ចូលរួមការចរចាលើការបង្កើតតំបន់ពាណិជ្ជកម្មសេរី និងយន្តការសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃកិច្ចព្រមព្រៀងទាំងនោះ
- សម្របសម្រួលនិងតាមដានការងារពាក់ព័ន្ធកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ក្នុងតំបន់និងពិភពលោក
- ធ្វើជាលេខាធិការដ្ឋាន ដើម្បីសម្របសម្រួលកម្រិតអគ្គនាយកដ្ឋាន និងនាយកដ្ឋានក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការអនុវត្តកាតព្វកិច្ចនានាពាក់ព័ន្ធជាមួយនឹងតំបន់ពាណិជ្ជកម្មសេរី ការសម្រួលពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ
- ពិនិត្យនិងផ្តល់អនុសាសន៍អំពីការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន។

**មាត្រា១៦ ថ្មី.-**

អគ្គនាយកដ្ឋានគោលនយោបាយមានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

- នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ
- នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច
- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន។

**មាត្រា១៧ ថ្មី.-**

នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយ លើការងារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ។

នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយ លើការងារស្ថិតិនិងវិភាគសេដ្ឋកិច្ច។

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយ លើការងារសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន។

**មាត្រាបួន.-**

មាត្រា២៤ និងមាត្រា២៥ នៃជំពូកទី៧ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី៧
## អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា២៤ ថ្មី.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិមាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

- នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី១
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី២
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី៣ ។

**មាត្រា២៥ ថ្មី.-**

នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស ។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី១ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង និងក្រុង ស្រុក ខណ្ឌ ព្រមទាំងឃុំ សង្កាត់នៃរាជធានី ខេត្តទាំងនេះ។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី២ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម និងក្រុង ស្រុក ព្រមទាំងឃុំ សង្កាត់នៃខេត្តទាំងនេះ។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី៣ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង និងក្រុង ស្រុក ព្រមទាំងឃុំ សង្កាត់នៃខេត្តទាំងនេះ។

**មាត្រា៨.-**

មាត្រា៣៣ និងមាត្រា៣៤ នៃជំពូកទី៩ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី៩
## អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**មាត្រា៣៣ ថ្មី.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានរចនាសម្ព័ន្ធនៅថ្នាក់កណ្ដាលនិងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក-ថ្នាក់កណ្ដាល**

- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋានផែនការ និងបច្ចេកទេស
- នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានសវនកម្មគយ

- នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស
- នាយកដ្ឋានរដ្ឋាករ
- នាយកដ្ឋានរបបគយ
- នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ
- នាយកដ្ឋានគ្រប់គ្រងការនាំចេញ
- លេខាធិការដ្ឋាន
- សាលាជាតិគយ ថ្នាក់ស្មើនាយកដ្ឋាន។

**ខ-ថ្នាក់មូលដ្ឋាន**

អង្គភាពថ្នាក់មូលដ្ឋាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមមានជាអាទិ៍ សាខាគយនិងរដ្ឋាកររាជធានី ខេត្ត ការិយាល័យគយនិងរដ្ឋាករត្រួតពិនិត្យបែបបទគយ និងបណ្ដាការិយាល័យគយនិងរដ្ឋាករដទៃទៀត។

**មាត្រា៣៤ ថ្មី.-**

នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារហិរញ្ញវត្ថុ និងបុគ្គលិក។

នាយកដ្ឋានផែនការ និងបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារផែនការ និងបច្ចេកទេស។

នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារច្បាប់ និងទំនាក់ទំនងសាធារណៈ។

នាយកដ្ឋានសវនកម្មគយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារសវនកម្មគយ។

នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារបង្ការនិងបង្ក្រាបបទល្មើស។

នាយកដ្ឋានរដ្ឋាករ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររដ្ឋាករ។

នាយកដ្ឋានរបបគយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររបបគយ។

នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារគ្រប់គ្រងតំបន់រួចពន្ធ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារសហប្រតិបត្តិការគយអន្តរជាតិ។

នាយកដ្ឋានគ្រប់គ្រងការនាំចេញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងារគ្រប់គ្រងការនាំចេញ។

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារលេខាធិ-ការដ្ឋានរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

សាលាជាតិគយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារបណ្ដុះបណ្ដាលមុខជំនាញទាក់ទងនឹងគយនិងរដ្ឋាករ។

**មាត្រាប្រាំមួយ.-**

មាត្រា៣៨ និងមាត្រា៣៩ នៃជំពូកទី១០ អគ្គនាយកដ្ឋានពន្ធដារ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

**ជំពូកទី១០**

**អគ្គនាយកដ្ឋានពន្ធដារ**

**មាត្រា៣៨ ថ្មី.-**

អគ្គនាយកដ្ឋានពន្ធដារមានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក-ថ្នាក់កណ្តាល**

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ ថ្នាក់ស្មើនាយកដ្ឋាន
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ ថ្នាក់ស្មើនាយកដ្ឋាន។

សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ។

**ខ-ថ្នាក់មូលដ្ឋាន**

នៅខណ្ឌនានា នៃរាជធានីភ្នំពេញ និងខេត្តនីមួយៗមានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលដឹកនាំ ដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួនមានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ។

នៅស្រុក ក្រុង មានការិយាល័យពន្ធដារស្រុក ក្រុង មានថ្នាក់ស្មើការិយាល័យនៃសាខាពន្ធដារខេត្ត ខណ្ឌ និងដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

**មាត្រា៣៩ ថ្មី.-**

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងាររដ្ឋបាលនិងកិច្ចការទូទៅ។

នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារហិរញ្ញវត្ថុ និងបុគ្គលិក។

នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារលើការងារនីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ។

នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារលើការងារគ្រប់គ្រងពន្ធចលនទ្រព្យ និងអចលនទ្រព្យ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារស៊ើបអង្កេតបទល្មើសពន្ធដារ។

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងអ្នកជាប់ពន្ធធំ។

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងសាខាពន្ធដារខេត្ត-ខណ្ឌ។

នាយកដ្ឋានសវនកម្មសហគ្រាស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសវនកម្មសហគ្រាស។

សាលាជាតិពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារបណ្តុះបណ្តាលមុខជំនាញទាក់ទងនឹងពន្ធដារ។

ទីចាត់ការពន្ធដាររាជធានីភ្នំពេញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសម្របសម្រួលការងារសាខាពន្ធដារខណ្ឌទាំងអស់នៅរាជធានីភ្នំពេញ។

សាខាពន្ធដារខេត្ត-ខណ្ឌ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងអ្នកជាប់ពន្ធដទៃទៀតតាមការចាំបាច់។

**មាត្រាប្រាំពីរ.-**

មាត្រា៤១ មាត្រា៤២ និងមាត្រា៤៣ នៃជំពូកទី១១ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី១១

## អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

**មាត្រា៤១ ថ្មី.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានភារកិច្ចដូចតទៅ÷

- រៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងនិងជំរុញការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ នៅទូទាំងប្រទេស
- ស្រាវជ្រាវនិងគ្រប់គ្រងទ្រព្យឥតម្ចាស់និងមរតកឥតបណ្តឹង
- គ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋនិងដើមទុនរបស់រដ្ឋ
- គ្រប់គ្រងសហគ្រាសសាធារណៈ អង្គភាពសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- ប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធការងារឯកជនភាវូបនីយកម្ម ការជម្រះបញ្ជីសហគ្រាសសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត

- គ្រប់គ្រងនិងរៀបចំបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ សម្បទានរ៉ែ និងសម្បទានដទៃទៀត ដែលបានផ្តល់ឱ្យវិស័យឯកជន
- រៀបចំនីតិវិធីវាយតម្លៃការដាក់ជួល លក់ ដូរ និងផ្ទេរសិទ្ធិទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំផែនការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ មានលក្ខណៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លើការងារប្រមូលចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រក្សាការពារទិន្នន័យនៃការគ្រប់គ្រងការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ស្រាវជ្រាវរកប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ។

**មាត្រា៤២ ថ្មី.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធមានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

- នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលសាធារណៈ
- នាយកដ្ឋានសហគ្រាសសាធារណៈ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា៤៣ ថ្មី.-**

នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ។

នាយកដ្ឋានចំណូលសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលសាធារណៈ។

នាយកដ្ឋានសហគ្រាសសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសហគ្រាសសាធារណៈ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារបច្ចេកវិទ្យាព័ត៌មាន។

**មាត្រាប្រាំបី.-**

មាត្រា៤៦ ថ្មី និងមាត្រា៤៧ ថ្មី នៃជំពូកទី១២ អគ្គនាយកដ្ឋានរតនាគារជាតិ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី១២

## អគ្គនាយកដ្ឋានរតនាគារជាតិ

**មាត្រា៤៦ ថ្មី (មួយ).-**

អគ្គនាយកដ្ឋានរតនាគារជាតិមានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក-ថ្នាក់កណ្តាល**

- នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក
- នាយកដ្ឋានចំណូលថវិកា
- នាយកដ្ឋានចំណាយថវិកា
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- អធិការកិច្ចរតនាគារ ថ្នាក់ស្មើនាយកដ្ឋាន
- នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់និងវិភាគការអនុវត្តថវិកា។

**ខ-ថ្នាក់មូលដ្ឋាន**

នៅរាជធានី ខេត្ត មានរតនាគាររាជធានី ខេត្ត ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន នៅថ្នាក់កណ្តាល អមដោយអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យ នៅថ្នាក់កណ្តាល។

**មាត្រា៤៧ ថ្មី (មួយ).-**

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងាររដ្ឋបាល និងបុគ្គលិក។

នាយកដ្ឋានចំណូលថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារចំណូលថវិកា។

នាយកដ្ឋានចំណាយថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារចំណាយថវិកា។

នាយកដ្ឋានគណនេយ្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគណនេយ្យ។

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារបច្ចេកវិទ្យាព័ត៌មាន។

អធិការកិច្ចរតនាគារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារអធិការកិច្ចរតនាគារ។

នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់និងវិភាគការអនុវត្តថវិកា បំពេញមុខងារជាសេនាធិការ ឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងសាច់ប្រាក់និងវិភាគការអនុវត្តថវិកា។

**មាត្រាប្រាំបួន.-**

មាត្រា៥៤ និងមាត្រា៥៥ នៃជំពូកទី១៤ អគ្គាធិការដ្ឋាន នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី១៤
## អគ្គាធិការដ្ឋាន

**មាត្រា៥៤ ថ្មី.-**

អគ្គាធិការដ្ឋានមានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី១
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី២
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី៣។

**មាត្រា៥៥ ថ្មី.-**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋានលើការងាររដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង។

នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី១ បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋានលើការងារអធិការកិច្ចហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិទី១ រដ្ឋបាលថ្នាក់ក្រោមជាតិទី១ គ្រឹះស្ថាន-សហគ្រាសទី១ និងនីតិបុគ្គលឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ។

នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី២ បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋានលើការងារអធិការកិច្ចហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិទី២ រដ្ឋបាលថ្នាក់ក្រោមជាតិទី២ គ្រឹះស្ថាន-សហគ្រាសទី២ និងនីតិបុគ្គលឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ។

នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី៣ បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋានលើការងារអធិការកិច្ចហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិទី៣ រដ្ឋបាលថ្នាក់ក្រោមជាតិទី៣ គ្រឹះស្ថាន-សហគ្រាសទី៣ និងនីតិបុគ្គលឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ។

**មាត្រា៨ប.-**

មាត្រា៦០ នៃជំពូកទី១៦ អង្គភាពមូលដ្ឋាន នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

## ជំពូកទី១៦
## អង្គភាពថ្នាក់មូលដ្ឋាន

**មាត្រា៦០ ថ្មី.-**

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត បំពេញមុខងារជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការសម្របសម្រួលនិងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអភិបាលហិរញ្ញវត្ថុ នៅរាជធានី ខេត្ត ដោយធ្វើការសម្របសម្រួលរវាងរដ្ឋបាលថ្នាក់ជាតិផ្សេងទៀតនៅថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយអង្គភាពថ្នាក់មូលដ្ឋាននិងអង្គភាពថ្នាក់កណ្តាលទាំងឡាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៨បមួយ.-**

ប្រកាសពាក់ព័ន្ធនឹងការបង្កើត ឬការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងវិទ្យាស្ថាន និងអង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលកំពុងអនុវត្ត ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានប្រកាសថ្មី របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មកជំនួស។

**មាត្រាដប់ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាដប់បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាដប់បី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក
ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧

# អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

